# ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០១៩

## កម្ពុជា ឡាវ មីយ៉ាន់ម៉ា ជួបជជែកគ្នារកវិធីការពារពលករទេសន្តរប្រវេសន៍

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 01 November 2019 | 11:13 ICT

**សៀមរាបៈ** ថ្នាក់ដឹកនាំកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា (CLM) បានជួបពិគ្រោះយោបល់គ្នាជាលើកទី ២ នៅខេត្តសៀមរាបកាលពីថ្ងៃពុធជាជំនួបក្នុងកម្រិតថ្នាក់ដឹកនាំបច្ចេកទេស ជុំវិញតួនាទីប្រទេសបញ្ជូនពលករ ដើម្បីពង្រឹងកិច្ចការពារពលករទេសន្តរប្រវេសន៍ដោយមានថ្នាក់ដឹកនាំប្រទេសទាំង ៣ និងក្រុមអង្គការសង្គមស៊ីវិលដែលធ្វើការលើបញ្ហានេះចូលរួមប្រមាណ ១០០ នាក់។

ក្នុងជំនួបជាថ្មីក្នុងរយៈពេល ២ ថ្ងៃនេះលោកឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានថ្លែងថា នេះគឺជាឱកាសមួយដែលនាំឲ្យប្រទេសទាំង ៣ បានផ្លាស់ប្តូរយោបល់ បទពិសោធសម្រាប់ដោះស្រាយបញ្ហានានាទាក់ទងនឹងពលករទេសន្តរប្រវេសន៍ហើយក្នុងនាមជាប្រទេសបញ្ជូនពលករ នឹងរួមមតិគ្នាដើម្បីឈានទៅពិភាក្សាជាមួយភាគីថៃ ខណៈប្រទេសនេះទទួលពលករច្រើនក្នុងតំបន់។ លោកបញ្ជាក់ថា៖ «ប្រទេសយើងទាំង ៣ ជាប្រទេសជិតខាងគ្នាមានវប្បធម៌ប្រហាក់ប្រហែលគ្នាមានព្រំដែនជាប់ជាមួយប្រទេសថៃដូចគ្នា ហើយប្រជាពលរដ្ឋយើងក៏បាន និងកំពុងតែនាំគ្នាទៅធ្វើការក្នុងប្រទេសថៃទាំងស្របច្បាប់ និងមិនស្របច្បាប់យ៉ាងច្រើនកុះករ។ មួយចំនួនបាននិងកំពុងប្រឈមនឹងបញ្ហាជាច្រើនក្នុងដំណើរការទេសន្តរប្រវេសន៍តាំងពីចាកចេញនៅកន្លែងធ្វើការរហូតដល់ពេលត្រឡប់មកវិញ»។ លោក ស ខេង បន្តថាការធ្វើទេសន្តរប្រវេសន៍ គឺជាសិទ្ធិពលរដ្ឋក្នុងការជ្រើសរើសការងារ មុខរបរ និងទីកន្លែងរស់នៅ តែក្នុងនាមថ្នាក់ដឹកនាំ គឺត្រូវតែគិតគូរអំពីសិទ្ធិ ផលប្រយោជន៍ និងសេចក្តីថ្លៃថ្នូរ និងចូលរួមការពារដល់ពលរដ្ឋរបស់ខ្លួនហើយក្នុងឋានៈជាប្រទេសបញ្ជូនគឺចាំបាច់ត្រូវរួមសហការគ្នាដោះស្រាយ។ យ៉ាងណាក្តីលោក ស ខេង បានចាត់ទុកការមូលមាត់គ្នានេះ មិនមែនជាការដាក់សម្ពាធលើភាគីថៃទេ ប៉ុន្តែគឺមានគោលដៅ ដើម្បីមានវិធានការរួមគ្នារវាងប្រទេសបញ្ជូន និងប្រទេសទទួលក្នុងកិច្ចការពារសិទ្ធិពលករដែលងាយរងគ្រោះតាមរយៈការបែងចែកផលប្រយោជន៍រវាងពលករ និងនិយោជិត។

លោកបញ្ជាក់ថា៖ «ការរួមគ្នាប្រទេសទាំង ៣ នេះគឺជាការរួមចំណែកជួយប្រមូលនូវធាតុចូលល្អថ្មីៗ ដើម្បីប្រឹក្សាជាមួយថៃដែលជាជំនួយដល់គាត់ឲ្យគាត់ដោះស្រាយបញ្ហាកំពុងតែប្រឈមដែលអន្តរជាតិកំពុងតែរិះគន់គាត់ដែរ ដូចជាទាក់ទងនឹងកម្មករធ្វើការលើទូក។ កុំឲ្យមានជាទស្សនៈថាយើងទាំង ៣ នាក់ (ប្រទេសទាំង ៣) ចាប់ដៃគ្នាទៅធ្វើបាបថៃដែលនាំឲ្យមានការអន្តរាយតែម្តង»។ លោកបានបន្ថែមថា៖ «ទោះបីយើងបានឯកភាពក្នុងកម្រិតជំនាញ និងបច្ចេកទេសនៅទីនេះក៏ដោយ។ យើងឯកភាពគ្នាក្នុងកម្រិតថ្នាក់នយោបាយរវាងប្រទេសទាំង ៣ ដែលមានវត្តមាននៅទីនេះ ប៉ុន្តែក៏មិនទាន់អាចយកទៅជជែកពិភាក្សាដោយត្រង់នោះទេ (ប្រទេសថៃ)។ សូមពិចារណារកវិធីសាស្ត្រតើយើងអាចថាបន្ទាប់ពីយើងបានឯកភាពគ្នា យើងអាចលើកបញ្ហានេះជជែកពិភាក្សាជាមួយថៃក្នុងកម្រិត (មន្ត្រី) ជំនាញសិន ក្រោយពេលដែលកម្រិតជំនាញស្រុះស្រួលឯកភាពគ្នាហើយ ចាំថាយើងអាចប្រជុំ ៤ ភាគី»។

លោក ផេងសាវ៉ាញ់ ធីផាវង្សសៃ ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិ ប្រឆាំងការជួញដូរមនុស្សក្រសួងសន្តិសុខសាធារណៈ និងជាគណៈប្រតិភូនៃសាធារណរដ្ឋប្រជាមានិតឡាវបានថ្លែងថា ប្រទេសឡាវក៏កំពុងជួបបញ្ហាទេសន្តរប្រវេសន៍ឆ្លងដែនផងដែរ ជាពិសេសទៅប្រទេសថៃ ដែលជួបការកេងប្រវ័ញ្ចកម្លាំងពលកម្ម។ លោកថា៖ «ដូច្នេះកិច្ចពិភាក្សានៅពេលនេះនឹងផ្តល់នូវសារៈសំខាន់ដល់រដ្ឋាភិបាលនៃប្រទេសទាំង ៣ ដែលមានការបញ្ជូនពលករច្រើនដូចគ្នារួមគ្នាដោះស្រាយបញ្ហាដែលប្រឈម និងស្វែងរកដំណោះស្រាយសមស្រប»។

យោងតាមកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ដែលត្រូវបានអនុម័តនៅប្រទេសម៉ារ៉ុកកាលពីខែធ្នូឆ្នាំ ២០១៨ បានកំណត់ថា ប្រទេសជាសមាជិកចាំបាច់ត្រូវជំរុញអនុវត្តដើម្បីការពារពលករទេសន្តរប្រវេសន៍ពីរាល់ទម្រង់នៃការជួញដូរ និងកេងប្រវ័ញ្ចនៅគ្រប់ដំណាក់កាលនៃការធ្វើទេសន្តរ

ប្រវេសន៍ផងដែរ។ ដោយឡែកកាលពីខែវិច្ឆិកា ឆ្នាំ ២០១៧ អាស៊ាន ក៏បានចុះកិច្ចព្រមព្រៀងជាឯកច្ឆន្ទ និងបានអនុម័តច្បាប់ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ដើម្បីបង្កើនប្រសិទ្ធភាពនៃអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារផងដែរ។

លោកស្រី គ្រីស្ទីន ផាកូ ប្រធានបេសកកម្មអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ប្រចាំកម្ពុជាបានថ្លែងក្នុងឱកាសនេះដែរថា ជំនួបថ្នាក់ដឹកនាំនៃប្រទេសទាំង ៣ នេះគឺមានសារៈសំខាន់ខ្លាំងដែលគួររួមគ្នារកវិធីដោះស្រាយ ខណៈពលករភាគច្រើននៅតែប្រឈមបញ្ហាជាពិសេសការជួញដូរខុសច្បាប់ និងធ្លាក់ចូលក្នុងឧស្សាហកម្មផ្លូវភេទតាមទូកនេសាទ និងឧស្សាហកម្មខុសច្បាប់។ លោកស្រីបន្តថាជំនួបនេះគឺជាក្តីសង្ឃឹមមួយសម្រាប់ពលរដ្ឋរងគ្រោះក្នុងការរួមគ្នាបន្តប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាពសម្រាប់ពិភពលោក។ ដូច្នេះក្នុងនាមអង្គការ IOM នឹងព្យាយាមបន្តទៀតក្នុងការសម្របសម្រួលជាមួយប្រទេសទាំងនេះ ជាពិសេសប្រទេសដែលទទួលពលករច្រើនក្នុងតំបន់ហើយច្រើនបំផុតពីប្រទេស ឡាវ ភូមា និងកម្ពុជានេះ។ លោកស្រីបញ្ជាក់ថា៖ «យើងគួរតែធ្វើប្រតិបត្តិការយ៉ាងម៉េចបន្ថែមទៀតដើម្បីឲ្យមាននូវតួនាទីដ៏សំខាន់សម្រាប់ការងារជនទេសន្តរប្រវេសន៍តាមរយៈច្បាប់គ្រប់គ្រងស្តង់ដាការងារ ព្រោះទេសន្តរប្រវេសន៍នេះ ភាគច្រើនមាននៅក្នុងតំបន់ដែលតម្រូវឲ្យមានកិច្ចសហការគ្នាជាសកល និងតំបន់ដោយកំណត់អំពីអាទិភាពរបស់ខ្លួននៅក្នុងសិក្ខាសាលានេះ ដើម្បីឈានទៅអនុវត្តឲ្យបាននៅឆ្នាំ ២០៣០»។ បើតាមលោកស្រី គ្រីស្ទីន ផាកូ បច្ចុប្បន្នមានពលករទេសន្តរប្រវេសន៍ចម្រុះជាតិសាសន៍ប្រមាណ ២៤៤ លាននាក់ បានធ្វើចំណាកស្រុកនៅលើពិភពលោក ខណៈនៅក្នុងតំបន់អាស៊ីមានប្រមាណ ៨២,៥ លាននាក់ ក្នុងនោះមានស្ត្រីប្រមាណពាក់កណ្តាល៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០២នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 31-10-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០២នាក់ នាថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រក បុសបស្បូវ ខេត្ត ព្រះវិហារ ៕

## អាណិតណាស់ ខំទៅធ្វើការនៅស្រុកគេ បែរជាស្លាប់ដោយសារសត្វដំរីជាន់ទៅវិញ

https://www.popular.com.kh/ October 31, 2019

ពលករខ្មែរម្នាក់ ឈ្មោះ អាត សុខ ភេទប្រុស អាយុ ២៩ឆ្នាំ ត្រូវបានអាជ្ញាធរថៃប្រទះឃើញសាកសពស្លាប់យ៉ាងអាណោចអាធ័មនៅក្បែរខ្ទមក្នុងចម្ការដើមព្រេងខ្យល់ ដោយសាកសពមានសភាពឡើងទុ និង សំប៉ែត ដែលគេមានការសង្ស័យថា ស្លាប់ដោយសារដំរីព្រៃជាន់ ។ ជនរងគ្រោះកាន់លិខិតឆ្លងដែនធ្វើការ លេខ T0434011 មានស្រុកកំណើត រស់នៅខេត្តព្រៃវែង បានស្លាប់បាត់បង់ជីវិត ។ ហេតុការណ៍នេះ បានកើតឡើងកាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០១៩ នៅក្នុងតំបន់ ចម្ការដើមព្រេងខ្យល់មួយកន្លែង ស្ថិតនៅភូមិ ១២ ឃុំថាតាក់កៀប ស្រុកថាតាក់កៀប ខេត្តឆាកឈើងសៅ ប្រទេសថៃ ។

បើតាមព័ត៌មានបឋមបានឱ្យដឹងថា នៅកន្លែងកើតហេតុមានពលករខ្មែរ ចូលមកធ្វើការដាំដើមព្រេងខ្យល់ និងកាប់ដើមព្រេងខ្យល់ ចំនួន ៨នាក់ ក្មេង ០២នាក់ ស្នាក់នៅក្នុងខ្ទមបួនខ្នងក្នុងករណីនេះ គេសង្ស័យជនរងគ្រោះអាចត្រូវសត្វដំរីព្រៃជាន់ ស្លាប់បាត់បង់ជីវិត ពីព្រោះខ្ទមស្នាក់នៅក៏ត្រូវសត្វដំរីព្រៃជាន់ខ្ទេចខ្ទីដែរ។ បច្ចុប្បន្នសាកសពជនរងគ្រោះត្រូវបានសមត្ថកិច្ចថៃបញ្ជូនយកទៅរក្សាទុកនៅមន្ទីរពេទ្យថាតាក់កៀប ដើម្បីធ្វើការកោសល្យវិច័យតាមនីតិវិធី ៕

## ទៀតហើយ! គេឃើញជនភៀសខ្លួននៅក្នុងរថយន្តដឹកទំនិញ

http://nokorwatnews.com/ 31-10-2019

សកម្មភាពជួញដូរមនុស្ស កំពុងតែកើតឡើងយ៉ាងខ្លាំងនៅក្នុងតំបន់អឺរ៉ុប ក្នុងនោះមានបារាំង បែលហ្ស៊ិចនិងអង់គ្លេស ។ គោលដៅចុងក្រោយបង្អស់នៃជនភៀសខ្លួន ប្រថុយជីវិត គឺសំដៅទៅកាន់ប្រទេសអង់គ្លេស ដោយនៅទីនោះងាយស្រួលរកការងាធ្វើ។ នៅពេលនេះ ប៉ូលិសបែលហ្ស៊ិចបានរកឃើញមនុស្ស១២នាក់ នៅមានជីវិត ក្នុងរថយន្តដឹកទំនិញក្លាសេ ស្ថិតនៅចំណតរថយន្ត ជាយក្រុង Turnhout កាលពីថ្ងៃទី៣០ ខែតុលា ក្រោយពេលអ្នកបើកបររថយន្តទូរស័ព្ទប្រាប់ប៉ូលិស។

អ្នកនាំពាក្យស្នងការប៉ូលិសបែលហ្ស៊ិចបញ្ជាក់ថា អ្នកបើកបររថយន្តខាងលើ ពេលនោះបើករថយន្តដឹកជញ្ជូនបន្លែនិងផ្លែឈើ បានទូរស័ព្ទប្រាប់ប៉ូលិសក្រោយឃើញជនភៀសខ្លួន១២នាក់នៅក្នុងរថយន្ត។ ជនភៀសខ្លួនទាំងនោះត្រូវបានបញ្ជូនទៅកាន់ការិយាល័យគ្រប់គ្រងអន្តោប្រវេសនៅទីក្រុង Antwerp ។ តាមការលើកឡើងរបស់ប៉ូលិសបែលហ្ស៊ិច ជនភៀសខ្លួនទាំងនោះ ជាជនជាតិស៊ីរីនិងស៊ូដង់ ព្យាយាម ចូលទៅកាន់ប្រទេសអង់គ្លេស។

កាលពីថ្ងៃទី២៧ខែតុលា បានរាំង បានរកឃើញ ជនភៀសខ្លួន៨នាក់នៅក្នុងរថយន្តដឹកទំនិញក្លាសេឆ្ពោះទៅកាន់ប្រទេសអង់គ្លេស។ ជនភៀសខ្លួនទាំងនោះស្ថិតនៅក្នុង ស្ថានភាពចុះកម្តៅយ៉ាងខ្លាំង ប្រសិនបើនៅក្នុងរថយន្តនោះប៉ុន្មានម៉ោងទៀតនឹងស្លាប់ជាមិនខាន។

កាលពីសប្តាហ៍កន្លងមក មានជនភៀសខ្លួន៣៩នាក់ ត្រូវបានគេរកឃើញស្លាប់នៅក្នុងរថយន្តដឹកទំនិញក្លាសេ ចូលទៅកាន់ប្រទេសអង់គ្លេស ដោយឆ្លងកាត់កំពង់ផែ Zeebrugge ប្រទេសបែលហ្ស៊ិច ។ ការស្លាប់ជនភៀសខ្លួនធ្វើឲ្យកក្រើកពិភពលោក ក៏ដូចជាថ្កោលទោស ដល់ច្បាប់អន្តោប្រវេសន៍តានតឹងក្នុងតំបន់អឺរ៉ុប ៕

## ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០១៩

## ជនជាតិអាមេរិកាំងកាត់ទោសឲ្យជាប់ពន្ធនាគារជាង ២ឆ្នាំពីបទរំលោភផ្លូវភេទ

https://www.rfa.org/khmer/ ដោយ ម៉ៅ សុជានី 2019-11-02

តុលាការខេត្តសៀមរាប កាត់ទោសបុរសជនជាតិអាមេរិកាំងម្នាក់ជាមេធាវី ឲ្យជាប់ពន្ធនាគារ ២ឆ្នាំកន្លះ ពីបទរំលោភផ្លូវភេទលើកុមារីខ្មែរ ៣នាក់។ តុលាការ ក៏បានបង្គាប់ឲ្យទណ្ឌិតរូបនេះ បង់ប្រាក់ផាកពិន័យចំនួនជិត ៤ពាន់ដុល្លារអាមេរិក សម្រាប់កុមារីម្នាក់ៗ។ ប៉ុន្តែជនជាប់ចោទ បានបដិសេធចំពោះការចោទប្រកាន់នេះ។

អ្នកនាំពាក្យសាលាដំបូងខេត្តសៀមរាប លោក យីង ស្រាំង (Yin, Srang) ត្រូវបានទីភ្នាក់ងារព័ត៌មាន អេភី ដកស្រង់សំដី កាលពីថ្ងៃទី១ ខែវិច្ឆិកាថា លោក រ៉ាស់ ហ្សេម ក្លែន (Rough James Cline) ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារ ជាង ២ឆ្នាំ ពីបទជួញដូរផ្លូវភេទលើកុមារីខ្មែរចំនួន ៣នាក់ អាយុក្រោម ១៥ឆ្នាំ ដោយបានផ្តល់ប្រាក់ចំនួន ១២០ដុល្លារអាមេរិក ជាថ្នូរនឹងការរួមភេទ នៅពេលទណ្ឌិតរូបនេះ បានមកលេងកម្ពុជា ចន្លោះពីខែកុម្ភៈ ដល់ខែឧសភា ឆ្នាំ២០១៩ នេះ។

អង្គការក្រៅរដ្ឋាភិបាលមួយឈ្មោះ Action Pour Les Enfants ហៅកាត់ថា APLE ដែលបានតាមដានសកម្មភាព របស់ជនបរទេសសង្ស័យទិញដូរផ្លូវភេទលើកុមារ បានប្រាប់ប៉ូលិស អំពីសកម្មភាពជួញដូរផ្លូវភេទលើកុមារីខ្មែរ របស់ លោកមេធាវី Cline។ ភាពក្រីក្រ និងបញ្ហាអនុវត្តច្បាប់នៅមានកម្រិតទាបនេះហើយ គឺជាកត្តាចំបង ដែលនាំឲ្យកម្ពុជាក្លាយជាកន្លែងទាក់ទាញភ្ញៀវទេសចរផ្លូវភេទ។មន្ត្រីសង្គមស៊ីវិល ទទូចឲ្យអាជ្ញាធររបបក្រុងភ្នំពេញ បញ្ជូនឧក្រិដ្ឋជនជួញដូរផ្លូវភេទចេញពីកម្ពុជា ក្រោយពីបានទទួលទោសជាប់ពន្ធនាគាររួច ដើម្បីទប់ស្កាត់ការជួញដូរផ្លូវភេទនេះទៅលើកុមារផ្សេងទៀត៕

## កុមារីខ្មែរ ៦នាក់ទទួលបានសំណងរដ្ឋប្បវេណីជាង ២ម៉ឺនដុល្លារ ករណីរំលោភផ្លូវភេទ

https://www.rfa.org/khmer/ ដោយ មួង ណារ៉េត 2019-10-18

កុមារីខ្មែរ ៦នាក់ ទើបតែបានបានទទួលសំណងរដ្ឋប្បវេណីករណីរំលោភផ្លូវភេទ ពីជនជាតិស៊ុយអែត ជាទឹកប្រាក់ជាង ២ម៉ឺន ៣ពាន់ដុល្លារ (២៣.២៥០) កាលពីដើមខែតុលាកន្លងទៅនេះ។ សំណងនេះ ត្រូវបានតុលាការស៊ុយអែត កំណត់នៅក្នុងសាលក្រម កាលពីខែវិច្ឆិកា ឆ្នាំ២០១៦ ដែលតុលាការនេះ រកឃើញជនជាតិស៊ុយអែតលោក អ៊ុហ្វ គ្រីស្ទាន ហ្គោរ៉ែនសិន (Ulf Christian Goransson) មានពិរុទ្ធភាពពីបទរំលោភ និងកេងប្រវ័ញ្ចផ្លូវភេទកុមារខ្មែរ។ តុលាការផ្តន្ទាទោសឱ្យជនជាតិស៊ុយអែតរូបនេះ ជាប់ពន្ធនាគារ ២ឆ្នាំ ៧ខែ និងបង្គាប់ឱ្យផ្តល់ប្រាក់សំណងទាំងនេះទៅជនរងគ្រោះខ្មែរទាំង ៦នាក់នេះ។ ករណីរំលោភ និងកេងប្រវ័ញ្ចផ្លូវភេទលើអនីតិជនខ្មែរនេះ កើតមានឡើងកាលពីឆ្នាំ២០១៥ ដែលកាលណោះលោក អ៊ុហ្វ គ្រីស្ទាន ហ្គោរ៉ែនសិន នៅស្រុកខ្មែរ។ ប៉ុន្តែ ក្រោយមកទណ្ឌិតរូបនេះ បានរត់គេចខ្លួនពីកម្ពុជា ទៅប្រទេសស៊ុយអែតវិញ។

តាមសេចក្តីថ្លែងការណ៍របស់អង្គការសកម្មភាពដើម្បីកុមារ ដែលហៅកាត់ថា APLE បញ្ជាក់ថា ការឈានទៅចាប់ខ្លួន និងផ្តន្ទាទោសជនជាតិស៊ុយអែតនេះ រហូតដល់ប្រទេសស៊ុយអែត គឺដោយអង្គការសកម្មភាពដើម្បីកុមារសហការជាមួយសមត្ថកិច្ចប៉ូលិសស៊ុយអែត៕

## នារីបម្រើសេវាខារ៉ាអូខេម្នាក់ ចេញមុខប្តឹងមក សមត្ថកិច្ចទាំងយប់ បន្ទាប់ពីថៅកែបង្ខំឲ្យបម្រើសេវាផ្លូវភេទជាមួយភ្ញៀវញឹកញាប់

---

http://kampucheathmey.com/ វិទូ4/11/2019 1:33 Pm

ភ្នំពេញ ៖ នារីម្នាក់ ដោយសារ អស់ទ្រាំ និងលែងខ្មាសអៀន ក្រោយត្រូវថៅកែខារ៉ាអូខេជនជាតិចិនយីហោ ( ជីនជន ) បង្ខំអោយដេកជាមួយភ្ញៀវ ជាច្រើនលើកច្រើនសា ហើយកាត់យកលុយនាងអស់ជិតពាក់ៗកណ្តាលទៀតណាមួយក្រុមភ្ញៀវចិនទាំងនោះ ពេលមកច្រៀងម្តងៗតែងលូកលាន់កេរខ្មាសនាងនិងវាយទះកំផ្លៀងនាងទៀតនោះ ទើបនាងសុខចិត្តចេញមកប្តឹងសមត្ថកិច្ចទាំងយប់រំលងអធ្រាត្រឈានចូលថ្ងៃទី៤ ខែវិច្ឆិកា ដោយបានលើកដៃសំណូមពរ ដល់អាជ្ញាធរពាក់ព័ន្ធតាំងពីមេប៉ុស្តិ៍ លោកអធិការ និងលោកស្នងការ រហូតដល់អភិបាលខណ្ឌអភិបាលក្រុង មេត្តាជួយដល់នាង ក៏ដូចនារីខ្មែរផ្សេងៗទៀតផង ដែលកំពុងរងគ្រោះ ដោយសារថៅកែចិនម្នាក់នេះ។ នារីរងគ្រោះម្នាក់បានអះអាងរៀបរាប់ទាំងទឹកភ្នែកថា ថៅកែខារ៉ាអូខេជនជាតិចិន យីហោ ជីនជន តែងបង្ខំអោយនាងដេកជាមួយភ្ញៀវ តែគាត់មិនព្រម រួចក៏ដេញគាត់ចេញមកក្រៅ ឈប់ឲ្យធ្វើការ លុយក៏មិនបើកឲ្យដែរ។ ដោយអស់ទ្រាំ និងលែងខ្មាសអៀនទៀតនោះ នារីរងគ្រោះ បានលើកដៃសំណូមពរដល់អាជ្ញាធរពាក់ព័ន្ធ សូមមានចំណាត់ការលើហាងខារ៉ាអូខេ យីហោ ( ជីនជន) នេះផង ដើម្បីកុំអោយមាននារីណាផ្សេងទៀត រងគ្រោះ ដោយសារម្ចាស់ហាងជនជាតិចិននេះធ្វើបាប។

នារីជនជាតិខ្មែរម្នាក់នេះ បានរៀបរាប់ទាំងទឹកភ្នែកទៀតថា នាងមានស្រុកកំណើតនៅខេត្តតាកែវ បានមកធ្វើការនៅហាងខារ៉ាអូខេ ជីនជន របស់ថៅកែចិន មានទីតាំងនៅមុខព្រលានយន្តហោះអន្តរជាតិភ្នំពេញ តាមបណ្តោយផ្លូវសហព័ន្ធរុស្ស៊ី ស្ថិតនៅភូមិព្រៃទា សង្កាត់ចោមចៅ៣ អស់រយៈពេលជាង១ខែហើយ នៅក្នុងហាងនេះ មានតែភ្ញៀវចិនទេ ដែលបានចូលមកកម្សាន្ត។ កន្លងទៅនាង ត្រូវបានថៅកែជនជាតិចិនបង្ខំឲ្យដេកជាមួយភ្ញៀវចិនចំនួន៥ដងមកហើយ បើមិនព្រម គឺដេញចេញពីការងារ នៅពេលដេកម្តងៗមុនដំបូងថា ឲ្យ១៥០ដុល្លារដល់ពេលដេក រួចឲ្យតែ១០០ដុល្លារប៉ុណ្ណោះ ហើយកាត់យកកុំមីស្យុង១៥ដុល្លារថែមទៀត ដូច្នេះក្នុង១៥០ដុល្លារនាងទទួលបានតែ៨៥ដុល្លារ

ប៉ុណ្ណោះ គេកាត់យកអស់៦៥ទៅហើយ។ នាងបន្តថា នៅយប់កើតហេតុនេះ មានភ្ញៀវចិន ចូលមកច្រៀងលេង មានគ្នា៤នាក់ ហើយស្រីៗពួកនាងមានគ្នា៥នាក់ទាំងអ្នកកាន់បន្ទប់។ ក្នុងពេលនោះនាង ត្រូវបានជនជាតិចិនលូកចាប់ប្រដាប់សំខាន់ៗរបស់នាង តែនាងបេះដៃចេញ អ្នកខ្លះទាញខ្សែអាវចង់ស្រាយចេញ អ្នកខ្លះលូកដល់អាវក្នុងនាងទាញដៃចេញ តែរាល់ការទាញដៃចេញម្តងៗ ត្រូវបានគេវាយនាងគ្រប់ដៃគឺ៤នាក់វាយនាង៥ដងទៅហើយ ពេលប្តឹងថៅកែ គេមិនជួយរកដំណោះស្រាយទេ បែរជានិយាយថា មកពីគេស្រឡាញ់ទើបគេបេះបោចអីចឹង។ ប៉ុន្តែដោយសារនាងមិនព្រមឲ្យគេបេះបោចគ្រប់គ្នា ទើបថៅកែចិនសម្រេចដេញនាងចេញទាំងយប់បែបនេះតែម្តង។

គេសង្កេតឃើញថា នៅក្នុងខណ្ឌពោធិ៍សែនជ័យរបស់លោកហែម ដារិទ្ធជាអភិបាលខណ្ឌ និង លោកឃឹម សារ៉ាន់ ជាអធិការខណ្ឌ សម្បូរហាងចិនរីកដុះដាលដូចផ្សិត ហើយក្នុងហាងទាំងនោះសម្បូរបង្កប់សេវាផ្លូវភេទដូចៗគ្នាអីចឹង តែអាជ្ញាធរសង្កាត់ខណ្ឌរួមទាំងអភិបាល និងអធិការមិនសូវខ្វាយខ្វល់ប៉ុន្មានទេ ដល់ផ្ទុះរឿងអញ្ចឹង បានដឹងថា តាមហាងចិននីមួយៗពិតជាមិនធម្មតាមែន រឿងបទល្មើសលើនារីភេទ៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 01-11-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០១នាក់ នាវេលាម៉ោង ១៦និង២០នាទី ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## រកឃើញសពពលករខ្មែរ២នាក់ទៀត ដែលបាត់ខ្លួនក្នុងហេតុការណ៍សត្វដំរីព្រៃដេញជាន់

http://kampucheathmey.com/ សោ និយមវត្ត4/11/2019 10:22 Am

ប្រទេសថៃ ៖ សពពលករខ្មែរចំនួន នាក់ ដែលបានបាត់ខ្លួន នៅក្នុងហេតុការណ៍សត្វដំរីព្រៃដេញជាន់នៅខេត្តឆះឈើងសៅ កាលពីពេលថ្មីៗនេះ បានរកឃើញហើយ ដោយពួកគេ(២នាក់ ប្តី ប្រពន្ធ ) បានរត់ទៅស្លាប់នៅក្នុងព្រៃចម្ការដើមប្រេងខ្យល់ បន្ទាប់ពីសមត្ថកិច្ចថៃ តាមស្វែងរកអស់រយៈពេល១ព្រឹកធំ។

គួររំលឹកដែរថា កាលពីល្ងាចថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ មានពលករខ្មែរ មួយក្រុមចំនួន៨នាក់ ដែលក្នុងនោះមានក្មេង២ នាក់ បានមកសង់រោង និងបោះបង្គោលសម្រាប់ចងអង្រឹងស្នាក់នៅដើម្បីស៊ីឈ្នួល កាប់ដើមប្រេងខ្យល់ ត្រង់ចំណុចភូមិ១២ ឃុំថាតៈកៀប ស្រុកថាតៈកៀប ខេត្តឆះឈើងសៅ ប្រទេសថៃ ដែលចំណុចនេះ ត្រូវបានប្រជាពលរដ្ឋថៃនិយាយថា គឺជាផ្លូវដែលសត្វដំរីព្រៃតែងតែឆ្លងកាត់ដើម្បីរកចំណីអាហារក្នុងពេលយប់ជ្រៅ។ លុះនៅពេលរំលងអធ្រាត្រ យប់ថ្ងៃទី៣១ ក៏ស្រាប់តែមានសត្វដំរីព្រៃប្រមាណ ជាង ៣០ ក្បាល បានចេញពីព្រៃ ហើយក៏បានធ្វើដំណើរតាមផ្លូវរបស់វាមែន ប៉ុន្តែដោយសារតែមានរោង និង អង្រឹងព្រោងព្រាតនៅពីមុខ ព្រមទាំងមានសត្វឆ្កែអ្នកស្រុកដេញព្រុសពីក្រោយផងនោះ អាចធ្វើអោយសត្វដំរីក្តៅក្រហាយ ទើបពួកវានាំគ្នា សម្រុកជាន់ទៅលើរោង និងអង្រឹងដែលពលករខ្មែរដេកនៅក្នុងនោះ បណ្តាលអោយពលករខ្មែរម្នាក់ឈ្មោះ សុខ អាត ភេទប្រុស អាយុ ២៩ ឆ្នាំ ជាអ្នករស់នៅខេត្តព្រៃវែង ត្រូវបានសត្វដំរីជាន់បាក់ឆ្អឹងគ្មានសល់ និងត្រូវស្លាប់នៅនឹងកន្លែងតែម្តង ដោយឡែកពលករខ្មែរ ចំនួន ២ នាក់ទៀត ត្រូវបានបាត់ខ្លួន។

ក្រោយពេលកើតហេតុ ទាំងអាជ្ញាធរ ក៏ដូចជាសមត្ថកិច្ច ខេត្តឆះឈើងសៅ បាននាំគ្នាតាមរកពេញមួយយប់ រហូតដល់ថ្ងៃទី១ ខែវិច្ឆិកា វេលាម៉ោង ៩ និង ៤០ នាទី ទើប រកឃើញសព ពលករខ្មែរ ០២នាក់ បន្ថែមទៀត ដែលពួកគេបានរត់ទៅស្លាប់នៅក្នុងព្រៃចម្ការដើមប្រេងខ្យល់ ចម្ងាយពីកន្លែងកើតហេតុប្រមាណ ២០០ ម៉ែត្រ។ យោងតាម

របាយការណ៍បន្ថែម របស់កម្លាំងសមត្ថកិច្ចតម្រួតថៃ បានអះអាងថា ពលករខ្មែរដែលស្លាប់នោះ គឺជាប្ដី ប្រពន្ធ នឹងគ្នា មាន ឈ្មោះ ហាយ លី ( ប្ដី ) អាយុ ២៣ឆ្នាំ និងប្រពន្ធ ឈ្មោះ សាន សាណេន ១៩ឆ្នាំ បន្ទាប់ពីមានករណីសត្វដំរីព្រៃ ជាង ៣០ ក្បាល បាន ចូលលុកលុយក្នុង ចម្ការដើមប្រេងខ្យល់ និងបានតេជាន់ទៅលើពលករខ្មែរ ដែលស្នាក់នៅទីនោះរួចមក។ បច្ចុប្បន្នសពជនរងគ្រោះ ត្រូវបានសមត្ថកិច្ចថៃ ដឹកយកទៅរក្សាទុកនៅមន្ទីរពេទ្យស្រុក ថាតះកៀប ជាបណ្ដោះអាសន្ន ដើម្បីធ្វើកោសល្យវិច័យតាមផ្លូវច្បាប់៕

## តំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានចុះមកមន្ទីរការងារខេត្តឈុនបុរី សហការជាមួយមន្ត្រីពាក់ព័ន្ធភាគីថៃ ដើម្បីរកដំណោះស្រាយជូនបងប្អូនពលករពលការនីខ្មែរ

https://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok November 1 at 8:54 PM •

ថ្ងៃសុក្រ ៥កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី០១ ខែវិច្ឆិកាឆ្នាំ២០១៩ តំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានចុះមកមន្ទីរការងារខេត្តឈុនបុរី សហការជាមួយមន្ត្រីពាក់ព័ន្ធភាគីថៃ ដើម្បីរកដំណោះស្រាយ និងទាមទារសិទ្ធិអត្តប្រយោជន៍ជូនបងប្អូនពលករពលការនីខ្មែរប្រមាណ៣០០នាក់ ដែលនិយោជកក្ស័យធន និងបិទអាជីវកម្មកាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ នៅខេត្តឈុនបុរី។ ការដោះស្រាយទទួលបានលទ្ធផលដូចខាងក្រោម៖

-មន្ទីរការងារនៃក្រសួងការងារថៃ អនុញ្ញាតឱ្យពលករអាចប្ដូរការងារបាន ដោយពុំចាំបាច់បង់ប្រាក់ដំណើរការប្ដូរនិយោជក។

-ក្រុមហ៊ុនស្វែងរកការងារជូនពលករបានចំនួន២កន្លែង ដែលអាចទទួលពលករបានចំនួន២០០នាក់ និងកំពុងពន្លឿនស្វែងរកទីកន្លែងការងារថ្មីបន្ថែម។

-ពលករទទួលបានប្រាក់ឈ្នួល និងប្រាក់សំណងជំងឺចិត្តគ្រប់ចំនួនតាមច្បាប់ការងារថៃ។

-ជំរុញឱ្យនិយោជក ទូទាត់ប្រាក់អតីតភាពការងារដល់ពលករ ឱ្យបានឆាប់រហ័ស។

## វៀតណាម ថ្កោលទោសការជួញដូរមនុស្ស និងអំពាវនាវឱ្យប្រទេសក្នុងតំបន់ជួយនាំគ្នាទប់ស្កាត់

http://km.rfi.fr/ ដោយ ហេង ឧត្ដម 02/11/2019

នៅក្នុងសន្និសីទកាសែតនាថ្ងៃសៅរ៍ ទី២វិច្ឆិកា ក្រសួងការបរទេសវៀតណាម ចេញមុខថ្កោលទោសអំពើជួញដូរមនុស្ស ហើយបានអំពាវនាវឱ្យប្រទេសក្នុងតំបន់អាស៊ាននិងអន្តរជាតិ ចូលរួមនាំគ្នាជួយទប់ស្កាត់ការជួញដូរមនុស្ស។ ប្រតិកម្មរបស់ក្រសួងការបរទេសវៀតណាមយ៉ាងដូច្នេះ បន្ទាប់ពីប៉ូលីសស៊ើបអង្កេតរបស់អង់គ្លេស បញ្ជាក់ពីថ្ងៃសុក្រទី១វិច្ឆិកា ថាសាកសពមនុស្សទាំង៣៩នាក់ដែលស្លាប់ក្នុងរថយន្តកាំមីញ៉ុង នៅក្បែរទីក្រុងឡុងនោះ គឺភាគច្រើនជាជនជាតិវៀតណាម។

ការស៊ើបអង្កេតលម្អិត រកអត្តសញ្ញាណសាកសព កំពុងតែបន្តនៅទៀតឡើយ តែលទ្ធផលបឋមតាមរយៈការផ្ទៀងផ្ទាត់អាដេអ៊ីន ប៉ូលីសផ្នែកវិទ្យាសាស្ត្រអង់គ្លេស បង្ហាញថា អ្នកស្លាប់ភាគច្រើនក្នុងចំណោមជនភៀសខ្លួនទាំង៣៩នាក់នោះ ជាជនជាតិវៀតណាម។ នគរបាលអង់គ្លេស កំពុងតែទាក់ទងក្រុមគ្រួសារសព និងអាជ្ញាធរទូតវៀតណាមនៅក្រុងឡុងដ៍ និងក្រុងហាណូយ។ ប៉ូលីសអង់គ្លេស ក៏ប្រកាសឱ្យអ្នកដែលសង្ស័យបាត់សមាជិកគ្រួសារ ឬក៏អាចមានតម្រុយឈានទៅកំណត់អត្តសញ្ញាណរបស់ជនរងគ្រោះបាន សូមឱ្យទាក់ទងផ្ដល់ព័ត៌មានបន្ថែមទៀត ទៅឱ្យខាងប៉ូលីសស៊ើបអង្កេត។

សាកសពមនុស្ស៣៩នាក់ ប្រុស៣១ ស្រី៨នាក់ ត្រូវគេរកឃើញស្លាប់ កាលពីថ្ងៃទី២៣តុលា ក្នុងឡានកាំមីញ៉ុង ក្បែរទីក្រុងឡុង ប្រទេសអង់គ្លេស។ ឡានកុងតឺន័រ ដឹងមនុស្សភៀសខ្លួននោះ ចេញពីប្រទេសបែលស៊ិក។ ពេលនេះ

ប៉ូលីសអង់គ្លេសបានស្រាវជ្រាវនិងឃាត់ខ្លួនបុរសជនជាប់សង្ស័យពីរនាក់ម្នាក់វ័យ៤០ឆ្នាំឈ្មោះ Ronan Hughes និងប្អូនប្រុស Christopher អាយុ៣៤ឆ្នាំ ដើមកំណើតមកពីអៀកឡង់ខាងជើង។

ក្នុងសំណុំរឿងដដែលនេះ តុលាការអៀកឡង់ កាលពីថ្ងៃសុក្រ ទី១វិច្ឆិកា ក៏បានចោទប្រកាន់បុរសម្នាក់ វ័យ ២៣ឆ្នាំ ពីបទល្មើសជួញដូរមនុស្ស និងបទឧក្រិដ្ឋឃាតកម្មអចេតនា ទៅលើជនភៀសខ្លួនទាំង៣៩នាក់។ អយ្យការអៀកឡង់ បញ្ជាក់ប្រាប់កាសែតបារាំងAFP ថា យុវជននេះ ត្រូវឃុំខ្លួនបណ្តោះអាសន្ន រហូតដល់ថ្ងៃទី១១វិច្ឆិកា។ ប៉ុន្តែ ប៉ូលីសអង់គ្លេស កំពុងស្នើសុំធ្វើប័ត្យាប័នជនត្រូវចោទរូបនេះ ទៅប្រឈមសំណាញ់ច្បាប់អង់គ្លេសតែម្តង។ ចំណែកនគរបាលវៀតណាមវិញ ក៏បានប្រកាសពីការចាប់ឃាត់ខ្លួនមនុស្សប្រុសពីរនាក់ ផងដែរ។

នៅក្នុងសន្និសីទកាសែតថ្ងៃសៅរ៍ ទី២វិច្ឆិកាអ្នកនាំពាក្យក្រសួងការបរទេសវៀតណាម លោកស្រី ឡេ ធី ធូ ហាំង (Lê Thị Thu Hằng) បានអំពាវនាវឱ្យប្រទេសគ្រប់ជ្រុងជ្រោយនៃពិភពលោក ចូលរួមនាំគ្នាជួយទប់ស្កាត់អំពើជួញដូរមនុស្ស ដើម្បីជៀសវាងសោកនាដកម្មសម្លាប់មនុស្ស ដូចករណីមួយនេះទៀត៕

## វៀតណាមប្រកាសថា បានចាប់ខ្លួនជនសង្ស័យក្នុងករណីដែលគេសង្ស័យថាជាការជួញដូរមនុស្សនៅអង់គ្លេស

https://khmer.voanews.com/ 04 វិច្ឆិកា 2019

ហូជីមិញ៖ ទីក្រុង Essex ជាកន្លែងដែលអាជ្ញាធរបានរកឃើញសាកសពជនជាតិវៀតណាមចំនួន ៣៩ នាក់ ដែលពួកគេជឿជាក់ថា បានថប់ដង្ហើមស្លាប់នៅក្នុងរថយន្តកុងតឺណឺមួយគ្រឿង។ ប៉ូលិសក្នុងខេត្ត Ha Tinh នៃប្រទេសវៀតណាមបាននិយាយថា ពួកគេបានចាប់ខ្លួននិងចោទប្រកាន់ជនសង្ស័យពីរនាក់ បន្ទាប់ពីពលរដ្ឋ១០គ្រួសារនៅក្នុងខេត្តនេះ បានរាយការណ៍ថា ពួកគេមានការព្រួយបារម្ភថា សមាជិកគ្រួសាររបស់ពួកគេស្ថិតក្នុងចំណោមជនរងគ្រោះ ៣៩ នាក់នោះ។ ករណីនេះ បានឈានដល់កម្រិតខ្ពស់បំផុតនៃរដ្ឋាភិបាល ដោយទាំងនាយករដ្ឋមន្ត្រីអង់គ្លេស និងវៀតណាមបញ្ជាឱ្យមានការស៊ើបអង្កេត។ ការស៊ើបអង្កេត បានពង្រីកដល់បណ្តាប្រទេសដែលត្រូវបានឆ្លងកាត់ ដូចជាប្រទេសចិន អៀរឡង់ និងប៊ែលហ្ស៊ិក ដែលមន្ត្រីនិយាយថា អ្នកបើកបររថយន្តកុងតឺណឺបាន និយាយថាខ្លួន កំពុងដឹកជញ្ជូននំ។

ការបង្ហោះសារនៅលើគេហទំព័ររបស់ប៉ូលិសមួយបានសរសេរថា «ប៉ូលិសនៅក្នុងខេត្ត Ha Tinh បានប្រមូលផ្តុំកម្លាំង និងមធ្យោបាយដើម្បីធ្វើការស៊ើបអង្កេតឱ្យបានច្បាស់អំពីការរំលោភបំពានច្បាប់របស់បុគ្គល និងស្ថាប័នដែលពាក់ព័ន្ធ»។ ពួកគេមិនបានប្រាប់ឈ្មោះជនសង្ស័យទេ ប៉ុន្តែបាននិយាយថា ពួកគេបានឃុំខ្លួនអ្នកផ្សេងទៀតដើម្បីសាកសួរផងដែរ។

អ្នកស្រី Hoang Thi Ai កាន់ទូរស័ព្ទបង្ហាញរូបថតកូនប្រុសរបស់អ្នកស្រី ដែលអ្នកគិតថា អាចជាជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះដែលស្លាប់នៅក្នុងរថយន្តកុងតឺណឺនៅប្រទេសអង់គ្លេស នៅផ្ទះរបស់អ្នកស្រីក្នុងស្រុក Dien Chau ខេត្ត Nghe An ប្រទេសវៀតណាម កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩។

ជនសង្ស័យ ត្រូវបានចោទប្រកាន់ពីបទ «រៀបចំ និងជាឈ្មួញកណ្តាលដើម្បីឲ្យមនុស្សភៀសខ្លួនទៅក្រៅប្រទេស ឬស្នាក់នៅបរទេសដោយខុសច្បាប់»។ ប៉ូលិសអង់គ្លេសក៏បានចាប់ខ្លួន ឬ ចោទប្រកាន់មនុស្សយ៉ាងតិចណាស់៥នាក់ដែរ ដោយសង្ស័យថា បានសម្លាប់មនុស្ស និងឃុបឃិតក្នុងការជួញដូរមនុស្ស។

អ្នកនាង Hsiao-Hung Pai ជាអ្នកសារព័ត៌មានមួយរូប និងជាអ្នកនិពន្ធសៀវភៅមានចំណងជើងថា «Chinese Whispers: The Story Behind Britain's Hidden Army of Labour» ដែលរៀបរាប់អំពីរឿងរ៉ាវនៅពីក្រោយកម្លាំងពលកម្មលាក់មុខរបស់ចក្រភពអង់គ្លេស។ អ្នកនាងបានសរសេរនៅក្នុងសារព័ត៌មាន the Guardian

កាលពីថ្ងៃពុធ ទី៣០ ខែតុលា កន្លងទៅនេះថា វាមិនមានភាពប្រសើរទេ ក្នុងការផ្តោតតែទៅលើបទឧក្រិដ្ឋ ឬ តែទៅលើ«ជនល្មើសជួញដូរមនុស្ស»នោះ។ អ្នកនាងអះអាងថា ជនរងគ្រោះ ៣៩នាក់ដែលត្រូវបានគេរកឃើញកាលពីខែមុននោះ មិនមែនជាជនរងគ្រោះដែលអស់សង្ឃឹមហើយត្រូវបានគេបញ្ឆោតឲ្យធ្លាក់ចូលទៅក្នុងការជួញដូរមនុស្សនោះទេ តែផ្ទុយទៅវិញ ពួកគេជាអ្នកធ្វើការដែលតស៊ូដើម្បីអនាគតរបស់ក្រុមគ្រួសាររបស់ពួកគេ។

**ការស្លាប់នៅក្នុងរថយន្តកុងតឺណឺនៅមានចំនួនច្រើនទៀត**

អ្នកនាង Hsiao-Hung Pai បានសរសេរទៀតថា «ជាការពិតជាក់ស្តែងជនជាតិវៀតណាមវ័យក្មេងទាំងប្រុសទាំងស្រី ដែលជ្រើសរើសធ្វើដំណើរតាមផ្លូវគ្រោះថ្នាក់ទាំងនេះ គឺដោយសារតែពួកគេមិនអាចមកអង់គ្លេសតាមផ្លូវត្រឹមត្រូវបាន»។ អ្នកនាង Hsiao-Hung Pai ក៏បានសរសេរផងដែរថា «នឹងមានការស្លាប់នៅក្នុងរថយន្តកុងតឺណឺទៀត បើសិនជាប្រទេសអង់គ្លេសមិនផ្លាស់ប្តូរ» គោលនយោបាយរបស់ខ្លួនដែលប្រឆាំងនឹងជនចំណាកស្រុកទេនោះ។ អ្នកនាង Hsiao-Hung Pai បានសរសេរទៀតថា «សូមអនុញ្ញាតឲ្យពលរដ្ឋវ័យក្មេងរបស់យើងមានឱកាសរស់នៅ និងធ្វើការដោយបើកចំហ»។

ដោយឡែកសារព័ត៌មានក្នុងស្រុកមួយបានរាយការណ៍ថា ប៉ូលិសនៅខេត្តមួយផ្សេងទៀតរបស់វៀតណាម គឺខេត្ត Nghe An បាននិយាយថា កាលពីចុងខែតុលា ពួកគេបានចាប់ខ្លួនមនុស្ស ៤ នាក់ដែលសង្ស័យថា ពាក់ព័ន្ធនឹងការជួញដូរមនុស្ស។ វាមិនមានភាពច្បាស់លាស់ទេថា តើបណ្តាញនេះមានជាប់ទាក់ទងជាមួយរឿងជនរងគ្រោះ៣៩នាក់ដែលគេរកឃើញនៅក្នុងទីក្រុង Essex ឬយ៉ាងណានោះ ក៏ប៉ុន្តែ ការស្លាប់នៅក្នុងរថយន្តកុងតឺណឺ បានធ្វើឲ្យការយកចិត្តទុកដាក់និងភាពបន្ទាន់ទាក់ទងនឹងការស៊ើបអង្កេតដែលមានស្រាប់ មានការកើនឡើង។

សម្រាប់ប៉ូលិសនៅទីក្រុង Essex ការស្លាប់នៅក្នុងរថយន្តកុងតឺណឺនេះ ត្រូវបានគេរាយការណ៍ថា គឺជាការស៊ើបអង្កេតដ៏ធំបំផុតដែលពួកគេបានធ្វើ ដែលមានចំនួនមនុស្សស្លាប់ច្រើន។ ទោះបីជាប្រទេសវៀតណាមបានកាត់បន្ថយភាពក្រីក្រយ៉ាងខ្លាំងចាប់តាំងពីសង្គ្រាមរវាងសហរដ្ឋអាមេរិកនិងវៀតណាមបានចប់ទៅក៏ដោយ ក៏អ្នកខ្លះនៅតែយល់ថា ពួកគេអាចរកប្រាក់បានច្រើនដើម្បីផ្គត់ផ្គង់គ្រួសាររបស់ពួកគេដោយធ្វើដំណើរទៅបរទេស។ ក្នុងចំណោមជនចំណាកស្រុកនៅអាស៊ី ជនជាតិវៀតណាមបង់ថ្លៃខ្ពស់ជាងគេដល់មេខ្យល់។ ចំនួនជនចំណាកស្រុកកំពុងកើនឡើងនេះបើយោងតាមអង្គការពលកម្មអន្តរជាតិនៅប្រទេសវៀតណាម។

អង្គការពលកម្មអន្តរជាតិផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលឲ្យសហការដើម្បីធានាឲ្យមានបណ្តាញសុវត្ថិភាពសម្រាប់ការធ្វើចំណាកស្រុក ដូច្នេះប្រជាពលរដ្ឋ មិនចាំបាច់ងាកទៅរកឈ្មួញកណ្តាលទេ។ ជនចំណាកស្រុក នៅតែប្រើប្រាស់បណ្តាញគ្មានសុវត្ថិភាពនេះ ព្រោះថាសាកលភាវូបនីយកម្ម បានបង្កើតការងារកាន់តែច្រើននៅតាមកន្លែងនានាជាច្រើនទៀត។ ទោះជាយ៉ាងនេះក្តី គ្រាដែលសាកលភាវូបនីយកម្មបានធ្វើឲ្យលំហូក្រុមហ៊ុននិងមូលធនឆ្លងកាត់ព្រំដែននោះ វាមិនបានធ្វើឲ្យពលករឆ្លងកាត់ព្រំដែនបានដោយងាយនោះទេ ដែលជាហេតុជំរុញពួកគេឱ្យធ្លាក់ចូលទៅក្នុងការជួញដូរមនុស្ស។

កាលពីថ្ងៃអង្គារទី ២៩ ខែតុលា កន្លងទៅនេះ លោក Chang -Hee Lee ជានាយកប្រចាំប្រទេសនៃអង្គការពលកម្មអន្តរជាតិប្រចាំនៅទីក្រុងហាណូយបាននិយាយថា៖ «តាមរយៈកិច្ចសហការនិងកិច្ចសហប្រតិបត្តិការ ពលករចំណាកស្រុក អាចជាកម្លាំងអភិវឌ្ឍន៍វិជ្ជមាន ហើយហានិភ័យចំពោះសុវត្ថិភាពរបស់ពលករចំណាកស្រុក អាចត្រូវបានកាត់បន្ថយ»៕

# ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១៩

## រដ្ឋបាលស្រុកសង្កែផ្សព្វផ្សាយស្តីពីទប់ស្កាត់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

http://www.rasmeinews.com/ November 5, 2019, 6:54 AM

ដោយៈគ្រញូង/បាត់ដំបងៈកាលពីព្រឹកថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៩ រដ្ឋបាលស្រុកសង្កែបានធ្វើវេទិកាផ្សព្វផ្សាយស្តីពីទប់ស្កាត់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សការធ្វើចំណាកស្រុកនិងការស្វែងរកការងារក្នុងស្រុក។ក្រោមអធិបតីភាពលោកស្រីសុំចិន្តាអភិបាលរងខេត្ត។

លោក សុខ ហឿន អភិបាលស្រុកសង្កែ បានលើកឡើងថា នៅក្នុងស្រុកសង្កែមាន១០ឃុំ ៦៤ភូមិ មានប្រជាពលរដ្ឋចំនួន៣០.១៤៧គ្រួសារ ស្មើ១២០.០៤៣នាក់ ស្រី៦១.៩៩១នាក់។ អាយុ១៨ឆ្នាំឡើងមាន៩៧.៤៣៩នាក់ ស្រី៥០.២៣២នាក់។ ប្រជាពលរដ្ឋដែលធ្វើការចំណាកស្រុកមាន៧.១២៣នាក់ស្រី៣.៣៣១នាក់។ក្នុងនោះចំណាកក្នុងស្រុក១.៤៥៨នាក់ស្រី៧៨៨នាក់និងចំណាកក្រៅស្រុក៥.៦៦៥នាក់ស្រី២.៥៨៣នាក់។

លោក ទូច ស្វាង មេឃុំអន្លង់វិលបានរៀបរាប់ថា ប្រជាពលរដ្ឋគាត់ពីរនាក់ប្រពន្ធទៅធ្វើពលករអ្នកនេសាទនៅប្រទេសថៃជិត១០ឆ្នាំទើបរត់រួចមក។ គឺថៅកែថៃមិនឱ្យមានកូនទេ ហើយមានពលករខ្មែរយើងជាច្រើនចង់វិលមកផ្ទះវិញក៏គេមិនឱ្យមកដែរ។ បន្តមកតំណាងខាងអង្គការសាម៉ារីតាន់ភឺសបានបញ្ជាក់ថា អង្គការទើបមកបង្កើតថ្មីក្នុងឃុំគោលដៅចំនួនបួនមានឃុំកោឃុំវត្តតាមិមឃុំកំពង់ព្រះ និងឃុំកំពង់ព្រៀងមានរយៈពេលបីឆ្នាំ ដើម្បីជួយសម្រួលលើបញ្ហាប្រជាពលរដ្ឋចំណាកស្រុកដើម្បីឱ្យស្របច្បាប់៕S/

## សមត្ថកិច្ចឃាត់ខ្លួនពលរដ្ឋខ្មែរ៧នាក់បម្រុងឆ្លងដែនខុសច្បាប់ទៅថៃ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 04/11/2019

បាត់ដំបង ៖ កាលពីម្សិលមិញសមត្ថកិច្ចការពារព្រំដែនបានឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន៧នាក់ ដែលបម្រុងលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ។ ការឃាត់ខ្លួននេះធ្វើឡើងនៅត្រង់ចំណុចក្រោយកាស៊ីណូគីឡូ១៣ ភូមិតាស្តា ឃុំតាស្តា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

បើតាមប្រភពពីកម្លាំងសមត្ថកិច្ចបានឲ្យដឹងថា ខណកម្លាំងដើរល្បាតក៏បានប្រទះឃើញពលរដ្ឋខ្មែរចំនួន០៧នាក់ បំម្រុងលបលួចឆ្លដែនខុសច្បាប់ទៅក្នុងទឹកដីថៃ ក្រោយកាស៊ីណូ គីឡូ១៣ ភ្លាមៗនោះក៏ត្រូវបានកម្លាំងចំរុះធ្វើកាឃាត់ខ្លួនយកមកទីចាត់ការទំនាក់ទំនងព្រុំដែនដើម្បីសួរនាំតែម្តង។ សមត្ថកិច្ចដដែលនោះ បានបញ្ជាក់ឲ្យដឹងទៀតថា ពលករចំនួន៧នាក់ដែលបម្រុងលបលួចដែលឃាត់ខ្លួនយកមកសួរនាំរួមមាន៖ ទី១. ឈ្មោះ យុន សុភាព ភេទប្រុស អាយុ ៣៣ឆ្នាំ ភូមិ ឃុំ ទន្លេបិត ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម, ទី២. សួន ស្រីមុំភេទស្រី អាយុ ១៩ឆ្នាំ ភូមិទួលគ្រោះ ឃុំ ស្រុកស្នួល ខេត្ត ក្រចេះ, ទី៣. ជួប ប៊ុនលី ភេទប្រុស អាយុ ២៣ឆ្នាំ ភូមិទួលគ្រោះ ឃុំចំរើនផលស្រុកសំពៅមាស ខេត្តពោធិសាត់។ទី៤ . ស្រស់ ជាវ៉ា ភេទប្រុស អាយុ២០ឆ្នាំ ភូមិស្រះរាំងឃុំ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ, ទី៥. ធន ទន់ ភេទស្រី អាយុ ៤២ឆ្នាំ ភូមិបាក់កា ឃុំតាយ៉ែន ស្រុកសូនិគម ខេត្តសៀមរាប, ទី៦. គី ថា ភេទប្រុស អាយុ ៥១ឆ្នាំ ភូមិនិគម ឃុំជ្រោយស្ដៅ ស្រុកថ្មគោល ខេត្តបាត់ដំបង និងទី៧. ប៊ិន រិត ភេទប្រុស អាយុ៣៤ឆ្នាំ ភូមិខ្លប ឃុំព្រែកតាតិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

ក្រោយសាកសួរកម្លាំងទំនាក់ទំនងព្រំដែនកម្ពុជាថៃក៏បានប្រគល់ពលករខ្មែរទាំង ០៧នាក់ ទៅអធិការដ្ឋាននគបាលស្រុកសំពៅលូនដើម្បីចាត់ការបន្ត៕

## ជីវិតកម្មករចំការកៅស៊ូរកចំណូលបានត្រឹមមួយរស់ ព្រោះខ្វះជំនាញ និងកម្រិតវប្បធម៌មានកម្រិត

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ម៉ោង ០៧:៤០ សុវណ្ណ ណែត

រតនគិរី ៖ ដោយសារតែខ្វះជំនាញនិងកម្រិតវប្បធម៌រៀនសូត្របានតិចតួច ប្រជាពលរដ្ឋមួយចំនួនបានបង្ខំចិត្តចាកចេញពីស្រុកកំណើតទៅធ្វើការនៅតាមបណ្តាខេត្តឆ្ងាយៗ ហើយមានអ្នកខ្លះក៏បានចំណាកស្រុកទៅកាន់ប្រទេសជិតខាង ជាពិសេសប្រទេសថៃ ដែលរង់ចាំទទួលយកពលករដែលប្រើកំលាំងកាយជាជាងជំនាញ ។ មិនខុសគ្នាដែរ នៅតាមជាយដែននៃប្រទេសកម្ពុជា ជាពិសេសបណ្តាខេត្តដែលមានសក្តានុពលសម្រាប់ដំណាំកៅស៊ូ ក៏ទទួលយកកម្មករពីខេត្តផ្សេងៗច្រើនផងដែរ ដើម្បីបម្រើការងារនៅក្នុងចំការកៅស៊ូ ក៏ប៉ុន្តែការងារនេះមិនទទួលបានប្រាក់ចំណូលច្រើនប៉ុន្មានទេ ពោលគឺបានត្រឹមតែមួយរស់ប៉ុណ្ណោះ មិនមានអ្វីសល់ជាដុំកំភួនឡើយ ។

លោក វេង រឹទ្ធ ជាកម្មករចំការកៅស៊ូមួយកន្លែងនៅស្រុកបរកែវ នៃទឹកដីខេត្តរតនគិរី និងជាអ្នកចំណាកស្រុកពីខេត្តព្រៃវែង បានអោយដឹងថាលោកធ្វើការនៅក្នុងចំការកៅស៊ូក្នុងស្រុកបរកែវ បានរយៈពេល៤ទៅ៥ឆ្នាំមកហើយ ដោយទទួលបានចំណូលត្រឹមតែមួយរស់ប៉ុណ្ណោះ មិនមានអ្វីសេសសល់ច្រើននោះទេ ។ ប៉ុន្តែសម្រាប់ការងារវិញ ក៏មិនពិបាកណាស់ណានោះទេ តែមិនមានជម្រើសសម្រាប់លោកក្នុងការប្រកបរបរក្រៅពីកម្មករចំការកៅស៊ូ ដោយសារតែលោកមិនមានជំនាញអ្វីនៅក្នុងខ្លួន ។ កម្មករចំការកៅស៊ូបានពោលបន្តទាំងទឹកមុខស្រពោនថា ក្នុងមួយថ្ងៃលោកក៏ដូចជាកម្មករផ្សេងទៀត ត្រូវធ្វើការចាក់ជ័រកៅស៊ូនិងប្រមូលជ័រកៅស៊ូទុកមួយកន្លែង ដើម្បីអោយឡានដែលប្រមូលទិញមកដឹកទៅកែច្នៃនៅរោងចក្រ ហើយប្រាក់កម្រៃដែលលោកទទួលបាន គឺបានតែ៦៥ម៉ឺនរៀលប៉ុណ្ណោះ ក្នុងមួយខែ ដូច្នេះបើប្រៀបធៀបនឹងការងារនៅទីក្រុងគឺមានគំលាតខុសគ្នាឆ្ងាយ ។ លោកបានថា «ខ្ញុំនឹងភរិយាធ្វើការក្នុងចំការកៅស៊ូទាំងពីរនាក់តាំងពីជាង៤ឆ្នាំមុន ដោយទាំងពីរនាក់អាចបានប្រាក់ខែប្រមាណជាង ១លានរៀល ហើយប្រាក់ខែនេះ បើយកមកទូទាត់ការចំណាយប្រចាំថ្ងៃវិញទៅ មិនជាសល់ប៉ុន្មានទេ ដោយមានកូនក្នុងបន្ទុកចំនួន២នាក់ផងដែរ តែពួកគេនៅតូចៗមិនទាន់ចូលរៀនទៀត បើសិនជាពួកគេចូលរៀនទៀតនោះ ការចំនាយកាន់តែខ្ពស់ទៀតហើយ » ។

## វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ ឃុំ-សង្កាត់/ក្រុង-ស្រុក

https://www.facebook.com/deputygovernoryousophear/ 04-11-2019

នៅព្រឹកថ្ងៃចន្ទ ទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រុមការងារលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប សហការជាមួយរដ្ឋបាលសាលាស្រុកពួក ដែលគាំទ្រដោយរដ្ឋបាលសាលាខេត្តសៀមរាប និងមានការគាំទ្រពីអង្គការ UN WOMEN បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ ឃុំ-សង្កាត់/ក្រុង-ស្រុក និងអ្នកពាក់ព័ន្ធ អំពីការអនុវត្តតួនាទីភារកិច្ច ច្បាប់ពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពានលើកុមារ និងពង្រឹងលើកិច្ចសហប្រតិបត្តិការក្នុងការផ្តល់សេវាជួយជនរងគ្រោះឲ្យបានសមស្របនិងមានប្រសិទ្ធិភាព។

វគ្គបណ្តុះបណ្តាលប្រព្រឹត្តទៅនៅបន្ទប់ប្រជុំរដ្ឋបាលស្រុកពួក ដែលដឹកនាំដោយលោកស្រីឧត្តមសេនីយ៍ត្រី ដួង ថាវរី ស្នងការនគរបាលខេត្ត ជាអនុប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងជាតំណាងលោកជំទាវ យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងមានការអញ្ជើញចូលរួមពីលោកស្រី ឆែម សុជា អភិបាលរង

ស្រុកពួក លោក អ៊ឹម ចំរើន អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត លោកស្រី ងិន សារិន អនុប្រធានមន្ទីរកិច្ចការនារីខេត្ត តំណាងមន្ទីរសង្គមកិច្ចខេត្ត និងមានការអញ្ជើញចូលរួមពី ព្រះសង្ឃ ប្រធាន អនុប្រធានការិយាល័យជុំវិញស្រុក មេឃុំ ស្មៀន អ.ក.ន.ក អធិការ កងរាជអាវុធហត្ថ ប្រជាការពារ មណ្ឌលសុខភាព នាយប៉ុស្តិ៍ នាយកសាលា យុវជន និងអង្គការដៃគូ សរុប ៥២នាក់ ស្រី១៤នាក់។

## ឃាត់ខ្លួនពលករខ្មែរ លួចឆ្លងដែនខុសច្បាប់ មកពីប្រទេសថៃ ចំនួន ០៤នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 05-11-2019

នៅថ្ងៃអង្គារ ៩កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ០៣និង៤០នាទីព្រឹក កម្លាំងប៉ុស្តិ៍នគរបាល ច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី បានចុះល្បាតនៅចំណុចស្លាបឆ្វេង នៃច្រក និងបានឃាត់ខ្លួនពលករខ្មែរ លួចឆ្លងដែនខុសច្បាប់ មកពីប្រទេសថៃ ចំនួន ០៤នាក់។ នគរបាលអន្តោប្រវេសន្តបានឲ្យដឹងថា ពលករខ្មែរដែលឆ្លងដែនខុសច្បាប់ ទាំង ០៤នាក់ ស្រី ០២នាក់ ត្រូវបានយកមកសាកសួរ អប់រំ ណែនាំ និងបញ្ជូនទៅអធិការដ្ឋាននគរបាលស្រុកសំពៅលូន អប់រំបន្តទៀត៕

## រាជបណ្ឌិត្យសភាកម្ពុជា បើកសិក្ខាសាលាស្តីពី «លំហូរពលករទេសន្តរប្រវេសន៍កម្ពុជា ផលប្រយោជន៍ និងបញ្ហាប្រឈម»

http://www.freshnewsasia.com/ 2019-11-05

**(ភ្នំពេញ)៖** រាជបណ្ឌិត្យសភាកម្ពុជា ដែលរៀបចំដោយវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គមនៅព្រឹកថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ បានបើកសិក្ខាសាលា «លំហូរពលករទេសន្តរប្រវេសន៍កម្ពុជា ដោយផ្តោតលើផលប្រយោជន៍ និងបញ្ហាប្រឈម» ក្រោមការឧបត្ថម្ភថវិកា ពីរាជរដ្ឋាភិបាលកម្ពុជា។

សិក្ខាសាលានេះបានធ្វើឡើងក្រោមវត្តមានលោកបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា តំណាងលោកបណ្ឌិតសភាចារ្យ សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ដោយមានការអញ្ជើញចូលរួមពីសំណាក់លោកស្រី វាគ្មិន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវមួយចំនួន។ បើតាមលោកបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ បានថ្លែងថា ស្របពេលដែលប្រទេសកម្ពុជាបាននឹងកំពុងធ្វើសមាហរណកម្មទៅក្នុងតំបន់ និងក្នុងពិភពលោក ការកើនឡើងនៃសេចក្តីត្រូវការនូវប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់ ជីវភាពគ្រួសារឱ្យបានកាន់តែល្អប្រសើរ បានជំរុញឱ្យពលករខ្មែរ ធ្វើចំណាកស្រុកទៅស្វែងរកការងារនៅក្រៅប្រទេស តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន។ លោកបានឱ្យដឹងថា ការធ្វើចំណាកស្រុកទៅក្រៅប្រទេសដើម្បីការងារគឺជាការចូលរួមចំណែក មួយក្នុងការលើកកម្ពស់ជីវភាពគ្រួសារ និងនាំមកនូវសាច់ប្រាក់ចាក់បញ្ចូល ក្នុងចរន្តសេដ្ឋកិច្ចជាតិក៏ពិតមែន តែរាជរដ្ឋាភិបាលបានចាត់ទុកការធ្វើចំណាកស្រុកជាជម្រើសចុងក្រោយ និងគ្រាន់តែជាដំណាក់កាលបណ្តោះអាសន្នតែប៉ុណ្ណោះ។ លោកបណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ បានបន្តថា រាជរដ្ឋាភិបាលបានអនុញ្ញាត ឱ្យបញ្ជូនពលករទៅបម្រើការងារ នៅក្រៅប្រទេសដោយផ្អែក លើបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិដូចជា៖ ធម្មនុញ្ញអង្គការអន្តរជាតិស្តីពី សន្តរប្រវេសន៍ ដែលក្នុងនោះប្រទេសកម្ពុជាបានអនុម័តយល់ព្រម ការធ្វើទេសន្តរប្រវេសន៍ ដោយមានសុវត្ថិភាព របៀបរៀបរយ និងស្របច្បាប់ ដើម្បីហានិភ័យរបស់ពលករ ពីការកេងប្រវ័ញ្ច ការរំលោភបំពាន ការរត់ពន្ធជនទេសន្តរប្រវេសន៍ និងរាល់ទម្រង់នៃអំពើជួញដូរមនុស្ស ការរក្សានូវតុល្យភាព នៃកម្លាំងពលកម្មក្នុងស្រុក ដែលជាសេចក្តីត្រូវការ សម្រាប់ការអភិវឌ្ឍ របស់ប្រទេសជាតិ សេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តប្រវេសន៍។

តាមរយៈខិតខំជួយពលករ ដែលធ្វើការនៅបរទេស ដើម្បីធានាបាននូវផលប្រយោជន៍ស្របច្បាប់ និងជួយផ្តល់ភាពស្របច្បាប់ដល់ពលករ សហការជាមួយ ប្រទេសជាដៃគូ ទទួលស្គាល់ពលករដែលមានជំនាញទៅវិញទៅមក

ជាមួយកម្ពុជា សហការជាមួយបណ្តាប្រទេសអាស៊ាន ក្នុងកិច្ចសហប្រតិបត្តិការ លើវិស័យរបបសន្តិសុខសង្គម ដោយធានា ចំពោះពលករស្របច្បាប់ នៅគ្រប់ប្រទេសនៅពេលមានគ្រោះថ្នាក់ដល់ ជីវិតឱ្យទទួលបានសំណងតាមច្បាប់។

បើយោងតាមរបាយការណ៍របស់ក្រសួងការបរទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០១៨ និងទិសដៅការងារ ឆ្នាំ២០១៩ នាថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៩ បានបង្ហាញថា ប្រជាពលរដ្ឋខ្មែរចេញទៅធ្វើការងារនៅក្រៅប្រទេសមានចំនួន ១,២៣៤,១១១ (ស្រី៤៩៩,០៧០នាក់) រួមមានៈប្រទេសថៃ មានចំនួន១,១៤៦,៦៨៥នាក់, ប្រទេសកូរ៉េខាងត្បូង មានចំនួន៤៩,០៩៩នាក់, ប្រទេសជប៉ុន មានចំនួន៩,១០០នាក់, ប្រទេសម៉ាឡេស៊ី មានចំនួន៣០,១១៣នាក់, ប្រទេសសិង្ហបុរី មានចំនួន៨៣១នាក់, តំបន់រដ្ឋបាលពិសេសហុងកុងមានចំនួន៥៤នាក់ និងប្រទេសអារ៉ាប់ប៊ីសាអូឌីត មានចំនួន១៦នាក។

**ជាមួយគ្នានេះដែរ ពលករដែលបានត្រឡប់មកប្រទេសវិញ ចម្លោះ ឆ្នាំ២០១៤-២០១៨ មានចំនួន២៧១,៦១២នាក់ គឺប្រមាណ២២ភាគរយ នៃចំនួនពលករ ដែលកំពុងស្នាកនៅ និងធ្វើការនៅបរទេសគិតមកដល់ឆ្នាំ២០១៨។ ក្នុងនោះចំណោមពលករដែលបានត្រឡប់មកប្រទេសវិញ រួមមានៈ**

* ជប៉ុន ចំនួន១,៨៨២នាក់ ស្មើនឹង ០,១៥ភាគរយ
* កូរ៉េ ចំនួន ១៣,១០២នាក់ ស្មើនឹង ១,០៦ភាគរយ
* ម៉ាឡេស៊ី ចំនួន ១៦,៥០៨នាក់ ស្មើនឹង ១,៣៤ភាគរយ
* ប្រទេសថៃ ចំនួន ២៤០,០១៤នាក់ ស្មើនឹង១៩,៤៤ភាគរយ៕

## ប្រទះឃើញសាកសព ពលករខ្មែរ ម្នាក់ស្លាប់អណ្តែតនៅក្នុងសមុទ្រ ខេត្តត្រាត

https://www.facebook.com/prakpheaktraofficial/ ប្រាក់ ភក្ត្រា-Prak Pheaktra **04-11-2019**

យោងតាមរបាយការណ៍ ពីសមត្ថកិច្ចតម្រួតជើងទឹក ខេត្តត្រាត ប្រទេសថៃ បានអោយដឹងថា នៅវេលាម៉ោង០៤:៣០នាទីល្ងាច ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៩ កម្លាំងសមត្ថកិច្ចជើងទឹក សហការជាមួយភ្នាក់ងារសង្គ្រោះត្រាតបានដឹកនាំកម្លាំងចុះទៅ ពិនិត្យសាសពបុរសម្នាក់ ស្លាប់អណ្តែតទឹក នៅម្តុំសមុទ្រកោះគូត ស្រុកខ្លុងយ៉ៃ ខេត្តត្រាត ។ តាមការកោសល្យវិច័យ របស់សមត្ថកិច្ចថៃ ប្រាប់ថា សាកសពអ្នកស្លាប់មានឈ្មោះ យ៉េន យ៉ត (Yien Yot ) ភេទប្រុស អាយុ៤០ឆ្នាំ សញ្ជាតិខ្មែរ ជាពលករធ្វើការនៅទូកនេសាទ បន្ទាប់ពីបាត់ខ្លួនកាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ កន្លងទៅ។ បច្ចុប្បន្នសាកសពជនរងគ្រោះ ត្រូវបានសមត្ថកិច្ចថៃ បញ្ជូនយកនៅរក្សាទុកនៅមន្ទីរពេទ្យ និងកំពុងទំនាក់ទំនងទៅថៅកែ អោយស្វែងរកសាច់ញាតិ ទទួលយកទៅធ្វើបុណ្យតាមប្រពៃណី។

## អឺរ៉ុបបង្កើនការត្រួតពិនិត្យ តាមរថយន្តដឹកទំនិញ ដោយក្រុមជួញដូរមនុស្សកំពុងតែប្រើប្រាស់មធ្យោបាយនេះ

http://nokorwatnews.com/archives/ 05-11-2019

ក្រុមជួញដូរមនុស្សបានប្រើប្រាស់រថយន្តដឹកទំនិញក្លាសេ សម្រាប់ដឹកជញ្ជូនជនភៀសខ្លួនជាច្រើនចូលទៅកាន់តំបន់អឺរ៉ុប។ ការបែកធ្លាយ គម្រោងដឹកជញ្ជូនបែបនេះ ក្រោយពេលរកឃើញមានអ្នកស្លាប់៣៩នាក់ជាជនជាតិវៀតណាមនៅក្នុងរថយន្តក្លាសេ ប្រទេសអង់គ្លេស។

នៅពេលនេះប៉ូលិសក្រិចក៏បាន រកឃើញជនភៀសខ្លួន៤១នាក់ ក្នុងរថយន្តដឹកទំនិញក្លាសេ។ កាលពីថ្ងៃទី៤ ខែវិច្ឆិកា ប៉ូលិសក្រិច បានរកឃើញជនភៀសខ្លួន៤១នាក់នៅក្នុងរថយន្តក្លាសេ ។ កម្លាំងប៉ូលិសក្រិចបានឲ្យដឹងថា នៅពេលត្រួតពិនិត្យ ជាប្រចាំ ក៏បាន រកឃើញរថយន្តដឹកទំនិញក្លាសេ កំពុងតែបើកបរនៅលើផ្លូវល្បឿនលឿន ស្ថិតនៅភាគខាជើងប្រទេសនេះ បង្កឲ្យមានការសង្ស័យ ។ នៅពេលនោះកម្លាំងប៉ូលិសក៏បានត្រួតពិនិត្យ ក៏ឃើញជនភៀស

ខ្លួនដើមកំណើតអាហ្វហ្គានីស្ថាន៤១នាក់នៅខាងក្នុង ចំណែកអ្នកបើកបរក៏បានរត់គេចខ្លួន។ ក្នុងចំណោមនោះមាន ៧នាក់ស្ថិតនៅសភាពចុះខ្សោយ ក៏បានបញ្ជូនទៅកាន់មន្ទីរពេទ្យ។

អ្នកបើកបររថយន្ត មានដើមកំណើតGruzia សង្ស័យដឹកជញ្ជូនជនភៀសខ្លួនខុសច្បាប់ ក៏ត្រូវប៉ូលិសឃាត់ខ្លួននៅនឹងកន្លែង។ចំណែកអ្នកបើកបរម្នាក់ទៀត ក៏បានរត់គេចខ្លួនពេលប៉ូលិសកំពុងតែត្រួតពិនិត្យ សួរនាំអ្នកបើកបរផ្ទាល់។ កម្លាំងប៉ូលិសក៏បានស្វែងរកចាប់ខ្លួនអ្នកបើកបរទីពីរដែលគេចខ្លួនបាត់។ ការចាប់រថយន្តដឹកជនភៀសខ្លួនខុសច្បាប់ខាងលើកើតឡើង ស្ថិតនៅផ្លូវល្បឿនលឿនចូលទៅកាន់ទីក្រុង Xanthi ភាគខាងជើងប្រទេសក្រិច។ទីក្រុងនេះមានចម្ងាយពីព្រំដែន ក្រិច តួកគី តែប៉ុន្មានគីឡូម៉ែត្រ តែប៉ុណ្ណោះ ដែលជាច្រកផ្លូវដ៏សំខាន់បំផុតដែលក្រុមជនភៀសខ្លួនតែងតែ លួចលាក់ចូលទៅកាន់អឺរ៉ុប។ កាលពីឆ្នាំ២០១៦ អឺរ៉ុបនិង តួកគី បានចុះហត្ថលេខា ទប់ស្កាត់ជនភៀសខ្លួនចូលទៅកាន់អឺរ៉ុប។

កន្លងមកថ្មីៗ ប៉ូលិសប៊ែលហ្ស៊ិចបានរកឃើញមនុស្ស១២នាក់ នៅមានជីវិត ក្នុងរថយន្តដឹកទំនិញក្លាសេ ស្ថិតនៅចំណតរថយន្ត ជាយក្រុង Turnhout កាលពីចុងខែតុលា ក្រោយពេលអ្នកបើកបររថយន្តទូរស័ព្ទប្រាប់ប៉ូលិស។ អ្នកនាំពាក្យស្នងការប៉ូលិសប៊ែលហ្ស៊ិចបញ្ជាក់ថា អ្នកបើកបររថយន្តខាងលើ ពេលនោះបើករថយន្តដឹកជញ្ជូនបន្លែនិងផ្លែឈើ បានទូរស័ព្ទប្រាប់ប៉ូលិសក្រោយឃើញជនភៀសខ្លួន១២នាក់នៅក្នុងរថយន្ត។ ជនភៀសខ្លួនទាំងនោះត្រូវបានបញ្ជូនទៅកាន់ការិយាល័យគ្រប់គ្រងអន្តោប្រវេសន៍នៅទីក្រុង Antwerp ។ តាមការលើកឡើងរបស់ប៉ូលិសប៊ែលហ្ស៊ិច ជនភៀសខ្លួនទាំងនោះ ជាជនជាតិស៊ីរីនិងស៊ូដង់ ព្យាយាម ចូលទៅកាន់ប្រទេសអង់គ្លេស។

កាលពីថ្ងៃទី២៧ខែតុលា បារាំង បានរកឃើញ ជនភៀសខ្លួន៨នាក់នៅក្នុងរថយន្តដឹកទំនិញក្លាសេឆ្ពោះទៅកាន់ប្រទេសអង់គ្លេស។ ជនភៀសខ្លួនទាំងនោះស្ថិតនៅក្នុង ស្ថានភាពចុះកម្តៅយ៉ាងខ្លាំង ប្រសិនបើនៅក្នុងរថយន្តនោះប៉ុន្មានម៉ោងទៀតនឹងស្លាប់ជាមិនខាន។

បច្ចុប្បន្នដោយសារតែ អឺរ៉ុបរិតបន្តឹងច្បាប់ ទើបជនភៀសខ្លួន ជាច្រើនបានសម្រេចធ្វើដំណើរតាមវិធីដ៏គ្រោះថ្នាក់ ក៏ដូចជាធ្លាក់ចូលក្នុងដៃក្រុមជួញដូរមនុស្ស។ ជាក់ស្តែងនៅក្នុងប្រទេស បារាំងក៏ដូចជាអង់គ្លេស ចាប់បានជនភៀសខ្លួនជាច្រើនធ្វើដំណើរតាម រថយន្តដឹកទំនិញក្លាសេ។ សោកនាដកម្មធំបំផុតនោះគឺ ជនភៀសខ្លួន ស្លាប់៣៩នាក់ នៅក្នុងប្រទេសអង់គ្លេស ដែលជាហេតុជំរុញឲ្យអឺរ៉ុប ពិចារណាឡើងវិញ នូវច្បាប់រិតបន្តឹងជនភៀសខ្លួន៕

## ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០១៩

### សម្តេចតេជោ ហ៊ុន សែន នឹងអញ្ជើញបើកសន្និសីទ អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន លើកទី១២

https://dap-news.com/ Posted on November 6, 2019

ភ្នំពេញ៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅព្រឹកថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ នឹងអញ្ជើញជាអធិបតី ដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកសន្និសីទ អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិនលើកទី១២ ដែលប្រារព្ធធ្វើឡើង នៅខេត្តសៀមរាប។ យោងតាមគេហទំព័រហ្វេសប៊ុក របស់សម្តេចតេជោ ហ៊ុន សែន បានឲ្យដឹងថា សន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិនលើកទី១២ នឹងត្រូវធ្វើឡើងក្រោមប្រធានបទ «តួនាទីព្រះរាជអាជ្ញាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងតំបន់»។ សន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិនលើកទី១២ មានរយៈពេលពីរថ្ងៃនេះ នឹងមានការអញ្ជើញចូលរួមពី អគ្គព្រះរាជអាជ្ញាអគ្គរដ្ឋអាជ្ញាឬប្រធានប្រតិភូមកពីបណ្តាប្រទេលស នៃសមាគមអាស៊ាន និងប្រទេសចិនផងដែរ៕

# ប្រសាសន៍សំខាន់ៗរបស់សម្ដេចតេជោ ហ៊ុន សែន អញ្ជើញជាអធិបតីភាពបើកសន្និសីទ អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន លើកទី១២ ដែលប្រារព្ធធ្វើឡើងនៅខេត្តសៀមរាប

https://www.chnchannel.com/ អត្ថបទដោយ Kongkea Leuk កាលបរិច្ឆេទ ថ្ងៃទី 6 ខែ វិច្ឆិកា ឆ្នាំ 2019

**សៀមរាប៖** សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា នៅព្រឹកថ្ងៃពុធ ទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ បានអញ្ជើញជាអធិបតីភាពបើកសន្និសីទ អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន លើកទី១២ ដែលប្រារព្ធធ្វើឡើងនៅខេត្តសៀមរាប។ សន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិនលើកទី១២ ត្រូវធ្វើឡើងក្រោមប្រធានបទ «តួនាទីព្រះរាជអាជ្ញាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងតំបន់»។ ខាងក្រោមជាប្រសាសន៍សំខាន់ៗរបស់សម្ដេចតេជោ ហ៊ុន សែន៖

- សម្ដេចតេជោ ហ៊ុន សែន បានថ្លែងថា ថ្ងៃនេះ កម្ពុជាពិតជាមានកិត្តិយសដែលបានធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទដ៏មានសារៈសំខាន់នេះ ស្របពេលដែលបញ្ហាប្រទេសសមាជិកអាស៊ាន ក៏ដូចជាប្រទេសនៅក្នុងតំបន់កំពុងរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាឧក្រិដ្ឋកម្មឆ្លងដែនប្រកបដោយគ្រោះថ្នាក់ ហើយកំពុងរីករាលដាលនៅក្នុងតំបន់របស់យើង។
- សម្ដេចតេជោ ហ៊ុន សែន បានថ្លែងថា ភាពជឿនលឿននៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព័ត៌មានក្នុងយុគសម័យទំនើបនេះ បានធ្វើឱ្យចរន្តសេដ្ឋកិច្ចពិភពលោកមានការវិវត្តយ៉ាងលឿន។ ទន្ទឹមនេះ ការរីកចម្រើនទីផ្សារការងារក្នុងពិភពលោក ក៏ដូចជានៅក្នុងបញ្ហាប្រទេសអាស៊ាន បានជំរុញឱ្យប្រទេសសមាជិកអាស៊ាន និងប្រទេសក្នុងតំបន់ទទួលបាននូវកំណើនសេដ្ឋកិច្ច ពាណិជកម្ម និងការវិនិយោគក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់ និងបានបង្កើតឱ្យមានទីផ្សារការងារយ៉ាងច្រើនសន្ធឹកសន្ធាប់។ តាមរយៈចរន្តនៃទីផ្សារការងារ និងដំណើរចល័តនៃកម្លាំងពលកម្មអន្តរជាតិធ្វើឱ្យកើតនូវ «អំពើជួញដូរមនុស្ស» ជាយថាហេតុនៅក្នុងបញ្ហាប្រទេសសមាជិកអាស៊ាន រួមទាំងបញ្ហាប្រទេសនៅក្នុងតំបន់ផងដែរ។
- សម្ដេចតេជោ បានថ្លែងថា ការកេងប្រវ័ញ្ចគ្រប់រូបភាពពីស្ថានភាពស្វែងរកការងារនៅក្នុងស្រុក និងការធ្វើចំណាកស្រុកទៅក្រៅប្រទេស ធ្វើឱ្យឧក្រិដ្ឋជនឆ្លៀតឱកាសបង្កើតឱ្យមាន «អំពើជួញដូរមនុស្ស» ការកេងប្រវ័ញ្ចពលកម្ម ជួញដូរផ្លូវភេទ ជួញដូរទារក និងកុមារ និងការជួញដូរសរីរាង្គមនុស្ស ដែលជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរចាំបាច់តម្រូវឱ្យប្រទេសសមាជិកអាស៊ាន និងចិនផ្ដោតការយកចិត្តទុកដាក់ខ្ពស់ និងត្រូវរួមគ្នាទប់ស្កាត់ឱ្យបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ទាំងនៅក្នុងតំបន់ និងក្នុងពិភពលោក។
- សម្ដេចតេជោ ហ៊ុន សែន បានថ្លែងថា «អំពើជួញដូរមនុស្ស» នៅកម្ពុជាបច្ចុប្បន្នក៏ដូចជាបញ្ហាឆ្នាំកន្លងមក ត្រូវបានរាជរដ្ឋាភិបាលចាត់វិធានការ បង្ការ ទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលា តាមរយៈការពង្រឹងច្បាប់ ការអនុវត្តនូវគោលនយោបាយបង្ការ ទប់ស្កាត់ និងការពារជនរងគ្រោះ ជាមួយការអនុវត្តច្បាប់ព្រហ្មទណ្ឌយ៉ាងខ្ជាប់ខ្ជួន។ ហើយជាបន្តបន្ទាប់ ដោយមានកិច្ចសហការល្អរវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ ស្ថាប័នអយ្យការ និងតុលាការធ្វើឱ្យកម្ពុជាទទួលបាននូវលទ្ធផលគួរជាទីមោទនៈ ក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែនកន្លងមក។
- សម្ដេចតេជោនាយករដ្ឋមន្ត្រី បានថ្លែងថា កម្ពុជាបានអនុម័ត និងកំពុងរៀបចំច្បាប់គោលនយោបាយ លិខិតបទដ្ឋានពាក់ព័ន្ធជាមួយនឹងការបង្ការ ទប់ស្កាត់បង្ក្រាប និងផ្ដន្ទាទោស «អំពើជួញដូរមនុស្ស» រួមមាន ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទឆ្នាំ ២០០៨ ក្រមព្រហ្មទណ្ឌឆ្នាំ២០១០ សេចក្ដីព្រាងច្បាប់ស្ដីពី «ការពពោះជំនួស» សេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋាន

នានា ព្រមទាំងបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាច្រើនទៀត ជាមួយបញ្ហាប្រទេសជាមិត្ត ទាំងក្នុងតំបន់ និងអន្តរជាតិ ទាក់ទងអំពើជួញដូរមនុស្ស ជាពិសេសចំពោះស្ត្រី និងកុមារ ការសង្គ្រោះ ការស្តារឡើងវិញ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មជនរងគ្រោះដោយ «អំពើជួញដូរ»។

- សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ការបង្ការទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោស «អំពើងជួញដូរមនុស្ស» គឺជាគោលនយោបាយដ៏សំខាន់ដែលរាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ខ្ពស់ និងបានអនុវត្តកន្លងមកតាមរយៈការផ្សព្វផ្សាយគ្រប់ទម្រង់នៃ «អំពើជួញដូរមនុស្ស» តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន។
- សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ការប្រយុទ្ធប្រឆាំង «អំពើជួញដូរមនុស្ស» លំបាក និងស្មុគស្មាញ គឺជាបទល្មើសឆ្លងដែនខុសច្បាប់ និងជាឧក្រិដ្ឋកម្ម ដែលមានវិសាលភាពទាំងក្នុងតំបន់អាស៊ាន និងសកលលោក។
- សម្តេចតេជោ ហ៊ុន សែន ថ្លែងថា ដើម្បីប្រយុទ្ធប្រឆាំង «អំពើជួញដូរមនុស្ស» នេះឱ្យបានទាន់ពេលវេលា ប្រទេសសមាជិកអាស៊ាន-ចិន ត្រូវមានគោលការណ៍រួមមួយ ឯកភាពគ្នា សហការគ្នាយ៉ាងជិតស្និទ្ធ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។
- សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា នៅឆ្នាំ២០២៤ អាស៊ាន នឹងធ្វើជាម្ចាស់ផ្ទះប្រកួតបាល់ទាត់ពិភពលោក។ អាស៊ានអាចបង្កើតជាក្រុមមួយទៅប្រកួតបាល់ទាត់ពិភពលោក ដែលជាអត្តសញ្ញាណមួយរបស់អាស៊ាន។
- សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា អាស៊ានជាសហគមន៍តែមួយ តែមានច្បាប់ដោយឡែកពីគ្នា ដែលពិបាក់ក្នុងការប្រយុទ្ធប្រឆាំងជាមួយការជួញដូរមនុស្ស ក្នុងន័យនេះសម្តេចតេជោ លើកទឹកចិត្ត ឱ្យខិតខំធ្វើកិច្ចសហប្រតិបត្តិការតាមរយៈកិច្ចព្រមព្រៀងរួមគ្នា ដែលអាចធ្វើទៅបាន។
- សម្តេចតេជោ ហ៊ុន សែន ក៏បានផ្តល់នូវអនុសាសន៍ចំនួន៤ ដើម្បីចូលរួមប្រយុទ្ធប្រឆាំង «ការជួញដូរមនុស្ស» នេះឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។ អនុសាសន៍ទាំង៤នោះរួមមានៈ

១. អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន ត្រូវរួមគ្នាធ្វើកិច្ចសហប្រតិបត្តិការឱ្យបានជិតស្និទ្ធជាមួយបញ្ហាស្ថាប័ន និងប្រទេសពាក់ព័ន្ធនឹង « អំពើជួញដូរមនុស្ស » ជាពិសេសនៅក្នុងប្រទេសឆ្លងកាត់ និងប្រទេសគោលដៅ ដើម្បីឆ្លើយតប និងដោះស្រាយឱ្យបានទាន់ពេលកំណត់ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។

២. អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិនត្រូវរួមគ្នាពិនិត្យ និងវាយតម្លៃបញ្ហា « អំពើជួញដូរមនុស្ស » តាមរយៈស្មារតីទទួលខុសត្រូវខ្ពស់ ប្រកបដោយគុណភាព និងប្រសិទ្ធភាពជាមួយប្រទេស និងនៃការយោគយល់គ្នាដែលបានចុះហត្ថលេខាកន្លងមក ។

៣. អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន និងស្ថាប័នពាក់ព័ន្ធត្រូវរួមគ្នាបន្ត និងបង្កើនកិច្ចសហការឱ្យបានទូលំទូលាយ បង្កលក្ខណៈងាយស្រួល និងចូលរួមផ្តល់ធនធានសម្រាប់ប្រតិបត្តិការជាប្រព័ន្ធដើម្បីអាចឆ្លើយតបបញ្ហាបានទាន់ពេលវេលាស្តីពី «អំពើជួញដូរមនុស្ស »ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

៤ អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិនត្រូវរួមគ្នាធ្វើកំណត់ត្រា និងចងក្រងរបាយការណ៍ជាមួយនឹងភស្តុតាងជាក់ស្តែង ដើម្បីបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងរួមគ្នាជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការចូលរួមប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាឧក្រិដ្ឋកម្មបង្កគ្រោះថ្នាក់ដល់សង្គមជាតិ និងកំពុងប៉ះពាល់ដល់កិច្ចដំណើរការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចនៅក្នុងតំបន់ និងសកលលោក។

- សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា វៀតណាម មានពលករធ្វើការនៅកូរ៉េខាងត្បូងជាង ២០ម៉ឺននាក់។
- សម្តេចតេជោនាយករដ្ឋមន្ត្រី បានថ្លែងថា ពលករខ្មែរទៅធ្វើការនៅកូរ៉េខាងត្បូង ទោះបីមានការរៀបចំប្រលងត្រឹមត្រូវ ក៏នៅតែមានអ្នកចាញ់បោកក្រុមជនឆបោកមួយចំនួន។

- សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា រាជរដ្ឋាភិបាលកំពុងធ្វើកំណែទម្រង់នយោបាយព្រហ្មទណ្ឌមួយឱ្យបានច្បាស់លាស់។ សម្តេចតេជោ បន្តថា ដ្បិតថា តុលាការជាប្រព័ន្ធឯករាជ្យ តែបើរាជរដ្ឋាភិបាលមិនមាននយោបាយព្រហ្មទណ្ឌមួយច្បាស់លាស់ទេ នឹងមានគ្រោះថ្នាក់ដល់ដំណើរការរបស់រដ្ឋ។
- សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា កម្ពុជា ជ្រើសរើសប្រព័ន្ធមួយដែលមានកិច្ចសហប្រតិបត្តិការមួយជាប់លាប់រវាងតុលាការ ជាមួយស្ថាប័ននីតិប្រតិបត្តិ ដើម្បីការគ្រប់គ្រងរដ្ឋមួយបានជាប់លាប់។
- សម្តេចតេជោ ហ៊ុន សែន បានសង្ឃឹមថា អង្គសន្និសីទនឹងបន្តប្រើប្រាស់យន្តការអគ្គព្រះរាជអាជ្ញាអាស៊ាន- ចិន ដែលជាវេទិកាពង្រឹងកិច្ចសហប្រតិបត្តិការពារប្រកបដោយឆន្ទៈរួមតែមួយ ក្នុងការប្រយុទ្ធប្រឆាំង «អំពើជួញដូរមនុស្ស» និងបទល្មើសឆ្លងដែនគ្រប់រូបភាពដើម្បីធានានូវសន្តិសុខ និងសុវត្ថិភាពឆ្លងដែនដល់បញ្ហាប្រជាជននៅក្នុងប្រទេសអាស៊ាន- ចិន និងនៅក្នុងតំបន់។
- សម្តេចតេជោ ហ៊ុន សែន បានបញ្ចប់ការថ្លែងសុន្ទរកថានៅវេលាម៉ោង ៩៖៣៨នាទី នាព្រឹកថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩៕

## នាយករដ្ឋមន្ត្រីកម្ពុជា ឲ្យអគ្គព្រះរាជអាជ្ញា អាស៊ាន-ចិន បង្កើនកិច្ចសហការ ឆ្លើយតបទាន់ពេលវេលា អំពើជួញដូរមនុស្ស

https://dap-news.com/ Posted on November 6, 2019

ភ្នំពេញ ៖ នៅចំពោះមុខ មន្ត្រីជាន់ខ្ពស់ អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានអំពាវនាវឲ្យពួកគាត់ និងស្ថាប័នពាក់ព័ន្ធបង្កើន កិច្ចសហប្រតិបត្តិការ ឲ្យបានទូលំទូលាយ ដើម្បីអាចឆ្លើយតបទាន់ ពេលវេលាអំពើជួញដូរមនុស្ស ។ ក្នុងពិធីបើកសន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន លើកទី១២ ក្រោមប្រធានបទ តួនាទីព្រះរាជអាជ្ញាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងតំបន់ នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១៩ សម្តេចតេជោ បានថ្លែងថា ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺជាបញ្ហាសកល និងជាបទល្មើឆ្លងដែនខុសច្បាប់។ សម្តេចបន្តថា អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន ត្រូវរួមគ្នាធ្វើកិច្ចសហប្រតិបត្តិការឲ្យបានជិតស្និទ្ធ ជាមួយបញ្ហាស្ថាប័ន និងប្រទេសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ជាពិសេសប្រទេសឆ្លងកាត់ និងប្រទេសគោលដៅ ដើម្បីឆ្លើយតបនិងដោះស្រាយឲ្យបានទាន់ពេលកំណត់ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។ សម្តេចបន្ថែមថា អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន ត្រូវរួមគ្នាពិនិត្យ និងវាយតម្លៃបញ្ហា អំពើជួញដូរមនុស្ស តាមរយៈស្មារតីទទួលខុសត្រូវខ្ពស់ ប្រកបដោយគុណភាព និងប្រសិទ្ធភាពជាមួយប្រទេស និងការយោគយល់គ្នា ដែលបានចុះហត្ថលេខាកន្លងមក។ សម្តេចមានប្រសាសន៍ថា "អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន និងស្ថាប័នពាក់ព័ន្ធត្រូវរួមគ្នាបន្ត និងបង្កើនកិច្ចសហការឲ្យបានទូលំទូលាយ បង្កលក្ខណៈងាយស្រួល និងចូលរួមផ្តល់ធនធាន សម្រាប់ប្រតិបត្តិការជាប្រព័ន្ធ ដើម្បីអាចឆ្លើយតបបញ្ហាបានទាន់ ពេលវេលាស្តីពី អំពើជួញដូរមនុស្ស ប្រកបដោយប្រសិទ្ធភាពខ្ពស់"។

បន្ថែមពីនេះនាយករដ្ឋមន្ត្រីកម្ពុជា លើកឡើងថា អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន ត្រូវរួមគ្នាធ្វើកំណត់ត្រា និងចងក្រងរបាយការណ៍ជាមួយករណីស្តុតាងជាក់ស្តែង ដើម្បីបង្ហាញអំពីកិច្ច ខិតខំប្រឹងប្រែងរួមគ្នា ជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការចូលរួមប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ដែលជាឧក្រិដ្ឋកម្មបង្កគ្រោះថ្នាក់ដល់សង្គមជាតិ និងកំពុងប៉ះពាល់ដល់កិច្ច ដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងតំបន់និងសកលលោក។ នាយករដ្ឋមន្ត្រីបញ្ជាក់ថា ការរីកចម្រើនទីផ្សារការងារក្នុងពិភពលោក ក៏ដូចជាបញ្ហាប្រទេសអាស៊ាន បានជំរុញឲ្យប្រទេសសមាជិកអាស៊ាន និងប្រទេសក្នុងតំបន់ទទួលបាននូវកំណើនសេដ្ឋកិច្ច ពាណិជកម្ម និងការវិនិយោគក្នុងកម្រិតមួយ គួរឲ្យកត់សម្គាល់ និងបានបង្កើតឲ្យមានទីផ្សារការងារយ៉ាងច្រើនសន្ធឹកសន្ធាប់។ នាយករដ្ឋមន្ត្រីអះអាងថា ការកេងប្រវ័ញ្ចគ្រប់រូបភាពពីស្ថានភាព ស្វែងរកការងារក្នុងស្រុក និងការធ្វើចំណាកស្រុកធ្វើឲ្យឧក្រិដ្ឋជនឆ្លៀត ឱកាសបង្កើតឲ្យមានអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច

ពលកម្ម ជួញដូរផ្លូវភេទ ជួញដូរទារក-កុមារ និងការជួញដូរសេរីរាង្គមនុស្ស ដែលជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរចាំបាច់ តម្រូវឲ្យប្រទេស សមាជិកអាស៊ាន និងចិនផ្ដោតការយកចិត្តទុកដាក់ខ្ពស់ និងត្រូវរួមគ្នាទប់ស្កាត់ឲ្យបានទាន់ពេលវេលា។ ឆ្លៀតឱកាសនោះដែរ សម្ដេចតេជោ ហ៊ុន សែន បន្ថែមថា អំពើជួញដូរមនុស្សនៅកម្ពុជាបច្ចុប្បន្ន ត្រូវបានរាជរដ្ឋាភិបាលចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបបានទាន់ ពេលវេលាតាមរយៈការពង្រឹងច្បាប់ ការអនុវត្តគោលនយោបាយបង្ការ ទប់ស្កាត់ និងការពារជនរងគ្រោះ ជាមួយការអនុវត្តច្បាប់ព្រហ្ម ទណ្ឌយ៉ាងខ្ជាប់ខ្ជួន ៕ ដោយ អេង ប៊ូធេង

## សម្ដេចតេជោ ហ៊ុន សែន ផ្ដល់អនុសាសន៍៤ចំណុច ដើម្បីចូលរួមប្រយុទ្ធប្រឆាំង «ការជួញដូរមនុស្ស» ឱ្យកាន់តែមានប្រសិទ្ធភាព

http://freshnewsasia.com/ 2019-11-06

**(សៀមរាប)៖** សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានផ្ដល់អនុសាសន៍ចំនួន៤ចំណុច ដើម្បីចូលរួមប្រយុទ្ធប្រឆាំង «ការជួញដូរមនុស្ស» ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។ ការផ្ដល់អនុសាសន៍នេះ បានធ្វើឡើងក្នុងពិធីបើកសន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន លើកទី១២ ដែលប្រារព្ធធ្វើឡើងនៅខេត្តសៀមរាប នាព្រឹកថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ ក្រោមប្រធានបទ **«តួនាទីព្រះរាជអាជ្ញាក្នុងការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សនៅក្នុងតំបន់»។ អនុសាសន៍របស់សម្ដេចតេជោ ហ៊ុន សែន សម្រាប់សន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន លើកទី១២ រួមមានដូចតទៅ៖**

១៖ អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន ត្រូវរួមគ្នាធ្វើកិច្ចសហប្រតិបត្តិការឱ្យបានជិតស្និទ្ធជាមួយបណ្ដាស្ថាប័ន និងប្រទេសពាក់ព័ន្ធនឹង «អំពើជួញដូរមនុស្ស » ជាពិសេសនៅក្នុងប្រទេសឆ្លងកាត់ និងប្រទេសគោលដៅ ដើម្បីឆ្លើយតប និងដោះស្រាយឱ្យបានទាន់ពេលកំណត់ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។

២៖ អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិនត្រូវរួមគ្នាពិនិត្យ និងវាយតម្លៃបញ្ហា «អំពើជួញដូរមនុស្ស» តាមរយៈស្មារតីទទួលខុសត្រូវខ្ពស់ ប្រកបដោយគុណភាព និងប្រសិទ្ធភាពជាមួយប្រទេស និងនៃការយោគយល់គ្នាដែលបានចុះហត្ថលេខាកន្លងមក ។

៣៖ អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន និងស្ថាប័នពាក់ព័ន្ធត្រូវរួមគ្នាបន្ត និងបង្កើនកិច្ចសហការឱ្យបានទូលំទូលាយ បង្កលក្ខណៈងាយស្រួល និងចូលរួមផ្ដល់ធនធានសម្រាប់ប្រតិបត្តិការជាប្រព័ន្ធដើម្បីអាចឆ្លើយតបបញ្ហាបានទាន់ពេលវេលាស្ដីពី «អំពើជួញដូរមនុស្ស »ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

៤៖ អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន ត្រូវរួមគ្នាធ្វើកំណត់ត្រា និងចងក្រងរបាយការណ៍ជាមួយនឹងភស្តុតាងជាក់ស្ដែង ដើម្បីបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងរួមគ្នាជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការចូលរួមប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាឧក្រិដ្ឋកម្មបង្កគ្រោះថ្នាក់ដល់សង្គមជាតិ និងកំពុងប៉ះពាល់ដល់កិច្ចដំណើរការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចនៅក្នុងតំបន់ និងសកលលោក។

សូមបញ្ជាក់ថា សន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន ជាវេទិកានៃមហាអយ្យការក្នុងតំបន់ ដើម្បីចែករំលែកនូវបទពិសោធន៍ និងការអនុវត្តល្អក្នុងការប្រយុទ្ធប្រឆាំង ការទប់ស្កាត់ ការបង្ក្រាប និងការដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មឆ្លងដែន រួមទាំង «អំពើជួញដូរមនុស្ស» ផងដែរ ហើយក៏ជាយន្តការសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការរវាងបណ្ដាប្រទេសក្នុងតំបន់អាស៊ានចិន។ណសន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិនលើកទី១២ នាពេលនេះ គឺដើម្បីរកដំណោះស្រាយ ក៏ដូចជាកិច្ចសហប្រតិបត្តិការរួមគ្នា ហើយចុងក្រោយអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន នឹងចេញនូវសេចក្ដីប្រកាសរួមមួយជាគោលសម្រាប់អនុវត្តស្របទៅនឹងអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន៕

## នាយករដ្ឋមន្ត្រីកម្ពុជា៖ ពលករខ្មែរ មួយចំនួន នៅតែបន្តចាញ់ បោកមេខ្យល់ ទោះមានការប្រឡង ជ្រើសរើសត្រឹមត្រូវ

https://dap-news.com/ Posted on November 6, 2019

ភ្នំពេញ ៖ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃកម្ពុជា បានថ្លែងថា ពលករខ្មែរ ដែលទៅធ្វើការងារ នៅប្រទេសកូរ៉េខាងត្បូងមួយ ចំនួននៅតែបន្តចាញ់ ក្រុមបោកមេខ្យល់ រត់ការលើសេវាផ្សេងៗ ទោះបីជាមានការរៀបចំប្រឡងជ្រើសរើសត្រឹមត្រូវ និងច្បាស់លាស់ក៏ដោយ ។

ក្នុងពិធីបើកសន្និសីទ អគ្គព្រះរាជអាជ្ញា អាស៊ាន-ចិន លើកទី១២ ក្រោមប្រធានបទ "តួនាទីព្រះរាជអាជ្ញា ក្នុងការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស នៅក្នុងតំបន់" នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៩ សម្ដេចតេជោ បានឲ្យដឹងថា សព្វថ្ងៃនេះមានពលករខ្មែរ ទៅធ្វើការនៅកូរ៉េ ជាង៥ម៉ឺននាក់ ចំណែកពលករវៀតណាមវិញ មានជាង២០ម៉ឺននាក់ ។ សម្ដេចតេជោ មានប្រសាសន៍ថា "ខ្ញុំនិយាយអំពីពលករដែលទៅពី កម្ពុជា ទៅកូរ៉េ នៅមានអ្នកចាញ់បោកគេទៀត ។ ទោះបីយើងបញ្ជូនតាមផ្លូវការ មានការប្រឡងច្បាស់លាស់ ។ ឧទាហរណ៍ សេវាត្រូវបង់ចំនួនប៉ុននេះ ប៉ុន្តែនៅមានអ្នករត់ការទៅពីលើ ដើម្បីទទួលបានប្រាក់ពីពលករ នេះជាការកេងប្រវ័ញ្ចមួយ ទៅលើកម្លាំងញើសឈាម របស់កម្មករនេះបន្ថែមទៀត" ។

ដើម្បីប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ឲ្យបានទាន់ពេលវេលា នាយករដ្ឋមន្ត្រីនៃកម្ពុជា បានអំពាវនាវឲ្យប្រទេសសមាជិក អាស៊ាន-ចិន ត្រូវមានគោលការណ៍រួមមួយ ឯកភាពគ្នា សហការគ្នាយ៉ាងជិតស្និទ្ធ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។ សម្ដេចនាយករដ្ឋមន្ត្រីមានប្រសាសន៍បន្ថែមថា អំពើជួញដូរមនុស្ស គឺជាគោលនយោបាយដ៏សំខាន់ ដែលរាជរដ្ឋាភិបាលកម្ពុជា បានផ្ដោតការយកចិត្តទុកដាក់ខ្ពស់ និងបានអនុវត្តកន្លងមក តាមរយៈការផ្សព្វផ្សាយគ្រប់ទម្រង់នៃ អំពើជួញដូរមនុស្ស តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន ។ ជាងនេះទៅទៀត សម្ដេចតេជោ ហ៊ុន សែន បានថ្លែងថា ការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស គឺជាបញ្ហាលំបាក និងស្មុគស្មាញហើយជាបទល្មើសឆ្លងដែនខុសច្បាប់ និងជាឧក្រិដ្ឋកម្ម ដែលមានវិសាលភាពទាំងក្នុងតំបន់អាស៊ាន និងសកលលោក។

សូមរំលឹកថា កម្ពុជា បានអនុម័ត និងកំពុងរៀបចំច្បាប់គោលនយោបាយ លិខិតបទដ្ឋានពាក់ព័ន្ធជាមួយនឹងការបង្ការ ទប់ស្កាត់បង្ក្រាប និងផ្ដន្ទាទោស អំពើជួញដូរមនុស្ស រួមមាន ៖ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ ក្រមព្រហ្មទណ្ឌឆ្នាំ២០១០៕ដោយ អេង ប៊ូឆេង

## ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន ទទួលជួបពិភាក្សាជាមួយឯកអគ្គរាជទូត អង់គ្លេស លោកជំទាវ Tina Redshaw

http://cambodiapolice.com/policekh/ 5:27 pm 5 វិច្ឆិកា 2019

**ភ្នំពេញ ៖** នៅព្រឹកថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានទទួលជួបសំណេះសំណាលពិភាក្សាការងារជាមួយនឹង លោកជំទាវ Tina Redshaw ឯកអគ្គរាជទូត នៃប្រទេសអង់គ្លេស និងមន្ត្រីអង់គ្លេសមួយចំនួនរបស់ស្ថានទូត ដែលចង់ស្វែងយល់ដឹងអំពីស្ថានភាពអនុវត្តច្បាប់ និងការបង្ក្រាបបទល្មើសឆ្លងដែន ដោយកងកម្លាំងនគរជាតិកម្ពុជា។ ការជួបសំណេះសំណាលនេះ បានប្រព្រឹត្តទៅនៅអគ្គស្នងការដ្ឋាននគរបាលជាតិ ដោយមានការអញ្ជើញចូលរួមពីមន្ត្រីជំនាញ នៃថ្នាក់ដឹកនាំនាយកដ្ឋាន និងអង្គភាព ដែលបាននិងកំពុងបំពេញភារកិច្ចបង្ក្រាបអំពើបទល្មើសឆ្លងដែនជាប្រចាំរៀងរាល់ថ្ងៃ។

ជាកិច្ចចាប់ផ្ដើម លោកជំទាវ Tina Redshaw បានថ្លែងអំណរគុណចំពោះ ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការនគរបាលជាតិ ចំពោះកិច្ចប្រឹងប្រែងរបស់អាជ្ញាធរកម្ពុជា ក្នុងនោះរួមមានការចូលរួមពីកងកម្លាំងនគរបាលខេត្តព្រះសីហនុផងដែរ ក្នុងការជួយរកសាកសពស្ត្រីជាតិអង់គ្លេសអាយុ២១ឆ្នាំកញ្ញា Amelia Bambridge ដែល បាន

បាត់បង់ជីវិតដោយការលង់ទឹក។ លោកជំទាវឯកអគ្គរាជទូត និងក្រុមមន្ត្រីជំនាញអង់គ្លេស បានស្នើ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន ជួយផ្តល់បទពិសោធន៍ខ្លះពាក់ព័ន្ធករណីបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសបញ្ហាគ្រឿងញៀន, បញ្ហាអំពើរត់ពន្ធជួញដូរមនុស្សឆ្លងដែន និងបទល្មើសបច្ចេកវិទ្យាផងដែរ។

ក្នុងប្រសាសន៍ឆ្លើយតប ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានសម្តែងនូវការសោកស្តាយ ចំពោះការបាត់បង់ជីវិតស្ត្រីទេសចរណ៍ជាតិអង់គ្លេស និងបានថ្លែងចូលរួមរំលែកទុក្ខដល់ក្រុមគ្រួសារសព។ ក្នុងប្រសាសន៍ពាក់ព័ន្ធបទពិសោធន៍បង្ក្រាបអំពើល្មើសឆ្លងដែន ឯកឧត្តមអគ្គស្នងការនគរបាលជាតិ បានលើកជុំវិញកង្វល់ពិភពលោកនូវបញ្ហាភេរវកម្ម ដែលកម្ពុជាមិនទាន់មានករណីនេះកើតឡើងនៅឡើយទេ ប៉ុន្តែកម្ពុជាបានស្ថិតក្នុងការតាមដានជានិច្ចជាមួយកង្វល់ភេរវកម្មរបស់ពិភពលោក។ ឯកឧត្តម នាយឧត្តមសេនីយ៍ បានបញ្ជាក់ប្រាប់ លោកជំទាវឯកអគ្គរដ្ឋទូតអង់គ្លេស ជុំវិញកិច្ចសហប្រតិបត្តិការរវាងកងកម្លាំងនគរបាលជាតិកម្ពុជាជាមួយនឹងក្រុមប្រឆាំងឧក្រិដ្ឋកម្មជាតិអង់គ្លេស NCA National Crime Agency, បទពិសោធន៍ នៃការបង្ក្រាបគ្រឿងញៀនរួមទាំងការបញ្ជាក់នូវប្រភពនាំចូល និងលំហូរឆ្លងកាត់ប្រទេសកម្ពុជា ទៅកាន់ប្រទេស ទី៣ថែមទៀត ដោយកម្ពុជាមិនមែនជាប្រទេសផលិតគ្រឿងញៀនទេ ប៉ុន្តែជាប្រទេសដែលរងគ្រោះនៃ ការប្រើប្រាស់គ្រឿងញៀន។ ដោយឡែកបទពិសោធន៍បង្ក្រាបករណីជួញដូរមនុស្ស និងបញ្ហាបទល្មើសឧក្រិដ្ឋបច្ចេកវិទ្យា ដែលកម្ពុជា និងពិភពលោកកំពុងប្រឈមនាបច្ចុប្បន្ននេះផងដែរ។

លោកជំទាវTina Redshaw បានថ្លែងអំណរគុណចំពោះ ឯកឧត្តមនាយឧត្តមសេនីយ៍សន្តិបណ្ឌិតអគ្គស្នងការនគរបាលជាតិ ដែលបានឆ្លៀតឱកាសឲ្យលោកជំទាវ និងមន្ត្រីជំនាញស្ថានទូតចូលជួបសំណេះសំណាល និងពិភាក្សាស្វែងយល់ពីបទពិសោធន៍បង្ក្រាបករណីឧក្រិដ្ឋឆ្លងដែនរបស់កម្ពុជា និងលោកជំទាវបានថ្លែងបើកចំហរចំពោះកិច្ចសហប្រតិបត្តិការរបស់ស្ថានទូតអង់គ្លេសជាមួយនឹងអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីកិច្ចសហការផ្តល់ព័ត៌មានទៅវិញទៅមកក្នុងការជួយបង្ក្រាបបទល្មើសឆ្លងដែននេះ៕

## ពលករខ្មែរទៅធ្វើការក្រៅប្រទេសមានប៉ុន្មាន? ប្រទេសណាខ្លះ?

https://kohsantepheapdaily.com.kh/ ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ ២០១៩ ម៉ោង ១៥:០៤ ស.សុខុម (អ៊ាង ម៉េងឡេង)

រាជធានីភ្នំពេញ ៖ ក្រុមអ្នកស្រាវជ្រាវវិទ្យាស្ថានមនុស្សសាស្ត្រ និងសង្គមសាស្ត្រនៃរាជបណ្ឌិត្យសភាកម្ពុជាបង្ហាញពីផលប្រយោជន៍ និងការប្រឈមនៃលំហូរពលករទេសន្តប្រវេសន៍កម្ពុជា ទៅក្រៅប្រទេស មុនដាក់សំណើជូនទៅរដ្ឋាភិបាល ដើម្បីរកដោះស្រាយនិងគោលការណ៍ច្បាប់នានា ការពារដល់ពលករស្របច្បាប់និងមិនស្របច្បាប់ដែលកំពុងធ្វើការងារនៅបរទេសមួយចំនួន (ថៃ កូរ៉េ ម៉ាឡេស៊ី សិង្ហបុរី អារ៉ាប៊ីសាអូឌីត ជប៉ុនជាដើម។

ថ្លែងក្នុងសិក្ខាសាលាស្តីពីលំហូពលករទេសន្តប្រវេសន៍កម្ពុជា ផ្តោតលើផលប្រយោជន៍ និងបញ្ហាប្រឈមនៅវិទ្យ ាស្ថានកុងជីនៃរាជបណ្ឌិត ្យសភាកម្ពុជា នាព្រឹកថ្ងៃទី៥ វិច្ឆិកា នេះ លោកបណ្ឌិត ឆេង វណ្ណារិទ្ធ ប្រធានគម្រោងស្រាវជ្រាវវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម បានបញ្ជាក់ថា នៅក្នុងឆ្នាំ២០១៨-ឆ្នាំ២០១៩ ពលករខ្មែរធ្វើការនៅបរទេសមានចំនួន១,២៣៤,១១១នាក់(ស្ត្រី៤៩៩,០៧០នាក់) ។ លោកបណ្ឌិតឆេង វណ្ណារិទ្ធ បន្តថា ទោះបីជាមានផលវិជ្ជមានពីទេសន្តប្រវេសន៍កម្ពុជា ជាមួយនឹងការខិតខំរបស់ក្រសួងការងារ និងភ្នាក់ងារជ្រើសរើសឯកជនមួយចំនួន ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារបានអនុវត្តកាន់តែល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ និងបានចូលរួមក្នុងការកែលម្អ ការលើកកម្ពស់លក្ខខណ្ឌការងារនិងភាពសុខដុមនៃទំនាក់ទំនងវិជ្ជាជីវៈ ក៏ដូចជាសុវត្ថិភាពការងារបានល្អប្រសើរ ។

លោកបណ្ឌិត ឆេង វណ្ណារិទ្ធ អះអាងថា ការធ្វើចំណាកស្រុកនិងឆ្លងដែនទៅធ្វើការនៅបរទេសរបស់ពលករខ្មែរទាំងស្របច្បាប់ និងមិនស្របច្បាប់ពេលវិលត្រឡប់មកមកវិញ គឺពួកគេជួបបញ្ហាគ្មានការងារធ្វើតាមជំនាញនៅបរទេស

ឬការងារមិនច្បាស់លាស់ ។ លោកបណ្ឌិតឆេង វណ្ណារិទ្ធ បន្តថា យោងតាមការស្រាវជ្រាវរយៈពេល៨ខែ(មីនាដល់តុលា២០១៩) ដោយសម្ភាសន៍ពលករចំណាកស្រុកចំនួន៨៩៨នាក់ មកពីខេត្តកំពង់ចាម បាត់ដំបង តាកែវ ព្រៃវែង កំពង់ស្ពឺកណ្ដាល ពោធិ៍សាត់ និងប៉ៃលិន) ។ លទ្ធផលបង្ហាញថា ពលករទេសន្តប្រវេសន៍អាយុចន្លោះ១៦ ដល់៥០ឆ្នាំ មានចំនួន៨៣៦នាក់(ស្មើ៩៣%)និងអាយុលើ៥៧ដល់៧៥ឆ្នាំមានចំនួន៦២នាក់(ស្មើ៧%)។ លោកបណ្ឌិត ឆេង វណ្ណារិទ្ធ ការធ្វើទេសន្តប្រវេសន៍ការងារនេះ ជាជំរើសរបស់ប្រជាជនក្រីក្រ ដែលក្នុងនោះពលករខ្មែរថៃចំនួន ១,១៤៦,៦៨៥នាក់,កូរ៉េខាងត្បូង មានចំនួន៤៩០៩៩នាក់,ជប៉ុនមាន៩,១០០នាក់,ម៉ាឡេស៊ីចំនួន៣០,១១៣នាក់, សិង្ហបូរីចំនួន៨៣១នាក់,ហុងកុងចំនួន៥៤នាក់និងអារ៉ាប៊ីសាអូឌីតចំនួន១៦នាក់ ។

## ឃាត់ខ្លួនមេខ្យល់បីនាក់ ពាក់ពន្ធ័ករណី នាំមនុស្សឆ្លងដែន ទៅចិនខុសច្បាប់

https://dap-news.com/national/ Posted on November 6, 2019

ភ្នំពេញ ៖ កម្លាំងនគរបាល នៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ចុះប្រតិបត្តិការស្រាវជ្រាវ សហការជាមួយអាជ្ញាធរមូលដ្ឋាន ខណ្ឌដូនពេញ ធ្វើការឃាត់ខ្លួនប្រុសស្រី៥នាក់ ក្នុងនោះមានមេខ្យល់ចំនួន៣នាក់ នារសៀលថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅមុំចំណតរថយន្តក្រុង (វ៉ាងរ៉ិច) ផ្លូវលេខ១៤៤ កែងផ្លូវ លេខ ៤៩ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ ក្នុងចំណោមអ្នក ដែលត្រូវឃាត់ខ្លួនមាននារី២នាក់ ជាជនរងគ្រោះ( អនីតិជនម្នាក់) ដែលត្រូវបានមេខ្យល់នាំឆ្លងដែន ចេញពីប្រទេសកម្ពុជា ឆ្លងកាត់ប្រទេសវៀតណាម ឆ្ពោះទៅប្រទេសចិនដោយខុសច្បាប់ ។

ប្រភពពីសមត្ថកិច្ច ជំនាញបានអោយដឹងថា ជនសង្ស័យប្រុសស្រីទាំង០៣នាក់ ដែលជាមេខ្យល់មាន ទី១ ឈ្មោះ ពៅ ដែន ភេទប្រុស អាយុ២១ឆ្នាំ ជាជនជាតិខ្មែរ មានមុខរបរជាបុគ្គលិកក្រុមហ៊ុន ។ ទី២ឈ្មោះ វ៉ន សុភា ភេទប្រុស អាយុ២១ឆ្នាំ ជាជនជាតិខ្មែរ មានមុខរបរជាសន្តិសុខ ។ ទី៣មានឈ្មោះ ចិត្ត ស្រីពេជ្រ ភេទស្រី អាយុ២៧ឆ្នាំ ជាជនជាតិខ្មែរ មានមុខរបរជាអ្នកបំរើការក្នុងហាងខារ៉ាអូខេ ។

ក្រោយពីការសួរនាំរបស់សមត្ថកិច្ច ជនរងគ្រោះខាងលើបានអោយដឹងថា មុនពេលពួកនាងសម្រេចចិត្តទៅប្រទេសចិន គឺមានស្ត្រីម្នាក់ដែលជាមេខ្យល់បានទាក់ទង និងលួងលោមថា បើប្អូនៗព្រមទៅប្រទេសចិន ពេលទៅដល់ភ្លាមនិងទទួលបានប្រាក់ចំណូលក្នុងម្នាក់ ពី២០០០ដុល្លារអាមេរិក ទៅ៣០០០ដុល្លារអាមេរិក ហើយរាល់ការរត់ឯកសារ និងសាហ៊ុយធ្វើដំណើរ គឺមានគេចេញអោយទាំងអស់ ។ នារីរងគ្រោះបានបន្តទៀតថា ពេលនោះពួកនាងបានសួរថា "គាត់ពុំមានលិខិតឆ្លងដែនទេ" ហើយនារីមេខ្យល់ក៏បានប្រាប់ថា នឹងនាំពួកនាងទៅធ្វើលិខិតឆ្លងដែន ព្រោះឥលូវគេធ្វើតែ១ថ្ងៃទេបានហើយ ហើយពេលដែលទទួលបានលិខិតឆ្លងដែននឹងធ្វើដំណើរទៅតាមច្រកព្រំដែនអន្តរជាតិបាវិត នៅពេលទៅដល់ហូជិមិញ គឺមានមេខ្យល់ផ្សេងគេចាំទទួលនៅទីនោះដើម្បីនាំឆ្លងដែនបន្តទៅប្រទេសចិន តែមកដល់ចំណុចកើតហេតុខាងលើក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

បច្ចុប្បន្ន ជនសង្ស័យប្រុសស្រី ជាមេខ្យល់ទាំង៣នាក់ ត្រូវបានកម្លាំងនគរបាល នៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ឃុំខ្លួនបណ្តោះអាសន្ន ដើម្បីកសាងសំណុំរឿងចាត់ការ តាមនីតិវិធី ចំណែកនារីរងគ្រោះទាំង២នាក់ បានប្រគល់ជូនមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ៕

# ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០១៩

## ពលករកម្ពុជាទៅធ្វើការនៅកូរ៉េ នៅតែចាញ់បោកគេ ទោះបីជារាជរដ្ឋាភិបាលបញ្ជូនតាមផ្លូវការក៏ដោយ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ម៉ោង ១៣:៤៩ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីបានអះអាងថា ទោះបីរាជរដ្ឋាភិបាលបានបញ្ជូលពលករទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូងជាផ្លូវការក្តីក៏មានពលករកម្ពុជានៅចាញ់បោកគេផងដែរ ។ សម្តេចបានលើកឡើងថា ក្នុងសន្និសីទអគ្គព្រះរាជអាជ្ញាកម្ពុជា-ចិន លើកទី១២ ក្រោមប្រធានបទ «តួនាទីព្រះរាជអាជ្ញាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងតំបន់» នាព្រឹកថ្ងៃទី០៦ ខែវិច្ឆកាយ៉ាងដូច្នេះថា ៖«ខ្ញុំនិយាយពីពលករដែលចេញពីកម្ពុជាទៅប្រទេសកូរ៉េខាងត្បូងនៅមានចាញ់បោកគេទៀត ទោះបីជាយើងបញ្ជូនតាមផ្លូវ មានការប្រឡងច្បាស់លាស់ ។

ឧទាហរណ៍សេវាត្រូវបង់ប៉ុណ្ណេះ ប៉ុន្តែនៅមានអ្នករត់ការនៅពីលើ ដើម្បីទទួលបានប្រាក់ពីពលករដែលនេះជាការកេងប្រវ័ញ្ចមួយទៅលើញើសឈាមរបស់កម្ពុជាថែមទៀត»។ សម្តេចបន្តថា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យបានទាន់ពេលវេលានាយករដ្ឋមន្ត្រីនៃកម្ពុជាបានអំពាវនាវឲ្យ ប្រទេសសមាជិក អាស៊ាន-ចិន ត្រូវមានគោលការណ៍រួមមួយឯកភាពគ្នាសហការគ្នាយ៉ាងជិតស្និទ្ធ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ។ នាយករដ្ឋមន្ត្រីបន្ថែមថា អំពើជួញដូរមនុស្ស គឺជាគោលនយោបាយដ៏សំខាន់ដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ខ្ពស់ និងបានអនុវត្តកន្លងមកតាមរយៈការផ្សព្វផ្សាយគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្សតាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន ។ ជាងនេះទៅទៀតសម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លំបាក និងស្មុគស្មាញគឺជាបទល្មើសឆ្លងដែនខុសច្បាប់ និងជាឧក្រិដ្ឋកម្មដែលមានវិសាលភាពទាំងក្នុងតំបន់អាស៊ាននិងសកលលោក។ ជាមួយគ្នានោះដែរ សម្តេចតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីបានឲ្យដឹងថា មានពលករកម្ពុជានៅប្រទេសកូរ៉េប្រមាណ៥ម៉ឺននាក់ ហើយវៀតណាមមានពលករនៅប្រទេសកូរ៉េ ខាងត្បូងជាង២០ម៉ឺននាក់ ៕ កែសម្រួលដោយ ៖ សុឃាក់

## អំពើជួញដូរមនុស្សជាឧក្រិដ្ឋកម្មកំពុងរីករាលដាលក្នុងតំបន់ តាមរយៈការរីកចម្រើនទីផ្សារការងារ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ម៉ោង ១៤:២២ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ អំពើជួយដូរមនុស្សជាឧក្រិដ្ឋកម្មមួយបានកំពុងរីករាលដាល នៅក្នុងតំបន់តាមរយៈការរីកចម្រើនទីផ្សារការងារ ហើយត្រូវយកចិត្តទុកដាក់ក្នុងការទប់ស្កាត់ឲ្យទាន់ពេលវេលា ។ នេះបើតាមសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី សម្តេចតេជោ បានលើកឡើងថាក្នុងសន្និសីទអគ្គព្រះរាជអាជ្ញាកម្ពុជា-ចិន លើកទី១២ ក្រោមប្រធានបទ ៖«តួនាទីព្រះរាជអាជ្ញាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងតំបន់» នាព្រឹកថ្ងៃទី០៦ ខែវិច្ឆកា នៅខេត្តសៀមរាបថា អំពើជួញដូរមនុស្ស គឺជាឧក្រិដ្ឋកម្មមួយបានកំពុងតែរីករាលដាក់នៅក្នុងតំបន់របស់យើង ។ សម្តេចបន្តថា ភាពជឿនលឿននៃវិស័យបច្ចេកវិទ្យាបានធ្វើឲ្យចរន្តសេដ្ឋកិច្ចនៅលើកពិភពលោកមានការវិវត្តន៍យ៉ាងលឿន ។ ទន្ទឹមនឹងនេះការរីកចម្រើនទីផ្សារនៅក្នុងពិភពលោកក៏ដូច ជា នៅក្នុងបណ្តាប្រទេសអាស៊ានបានជំរុញឲ្យប្រទេសជាសមាជិកអាស៊ាន និងប្រទេសក្នុង តំបន់ទទួលបានកំណើនសេដ្ឋកិច្ច ពាណិជ្ជកម្ម ការវិនិយោគ ក្នុងកម្រិតមួយគួរឲ្យកត់សម្គាល់ ហើយមានទីផ្សារការងារយ៉ាងច្រើន ។

សម្តេចបានគូសបញ្ជាក់ថា ៖«តាមរយៈចរន្តទីផ្សាការងារ និងដំណើរចល័តនៃកម្លាំងពលកម្ម អន្តរជាតិធ្វើឲ្យកើតឡើងនូវអំពើជួញដូរមនុស្សជាយថាហេតុ ក្នុងបណ្តាប្រទេសជាសមាជិកអាស៊ានរួមទាំងប្រទេសនៅក្នុងតំបន់ផងដែរ» ។ សម្តេចបន្ថែមថា ស្ថានភាពស្វែងរកការងារធ្វើ និងការធ្វើចំណាក់ស្រុកនៅក្រៅប្រទេសធ្វើឲ្យឧក្រិដ្ឋជនឆ្លៀតឱកាសប្រព្រឹត្តអំពើជួញដូរមនុស្សការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការជួយដូរផ្លូវភេទ ជួញដូរទារក និងកុមារ និងការជួយ

ជួរសេរីវង្គមនុស្សដែលជាឧក្រិដ្ឋកម្ម ដល់ចូន់ធូរចាំបាច់តម្រូវឲ្យប្រទេសសមាជិកអាស៊ាន និងចិនត្រូវធ្វើការទប់ស្កាត់ឲ្យបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាពនឹងតម្លាភាព ទាំងក្នុងតំបន់ និងក្នុងពិភពលោក ។ ជាមួយគ្នានោះដែរ សម្តេច ក៏បានលើកឡើងថា អំពើការជួញដូរមនុស្សនាពេលកន្លងមកត្រូវបានរាជរដ្ឋាភិបាលទប់ស្កាត់បានទាន់ពេលវេលាតាមរយៈយន្តការច្បាស់ និងនយោបាយការការទប់ស្កាត់ និងការការពារជនរងគ្រោះជាមួយការអនុវត្តច្បាប់ព្រហ្មទណ្ឌ និងច្បាប់ផ្សេងៗ ទៀត ។ សម្តេចបន្តថា អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន ត្រូវរួមគ្នាធ្វើកិច្ចសហប្រតិបត្តិការឲ្យបានជិតស្និទ្ធជាមួយបញ្ហាស្ថាប័ន និងប្រទេសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ជាពិសេសនៅក្នុង ប្រទេសឆ្លងកាត់ និងប្រទេសគោលដៅ ដើម្បីឆ្លើយតប និងដោះស្រាយឲ្យបានទាន់ពេលកំណត់ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ។

សម្តេចបន្ថែមថា អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន ត្រូវរួមគ្នាពិនិត្យ និងវាយតម្លៃបញ្ហាអំពើជួញដូរមនុស្សតាមរយៈស្មារតីទទួលខុសត្រូវខ្ពស់ប្រកបដោយគុណភាព និងប្រសិទ្ធភាពជាមួយប្រទេស និងនៃការយោគយល់គ្នាដែលបានចុះហត្ថលេខាកន្លងមក ។ សម្តេចមានប្រសាសន៍ថា «អគ្គព្រះរាជអាជ្ញា អាស៊ាន-ចិន និងស្ថាប័នពាក់ព័ន្ធត្រូវរួមគ្នាបន្ត និងបង្កើនកិច្ចសហការឲ្យបានទូលំទូលាយបង្គលក្ខណៈងាយស្រួល និងចូលរួមផ្តល់ធនធានសម្រាប់ប្រតិបត្តិការជាប្រព័ន្ធ ដើម្បីអាចឆ្លើយតបបញ្ហាបានទាន់ពេលវេលាស្តីពីអំពើជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាពខ្ពស់» ។ កែសម្រួលដោយ ៖ សុឃាក់

## សម្តេចតេជោ បញ្ជាក់ថា ការបង្ការទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោស អំពើជួញដូរមនុស្ស គឺជាគោលនយោបាយដ៏សំខាន់ដែលរាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ខ្ពស់

https://www.information.gov.kh/ វិច្ឆិកា 6, 2019

វិទ្យុជាតិកម្ពុជា៖ ដោយ លោកស្រី ផន វាសនា៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បញ្ជាក់ថា ការបង្ការទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោស «អំពើជួញដូរមនុស្ស» គឺជាគោលនយោ បាយដ៏សំខាន់ដែលរាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ខ្ពស់និងបានអនុវត្តកន្លងមក តាមរយៈការផ្សព្វផ្សាយគ្រប់ទម្រង់នៃ«អំពើជួញដូរមនុស្ស » តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន ។ក្នុងឱកាសអញ្ជើញជាអធិបតីក្នុងពិធីបើកសន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន លើកទី ១២ក្រោមប្រធានបទ«តួនាទីព្រះរាជអាជ្ញាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងតំបន់ នៅខេត្តសៀមរាប នៅថ្ងៃទី៦ ខែវិច្ឆិកា នេះ សម្តេច តេជោ បានបន្ថែមថា ជាក់ស្តែងរាជរដ្ឋាភិបាលបានប្រារព្ធទិវាប្រឆាំងអំពើជួញដូរមនុស្សនៅឆ្នាំ ២០១៨ កន្លងមក ដោយមានអ្នកចូលរួមប្រមាណ ៣០០០អង្គ/នាក់ ដែលជាថ្នាក់ដឹកនាំកំពូលសំខាន់ៗ ក្នុងស្ថាប័ននីតិប្បញ្ញ ត្តិនីតិប្រតិបត្តិ តុលាការ អង្គទូតនានានៅកម្ពុជារួមទាំងអាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ តំណាងសាសនានិយោជិត កម្មករនិយោជក សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ និស្សិតសិស្សានុសិស្ស និងប្រជាពលរដ្ឋ ។ ជាមួយនេះ រាជរដ្ឋាភិបាលបានធ្វើកិច្ចសហប្រតិ បត្តិការយ៉ាងជិតស្និទ្ធជាមួយអង្គការជាតិ-អន្តរជាតិនានា និងទូរទស្សន៍ បង្កើតឱ្យមានជាឃ្លីបវីឌីអូ និងបទយកការណ៍ ដើម្បីបង្ហាញឱ្យប្រជាជនគ្រប់ស្រទាប់យល់ដឹងនូវអំពើជួញដូរមនុស្សជាមួយនឹងការបង្កើតនូវយន្តការផ្សព្វផ្សាយជាប្រចាំឱ្យបានទូលំទូលាយនៅទូទាំងប្រទេស។

## វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ឃុំ-សង្កាត់/ក្រុង-ស្រុក

https://www.facebook.com/deputygovernoryousophear/ November 5 at 3:20 PM

ខេត្តសៀមរាប៖ ថ្ងៃអង្គារទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រុមការងារលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប សហការជាមួយរដ្ឋបាលសាលាស្រុកសូទ្រនិគម ដែលគាំទ្រដោយរដ្ឋបាល

សាលាខេត្តសៀមរាប និងមានការគាំទ្រពីអង្គការUN WOMEN បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ឃុំ-សង្កាត់/ក្រុង-ស្រុក និងអ្នកពាក់ព័ន្ធ អំពីការអនុវត្តតួនាទីភារកិច្ច ច្បាប់ពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពានលើកុមារ និងពង្រឹងលើកិច្ចសហប្រតិបត្តិការក្នុងការផ្តល់សេវាជួយជនរងគ្រោះឲ្យបានសមស្របនិងមានប្រសិទ្ធិភាព។

វគ្គបណ្តុះបណ្តាលប្រព្រឹត្តទៅនៅបន្ទប់ប្រជុំរដ្ឋបាលស្រុកសូទ្រនិគម ដែលដឹកនាំដោយលោកស្រីឧត្តមសេនីយ៍ត្រី ជួង ថាវី ស្នងការនគរបាលខេត្ត ជាអនុប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងជាតំណាងលោកជំទាវ យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងមានការអញ្ជើញចូលរួមពី លោក ម៉ក់ ប្រុស អភិបាលនៃគណៈអភិបាលស្រុក លោកស្រី ងិន មុំ ប្រធានក្រុមប្រឹក្សាស្រុក លោក អ៊ឹម ចំរើន អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត លោកស្រី ងិន សារិន អនុប្រធានមន្ទីរកិច្ចការនារីខេត្ត តំណាងមន្ទីរសង្គមកិច្ចខេត្ត និងមានការអញ្ជើញចូលរួមពី ប្រធាន អនុប្រធានការិយាល័យជុំវិញស្រុក មេឃុំ ស្មៀន អ.ក.ន.ក អធិការ កងរាជអាវុធហត្ថ ប្រជាការពារ មណ្ឌលសុខភាព នាយប៉ុស្តិ៍នាយកសាលា យុវជន និងអង្គការដៃគូ សរុប ៥៨នាក់ ស្រី១៧នាក់។

ថ្លែងក្នុងកិច្ចស្វាគមន៍ លោកអភិបាលនៃគណៈអភិបាលស្រុកសូទ្រនិគម បានជំរុញឲ្យអាជ្ញាធរស្រុក មេឃុំ និងអ្នកពាក់ព័ន្ធក្នុងស្រុកទាំងអស់ត្រូវយកចិត្តទុកអនុវត្ត សកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយត្រូវបង្កើនការផ្សព្វផ្សាយទប់ ស្កាត់បទល្មើស នានាពាក់ព័ន្ធ ពិសេសត្រូវពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការអន្តរាគមន៍បង្ក្រាបបទល្មើស និងការជួយផ្តល់សេវាជួយជនរងគ្រោះ ឲ្យបានសមស្រប និងទាន់ពេលវេលា។ បន្ថែមពីនោះ លោកអភិបាលបានគាំទ្រ និងលើកទឹកចិត្តដល់គ្រប់ឃុំទាំងអស់ធ្វើការរៀបចំ និងអនុវត្តតាមផែនការសកម្មភាពនៅក្នុងកញ្ចប់ថវិកាសេវាសង្គមឃុំ ដោយបានដាក់បញ្ចូលសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ពលករខ្មែរនិងពលករជនជាតិភូមាជាង100នាក់បាននិងកំពង់អត់ការងារធ្វើដោយសារសេដ្ឋកិច្ចថៃធ្លាក់ចុះ

https://www.facebook.com/neakmeasnews/ សារព័ត៌មាននាគមាស 06-11-2019

(ប្រទេសថៃ): នៅថ្ងៃទី៦ ខែវិច្ឆិកា, ឆ្នាំ២០១៩ បើយោងតាមប្រភពពីប្រទេសថៃនៅក្នុងស្រុកស៊ីរាចា ខេត្តឈុនបុរី ប្រទេសថៃបានឲ្យដឹងថា ពលករខ្មែរនិងពលករជនជាតិភូមាជាង១០០នាក់ បាននិងកំពង់អត់ការងារធ្វើដោយសារសេដ្ឋកិច្ចថៃធ្លាក់ចុះធ្វើអោយរោងចក្រមួយចំនួនក្ស័យធន និងបានបិតទ្វាបណ្តាលអោយពលករខ្មែរនិងពលករជនជាតិភូមាមួយចំនួនប្រឈមមុខនិងបាត់បង់ការងារធ្វើ ដូច្នេះហើយសូមបងប្អូនពលករខ្មែរដែលធ្វើការនៅក្នុងប្រទេសថៃ សូមបងប្អូនកុំប្តូការងារច្រើនហើយកុំជឿទៅលើការញុះញង់របស់ក្រុមឧទ្ទាមទណ្ឌិតសមរង្ស៊ីដែលធ្វើការប្រកាសវិលត្រឡប់ចូលមកប្រទេសកម្ពុជានាថ្ងៃ៩ វិច្ឆិកាខាងមុខដោយការអូសទាញបងប្អូនពលករខ្មែរឲ្យចូលរួមដើម្បីអមដំណើរក្រុមឧទ្ទាមទណ្ឌិតសមរង្ស៊ីឲ្យសោះបើមិនដូច្នោះទេបងប្អូននឹងបាត់បង់ការងារធ្វើព្រោះរាល់ថ្ងៃនេះសេដ្ឋកិច្ចថៃកំពុងធ្លាក់ចុះធ្វើអោយរោងចក្រមួយចំនួនក្ស័យធនបិតទ្វាជាបណ្តើរៗហើយ ប្រយ័ត្នអត់ការងារធ្វើណាបងប្អូន។

# ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០១៩

## តួនាទីព្រះរាជអាជ្ញា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងតំបន់

http://www.cen.com.kh/ November 6, 2019

សៀមរាប៖ សម្តេចតេជោ ហ៊ុន សែន បានស្នើឲ្យអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន ត្រូវរួមគ្នាធ្វើកិច្ច សហប្រតិបត្តិការឱ្យបានជិតស្និទ្ធជាមួយបញ្ហាស្ថាប័ននិងប្រទេសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សជាពិសេសនៅក្នុងប្រទេសឆ្លងកាត់ និងប្រទេសគោលដៅដើម្បីឆ្លើយតបនិងដោះស្រាយឱ្យបានទាន់ពេលកំណត់ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ។

នៅព្រឹកថ្ងៃពុធទី៦ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកសន្និសីទ អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិនលើកទី១២ ក្រោមប្រធានបទ "តួនាទីព្រះរាជអាជ្ញាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងតំបន់" ដែលប្រារព្ធធ្វើឡើងនៅខេត្តសៀមរាប។ សន្និសីទនេះ គឺមានរយៈពេលពីរថ្ងៃ ហើយមានការអញ្ជើញចូលរួមពីអគ្គព្រះរាជអាជ្ញា អគ្គរដ្ឋអាជ្ញា ប្រធានប្រតិភូមកពីបណ្តាប្រទេសនៃសមាគមអាស៊ាន និងប្រទេសចិនផងដែរ។

សម្តេចតេជោបានថ្លែងអំណរគុណលោក លោកស្រីអគ្គព្រះរាជអាជ្ញា អគ្គរដ្ឋអាជ្ញា នៃបណ្តាប្រទេសសមាគមអាស៊ាន និងសាធារណរដ្ឋប្រជាមានិតចិន និងភ្ញៀវកិត្តិយសជាតិ អន្តរជាតិទាំងអស់ ដែលកំពុងមានវត្តមាននៅលើទឹកដីខេត្តសៀមរាបអង្គរនេះ។ សម្តេចតេជោបានមានប្រសាសន៍បន្តថា កម្ពុជាពិតជាមានកិត្តិយសដែលបានធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទដ៏មានសារសំខាន់នេះ ស្របពេលដែលប្រទេសសមាជិកអាស៊ាន ក៏ដូចជាប្រទេសនៅក្នុងតំបន់កំពុងរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាឧក្រិដ្ឋកម្មឆ្លងដែនប្រកបដោយគ្រោះថ្នាក់ ហើយកំពុងរីករាលដាលនៅក្នុងតំបន់របស់យើង ។ សម្តេចតេជោបានមានប្រសាសន៍បន្តថា អំពើជួញដូរមនុស្ស គឺជាគោលនយោបាយដ៏សំខាន់ ដែលរាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ខ្ពស់ និងបានអនុវត្តកន្លងមក តាមរយៈការផ្សព្វផ្សាយគ្រប់ទម្រង់នៃ "អំពើជួញដូរមនុស្ស" តាំងពីថ្នាក់ជាតិរហូត ដល់ថ្នាក់មូលដ្ឋាន ។ ជាក់ស្តែងរាជរដ្ឋាភិបាលបានប្រារព្ធទិវាប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សនៅឆ្នាំ ២០១៨ កន្លងមក។ ជាមួយនេះ រាជរដ្ឋាភិបាលបានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអង្គការជាតិអន្តរជាតិនានា និងទូរទស្សន៍ បង្កើតឱ្យមានជាឃ្លីបវីឌីអូ និងបទយកការណ៍ ដើម្បីបង្ហាញឱ្យប្រជាពលរដ្ឋគ្រប់ស្រទាប់ យល់ដឹងនូវអំពើជួញដូរមនុស្ស ជាមួយនឹងការបង្កើតនូវយន្តការផ្សព្វផ្សាយ ជាប្រចាំឱ្យបានទូលំទូលាយនៅទូទាំងប្រទេស ។ ដូច្នេះ ដើម្បីដោះស្រាយបញ្ហាសកលនេះ ឱ្យបានទាន់ពេលវេលា បញ្ហាប្រទេសសមាជិកអាស៊ាន- ចិនត្រូវមានគោលការណ៍រួមមួយ ឯកភាពគ្នា សហការគ្នាយ៉ាងជិតស្និទ្ធ ប្រកប ដោយប្រសិទ្ធភាព និងតម្លាភាព ។

ក្នុងឱកាសនោះផងដែរ សម្តេចតេជោនាយករដ្ឋមន្ត្រី បានចែករំលែកនូវអនុសាសន៍មួយចំនួន ដល់អង្គសន្និសីទដូចខាងក្រោម៖

១)អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន ត្រូវរួមគ្នាធ្វើកិច្ច សហប្រតិបត្តិការឱ្យបានជិតស្និទ្ធជាមួយបញ្ញាស្ថាប័ន និងប្រទេសពាក់ព័ន្ធនឹង " អំពើជួញដូរមនុស្ស" ជាពិសេសនៅក្នុងប្រទេសឆ្លងកាត់ និងប្រទេសគោលដៅ ដើម្បីឆ្លើយតប និងដោះស្រាយឱ្យបានទាន់ពេលកំណត់ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ។

២)អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន ត្រូវរួមគ្នាពិនិត្យ និងវាយតម្លៃបញ្ហា " អំពើជួញដូរមនុស្ស" តាមរយៈស្មារតីទទួលខុសត្រូវខ្ពស់ ប្រកបដោយគុណភាព និងប្រសិទ្ធភាព ជាមួយប្រទេស និងស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងកិច្ចព្រមព្រៀង ឬ អនុស្សរណៈនៃការយោគយល់គ្នា ដែលបានចុះហត្ថលេខាកន្លងមក ។

៣)អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន និងស្ថាប័នពាក់ព័ន្ធត្រូវរួមគ្នាបន្ត និងបង្កើនកិច្ចសហការឱ្យបានទូលំទូលាយ បង្កលក្ខណៈងាយស្រួល និងចូលរួមផ្តល់ធនធានសម្រាប់ប្រតិបត្តិការជាប្រព័ន្ធ ដើម្បីអាចឆ្លើយតបបញ្ហាបានទាន់ពេលវេលាស្តីពី "អំពើជួញដូរមនុស្ស" ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

៤)អគ្គព្រះរាជអាជ្ញាអាស៊ាន-ចិនត្រូវរួមគ្នាធ្វើកំណត់ត្រា និងចងក្រងរបាយការណ៍ជាមួយនឹងភស្តុតាងជាក់ស្តែង ដើម្បីបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងរួមគ្នា ជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការចូលរួមប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាឧក្រិដ្ឋកម្មបង្កគ្រោះថ្នាក់ ដល់សង្គមជាតិ និងកំពុងប៉ះពាល់ដល់កិច្ចដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៅក្នុងតំបន់ និងសកលលោក ។

សម្តេចតេជោសង្ឃឹមថា អង្គសន្និសីទនឹងបន្តប្រើប្រាស់យន្តការអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន ដែលជាវេទិកាពង្រឹងកិច្ចសហប្រតិបត្តិការការពារ ប្រកបដោយឆន្ទៈរួមតែមួយ ក្នុងការប្រយុទ្ធប្រឆាំង "អំពើជួញដូរមនុស្ស" និងបទ

ល្មើសឆ្លងដែនគ្រប់រូបភាព ដើម្បីជានានូវសន្តិសុខ និងសុវត្ថិភាពឆ្លងដែនដល់បញ្ហាប្រជាជន នៅក្នុងប្រទេសអាស៊ាន-ចិន និងនៅក្នុងតំបន់ផងដែរ៕ដោយៈកូឡាប

## អំពើជួញដូរមនុស្ស បានបង្កនូវការគំរាមកំហែង ដោយផ្ទាល់ទៅលើវប្បធម៌ និងប្រពៃណី គ្រួសារ តម្លៃសង្គម

http://www.cen.com.kh/archives/ November 7, 2019

ខេត្តស្វាយរៀង៖ លោកស្រី ឯក សុវណ្ណភារៈ អភិបាលរងខេត្តស្វាយរៀង និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជនៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល១០ខែ (ចាប់ពីខែមករា-ខែតុលា ឆ្នាំ២០១៩) របស់ គ.ខ.ប.ជ និងមានការចូលរួមពីកងកម្លាំងទាំង៣ប្រភេទ លោកចៅក្រមនៃសាលាដំបូង លោក លោកស្រី ប្រធាន-អនុប្រធានមន្ទីរនានាជុំវិញខេត្ត និងមន្ត្រីដែលពាក់ព័ន្ធជាច្រើននាក់ទៀតដែលពិធីនេះបានប្រព្រឹត្តទៅនាសាលប្រជុំសាលាខេត្ត ។

លោកស្រី ឯក សុវណ្ណភារៈ អភិបាលរងខេត្ត បានឲ្យដឹងថា: តាមរបាយការណ៍បូកសរុបលទ្ធផលការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល១០ខែ (ចាប់ពីខែមករា-ខែតុលា ឆ្នាំ២០១៩) សភាពការណ៍មានការកើនឡើង១៥ករណី និងទទួលបានពាក្យបណ្តឹង៦ករណី ។ ចំណុចសំខាន់ៗដែលធ្វើឲ្យការងារប្រយុទ្ធប្រឆាំងជួញដូរមនុស្សមានដំណើរការល្អ និងផ្តល់នូវមតិណែនាំបន្ថែម ទៅដល់សមត្ថកិច្ចពាក់ព័ន្ធទាំងអស់ត្រូវបន្ត ពិនិត្យមើលទៅលើយន្តការ នៃរចនាសម្ព័ន្ធគ្រប់ថ្នាក់ទៅលើប្រព័ន្ធនីតិវិធី នៃការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ យុទ្ធសាស្ត្រនានា ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ត្រូវមានផែនការសកម្មភាព ស្របតាមបរិបថសង្គមនៅតាមមូលដ្ឋាន ត្រូវប្រើមធ្យោបាយសរុប កម្លាំងសរុប វិធានការសរុប ដើម្បីជំរុញផែនការសកម្មភាពអនុវត្តការងារនេះឲ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ ។

លោកស្រីអភិបាលរងខេត្តបន្ថែមថាទៀតថា: អំពើជួញដូរនេះ បានបង្កនូវការគំរាមកំហែង ដោយផ្ទាល់ទៅលើវប្បធម៌ និងប្រពៃណី គ្រួសារ តម្លៃសង្គមកម្ពុជា ដូច្នេះអាជ្ញាធរពាក់ព័ន្ធទាំងអស់ ត្រូវបន្តពង្រឹងគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដែលបានអនុវត្តជាប្រចាំបន្ថែមទៀត ដើម្បីតាមដាននូវសកម្មភាពបទល្មើសជួញដូរមនុស្ស និងត្រូវដាក់ផែនការតាមដានគ្រប់ ក្រុង ស្រុក និងតាមច្រកទ្វាព្រំដែននានាជាប់ប្រទេស ជិតខាង ក្នុងការទប់ស្កាត់ ការបង្ក្រាបការជួញដូរ មនុស្សឲ្យមានប្រសិទ្ធភាពខ្ពស់ ៕ ដោយៈ វ៉ៃកូ

## កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរយៈពេល១០ខែ(ចាប់ពីខែមករា-ខែតុលា ឆ្នាំ២០១៩)

https://gdlf-kh.com/ 07/11/2019 Kao sophy ខេត្តស្វាយរៀង

ខេត្តស្វាយរៀង៖ នៅព្រឹកថ្ងៃព្រហស្បតិ៍១១កើត ខែកត្តិក ឆ្នាំកុរ ឯកស័កព.ស២៥៦៣ ត្រូវនឹងថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ នៅសាលប្រជុំសាលាខេត្ត លោកជំទាវ ឯក សុវណ្ណភារៈ អភិបាលរងខេត្តស្វាយរៀង និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ តំណាងឯកឧត្តម ម៉ែន វិបុល អភិបាលខេត្ត បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល១០ខែ(ចាប់ពីខែមករា-ខែតុលា ឆ្នាំ២០១៩)របស់ គ.ខ.ប.ជ និងមានការចូលរួមពី កងកម្លាំងទាំង៣ប្រភេទ លោកចៅក្រមនៃសាលាដំបូង លោក លោកស្រី ប្រធាន-អនុប្រធានមន្ទីរនានាជុំវិញខេត្ត និងមន្ត្រីដែលពាក់ព័ន្ធជាច្រើនអ្នកទៀត។

លោកជំទាវ ឯក សុវណ្ណភារៈ អភិបាលរងខេត្ត បានអោយដឹងថា: តាមរបាយការណ៍បូកសរុបលទ្ធផលការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល១០ខែ(ចាប់ពីខែមករា-ខែតុលា ឆ្នាំ២០១៩) សភាពការណ៍មានការកើនឡើង១៥ករណី និងទទួលបានពាក្យបណ្តឹង០៦ករណី ។ ចំណុចសំខាន់ៗដែលធ្វើឲ្យការងារប្រយុទ្ធប្រឆាំងជួញដូរ

មនុស្សមានដំណើរការល្អ និងផ្តល់នូវមតិណែនាំបន្ថែមទៅដល់សមត្ថកិច្ចពាក់ព័ន្ធទាំងអស់ត្រូវបន្ត ពិនិត្យមើលទៅលើយន្តការនៃរចនាសម្ព័ន្ធគ្រប់ថ្នាក់ទៅលើប្រព័ន្ធនីតិវិធីនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ យុទ្ធសាស្ត្រនានា ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ត្រូវមានផែនការសកម្មភាពស្របតាមបរិបទសង្គមនៅតាមមូលដ្ឋាន ត្រូវប្រើមធ្យោបាយសរុប កម្លាំងសរុប វិធានការសរុប ដើម្បីជំរុញផែនការសកម្មភាពអនុវត្តការងារនេះឲ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ ។

លោកជំទាវអភិបាលរងខេត្តបន្ថែមថាទៀតថា: អំពើជួញដូរនេះ បានបង្កនូវការគំរាមកំហែង ដោយផ្ទាល់ទៅលើវប្បធម៌ និងប្រពៃណី គ្រួសារ តម្លៃសង្គមកម្ពុជា ដូច្នេះអាជ្ញាធរពាក់ព័ន្ធទាំងអស់ ត្រូវបន្តពង្រឹងគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដែលបានអនុវត្តជាប្រចាំបន្ថែមទៀត ដើម្បីតាមដាននូវសកម្មភាពបទល្មើសជួញដូរមនុស្ស និងត្រូវដាក់ផែនការតាមដានគ្រប់ ក្រុង ស្រុក និងតាមច្រកទ្វារព្រំដែននានាជាប់ប្រទេស ជិតខាង ក្នុងការទប់ស្កាត់ ការបង្ក្រាបការជួញដូរ មនុស្សឲ្យមានប្រសិទ្ធភាពខ្ពស់ ៕

## ជន ៣ នាក់ ពាក់ព័ន្ធការជួញដូរមនុស្សនឹងត្រូវបញ្ជូនទៅតុលាការ

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 07 November 2019 | 13:59 ICT

**ភ្នំពេញៈ** ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននឹងបញ្ជូនជនសង្ស័យប្រុសស្រីចំនួន ៣ នាក់ ទៅតុលាការនៅថ្ងៃព្រហស្បតិ៍នេះក្រោយបញ្ចប់ការសាកសួរ បន្ទាប់ពីជនសង្ស័យទាំងនេះត្រូវបានសមត្ថកិច្ចឃាត់ខ្លួនកាលពីថ្ងៃទី ៥ ពាក់ព័ន្ធករណីជួញដូរមនុស្សឆ្លងដែនពីប្រទេសកម្ពុជាទៅកាន់ប្រទេសចិន។

លោក កែវ ជា ប្រធានការិយាល័យប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញថា កម្លាំងសមត្ថកិច្ចការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយអាជ្ញាធរមូលដ្ឋានខណ្ឌដូនពេញបានចុះប្រតិបត្តិការស្រាវជ្រាវឃាត់ខ្លួនជនសង្ស័យប្រុសស្រី ៥ នាក់ ក្នុងនោះស្ត្រីរងគ្រោះ ២ នាក់ និងមេខ្យល់ប្រុសស្រី ៣ នាក់ កាលពីថ្ងៃទី ៥ វិច្ឆិកា ពាក់ព័ន្ធនឹងករណីជួញដូរមនុស្សឆ្លងដែន។ ពួកគេត្រូវបានឃាត់ខ្លួននៅចំណុចចំណតរថយន្តក្រុងមួយឈ្មោះ (វ៉ាំងរិច) ស្ថិតនៅផ្លូវលេខ ១៤៤ កែងផ្លូវលេខ ៤៩ សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ លោក កែវ ជា បានបង្ហាញថាជនសង្ស័យប្រុសស្រីទាំង ៣ នាក់ពាក់ព័ន្ធករណីជួញដូរមនុស្សឆ្លងដែននេះមានឈ្មោះ ពៅ ដែន ភេទប្រុស អាយុ ២១ ឆ្នាំ ជនជាតិខ្មែរជាបុគ្គលិកក្រុមហ៊ុនឯកជន។ ឈ្មោះ វ៉ន សុភា ភេទប្រុស អាយុ ២១ ឆ្នាំ ជនជាតិខ្មែរជាសន្តិសុខ និងឈ្មោះ ចិត្ត ស្រីពេជ្រ ភេទស្រី អាយុ ២៧ ឆ្នាំ ជនជាតិខ្មែរ មុខរបរបម្រើការងារក្នុងក្លិបខារ៉ាអូខេ។

ជនសង្ស័យទាំង ៣ នាក់ កំពុងត្រូវបានសាកសួរនៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ហើយនឹងបញ្ជូនទៅតុលាការរាជធានីភ្នំពេញនៅថ្ងៃនេះ។ លោកបានបញ្ជាក់ថា៖ «ជនសង្ស័យទាំង ៣ នាក់ ដែលយើងឃាត់ខ្លួនបានឥឡូវយើងកំពុងសាកសួរនៅឡើយ។ ស្អែក (ថ្ងៃព្រហស្បតិ៍) យើងនឹងបញ្ជូនទៅតុលាការហើយ។ ជនសង្ស័យនេះបានរៀបគម្រោងយកជនរងគ្រោះទៅប្រទេស ចិន ដោយឆ្លងកាត់តាមប្រទេសវៀតណាម។ ចំណែកជនរងគ្រោះទាំង ២ នាក់ យើងបានបញ្ជូនពួកគាត់ទៅកាន់គ្រួសារវិញហើយ»។

តាមរបាយការណ៍របស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញមុនឈានដល់ការឃាត់ខ្លួននេះ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្សបានស្រាវជ្រាវជាច្រើនថ្ងៃទើបឈានដល់ការឃាត់ខ្លួនជនសង្ស័យភ្លាមៗតែម្តង។ របាយការណ៍បញ្ជាក់ថាមុនពេលពួកនារីរងគ្រោះសម្រេចចិត្តទៅប្រទេស ចិន គឺស្ត្រីម្នាក់ដែលជាមេខ្យល់បានទាក់ទងនិងលួងលោមថា បើពួកនាងព្រមទៅប្រទេស ចិន ពេលទៅដល់ភ្លាមនឹងទទួលបានប្រាក់ម្នាក់ពី ២ ០០០-៣ ០០០ ដុល្លារអាមេរិក។ ក្នុងនោះរាល់ការធ្វើឯកសារ និងធ្វើដំណើរ ភាគីខាងមេខ្យល់ជាអ្នករ៉ាប់រងទាំងអស់តែម្តង។ របាយការណ៍បញ្ជាក់ទៀតថា ព្រោះតែនារីរងគ្រោះមិនមានលិខិតឆ្លងដែន មេខ្យល់បានប្រាប់ថានឹងនាំទៅធ្វើលិខិតឆ្លងដែន

ដោយចំណាយពេលធ្វើត្រឹមតែ ១ ថ្ងៃ និងរួចរាល់។ ក្រោយពីធ្វើលិខិតឆ្លងដែនរួចនឹងធ្វើដំណើរទៅតាមច្រកព្រំដែនអន្តរជាតិបាវិត។ នៅពេលទៅដល់ហូជីមិញ គឺមានមេខ្យល់ចាំទទួលដើម្បីនាំឆ្លងដែនទៅប្រទេស ចិន តែម្តង។

លោក យឹម វៈ អគ្គលេខាធិការរង អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃក្រសួងមហាផ្ទៃបញ្ជាក់ថា ចំពោះការទប់ស្កាត់ និងប្រឆាំងការជួញដូរមនុស្សនេះ រាជរដ្ឋាភិបាលក៏ដូចជាក្រសួងមហាផ្ទៃបានបង្កើតផែនការសកម្មភាពជាតិឆ្នាំ ២០១៩-២០២៣ ដើម្បីឆ្លើយតបឈានទៅការអនុវត្តអន្តរក្រសួងលើបញ្ហាការជួញដូរមនុស្សនេះ។ លោកថ្លែងថា៖ «នៅថ្ងៃពុធនេះ (ម្សិលមិញ) សម្តេចនាយករដ្ឋមន្ត្រី (ហ៊ុន សែន ) ក៏បានថ្លែងក្នុងការបើកសន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន-ចិន លើកទី ១២ នៅខេត្តសៀមរាប ដោយលោកបានលើកឡើងពីបញ្ហានៃការប្រយុទ្ធប្រឆាំងនៃការជួញដូរមនុស្សនេះដែរ។ ក្នុងនោះជំហររបស់រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស»៕

## ចៀសវាងចំណាកស្រុក ក្រសួងទេសចរណ៍ប្រាប់ឱ្យពលកររៀនផ្នែកបដិសណ្ឋារកិច្ច

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 08 November 2019 | 11:02 ICT

**សៀមរាប៖** ក្រសួងទេសចរណ៍បានអំពាវនាវឱ្យអតីតពលករ ដែលមានបំណងចង់វិលទៅធ្វើការចំណាកស្រុកនៅក្រៅប្រទេស និងយុវជន នាំគ្នាងាកមករៀនជំនាញផ្នែកបដិសណ្ឋារកិច្ចវិញ ចៀសវាងការធ្វើចំណាកស្រុក ដើម្បីទទួលបានការងារល្អនៅក្នុងប្រទេសស្របពេលតម្រូវការការងារវិស័យនេះកំពុងកើនឡើងខ្លាំង។

ការអំពាវនាវនេះធ្វើឡើងក្នុងកិច្ចសន្ទនា ទ្វេភាគីលើកទី ២ កាលពីថ្ងៃទី ៦ វិច្ឆិកា ស្តីពីការអភិវឌ្ឍ និងការទទួលស្គាល់ជំនាញបដិសណ្ឋារកិច្ចក្នុងវិស័យទេសចរណ៍រវាងក្រសួងទេសចរណ៍ និងអង្គការ ទេសន្តប្រវេសន៍អន្តរជាតិ (IoM) ដោយមានការចូលរួមពីលោក ប៉ាក់ សុខុម រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ និងលោក ពៅ ពិសិដ្ឋ អភិបាលរងខេត្តសៀមរាប។ កិច្ចសន្ទនានេះក៏មានប្រតិភូនៃព្រះរាជាណាចក្រថៃតំណាងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរពាក់ព័ន្ធសិស្សនិស្សិតប្រមាណ ២០០ នាក់ នៅសណ្ឋាគារសោមាទេវីស្ប៉ា និងរីសតខេត្តសៀមរាប។

រដ្ឋលេខាធិការ លោក ប៉ាក់ សុខុម បានថ្លែងថា៖ «ក្រសួងទេសចរណ៍បានដាក់កម្មវិធីផ្តល់ជំនាញថ្មីដល់អតីតពលករចំណាកស្រុក ក៏ដូចជាយុវជនមានទំនោរចំណាកស្រុក ឲ្យងាកមកចាប់ជំនាញជាក់លាក់មួយក្នុងវិស័យទេសចរណ៍កម្ពុជា ដែលកំពុងមានតម្រូវការជំនាញកាន់តែច្រើន។ លោកលើកឡើងថា ទោះបីប្រទេសកម្ពុជាពុំទាន់មានសាលាបណ្តុះបណ្តាល ជំនាញទេសចរណ៍គ្រប់គ្រាន់ ប៉ុន្តែក្រសួងទេសចរណ៍បានដាក់នូវផែនការ និងទម្រង់បណ្តុះបណ្តាលនានាដល់មូលដ្ឋានអាជីវកម្ម បម្រើសេវាកម្មទេសចរណ៍។ មានកម្មវិធីសិក្សាស្របតាមស្តង់ដាររួមរបស់អាស៊ាន ព្រមទាំងបានបណ្តុះបណ្តាលធនធាន គ្រូបង្គោលគ្រប់គ្រាន់។ សាលាបណ្តុះបណ្តាលនានាផ្សេងទៀតនៅកម្ពុជា បច្ចុប្បន្នក៏បានអនុវត្តកម្មវិធីអាស៊ានទាំងនេះយ៉ាងសកម្មផងដែរ។

លោក សុខុម ឱ្យដឹងថាបច្ចុប្បន្ន អតីតពលករមកពីប្រទេស ថៃ និងយុវជន ដែលមានគ្រួសារជីវភាពក្រីក្រសរុបចំនួន ៦០ នាក់ (នារី ៣៦ នាក់) បានទទួលការសិក្សាទាំងទ្រឹស្តី និងអនុវត្តផ្ទាល់លើជំនាញនៃសេវាកម្មសណ្ឋាគារនៅសាលាសណ្ឋាគារ និងទេសចរណ៍ ប៉ូលឌុយប្រ៊ូល ក្នុងខេត្តសៀមរាបរយៈពេល ៣ ខែ។ ពួកគេក៏បានចុះហ្វឹកហាត់ការងារនៅសណ្ឋាគាររយៈពេល ៣ ខែផងដែរ នៅព្រះរាជាណាចក្រថៃ។ លោកបញ្ជាក់ថា៖ «ជាការសាកល្បងចាប់ពីឆ្នាំ ២០១៨ មកក្រោមការគាំទ្ររបស់រដ្ឋាភិបាលស្វីសតាមរយៈអង្គការអន្តរជាតិទេសន្តប្រវេសន៍មានយុវជន ៦០ នាក់បានបញ្ចប់ការសិក្សា។ ក្នុងនោះ ៣៥ នាក់ នឹងបញ្ចប់កម្មសិក្សាឆាប់ៗនៅប្រទេស ថៃ ដើម្បីត្រឡប់មកបម្រើការងារនៅក្នុងប្រទេសកម្ពុជាវិញ»។ លោក សុខុម បានបន្តថា កម្មវិធីនេះនឹងបន្តដោយផ្តល់ជំនាញដល់យុវជនកាន់តែច្រើនថែមទៀត ដើម្បីផ្តល់ជំនាញដល់អតីតពលករត្រឡប់មកពីប្រទេស ថៃ និងយុវជនដែលពុំមានជំនាញ ហើយមានបំណងចំណាកស្រុក។

លោក នួន រស្មី នាយកសាលាបដិសណ្ឋារកិច្ច និងទេសចរណ៍ អេធីភី (ASEAN Tourism Professional consultant) ប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញថា ក្នុងវិស័យទេសចរណ៍កម្ពុជា គឺមានតម្រូវការការងារច្រើនផ្នែក។ ពលករ និងយុវជនអាចចំណាយពេលខ្លីក្នុងការរៀន ប៉ុន្តែងាយស្រួលក្នុងការទទួលបានការងារធ្វើ។ លោកថ្លែងថា៖ «ការងារក្នុងវិស័យនេះមានដូចជា អ្នកជំនាញផ្នែកកាហ្វេ ធ្វើភេសជ្ជៈ ផ្តល់សេវាកម្ម គិតលុយ និងជំនាញផ្នែកចុងភៅជាដើម ដែលកំពុងមានតម្រូវការជាច្រើននាក់សម្រាប់សណ្ឋាគារ ភោជនីយដ្ឋាន កំពុងជ្រើសរើសជារៀងរាល់ថ្ងៃតែម្តង»។ លោក រស្មី ឲ្យដឹងថាបច្ចុប្បន្នមានសាលាបណ្តុះបណ្តាលជំនាញទេសចរណ៍ជាច្រើនទាំងឯកជន និងរដ្ឋ។ ការបង្រៀនពលករ និងយុវជនតាមរយៈជំនួយពីបរទេស។ ការរៀនសម្រាប់ធ្វើការងារក្នុងវិស័យទេសចរណ៍ រៀនត្រឹមរយៈពេល ៣ ថ្ងៃ ១ ខែ ឬ ៣ ខែក៏អាចទទួលបានការងារល្អធ្វើ និងធាប់ទទួលបានការឡើងប្រាក់ខែថែមទៀត។ លោកបញ្ជាក់ថា៖ «បើពលករ និងយុវជនអាចចាប់យកជំនាញក្នុងវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ចនេះបានច្បាស់លាស់ ពួកគាត់ធ្វើការងារក្នុងវិស័យនេះរឹតតែយូរប្រាក់ខែពួកគាត់កើនឡើងកាន់តែខ្ពស់។ តម្រូវការការងារក្នុងវិស័យនេះមានរាល់ថ្ងៃកំពុងជ្រើសរើសគ្រប់កន្លែងទាំងអស់។ បច្ចុប្បន្នសូម្បីតែអ្នកដែលចង់ធ្វើការងារក្នុងវិស័យនេះមិនមានបទពិសោធការងារក៏គេយកទៅធ្វើការដែរ ព្រោះកំពុងមានកង្វះបុគ្គលិក»៕

## សេដ្ឋកិច្ចដែលប្រតិបត្តិក្រៅច្បាប់របស់ចក្រភពអង់គ្លេសទាក់ទាញជនចំណាកស្រុកវៀតណាម

https://khmer.voanews.com/ 07 វិច្ឆិកា 2019

ឡុងដ៍៖ ការស្លាប់របស់ជនចំណាកស្រុកចំនួន៣៩នាក់ដែលភាគច្រើននៃអ្នកស្លាប់ទាំងនោះត្រូវបានគេជឿថាជាជនជាតិវៀតណាមនៅខាងក្នុងកុងទីន័រទូទឹកកក្នុងរថយន្តត្រាក់នៅជិតទីក្រុងឡុងដ៍នៃចក្រភពអង់គ្លេសកាលពីសប្តាហ៍មុនបានផ្តោតយ៉ាងខ្លាំងលើជីវភាពរបស់អ្នកទាំងនោះ ដែលផ្សងគ្រោះថ្នាក់ដើម្បីរកជីវភាពប្រសើរឡើងនៅក្នុងចក្រភពអង់គ្លេស។ ជនជាតិវៀតណាមជាច្រើនបានត្រូវគេទាក់ទាញឲ្យធ្វើការនៅបរទេសដោយទទួលបានប្រាក់កម្រៃដ៏ច្រើននៅក្នុងឧស្សាហកម្មខុសច្បាប់។ រឿងដែលគេមិនធ្លាប់ឃើញនិងមិនធ្លាប់ឮសេដ្ឋកិច្ចខុសច្បាប់របស់ចក្រភពអង់គ្លេសជាជនចំណាកស្រុកជាច្រើនដែលបានចូលក្នុងចក្រភពអង់គ្លេសខុសច្បាប់ ចង់ទទួលប្រយោជន៍ពីឧស្សាហកម្មដែលខុសច្បាប់និងគ្មានបទបញ្ញត្តិ។

លោកស្រី Tamsin Barber ជាអ្នកជំនាញស្តីពីពលរដ្ឋវៀតណាមនៅក្នុងចក្រភពអង់គ្លេសនិយាយថា ពួកគេជាច្រើនមានឆន្ទៈធ្វើការប្រថុយប្រថានខ្លាំងបំផុត។ លោកស្រី Tamsin Barber និយាយថា៖ «ពួកគេដឹងថា នៅពេលដែលពួកគេទៅដល់ប្រទេសអង់គ្លេស ពួកគេអាចរកការងារធ្វើនៅក្នុងឧស្សាហកម្មកញ្ឆាដែលពួកគេរំពឹង នឹងរកប្រាក់បានយ៉ាងច្រើនដើម្បីសងពួកអ្នកជួញដូរមនុស្ស ហើយប្រាក់ដែលនៅសេសសល់ប៉ុន្មានផ្ញើរទៅឲ្យក្រុមគ្រួសារនៅវៀតណាម»។ ដូចជាឧស្សាហកម្មកញ្ឆាខុសច្បាប់ដែរ ជនជាតិវៀតណាមជាច្រើន ធ្វើការនៅកន្លែងធ្វើក្រចកដែលបានរីកចម្រើននៅតាមដងផ្លូវនានានៅក្នុងចក្រភពអង់គ្លេសក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ជនជាតិវៀតណាមផ្សេងទៀត ធ្វើការក្នុងភោជនីយដ្ឋាន ជាអ្នកបោសសម្អាត ខ្លះទៀតក្នុងផ្នែកបេស្សាកម្ម។

លោក Phil Robertson នៃអង្គការសិទ្ធិមនុស្ស Human Rights Watch និយាយថា ជនចំណាកស្រុកជាច្រើន បានធ្លាក់ចូលក្នុងអន្ទាក់នេះនៅពេលមកដល់អង់គ្លេស។លោក Phil Robertson នៃអង្គការសិទ្ធិមនុស្ស Human Rights Watch ៖ «នៅពេលទៅដល់អង់គ្លេស បំណុលដ៏ច្រើនរបស់ពួកគេមានចំនួនពី៣ទៅ៤ម៉ឺនដុល្លារ។ប្រសិនបើពួកគេ មិនធ្វើតាមបង្គាប់ឬបញ្ជារបស់ពួកអ្នកជួញដូរមនុស្ស អាចមានផលប៉ះពាល់ដល់ក្រុមគ្រួសាររបស់ពួកគេនៅវៀតណាម»។ ជនចំណាកស្រុកខ្លះ រស់នៅក្នុងស្ថានភាពដូចជាទាសករ។លោក Robertsonនៃអង្គការសិទ្ធិមនុស្ស Human Rights Watch បានថ្លែងទៀតថា៖ «ពួកគេភ័យខ្លាចមិនហ៊ានរាយការណ៍ឬប្រាប់ពួកអាជ្ញាធរ ពីព្រោះតែ ពួក

គេត្រូវគេរំលោភធ្វើបាបយ៉ាងខ្លាំង។បញ្ហាដែលកើតឡើងគឺ ពួកគេនឹងត្រូវគេចាប់ខ្លួនហើយបញ្ជូនត្រឡប់ទៅកាន់វៀតណាមវិញដែលពួកគេ បានជំពាក់បំណុលយ៉ាងច្រើន»។

លោកស្រី Tamsin Barber និយាយទៀតថា ថ្វីបើប្រថុយប្រថានក៏ដោយ ការបញ្ជូនសមាជិកក្រុមគ្រួសារទៅបរទេស ធម្មតាជាការសម្រេចរួមគ្នា។ លោកស្រី Tamsin Barber បានថ្លែងថា៖ «វិធីនានាដែលក្រុមគ្រួសារ អាចប្រើគឺប្រមូលប្រាក់មកពីការលក់ដីធ្លី យកផ្ទះរបស់ខ្លួនដាក់បញ្ចាំ អាចខ្ចីប្រាក់មកពីអ្នកមានប្រាក់ដែលមានការប្រាក់ខ្ពស់បំផុត»។ ប្រសិនបើជោគជ័យប្រាក់ចំណេញនេះ អាចធ្វើឲ្យមានការផ្លាស់ប្តូរសហគមន៍នៅក្នុងមាតុភូមិវិញ។នៅក្នុងឃុំ Do Thanh ផ្ទះខ្ទមតូចៗនៅផ្នែកខាងត្បូងទីក្រុងហាណូយត្រូវបានជំនួសដោយផ្ទះវីឡាប្រណិតៗ។លោក ង៉ៀង វ៉ាន់ទ្វី ជាអ្នកស្រុកនៅទីនោះនិយាយថា៖«លោកនិយាយថា កាលពីដំបូង ឃុំដូថាញ់ទាំងមូល ជាទីកន្លែងដែលពួកកសិករធ្វើស្រែចំការ។ក៏ប៉ុន្តែ បន្ទាប់មក មនុស្សខ្លះបានទៅធ្វើការនៅបរទេស ដែលពួកគេមានលុយ។ដោយហេតុនេះ ហើយបានជាមនុស្សជាច្រើនបានសម្រុកទៅបរទេស ដោយធ្វើដំណើរតាមយន្តហោះស្របច្បាប់និងធ្វើការខុសច្បាប់»។ ការធ្វើការងារខុសច្បាប់ បានបញ្ចប់ដោយសោកនាដកម្មជនចំណាកស្រុកចំនួន៣៩នាក់ស្លាប់នៅពេលឆ្លងកាត់ទៅប្រទេសអង់គ្លេស។លោកស្រី Tamsin Barber ថ្លែងថា៖ «ពួកជនចំណាកស្រុក ជ្រើសរើសផ្លូវប្រកបដោយគ្រោះថ្នាក់នេះ ពីព្រោះពួកគេអាចមានលទ្ធភាពរកប្រាក់ច្រើន»។ ផលប្រយោជន៍ប្រកបដោយសក្តានុពលពោរពេញទៅដោយភាពប្រថុយប្រថានប្រកបដោយការភ័យខ្លាច។ នេះជាគ្រោះថ្នាក់ដែលជនចំណាកស្រុកកំពុងប្រឈមដើម្បីស្វែងរកជីវភាពប្រសើរឡើងនៅក្នុងចក្រភពអង់គ្លេសនោះ៕

## ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០១៩

### ថៃបញ្ជូនពលករខ្មែរ ៤០នាក់ ដែលចូលទៅធ្វើការ ខុសច្បាប់មកឲ្យកម្ពុជាវិញ

https://dap-news.com/national/ Posted on November 9, 2019

បន្ទាយមានជ័យ: នៅព្រឹកថ្ងៃទី៩ ខែវិច្ឆិកានេះ កម្លាំងសមត្ថកិច្ចកម្ពុជាថៃបានសហការគ្នាប្រគល់ទទួលពលករខ្មែរចំនួន៤០នាក់ ដែលចូលទៅធ្វើការខុសច្បាប់ មកឲ្យកម្ពុជាវិញតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត។

### កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០២នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 12-11-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០២នាក់ នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៩ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រក ចាក់ច្រែង ខេត្តព្រះវិហារ ៕

### ក្រឡាប់រថយន្តដឹក ពលករខ្មែរ ស្លាប់០១នាក់ របួស១៤ នាក់

https://www.facebook.com/prakpheaktraofficial/ ប្រាក់ ភក្ត្រា-Prak Pheaktra 10-11-2019

យោងតាមរបាយការណ៍ ពីខេត្តចាន់បុរី ប្រទេសថៃ កាលពីវេលាម៉ោង០៩ព្រឹក ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ ២០១៩ នេះបានអោយដឹងថា មានករណីក្រឡាប់រថយន្តដឹកពលករខ្មែរធ្វើការបេះផ្លែឈើ បណ្តាលអោយមានមនុស្សចំនួន ១៥នាក់ រងរបួសធ្ងន់ និងស្រាល នៅក្នុងមានពលករស្លាប់បាត់បង់ជីវិត០១នាក់។ ប្រភពពីភ្នាក់ងារសង្គ្រោះ (សារស្វាងបូរិណាប៊ូនខេត្តចាន់បុរី) ប្រាប់ថា ហេតុការណ៍នេះបានកើតឡើងនៅលើផ្លូវជាតិមួយ ស្ថិតក្នុងតំបន់ស្រុកសយដាវ ខេត្តចាន់បុរី ប្រទេសថៃ ក្រោយពេលកើតហេតុ ជនរងគ្រោះត្រូវបានសមត្ថកិច្ចថៃបញ្ជូនយកទៅសង្គ្រោះនៅមន្ទីរពេទ្យ

សយដាវ និងមន្ទីរពេទ្យប្រាក់ប៉ុកក្លៅ ខេត្តចាន់បុរី។ ចំពោះហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍លើកនេះ គឺបណ្តាលមកពីរថយន្តបែកកង់ ។

### កម្លាំង សមត្ថកិច្ច ថៃ ឃាត់ ខ្លួន ជនជាតិ ថៃ ម្នាក់រកស៊ីក្លែងបន្លំប័ណ្ណស៊ីជម្ពូពលករបរទេស

https://www.facebook.com/prakpheaktraofficial/ ប្រាក់ ភក្រ្តា-Prak Pheaktra 08-11-2019

08/11/19 យោងតាមរបាយការណ៍ពីគេហទំព័រហ្វេសប៊ុកអគ្គនាយកដ្ឋានតម្រួតប្រទេសថៃ បានអោយដឹងថា កម្លាំងសមត្ថកិច្ចថៃ បានធ្វើការឃាត់ខ្លួនបុរសជនជាតិថៃម្នាក់ ឈ្មោះ ធុងឆៃ ហៅ បែង អាយុ២៨ឆ្នាំ មួយនិងគ្រឿងញៀនប្រភេទទឹកកក ចំនួន៤គីឡូក្រាម និងអត្តសញ្ញាប័ណ្ណសញ្ជាតិថៃ ក្លែងក្លាយ ចំនួន១៧០សន្លឹក ប័ណ្ណស៊ីជម្ពូពលករបរទេស ចំនួន១៩សន្លឹក ប័ណ្ណបើកបរ ចំនួន៨០សន្លឹក ព្រមទាំងត្រាក្លែងក្លាយរបស់នាយកដ្ឋានផ្សេងៗ និងឧបករណ៍កុំព្យូទ័រ ចំនួនចំនួនទៀត ។

តាមការបញ្ជាក់របស់សមត្ថកិច្ចជនសង្ស័យខាងលើជាប់ពាក់ព័ន្ធនឹងករណីគ្រឿងញៀនព្រមទាំងមានដីកាចាប់ខ្លួនពីតុលាការចំនួន១៣ ដីកា។ ដោយសមត្ថកិច្ចស្រាវជ្រាវដឹងថា ជនសង្ស័យរកស៊ីទទួលធ្វើប័ណ្ណស៊ីជម្ពូក្លែងក្លាយរបស់ពលករបរទេសតាមហ្វេសប៊ុកដោយគិតធ្វើឯកសារក្លែងក្លាយក្នុងតម្លៃមួយសន្លឹក៣០០០បាត ប័ណ្ណបើកបរក្លែងក្លាយមួយសន្លឹក៤០០០បាត អត្តសញ្ញាប័ណ្ណសញ្ជាតិថៃ ក្លែងក្លាយតំម្លៃមួយសន្លឹក៥០០០បាត អោយជនបរទេស បច្ចុប្បន្នជនសង្ស័យត្រូវបានសមត្ថកិច្ចថៃកសាងសំណុំរឿងដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ។

### ពីមុនពលករខ្មែរ ប៉ុន្តែបាត់បង់ភ្នែក ក្លាយ ជាអ្នក សុំទានតាមកម្មវិធីបុណ្យ ដើម្បីចញ្ចឹមជីវិត

https://www.facebook.com/LabourOfficial/ ពលករ 10/11/19

ប្រភពព័ត៌មាន៖ ពីខេត្តឆាកឈើងសៅ ប្រទេសថៃ បានអោយដឹងថា កម្លាំងអាជ្ញាធរសង្គមកិច្ចខេត្ត សហការជាមួយ សមត្ថកិច្ច ខេត្តឆាកឈើងសៅ បានធ្វើការឃាត់ខ្លួនបុរសជនជាតិខ្មែរ០១នាក់ ឈ្មោះ ធប ភេទប្រុស អាយុ ២៣ឆ្នាំ ខណៈពេលកំពុងអង្គុយសុំទាននៅកម្មវិធីបុណ្យលើកខួបព្រះតេជព្រះគុណសូថន។ ប្រភពបន្ថែមប្រាប់អោយដឹងថា បុរសខាងលើ បានអង្គុយពាក់វ៉ែនតាខ្មៅកាន់ប្រអប់បរិច្ចាគប្រាក់ដោយសរសេរជាភាសាថៃថា "សូមចូលរួមបរិច្ចាគ ប្រាក់ជួយសង្គ្រោះជនពិការភ្នែក " នៅក្នុងប្រអប់បរិច្ចាគមានទឹកប្រាក់ចំនួន១៣២៩បាត ២៥សាតាង។

តាមការសាកសួររបស់សមត្ថកិច្ច បុរសខាងលើបានប្រាប់ឲ្យដឹងថា គាត់បានចូលមកធ្វើការសំណង់នៅក្នុងប្រទេសថៃ ប៉ុន្តែអកុសលគាត់បានជួបឧបទ្ទវហេតុកំពុងធ្វើការត្រូវដែកគោលភ្លាតត្រូវភ្នែក បណ្តាលអោយគាត់មើលលែងឃើញ ធ្វើការអត់កើត ក៏ងាកមករកបរសុំទាន តាមកន្លែងដែលមានកម្មវិធីបុណ្យផ្សេងៗ ។ បច្ចុប្បន្នបុរសខាងលើត្រូវបានអាជ្ញាធរសង្គមកិច្ចប្រគល់ជូនសមត្ថកិច្ចអន្តោប្រវេសន៍ ខេត្តឆាកឈើងសៅ ដើម្បីបញ្ជូនអោយវិលត្រឡប់ទៅប្រទេសកម្ពុជាវិញ។

### តើហេតុអ្វីបានជាអាជ្ញាធរវៀតណាមមិនអាចបញ្ឈប់ការធ្វើចំណាកស្រុកដ៏ប្រថុយប្រថានរបស់ពលរដ្ឋខ្លួនទៅប្រទេសអ្នកមាន?

https://khmer.voanews.com/ 12 វិច្ឆិកា 2019

នាយករដ្ឋមន្ត្រីវៀតណាម បានបញ្ជាឲ្យមានការស៊ើបអង្កេតថាតើករណីរកឃើញសាកសពរបស់មនុស្ស៣៩ នាក់ នៅក្នុងរថយន្តកុងតឺណឺនៅក្នុងចក្រភពអង់គ្លេសកាលពីខែមុនជាករណីជួញដូរមនុស្សខុសច្បាប់ចេញពីប្រទេសវៀតណាមឬយ៉ាងណា។

តែប៉ុះ ខណៈពេលដែលការបញ្ហាឲ្យមានការស៊ើបអង្កេតនេះ ជួយបន្ធូរបន្ថយការខឹងសម្បារបស់ពលរដ្ឋវៀតណាម អ្នកជំនាញមានការព្រួយបារម្ភថា ការណ៍នេះគ្រាន់តែជាការលាក់បាំងពីអសមត្ថភាពរយៈពេលយូររបស់រដ្ឋាភិបាលវៀតណាមក្នុងការបញ្ឈប់ការជួញដូរមនុស្សទៅក្នុងប្រទេសអ្នកមានដើម្បីជាថ្នូរនឹងការរកប្រាក់ប៉ុណ្ណោះ។ ការរកឃើញរបស់ប៉ូលិសនៅប៉ែកអាគ្នេយ៍នៃចក្រភពអង់គ្លេសធ្វើឲ្យមានការចាប់អារម្មណ៍ភ្លាមៗលើការជួញដូរមនុស្សពីវៀតណាមទៅអឺរ៉ុប ទីដែលមានប្រាក់ចំណូលខ្ពស់ជាងនៅវៀតណាម។ ការចាប់ខ្លួនមនុស្សមួយចំនួនបានធ្វើឡើងនៅក្នុងចក្រភពអង់គ្លេស ហើយបុរសម្នាក់ត្រូវបានគេចោទប្រកាន់ពីការសមគំនិតជួញដូរមនុស្ស។ ក៏ប៉ុន្តែ អ្នកជំនាញនិយាយថា ប្រព័ន្ធអន្តរជាតិដ៏ស្មុគស្មាញក្នុងការនាំមនុស្សចេញពីវៀតណាមសម្រាប់ការងារ ដែលមានប្រាក់ឈ្នួលខ្ពស់នៅក្រៅប្រទេសមានការរីកចំរើនយ៉ាងខ្លាំងដែលមន្ត្រីរដ្ឋាភិបាលយល់ថា មានការពិបាកក្នុងការបញ្ឈប់ ឬមិនអាចបញ្ឈប់បាន ប្រសិនបើប្រៀបធៀបទៅពេលដែលវៀតណាមមានភាពក្រីក្រជាងសព្វថ្ងៃ។

លោក Carl Thayer សាស្ត្រាចារ្យចូលនិវត្តន៍ផ្នែកនយោបាយជំនាញកិច្ចការតំបន់អាស៊ីអាគ្នេយ៍នៅសាកលវិទ្យាល័យ The University of New South Wales ក្នុងប្រទេសអូស្ត្រាលីនិយាយថា៖ «នេះជាការប្រយុទ្ធប្រឆាំងដែលគ្មានទីបញ្ចប់មួយ»។ តម្លៃតបស្នងសម្រាប់អ្នកលួចជួញដូរមនុស្សមានច្រើន ហើយពួកគេបញ្ឆោះបញ្ឆោតជនរងគ្រោះដោយនិយាយថា នឹងមានការរស់នៅបែបហ៊ឺហាដែលពួកគេផ្តល់ឲ្យមនុស្សដែលក្រីក្រខ្លាំង»។

## កិច្ចប្រឹងប្រែងដើម្បីបញ្ឈប់ការជួញដូរមនុស្ស

បណ្តាញផ្សព្វផ្សាយព័ត៌មាន Viet Nam ដែលជាបណ្តាញផ្សព្វផ្សាយរបស់រដ្ឋ បានរាយការណ៍ថា បន្ទាប់ពីសាកសពរបស់មនុស្សចំនួន៣៩នាក់ ត្រូវបានគេរកឃើញ នាយករដ្ឋមន្ត្រីវៀតណាម លោក Nguyen Xuan Phuc បានប្រាប់រដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈ និងក្រសួងកិច្ចការបរទេស ឲ្យបើកការស៊ើបអង្កេតលើការជួញដូរមនុស្ស និងបង្កើត «វិធានការការពារពលរដ្ឋ» ប្រសិនបើចាំបាច់។ បណ្តាញផ្សព្វផ្សាយនេះបានឲ្យដឹងថា កាលពីឆ្នាំមុន រដ្ឋាភិបាលវៀតណាម និងអង់គ្លេសបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់មួយ «ដើម្បីដោះស្រាយអំពើទាសភាពសម័យទំនើប»។ នៅពេលដែលរដ្ឋមន្ត្រីការបរទេសវៀតណាមទូរស័ព្ទទៅមន្ត្រីអង់គ្លេសកាលពីថ្ងៃអង្គារទី២៩ ខែតុលា កន្លងទៅនេះ ដើម្បីពិភាក្សាលើករណីកាលពីពេលថ្មីៗនេះ ភាគីទាំងពីរបានយល់ស្របនឹងគ្នាថា «នឹងអំពាវនាវឲ្យសហគមន៍អន្តរជាតិពង្រឹងកិច្ចសហប្រតិបត្តិការដើម្បីបង្ក្រាបបទល្មើស»។

## ឧបសគ្គក្នុងការបង្ក្រាប

លោក Thayer និយាយថា មន្ត្រីសន្តិសុខសាធារណៈអាចនឹងផ្សព្វផ្សាយបញ្ហាជួញដូរមនុស្សជាសាធារណៈបន្ថែមទៀត និងធ្វើការបោសសម្អាតក្រុមជួញដូរមនុស្សឲ្យកាន់តែច្រើនបន្ថែមទៀត។ លោកបានបន្ថែមថា ពួកគេកម្រចាប់មនុស្សណាស់ឥឡូវនេះ។ ប៉ុន្តែ លោកបាននិយាយថា ជនរងគ្រោះនៃការជួញដូរមនុស្សដែលត្រូវបានគេរកឃើញខ្វះមធ្យោបាយក្នុងការសម្គាល់មេខ្យល់ជួញដូរមនុស្ស ហើយក្នុងពេលជាមួយគ្នានេះផងដែរ ដោយសារតែតំបន់សេដ្ឋកិច្ចពិសេសវៀតណាមនៅជាប់នឹងប្រទេសជិតខាងនោះ វាជាហេតុ ធ្វើឲ្យពលរដ្ឋរបស់ខ្លួនអាចចាកចេញពីប្រទេសដោយងាយស្រួល។ លោក Thayer និយាយថា៖ «ព្រំដែននៅមានចន្លោះប្រហោង ហើយមនុស្សម្នាអាចឆ្លងកាត់បាន»។ បណ្តាញជួញដូរមនុស្សបានកើនឡើងយ៉ាងខ្លាំងនៅក្នុងប្រទេសវៀតណាម ចាប់តាំងពីយ៉ាងហោចណាស់សតវត្សរ៍ទី១៩ ដែលជាញឹកញាប់បាននាំយកស្ត្រី និងក្មេងៗទៅហុងកុង ឬ ចិនដីគោក ដើម្បីលក់តាមរយៈការរៀបអាពាហ៍ពិពាហ៍ ឬ លក់ជាស្ត្រីរកស៊ីផ្លូវភេទ នេះបើយោងតាមសៀវភៅស្តីពីការជួញដូរមនុស្សក្នុងប្រទេសវៀតណាម ឆ្នាំ២០១៥។

លោក Frederick Burke ដែលជាមេធាវីនៅក្រុមហ៊ុនមេធាវី Baker McKenzie ក្នុងក្រុងហូជីមិញបាននិយាយថា ឥឡូវនេះ ដើម្បីបញ្ឈប់ស្ត្រីៗកុំឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយនឹងពលរដ្ឋនៃប្រទេសអ្នកមាននៅអាស៊ីអាគ្នេយ៍ មន្ត្រីរដ្ឋាភិបាលក្នុងប្រទេសវៀតណាម ធ្វើការត្រួតពិនិត្យប្រវត្តិរូបយ៉ាងហ្មត់ចត់ នៅពេលមានការដាក់ពាក្យសុំរៀប

អាពាហ៍ពិពាហ៍។ លោក Frederick Burke និយាយថា៖ «ច្បាស់ណាស់ ពួកគេនឹងពិនិត្យមើលវិធានការអ្វី (ដែលពួកគេអាចធ្វើបាន) បន្ទាប់ពីមានករណីក្នុងប្រទេសអង់គ្លេសកើតឡើង។ ពួកគេមានបញ្ហាខ្លាំងទាក់ទងនឹងការលក់ស្ត្រីឲ្យទៅធ្វើជាភរិយា។ បញ្ហាទាំងនេះ មិនមែនជាបញ្ហាថ្មីនោះទេ»។ លោក Burke បាននិយាយទៀតថា ពលរដ្ឋសាមញ្ញនៅវៀតណាមនៅតែយល់ថា ការស្លាប់ក្នុងប្រទេសអង់គ្លេសកាលពីខែមុនកើតឡើង ដោយសារតែជនរងគ្រោះទាំងនោះត្រូវបានមេខ្យល់បោកប្រាស់។ លោកនិយាយបន្ថែមទៀតថា បើមើលជារួមទៅលើការធ្វើចំណាកស្រុកដើម្បីរកការងារធ្វើ ពលរដ្ឋវៀតណាមនៅតែគិតថា «ការងារនៅក្រៅប្រទេសនៅតែមានភាពល្អប្រសើរជាង»។

**អ្នកក្រីក្រខ្លាំងមិនបានទទួលការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ចទេ**

នៅក្នុងប្រទេសវៀតណាម មន្ត្រីវៀតណាមបានធ្វើឲ្យជីវភាពរបស់ពលរដ្ឋខ្លួនប្រសើរឡើង ដោយបានជំរុញឲ្យមានការវិនិយោគពីបរទេសនៅក្នុងវិស័យផលិតកម្មសម្រាប់នាំចេញ ដែលបានបង្កើតការងារជាច្រើន។ ក្រុមហ៊ុន SSI Research នៅក្នុងទីក្រុងហាណូយបានឲ្យដឹងថា សេដ្ឋកិច្ចរបស់ប្រទេសនៅអាស៊ីអាគ្នេយ៍ដែលមានទឹកប្រាក់៣០០ពាន់លានដុល្លារមួយនេះ នឹងកើនឡើង៦,៨ភាគរយ នៅឆ្នាំនេះ។ សេដ្ឋកិច្ចប្រទេសនេះ បានកើន៧កន្លក់សញ្ញា១ភាគរយ នៅក្នុងឆ្នាំ២០១៨ ដែលជាអត្រាខ្ពស់បំផុតក្នុងរយៈពេល១១ឆ្នាំ។ ទោះជាយ៉ាងនេះក៏ដោយ ប្រាក់ឈ្នួលការងារប្រើកម្លាំងដែលទទួលបានតិចជាង២០០ដុល្លារក្នុង១ខែ ពិបាកនឹងប្រៀបធៀបជាមួយនឹងប្រាក់ឈ្នួលនៅក្នុងប្រទេសដែលមនុស្សត្រូវបានគេជួញដូរទៅ។ ពលរដ្ឋវៀតណាមនៅតែប្រថុយនឹងឱកាសធ្វើការនៅក្នុងរោងចក្រក្នុងប្រទេសរុស្ស៊ី ការងារសំណង់ក្នុងប្រទេសលីប៊ី និងធ្វើការនៅក្នុងកសិដ្ឋានអង់គ្លេស។

ប្រធានផ្នែកសេដ្ឋកិច្ចរបស់ក្រុមហ៊ុន IHS Markit Asia-Pacific លោក Rajiv Biswas និយាយថា ពលរដ្ឋវៀតណាមប្រមាណ១០%ក្នុងចំណោមពលរដ្ឋ៩៥លាននាក់រស់នៅក្នុងភាពក្រីក្រ ហើយអ្នកខ្លះរស់នៅក្នុង «ភាពក្រីក្រតោកយ៉ាក» ដែលរស់នៅឆ្ងាយពីមជ្ឈមណ្ឌលការងារឧស្សាហកម្ម។ លោក Rajiv Biswas បាននិយាយថា រដ្ឋាភិបាលគួរតែដោះស្រាយបញ្ហាភាពក្រីក្រនេះ ដែលមានមួយចំនួននៅតាមភ្នំដាច់ស្រយាល ប៉ុន្តែរដ្ឋាភិបាលនឹងមានការលំបាកក្នុងការដោះស្រាយបញ្ហានេះ។ លោក Biswas និយាយទៀតថា៖ «ខ្ញុំគិតថា ឥឡូវនេះ បញ្ហាសម្រាប់វៀតណាម គឺដោះស្រាយបញ្ហាអ្នករស់នៅក្នុងភាពក្រីក្រនៅតំបន់ភ្នំទាំងនោះ ហើយវានឹងមានការពិបាកក្នុងការដោះស្រាយដោយសារតែសមត្ថភាពធ្វើការរបស់ពួកគេក្នុងការងារឧស្សាហកម្ម ពីព្រោះថា ពួកគេគ្មានមធ្យោបាយដើម្បីធ្វើការងារបែបនោះទេ»៕

## ស្ត្រីបង់ក្លាដែសបម្រើតាមផ្ទះម្នាក់ ត្រូវថៅកែចាប់រំលោភ និងចងចាក់ប្រេងដុតដៃ

https://kbn.news/archives/ November 12, 2019

អារ៉ាប់ប៊ីសាអូឌីត៖ ថ្មីៗនេះស្ត្រីបង់ក្លាដែសម្នាក់ដែលជាអ្នកបម្រើការងារតាមផ្ទះ នៅប្រទេសអារ៉ាប់ប៊ីសាអូឌីតបានបញ្ចេញវីដេអូដ៏គួរឱ្យភ្ញាក់ផ្អើលមួយ ដែលនាងនិយាយអំពីការរំលោភបំពានផ្លូវភេទពីសំណាក់ថៅកែរបស់នាង។ ស្ត្រីរងគ្រោះ មានអាយុ២៥ឆ្នាំ បានលួចទៅវីដេអូខលទៅក្រុមគ្រួសារដោយសម្ងាត់កាលពីដើមខែវិច្ឆិកានេះ នាងនិយាយទាំងទឹកភ្នែក ប្រាប់អំពីការរំលោភបំពានផ្លូវភេទ និងរងទារុណកម្មពីសំណាក់ថៅកែ ហើយនាងទទូចអង្វរសុំអនុញ្ញាតិឱ្យបានត្រឡប់ទៅប្រទេសបង់ក្លាដែសវិញ បន្ទាប់ពីត្រូវបានគេចាប់ឃុំឃាំងអស់រយៈពេលជាង២សប្តាហ៍មកហើយ នាងគឺជាស្ត្រីម្នាក់ ក្នុងចំណោមស្ត្រី៣០០,០០០នាក់ ដែលបានធ្វើដំណើរទៅធ្វើការនៅក្រៅប្រទេស តាមរយៈក្រុមហ៊ុនមួយ ។

តាមរយៈវីដេអូដែលអង្គការ BRAC ទទួលបាន គឺនាងរៀបរាប់ថា «ខ្ញុំប្រហែលជារស់មិនបានយូរទេ សូមជួយសង្គ្រោះខ្ញុំផង ! ពួកគេបានចាក់សោខ្ញុំ រយៈពេល១៥ថ្ងៃហើយ ហើយពួកគេមិនបានផ្តល់អាហារអ្វីទេ ពួកគេគំរាមចាប់រំលោភ ដោយដុតដៃរបស់ខ្ញុំដោយប្រេងឆៅ ហើយចងខ្ញុំ ។ ពួកគេបាននាំខ្ញុំ ពីផ្ទះមួយទៅផ្ទះមួយទៀត នៅក្នុងផ្ទះ

ដំបូង ពួកគេបានធ្វើទារុណកម្មរំលោភបំពានផ្លូវភេទខ្ញុំ ហើយវាយខ្ញុំម្តងហើយម្តងទៀត បន្ទាប់មកបញ្ជូនខ្ញុំទៅកន្លែងមួយទៀត ដែលខ្ញុំទទួលរងដូចគ្នា ។ ខ្ញុំមិនគិតថាខ្ញុំនៅរស់ទេ ខ្ញុំគិតថាខ្ញុំស្លាប់ហើយ ពួកគេបានធ្វើទារុណកម្មវាយដំនិងរំលោភខ្ញុំ សូមជួយសង្គ្រោះខ្ញុំផង យកខ្ញុំទៅឆ្ងាយពីទីនេះ» ។

ក្រោយវីដេអូឃ្លីបនេះបែកធ្លាយលើបណ្តាញសង្គមធ្វើអោយមានការតវ៉ាជាច្រើននៅរដ្ឋធានីដាកា ប្រទេសបង់ក្លាដែស ហើយប្រជាជនបង់ក្លាដែសបានអំពាវនាវឱ្យអាជ្ញាធរប្រទេសទាំង២ ធ្វើមាតុភូមិនិវត្តន៍រូបនាង មកប្រទេសកំណើតវិញ ។ កាលពីខែមុន សាកសពរបស់ជនចំណាកស្រុកម្នាក់ឈ្មោះ Nazma Begum អាយុ៤២ឆ្នាំ ជាអ្នកបម្រើការងារតាមផ្ទះ ត្រូវបានប្រទេសអារ៉ាប់ប៊ីសាអូឌីត បញ្ជូនមកវិញ បន្ទាប់ពីនាងបានទូរស័ព្ទទៅប្រាប់កូនប្រុសរបស់នាងម្តងហើយម្តងទៀត ដើម្បីឲ្យជួយសង្គ្រោះនាង ។ នាងនិយាយប្រាប់កូនថា រូបនាងត្រូវបានគេធ្វើទារុណកម្ម ហើយប៉ូលិសរកឃើញថា នាងបានស្លាប់ ដោយសារជំងឺ ដែលមិនបានព្យាបាល ។

អង្គការ BRAC ដែលមានមូលដ្ឋាននៅទីក្រុងដាកា ដែលជាអង្គការសប្បុរសធម៌ដ៏ធំបំផុតមួយរបស់ពិភពលោក បានធ្វើការសម្ភាសន៍ទៅលើក្រុមស្ត្រីជាជនចំណាកស្រុកបង់ក្លាដែស អោយដឹងថា មានស្ត្រីប្រមាណជា៦១ភាគរយ និយាយថា ពួកនាងត្រូវបានរំលោភបំពានលើរាងកាយ ។ ហើយ១៤ភាគរយទៀត ប្រាប់ថា ពួកនាងត្រូវបានរំលោភបំពានផ្លូវភេទ ។ ហើយបើតាមរបាយការណ៍អង្គការដដែលនេះថា នៅឆ្នាំ២០១៩នេះ សាកសពពលការិនីចំនួន៤៨នាក់ ត្រូវបានបញ្ជូនមកពីប្រទេសអារ៉ាប់ប៊ីសាអូឌីតវិញ ៕

## អង្គការសង្គមស៊ីវិលចង់ឃើញរដ្ឋាភិបាលយកចិត្តទុកដាក់ខ្ពស់ទៅលើការបង្ក្រាបអំពើជួញដូរមនុស្សទៅចិន

https://www.rfa.org/khmer/news/ ដោយ អូន ភាព 2019-11-07

សង្គមស៊ីវិលចង់ឃើញរដ្ឋាភិបាលបង្ក្រាបអំពើជួញដូរមនុស្សឲ្យបានសកម្ម ជាពិសេស ជួយស្ត្រីខ្មែរដែលកំពុងរងគ្រោះនៅប្រទេសចិន។ ការលើកឡើងកង្វល់របស់សង្គមស៊ីវិលនេះ ស្របពេលដែលកម្ពុជាកំពុងធ្វើម្ចាស់ផ្ទះនៃសន្និសីទ អគ្គព្រះរាជអាជ្ញា អាស៊ាន-ចិនលើកទី១២។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ក្នុងសន្និសីទ ដែលបានធ្វើឡើងក្នុងខេត្តសៀមរាបនៅថ្ងៃទី៦ ខែវិច្ឆិកានេះថា រដ្ឋាភិបាលរបស់លោកកំពុងដោះស្រាយបញ្ហាជួញដូរមនុស្សពីថ្នាក់ជាតិដល់មូលដ្ឋាន។ លោក ហ៊ុន សែន មានប្រសាសន៍ថា ដើម្បីដោះស្រាយបញ្ហាសកលនេះឱ្យបានទាន់ពេលវេលា ប្រទេសសមាជិកអាស៊ាន-ចិន ត្រូវមានគោលការណ៍រួមមួយ ឯកភាពគ្នា សហការគ្នាយ៉ាងជិតស្និទ្ធ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។ លោក ហ៊ុន សែន បញ្ជាក់ថា ប្រទេសសមាជិកអាស៊ាន កំពុងរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាឧក្រិដ្ឋកម្មឆ្លងដែនប្រកបដោយគ្រោះថ្នាក់ ហើយកំពុងរីករាលដាលនៅក្នុងតំបន់។

ទោះបីជាយ៉ាងណា អនុប្រធានផ្នែកស្ត្រី និងកុមារ នៃសមាគម អាដហុក អ្នកស្រី មាស សាអ៊ីម បានប្រាប់អាស៊ីសេរីនៅថ្ងៃពុធម្សិលមិញថា រដ្ឋាភិបាលបានធ្វើកិច្ចការនេះតែនៅក្នុងប្រទេសប៉ុណ្ណោះ ប៉ុន្តែមិនមានចំណាត់ការសកម្មក្នុងការសង្គ្រោះស្ត្រីខ្មែរដែលកំពុងរងគ្រោះនៅប្រទេសចិនឡើយ។ អ្នកស្រីថាស្ត្រីជនរងគ្រោះមួយចំនួនត្រូវបានបាត់បង់ព័ត៌មានក្នុងការទាក់ទងនៅក្នុងប្រទេសចិន បើទោះបីដឹងទីតាំងស្នាក់នៅរបស់ជនរងគ្រោះក៏ដោយ គឺមិនអាចសង្គ្រោះបានទាន់ពេលនៅឡើយ។ អ្នកស្រីបញ្ជាក់ថា មេខ្យល់បានប្រើល្បិចកល់ច្រើននៅក្នុងការនាំស្ត្រីខ្មែរទៅប្រទេសចិន ដូចជាតាមផ្លូវគោកជាដើមហើយច្រករបៀងមួយចំនួនក៏មានអំពើពុករលួយកើតឡើងផងដែរ ទើបធ្វើឲ្យមេខ្យល់អាចនាំស្ត្រីខ្មែរទៅប្រទេសចិនបាន៖ «ខ្ញុំគិតថារដ្ឋាភិបាលមិនមែនមិនដឹងទេលោកដឹង ប៉ុន្តែបញ្ហាត្រង់ថា ច្បាប់នៅស្រុកចិន និងច្បាប់នៅស្រុកខ្មែរ ការបកស្រាយរបស់គាត់ផ្សេងគ្នា ហើយយន្តការពិតប្រាកដនៅក្នុងការការពារស្ត្រីរងគ្រោះខ្មែរដែលត្រូវបានគេជួញដូរពិតប្រាកដនៅស្រុកចិននោះគឺអត់ត្រូវបានមានដំណោះស្រាយពេញលេញនៅឡើយទេ»។

ថ្មីៗនេះស្ថានកុងស៊ុលចិនបានរឹតបន្តឹងក្នុងការចេញទិដ្ឋាការ ប្រភេទទេសចរណ៍ ហើយបានតម្រូវឲ្យមានប្រាក់តម្កល់ និងមានលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ច្បាស់លាស់ ប៉ុន្តែមេខ្យល់ឥឡូវបាននាំស្ត្រីខ្មែរទៅប្រទេសចិនតាមច្រកប្រទេសវៀតណាម ឬប្រទេសភូមា ដែលធ្វើឲ្យស្ត្រីខ្មែរងាយរងគ្រោះកាន់តែខ្លាំង។ អ្នកស្រីបន្តថាយន្តការរបស់កម្ពុជានៅមានកម្រិតក្រោមប្រទេសផ្សេងៗក្នុងតំបន់អាស៊ាន ហើយចំពោះប្រជាពលរដ្ឋ ដែលងាយរងគ្រោះមានកម្ពុជា ឡាវ និងភូមា គឺជាប្រទេសដែលងាយរងគ្រោះជាងគេ នៅក្នុងការបញ្ជូនពលករទៅខាងក្រៅប្រទេស៖ «រូបភាពពីខ្មែរទៅគឺឆបោកនិងជួញដូរ ប៉ុន្តែច្បាប់ចិនគិតថាជាការរៀបអាពាហ៍ពិពាហ៍ នៅមានស្ត្រីច្រើនដែលកំពុងរងគ្រោះហើយកំពុងបាត់ដំណឹង ទាក់ទងអត់បានព្រោះយើងអត់ដឹងច្បាស់ ហើយជនរងគ្រោះមួយភាគតូចដែលយើងនៅទាក់ទងបាននោះក៏មិនទាន់បានសង្គ្រោះទាន់ពេលនៅឡើយដែរ»។

របាយការណ៍ក្រសួងមហាផ្ទៃបានឲ្យដឹងថា ក្នុងរយៈពេល ៦ខែដើមឆ្នាំនេះប៉ូលិសបានជួយសង្គ្រោះជនរងគ្រោះ ២៦៣នាក់ពីការរំលោភផ្លូវភេទ ដែលមានការកើនឡើងជិត ១៥០ភាគរយ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ របាយការណ៍បានបញ្ជាក់ថា ក្នុងចំណោមករណីទាំងនោះមានកុមារចំនួន ៧០ នាក់ ដែលមានអាយុក្រោម ១៥ឆ្នាំមានជនរងគ្រោះចំនួន ៣១នាក់ ដែលមានអាយុចន្លោះពី ១៥ ទៅ ១៨ឆ្នាំ។

អាស៊ីសេរីព្យាយាមសុំការបំភ្លឺពីលោកស្រី ជូ ប៊ុនអេង អនុប្រធានគណៈកម្មការជាតិ ប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស នៃក្រសួងមហាផ្ទៃនៅថ្ងៃពុធម្សិលមិញនេះ ប៉ុន្តែទូរស័ព្ទចូលជាច្រើនដង មិនមានអ្នកទទួល។

អ្នកស្រី មាស សាអ៊ីម បន្ថែមទៀតថា សព្វថ្ងៃមានស្ត្រីខ្មែរប្រមាណ ១០នាក់ ជាជនរងគ្រោះនៃការ ជួញដូរមនុស្ស ដែលកំពុងជាប់ផុងនៅប្រទេសចិនមិនទាន់មានការជួយសង្គ្រោះបាននៅឡើយ៕

## ក្មេងស្រីអាយុ១៣ឆ្នាំម្នាក់មកជួបជុំគ្រួសារវិញ ក្រោយរងការរំលោភបំពានពីប្តីជនជាតិចិន

https://www.rfa.org/khmer/news/ ដោយ អូន ភាព 2019-11-13

ជនរងគ្រោះនៃការជួញដូរផ្លូវភេទ នៅប្រទេសចិនបានវិលត្រឡប់មកជួបជុំគ្រួសាររបស់នាងវិញហើយ បន្ទាប់ពីនាងបានស៊ូទ្រាំនឹងការរំលោភបំពានពីសំណាក់ជនជាតិចិនពីរនាក់។ សង្គមស៊ីវិលបញ្ជាក់ថា សព្វថ្ងៃមានស្ត្រីខ្មែរច្រើននាក់បានចាញ់បោកមេខ្យល់យកទៅប្រទេសចិន ក្រោមរូបភាពអាពាហ៍ពិពាហ៍ ប៉ុន្តែរដ្ឋាភិបាលយឺតយ៉ាងក្នុងការសង្គ្រោះពួកគេ។

ក្មេងស្រីជំទង់ជនជាតិខ្មែរអាយុ ១៣ឆ្នាំ បានវិលត្រឡប់មកជួបជុំគ្រួសាររបស់នាងវិញកាលពីសប្តាហ៍មុន បន្ទាប់ពីនាងត្រូវបានរំលោភបំពាន និងធ្វើទុក្ខទោសពីសំណាក់ប្តីពីរនាក់របស់នាងអស់រយៈពេល៨ខែ។ សារព័ត៌មានប្រចាំថ្ងៃរបស់ចិន South Morning Post បានដកស្រង់ព័ត៌មានចិនក្នុងស្រុក បានចេញផ្សាយកាលពីថ្ងៃទី១១ វិច្ឆិកា ថា ក្មេងស្រី ជាជនរងគ្រោះរូបនេះ បានភៀសខ្លួនចេញពីផ្ទះរបស់បុរសទី២ នៅក្នុងស្រុក យ៉ាងស៊ីន ខេត្តហ៊ូប៉ី កាលពីដើមខែតុលាឆ្នាំនេះ ហើយបានអំពាវនាវដល់អ្នកធ្វើដំណើរឆ្លងកាត់ឱ្យជួយសង្គ្រោះនាង។ កាសែតបន្តថា បន្ទាប់មកនាងត្រូវបានប៉ូលិសក្នុងស្រុក និងមន្ត្រីស្ថានទូតកម្ពុជានៅទីក្រុងប៉េកាំង បានជួយនាងឱ្យវិលត្រឡប់មកប្រទេសកម្ពុជាវិញ ហើយបានជួបជុំគ្រួសាររបស់នាងកាលពីសប្តាហ៍មុន។

ក្មេងស្រីបានប្រាប់ប៉ូលិសតាមរយៈអ្នកបកប្រែថា មេខ្យល់ម្នាក់បាននាំនាងទៅប្រទេសចិននៅខែកុម្ភៈ ដោយសន្យាថា នាងអាចរៀបការជាមួយបុរសល្អម្នាក់ និងបង្រៀនភាសាចិនដល់នាង និងជួយនាងរកការងារធ្វើ ប៉ុន្តែនាងត្រូវប្តីនាងធ្វើបាបវិញ។ ក្មេងស្រីបានឆ្លងកាត់ព្រំដែនក្នុងប្រទេសចិនហើយ បានទៅដល់ផ្ទះបុរសម្នាក់នៅក្នុងស្រុកយ៉ាងស៊ីន ជាកន្លែងដែលនាងបានទទួលរងនូវការរំលោភបំពានលើរាងកាយ និងពាក្យសំដីរយៈពេល ៦ខែ ពីបុរសនោះ និងក្រុមគ្រួសាររបស់គាត់។ នាងបាននិយាយថា នាងបានចាកចេញពីបុរសទីមួយនោះ ហើយបានជួបបុរសម្នាក់ទៀតជាប្តីទី២នៅក្នុងស្រុកតែមួយ តាមរយៈអ្នកដែលនាងបានជួបតាមអ៊ីនធឺណិត ប៉ុន្តែនាងត្រូវបានគេរំលោភបំពានម្តងទៀត។

អនុប្រធានផ្នែកស្ត្រី និងកុមារនៃសមាគមអាដហុក (Adhoc) អ្នកស្រី មាស សាអ៊ីម ធ្លាប់បានប្រាប់អាស៊ីសេរីថា មានស្ត្រីខ្មែរជាច្រើននាក់ត្រូវបានចាញ់បោកមេខ្យល់ទៅរៀបការនៅប្រទេសចិន ប៉ុន្តែរដ្ឋាភិបាលមិនមានចំណាត់ការក្នុងការសង្គ្រោះស្ត្រីដែលកំពុងរងគ្រោះនៅឡើយទេ។ អ្នកស្រីថា ស្ត្រីរងគ្រោះមួយចំនួនត្រូវបានបាត់បង់ព័ត៌មានក្នុងការទាក់ទងនៅក្នុងប្រទេសចិន បើទោះបីដឹងទីតាំងស្នាក់នៅរបស់ជនរងគ្រោះក៏ដោយ គឺមិនអាចសង្គ្រោះបានទាន់ពេលនៅឡើយ។ អ្នកស្រីបញ្ជាក់ថា មេខ្យល់បានប្រើល្បិចកលច្រើននៅក្នុងការនាំស្ត្រីខ្មែរទៅប្រទេសចិន ដូចជាតាមផ្លូវគោកជាដើម ហើយច្រករបៀងមួយចំនួនមានអំពើពុករលួយកើតឡើងផងដែរ ទើបធ្វើឱ្យមេខ្យល់អាចនាំស្ត្រីខ្មែរទៅប្រទេសចិនបាន៖ «ខ្ញុំគិតថា រដ្ឋាភិបាលមិនមែនមិនដឹងទេ លោកដឹង ប៉ុន្តែបញ្ហាត្រង់ថា ច្បាប់នៅស្រុកចិន និងច្បាប់នៅស្រុកខ្មែរ ការបកស្រាយរបស់គាត់ផ្សេងគ្នា ហើយយន្តការពិតប្រាកដនៅក្នុងការការពារស្ត្រីរងគ្រោះដែលត្រូវបានគេជួញដូរពិតប្រាកដនៅស្រុកចិននោះ គឺអត់ត្រូវបានដោះស្រាយពេញលេញនៅឡើយ»។ អ្នកស្រីបន្តថា យន្តការរបស់កម្ពុជានៅមានកំរិតក្រោមប្រទេសផ្សេងៗក្នុងតំបន់អាស៊ាន ហើយចំពោះប្រជាពលរដ្ឋដែលងាយរងគ្រោះមានកម្ពុជា ឡាវ និងភូមា គឺជាប្រទេសដែលងាយរងគ្រោះជាងគេនៅក្នុងការបញ្ជូនពលករទៅខាងក្រៅប្រទេស៖ «រូបភាពពីខ្មែរទៅគឺឆបោក និងជួញដូរ ប៉ុន្តែច្បាប់មិនគិតថា ជាការរៀបអាពាហ៍ពិពាហ៍ នៅមានស្ត្រីច្រើនដែលកំពុងរងគ្រោះ ហើយកំពុងបាត់ដំណឹងទាក់ទងអត់បាន ព្រោះយើងអត់ដឹងច្បាស់ ហើយជនរងគ្រោះមួយភាគតូចដែលយើងនៅទាក់ទងបាននោះ ក៏មិនទាន់បានសង្គ្រោះទាន់ពេលនៅឡើយ»។ អ្នកស្រី មាស សាអ៊ីម បន្តថា សព្វថ្ងៃមានស្ត្រីខ្មែរប្រមាណ ១០នាក់ ជាជនរងគ្រោះនៃការជួញដូរមនុស្សដែលកំពុងរងគ្រោះនៅប្រទេសចិន ហើយមិនទាន់មានការសង្គ្រោះនៅឡើយ។

របាយការណ៍ក្រសួងមហាផ្ទៃបានឱ្យដឹងថា ក្នុងរយៈពេល ៦ខែដើមឆ្នាំនេះ ប៉ូលិសបានជួយសង្គ្រោះជនរងគ្រោះ ២៦៣នាក់ ពីការរំលោភផ្លូវភេទ ដែលមានការកើនឡើង ១៥០ភាគរយ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ របាយការណ៍បានបញ្ជាក់ថា ក្នុងចំណោមករណីទាំងនោះមានកុមារចំនួន ៧០នាក់ដែលមានអាយុក្រោម១៥ឆ្នាំ មានជនរងគ្រោះចំនួន ៣១នាក់ ដែលមានអាយុចន្លោះពី ១៥ ទៅ ១៨ឆ្នាំ៕

## ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០១៩

## ក្រុមមេដឹកនាំអាស៊ាន ដាក់ចេញវិធានការអាទិភាពលប់បំបាត់គ្រប់ទម្រង់នៃអំពើកេងប្រវ័ញ្ច និងរំលោភបំពានកុមារនៅលើអ៊ីនធឺណិត

https://www.rfa.org/khmer/ ដោយ មាន ឫទ្ធិ 2019-11-04

ក្រុមមេដឹកនាំអាស៊ាន ប្រកាសដាក់ចេញវិធានការអាទិភាព ដើម្បីរួមគ្នាលប់បំបាត់គ្រប់ទម្រង់នៃអំពើកេងប្រវ័ញ្ច និងរំលោភបំពានកុមារនៅលើបណ្ដាញអ៊ីនធឺណិត។ វិធានការជាអាទិភាពទាំងនោះ រួមមានការបង្កើតក្របខណ្ឌច្បាប់ថ្នាក់ជាតិនៅតាមបណ្ដារដ្ឋសមាជិកអាស៊ាន ដើម្បីកែលម្អស្តង់ដារ និងគោលនយោបាយគាំពារកុមារ ពីអំពើកេងប្រវ័ញ្ច និងរំលោភបំពានគ្រប់ទម្រង់នៅលើបណ្ដាញអ៊ីនធឺណិត ការពង្រឹងការអនុវត្តច្បាប់ ព្រមទាំងការជំរុញឲ្យមានឡើងនូវការបង្កើតអង្គភាពជំនាញថ្នាក់ជាតិ ដើម្បីដឹកនាំ និងសហការស៊ើបអង្កេតសំណុំរឿង ទាក់ទងនឹងករណីបទល្មើសទាំងនេះ។

ការប្រកាសដាក់ចេញជាវិធានការអាទិភាព ដើម្បីទប់ស្កាត់បញ្ហាកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទគ្រប់ទម្រង់ ចំពោះកុមារនៅលើបណ្ដាញអ៊ីនធឺណិតនេះធ្វើឡើងខណៈក្រុមមេដឹកនាំអាស៊ានចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៥ និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងបាងកក ប្រទេសថៃ ពីថ្ងៃទី២ ដល់ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៩ នេះ។

សេចក្ដីថ្លែងការណ៍រួមរបស់ក្រុមមេដឹកនាំអាស៊ានទាំង ១០ប្រទេស ជំរុញឲ្យមានការពង្រឹងយន្តការប្រមូលទិន្នន័យតាមដាន និងរាយការណ៍ពាក់ព័ន្ធនឹងសម្ភារៈនានា ដែលចាត់ទុកថា ចូលរួមរំលោភបំពានផ្លូវភេទកុមារនៅលើ

បណ្ដាញអ៊ីនធឺណិត។ ពួកគេក៏ចង់ឃើញឲ្យមានការកែលម្អកម្មវិធីសិក្សាថ្នាក់ជាតិ និងតាមសាលារៀន ដើម្បីលើកកម្ពស់ការយល់ដឹងអំពីអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារ ក្នុងគ្រប់ទម្រង់នៅលើបណ្ដាញអ៊ីនធឺណិត។ ក្រុមមេដឹកនាំអាស៊ាន កត់សម្គាល់ថា ភាពជឿនលឿនយ៉ាងឆាប់រហ័ស និងការរីកសាយភាយនៃវិស័យអ៊ីនធឺណិត និងបច្ចេកវិជ្ជានៃការប្រាស្រ័យទាក់ទង កំពុងធ្វើឲ្យកុមារកាន់តែច្រើនឡើងៗ ប្រឈមនឹងភាពងាយរងគ្រោះទៅនឹងទម្រង់នៃការផលិត និងចែកចាយសម្ភារៈរំលោភបំពានផ្លូវភេទកុមារ និងទម្រង់ដទៃទៀត នៃអំពើកេងប្រវ័ញ្ចលើកុមារនៅតាមបណ្ដាញអ៊ីនធឺណិត ដែលគ្មានព្រំដែនកំណត់៕

## អង្គការសហប្រជាជាតិអំពាវនាវជាថ្មីឲ្យកម្ពុជាលុបចោលទោសឧក្រិដ្ឋសម្រាប់ស្ត្រីពពោះជំនួស

https://khmer.voanews.com/ 13 វិច្ឆិកា 2019

ភ្នំពេញ៖ អង្គការសហប្រជាជាតិបានអំពាវនាវឲ្យប្រទេសកម្ពុជាលុបចោលការសម្រេចរបស់ខ្លួនដែលចាត់ទុកការពពោះជំនួសថាជាបទឧក្រិដ្ឋ និងបានស្នើរដ្ឋាភិបាលកម្ពុជាឲ្យធានាថា សំណើច្បាប់នោះនឹងមិនដាក់ទោសឧក្រិដ្ឋចំពោះស្ត្រីដែលពពោះជំនួសគេនោះទេ។ នៅក្នុងការសង្កេតចុងក្រោយរបស់ខ្លួនដែលបានធ្វើឡើងកាលពីថ្ងៃសុក្រសប្ដាហ៍មុន គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកការលុបបំបាត់ការរើសអើងស្ត្រីហៅកាត់ថា CEDAW បានប្រឆាំងទៅនឹងការឃាយី និងការរើសអើងស្ត្រីដែលនៅតែកើតមាននៅក្នុងប្រទេសកម្ពុជា។ ក្ដីបារម្ភមួយក្នុងចំណោមក្ដីបារម្ភនានា ដែលរបាយការណ៍របស់គណៈកម្មាធិការអង្គការសហប្រជាជាតិនេះ បានលើកឡើងគឺការណ៍ដែលប្រទេសកម្ពុជាចាត់ទុកការពពោះជំនួសថាជាទោសឧក្រិដ្ឋ។ ការពពោះជំនួសកាលពីប៉ុន្មានឆ្នាំកន្លងមក បានបង្កឲ្យមានការរិះគន់ពីអន្តរជាតិ ដោយកុមារត្រូវបានលក់ឲ្យឪពុកម្ដាយបរទេស។ ស្ត្រីដែលពពោះជំនួសជារឿយៗគឺជាជនរងគ្រោះនៃការកេងប្រវ័ញ្ច។ នេះបើយោងតាមការបញ្ជាក់របស់អ្នកតាមដានស្ថានការណ៍នានា។ តាំងពីការពពោះជំនួសនេះត្រូវបានចាត់ទុកថាខុសច្បាប់កាលពីខែតុលា ឆ្នាំ ២០១៦ គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកការលុបបំបាត់ការរើសអើងស្ត្រី បានបញ្ជាក់ថា ស្ត្រីពពោះជំនួសគេជាង ៦០ នាក់ ត្រូវបានចាប់ខ្លួន និងអាចប្រឈមនឹងនីតិវិធីព្រហ្មទណ្ឌ។ ស្ត្រីទាំងនេះត្រូវបានដោះលែងនៅក្រោមលក្ខខណ្ឌដែលតម្រូវឲ្យស្ត្រីទាំងនោះចិញ្ចឹមកូនដែលកើតមករហូតដល់អាយុ ១៨ ឆ្នាំ។

របាយការណ៍នេះបានសរសេរដូច្នេះថា៖ «គណៈកម្មាធិការ [អង្គការសហប្រជាជាតិ] មានការព្រួយបារម្ភជាពិសេសថា កាតព្វកិច្ចដូចនេះបង្កើតឲ្យមានបន្ទុកផ្នែកហិរញ្ញវត្ថុ និងផ្នែកផ្លូវចិត្តបន្ថែមទៀតលើស្ត្រីដែលកំពុងស្ថិតក្នុងស្ថានការណ៍យ៉ាប់យ៉ឺន ដែលបណ្ដាលឲ្យពួកគេពពោះជំនួសគេ។ ហើយពួកគេប្រឈមនឹងការរើសអើង និងការមាក់ងាយពីក្រុមគ្រួសារ និងសហគមន៍ដែលពួកគេរស់នៅ ដោយសារតែធ្វើជាស្ត្រីពពោះជំនួសគេនេះ»។ អង្គការសហប្រជាជាតិអំពាវនាវឲ្យរដ្ឋាភិបាលកម្ពុជាលុបចោលការសម្រេចរបស់ខ្លួនកាលពីខែតុលា ឆ្នាំ ២០១៦ និងបញ្ចប់នូវការអនុវត្តដែលអនុញ្ញាតឲ្យមានការដោះលែងស្ត្រី ប្រសិនបើស្ត្រីទាំងនោះចិញ្ចឹមកូនដែលកើតមកពីការពពោះជំនួសនេះជាកូនរបស់ខ្លួន។

ប៉ុន្តែលោកស្រី ជូរ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជាបានអះអាងថា សហគមន៍អន្តរជាតិជួនកាលមិនយល់អំពីបរិបទក្នុងប្រទេសនោះទេ។ លោកស្រីបានថ្លែងយ៉ាងដូច្នេះថា៖ «ពេលខ្លះ អ្នកនៅក្រៅប្រទេសមិនយល់ពីស្ថានភាពនៅក្នុងប្រទេសកម្ពុជាទេ ហើយប្រហែលជាមិនយល់អំពីបទឧក្រិដ្ឋ មូលហេតុដែលនាំឲ្យមានបទឧក្រិដ្ឋកើតឡើង និងផលប៉ះពាល់មកលើប្រជាពលរដ្ឋរបស់យើងនោះទេ។ ពេលខ្លះ ពួកគេផ្ដោតតែលើសិទ្ធិរបស់ស្ត្រី ប៉ុន្តែពួកគេមិនផ្ដោតទៅលើសិទ្ធិរបស់កុមារនោះទេ»។ លោកស្រីមានប្រសាសន៍ថា ស្ត្រីពពោះជំនួសគេទាំងអស់ដែលត្រូវបានចាប់ខ្លួន ត្រូវបានដោះលែងពីពន្ធនាគារវិញហើយ ប៉ុន្តែពួកគេនៅស្ថិតក្រោមការឃ្លាំមើលរបស់តុលាការដោយមិនមានកាលកំណត់។

លោកស្រី ប៊ុនអេង បានមានប្រសាសន៍ថា សេចក្តីព្រាងច្បាប់នេះនឹងត្រូវលើកយកមកពិភាក្សាជាមួយនឹងភាគីពាក់ព័ន្ធទាំងអស់នៅដើមឆ្នាំ២០២០។ ក្រោពីដាក់ឲ្យការពពោះជំនួស ជារឿងខុសច្បាប់កាលពីឆ្នាំ២០១៦ រដ្ឋាភិបាលក៏បានធ្វើសេចក្តីព្រាងច្បាប់មួយដើម្បីដាក់កំណត់ពីការដាក់ពិន័យនិងបង្កើតបទបញ្ញត្តិនៅក្នុងឯកសារច្បាប់ដាច់ដោយឡែកមួយផងដែរ។

គណៈកម្មាធិការ CEDAW បានឲ្យដឹងថា រដ្ឋាភិបាលបានធានាថា ច្បាប់ថ្មីនេះនឹង«មិនដាក់ទោសឧក្រិដ្ឋឬការពិន័យផ្នែករដ្ឋបាលណាមួយទៅលើស្ត្រីដែលពពោះជំនួសនោះទេ។ បន្ថែមពីលើនេះទៀត ច្បាប់គួរតែ«យកចិត្តទុកដាក់ទៅលើវិសមភាពនៃទំនាក់ទំនងរវាងភាគីពាក់ព័ន្ធទាំងអស់នៅក្នុងការពពោះជំនួសនេះ»។

លោកស្រី ចក់ សុភាព នាយិកានៃមជ្ឈមណ្ឌលកម្ពុជាសម្រាប់សិទ្ធិមនុស្ស បានពន្យល់ថា ស្ត្រីជាច្រើនត្រូវបានបង្ខំឲ្យពពោះជំនួសគេ។ អ្នកស្រី ចក់ សុភាព បានសរសេរនៅក្នុងអ៊ីមែលមួយផ្ញើមកកាន់ VOA ថា៖ «ស្ត្រីដែលពពោះជំនួសនៅក្នុងប្រទេសកម្ពុជា ភាគច្រើនជួបនឹងការលំបាកផ្នែកសេដ្ឋកិច្ចនិងនយោបាយ ដែលធ្វើឲ្យពួកគេសម្រេចចិត្តពពោះជំនួស។ យើងបានឃើញរយៈពេលមួយឆ្នាំមកនេះ ស្ត្រីដែលពពោះជំនួសត្រូវបានប៉ូលិសវាយឆ្មក់ចាប់ខ្លួន ចោទប្រកាន់ពីបទជួញដូរមនុស្ស និងត្រូវបានឃុំខ្លួនដោយគ្មានតម្លាភាពពីអាជ្ញាធរ មិនមានការគិតគូរពីសុខុមាលភាពរបស់ពួកគេ ឬទារកដែលពួកគេបង្កើតនោះទេ»។

លោកស្រី រស់ សុភាព នាយិកានៃអង្គការយេនឌ័រនិងអភិវឌ្ឍន៍សម្រាប់កម្ពុជា បានលើកឡើងពីការព្រួយបារម្ភស្រដៀងគ្នានេះ។ លោកស្រីបានថ្លែងថា ថ្វីត្បិតតែយើងមានការព្រួយបារម្ភអំពីសីលធម៌និងវប្បធម៌ក៏ពិតមែន ក៏ប៉ុន្តែស្ត្រីដែលពពោះជំនួសមិនគួរត្រូវជាប់ពន្ធនាគារនោះទេ។ លោកស្រីបានថ្លែងយ៉ាងដូច្នេះថា៖ «សម្រាប់ខ្ញុំ ស្ត្រីទាំងអស់នោះមិនមែនជាឧក្រិដ្ឋជននោះទេ។ ពួកគេគ្រាន់តែជាជនរងគ្រោះប៉ុណ្ណោះ»។ លោកស្រី រស់ សុភាព បាននិយាយទៀតថា ជាជាងបង្ខំស្ត្រីដែលប្រឈមនឹងបញ្ហាសេដ្ឋកិច្ចរួចទៅហើយឲ្យចិញ្ចឹមបីបាច់កូននោះ រដ្ឋាភិបាលគួរតែធានាដល់សុខុមាលភាពរបស់កុមារ។ លោកស្រីបានថ្លែងយ៉ាងដូច្នេះថា៖ «ស្ត្រីពពោះជំនួសទាំងនោះមិនមានលទ្ធភាពដើម្បីចិញ្ចឹមកូនៗទាំងនោះទេ។ រដ្ឋាភិបាលគួរតែមានយុទ្ធសាស្ត្រមួយដើម្បីដោះស្រាយបញ្ហានេះ»។

ក៏ប៉ុន្តែលោកស្រី ប៊ុនអេង បានថ្លែងថា ចាប់តាំងពីការចាត់ទុកការពពោះជំនួសជារឿងខុសច្បាប់មក ស្ត្រីទាំងឡាយដឹងយ៉ាងច្បាស់ថា ពួកគេកំពុងតែប្រព្រឹត្តបទឧក្រិដ្ឋ ហើយពួកគេត្រូវតែទទួលខុសត្រូវចំពោះរឿងនេះ៕

## ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០១៩

## វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ឃុំ-សង្កាត់/ក្រុង-ស្រុក

https://www.facebook.com/deputygovernoryousophear/ លេខាធិការដ្ឋាន គខបជសៀមរាប 15-11-2019

ខេត្តសៀមរាប៖ ស្រុកជីក្រែង ថ្ងៃព្រហស្បតិ៍ ទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រុមការងារលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ឃុំ-សង្កាត់/ក្រុង-ស្រុក និងអ្នកពាក់ព័ន្ធ អំពីការអនុវត្តតួនាទីភារកិច្ចច្បាប់ពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពានលើកុមារ និងពង្រឹងលើកិច្ចសហប្រតិបត្តិការក្នុងការផ្តល់សេវាជួយជនរងគ្រោះឲ្យបានសមស្របនិងមានប្រសិទ្ធិភាព នៅបន្ទប់ប្រជុំរដ្ឋបាលស្រុកជីក្រែង ដោយមានការអញ្ជើញចូលរួមពី គណៈអភិបាល ស្រុក ប្រធានអនុប្រធានការិយាល័យជុំវិញស្រុក មេឃុំ ស្មៀន អ.ក.ន.ក អធិការ កងរាជអាវុធហត្ថ ប្រជាការពារ មណ្ឌលសុខភាពនាយប៉ុស្តិ៍នាយកសាលា យុវជន និងអង្គការដៃគូ សរុប ៧២នាក់។

## ឃាត់ខ្លួនមេខ្យល់ម្នាក់ ដែលបានធ្វើសកម្មភាព នាំមនុស្សឆ្លងដែនចូលទៅប្រទេសថៃ ដោយខុសច្បាប់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែតនាវេលាម៉ោង០៩ និង៤៥នាទី ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩ បានធ្វើការឃាត់ខ្លួនមេខ្យល់ម្នាក់ ដែលបានធ្វើសកម្មភាព នាំមនុស្សឆ្លងដែនចូលទៅប្រទេសថៃ ដោយខុសច្បាប់។ នគរបាលអន្តោប្រវេសន្តបានឲ្យដឹងថា មេខ្យល់នេះ មានឈ្មោះ ទ្រី គារ ភេទប្រុស អាយុ ៣១ឆ្នាំ មុខរបរ និងទីកន្លែងស្នាក់នៅ មិនពិតប្រាកដ រីឯជនរងគ្រោះមានឈ្មោះ ធឿង សុផាន ភេទស្រី អាយុ ២៧ឆ្នាំ ស្រុកកំណើតភូមិដូវនំ ឃុំមានជ័យ ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ ជនរងគ្រោះ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ ឲ្យគាត់យល់ពីច្បាប់ នៃការឆ្លងដែន និងជួយសម្រួលប្រថាប់ត្រា លិខិតឆ្លងដែនទាំងខ្មែរ-ថៃ ឲ្យរូបគាត់បានធ្វើដំណើរចូលទៅប្រទេសថៃ ដោយស្របច្បាប់ ចំណែកជនសង្ស័យ បានធ្វើការប្រគល់-ទទួល ជូនទៅកម្លាំង នៃអធិការដ្ឋាននគរបាលក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីអនុវត្តបន្តតាមនីតិវិធី៕

## ស្រ្តីពលករខ្មែរ ០១នាក់ ត្រូវបុរសសញ្ជាតិភូមា វាយស្លាប់នៅមុខវត្តថៃយ៉ាងអាណោចអាធ័ម

https://www.facebook.com/prakpheaktraofficial/ Prak Pheaktra album: NEWS LABOUR. 15/11/19

ប្រភពពីៈសមត្ថកិច្ចខេត្តអាងថង ប្រទេសថៃ បានអោយដឹងថា មានករណីស្រ្តីមេម៉ាយ ០១នាក់ ត្រូវបុរសជនជាតិ ភូមាវាយសម្លាប់ នៅមុខវត្តមួយកន្លែងស្ថិតនៅខេត្តអាងថង។ ហេតុការណ៍ខាងលេីនេះបានកើតឡើងនៅថ្ងៃព្រហស្បតិ៍ ទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្ថិតនៅមុខផ្លូវចូលវត្តរាជាគ្រូថាណារ៉ាម ស្ថិតនៅក្នុងភូមិ៤ សង្កាត់ហួតាក់ផាន ស្រុកវីឆៃធាន ខេត្តអាងថង ប្រទេសថៃ ស្ត្រីរងគ្រោះ ដែលស្លាប់បាត់បង់ជីវិតមានឈ្មោះ អ៊ុយ លឹម ភេទស្រី អាយុ ៤៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាពលករធ្វើការសំណង់នៅក្បែរកន្លែងកើតហេតុ។

ចំណែកឯជនបង្កហេតុ មានឈ្មោះ អាវ ភេទប្រុស អាយុ ៤៧ឆ្នាំ សញ្ជាតិភូមា មុខរបរជាកម្មករសំណង់ធ្វើការជាមួយជនរងគ្រោះ ។ ប្រភពពីកន្លែងកើតហេតុបញ្ជាក់ថា រឿងហេតុដែលឡើងដោយសារ តែជនបង្កហេតុឈ្មោះ អាវ បានលួចចាប់ចិត្តស្រលាញ់ស្ត្រីរងគ្រោះ ប៉ុន្តែស្ត្រីរងគ្រោះ មិនបានស្រលាញ់ នោះទេ ដោយស្ត្រីរងគ្រោះបានស្រលាញ់ រស់នៅជាមួយបុរសឈ្មោះ ស អាយុ ២៧ឆ្នាំ ត្រូវជាមិត្តរួមការងារនិងគ្នា។

# ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០១៩

## សម្តេចតេជោបកស្រាយ និងពន្យល់ពីការខិតខំ របស់រាជរដ្ឋាភិបាល ក្នុងការរកទីផ្សារការងារ និង បញ្ជូនពលករខ្មែរ ទៅធ្វើការនៅក្រៅប្រទេស

https://dap-news.com/national/ Posted on November 18, 2019

**ភ្នំពេញ៖** ក្នុងឱកាសអញ្ជើញ ប្រគល់សញ្ញាបត្រដល់និស្សិត សាកលវិទ្យាល័យធនធានមនុស្ស នៅព្រឹកថ្ងៃទី១៨ វិច្ឆិកានេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានធ្វើការបកស្រាយ និងពន្យល់ពីការខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាល ក្នុងការរកទីផ្សារការងារ និងបញ្ជូនពលករខ្មែរ ទៅធ្វើការនៅក្រៅប្រទេស ។

# ប្រសាសន៍សំខាន់ៗរបស់សម្តេចតេជោ ហ៊ុន សែន អញ្ជើញប្រគល់សញ្ញាបត្រជូននិស្សិតសាកលវិទ្យាល័យធនធានមនុស្សជិត២ពាន់នាក់

http://www.freshnewsasia.com/ 2019-11-18

**(ភ្នំពេញ)៖** នាព្រឹកថ្ងៃចន្ទ ៧រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០១៩នេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានអញ្ជើញជាអធិបតីប្រគល់សញ្ញាបត្រជូននិស្សិតសាកលវិទ្យាល័យធនធានមនុស្សសរុប១,៩៥៨នាក់ បន្ទាប់ពីពួកគេបានបញ្ចប់ការសិក្សាដោយជោគជ័យ។ ពិធីប្រគល់សញ្ញាបត្រនេះ ធ្វើឡើងនៅវិទ្យាស្ថានជាតិអប់រំ។

**ខាងក្រោមនេះជាប្រសាសន៍របស់សម្តេចតេជោ ហ៊ុន សែន៖**

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ការអនុញ្ញាតឱ្យវិស័យឯកជនចូលរួមផ្តល់ការអប់រំ គឺជាការដោះស្រាយបញ្ហាមួយចំគោលដៅ និងចំបញ្ហា។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ការអនុញ្ញាតឱ្យគ្រឹះស្ថានឧត្តមសិក្សារបស់រដ្ឋផ្តល់ការអប់រំបង់ថ្លៃអាចជួយឱ្យគ្រឹះស្ថានទាំងនោះអាចរស់បាន និងអភិវឌ្ឍន៍ខ្លួនឱ្យកាន់តែប្រសើរ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ការអនុញ្ញាតឱ្យវិស័យឯកជនចូលរួមអប់រំ និងឱ្យគ្រឹះស្ថានសិក្សាឧត្តមសិក្សាផ្តល់ការអប់រំបង់ថ្លៃ គឺជាជោគជ័យនៃគោលនយោបាយអប់រំរបស់រាជរដ្ឋាភិបាល។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា កម្ពុជាកំពុងមានការអភិវឌ្ឍ បើគ្មានការអភិវឌ្ឍការបណ្តុះបណ្តាលមិនមានប្រយោជន៍នោះឡើយ។ ពេលនិស្សិតបញ្ចប់ការសិក្សានឹងអត់មានការងារធ្វើ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ប្រទេសវៀតណាម កាលពីមុនមិនរីកចម្រើន និស្សិតបញ្ចប់ការងារសិក្សាគ្មានការងារធ្វើ។ ក្រោយពេលផ្លាស់ប្តូរនយោបាយសេដ្ឋកិច្ចធ្វើឱ្យវៀតណាមរីកចម្រើន ជាមួយធនធានមនុស្សដែលមានស្រាប់នោះ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ជំនាញវិជ្ជាជីវៈនៅកម្ពុជាមិនសូវមានអ្នកចាប់អារម្មណ៍ និងមិនចង់ធ្វើ ខណៈជំនាញវិជ្ជាជីវៈមានសារៈសំខាន់សម្រាប់សង្គម។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា រាជរដ្ឋាភិបាលកម្ពុជា បានប្រឹងប្រែងណាស់ក្នុងការរកទីផ្សារនៅក្រៅប្រទេស តែបែរជាត្រូវក្រុមប្រឆាំងរិះគន់ទៅវិញ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ក្នុងដំណើរទៅកាន់ប្រទេសកូរ៉េខាងត្បូងខាងមុខនេះ សម្តេចនឹងលើកឡើងពីបញ្ហាបញ្ជូនពលករទៅធ្វើការនៅក្នុងប្រទេសនេះ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា បើមិនចង់ឱ្យប្រជាពលរដ្ឋទៅធ្វើការនៅក្រៅប្រទេសងាយស្រួលទេ គឺបញ្ចប់កិច្ចព្រមព្រៀងបញ្ជូនពលករជាមួយប្រទេស បញ្ជូនពលករទៅនោះជាការស្រេចហើយ ប៉ុន្តែមិនចង់ធ្វើបែបនេះទេគឺប៉ះពាល់ដល់ពលករណាស់។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ក្នុងដំណើរទៅកាន់ប្រទេសកូរ៉េខាងត្បូង សម្តេចនឹងជួបជាមួយប្រធានាធិបតីកូរ៉េខាងត្បូង ដូច្នេះបើពលករនៅកូរ៉េមិនសប្បាយចិត្តនឹងធ្វើការនៅកូរ៉េ គ្រាន់តែសម្តេចបញ្ចប់កិច្ចព្រមព្រៀងបញ្ជូនពលករជាការស្រេចទៅហើយ។ សម្តេចតេជោ បានថ្លែងថា នេះគ្រាន់តែជាការវិភាគជូនពលករប៉ុណ្ណោះ តែរាជរដ្ឋាភិបាលមិនធ្វើដូច្នោះឡើយ ព្រោះពលរដ្ឋនឹងបាត់ចំណូល។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា កម្ពុជាទើបបញ្ជូនពលរដ្ឋទៅធ្វើការនៅកូរ៉េខាងត្បូង បានជាង ៥ម៉ឺននាក់ប៉ុណ្ណោះ ខណៈវៀតណាម និងថៃ បានបញ្ជូនប្រជាពលរដ្ឋទៅធ្វើការនៅកូរ៉េរាប់សិបម៉ឺននាក់។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា រាជរដ្ឋាភិបាលកំពុងប្រឹងប្រែងរកការងារនៅក្រៅប្រទេសជូនប្រជាពលរដ្ឋ។ ដូចជាស្នើឱ្យកូរ៉េខាងត្បូង និងជប៉ុន បង្កើនចំនួនកូតាសម្រាប់ពលករខ្មែរ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ក្នុងមួយឆ្នាំជួយដល់សាកលវិទ្យាល័យធនធានមនុស្សជាង ១០០លានរៀល ដើម្បីជួយដល់និស្សិតក្រីក្រ។
* សម្តេចតេជោ ហ៊ុន សែន ថ្លែងថាសង្គមមិនឈរនៅទ្រឹងនោះឡើយ គឺមានការវិវឌ្ឍន៍លឿនណាស់។ ក្នុងន័យនេះសម្តេចតេជោ ជំរុញឱ្យនិស្សិតបញ្ចប់ការសិក្សាប្រឹងប្រែងអភិវឌ្ឍន៍សមត្ថភាពខ្លួនបន្ត។
* សម្តេចតេជោ ហ៊ុន សែន បានខឹឱ្យទណ្ឌិត សម រង្ស៊ី ដែលចោទសម្តេចលួចកែសំបុត្រយន្តហោះរបស់ខ្លួន។ សម្តេចតេជោ បានថ្លែងខឹថា ពិភពលោកត្រូវប្រយ័ត្នចំពោះសមត្ថភាពរបស់សម្តេច ព្រោះសម្តេចអាចចូលទៅកែសំបុត្រយន្តហោះបាន។
* សម្តេចតេជោ ហ៊ុន សែន បានលើកឡើងថា បញ្ហាកម្រិតអន្តរជាតិទៅហើយទណ្ឌិត សម រង្ស៊ី ហ៊ានលើកយកមកបកស្រាយបោកប្រាស់ប្រជាពលរដ្ឋ។ ចុះទម្រាំការងារធម្មតាៗនៅក្នុងប្រទេសវិញ តើបុគ្គលនេះបោកប្រាស់ដូចម្តេចទៅ?
* សម្តេចតេជោ ហ៊ុន សែន បានថ្លែងបញ្ជាក់ថា តួនាទីរបស់សមាជិកឃុំ សង្កាត់របស់អតីតគណបក្សសង្គ្រោះជាតិគ្មានថ្ងៃទទួលបានវិញឡើយក្រោយបក្សរបស់ពួកគេត្រូវបានរំលាយកាលពីឆ្នាំ២០១៧។
* សម្តេចតេជោ បញ្ជាក់ថា ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិថ្មីនឹងធ្វើឡើងនៅខែឧសភា ឆ្នាំ២០២២ ខណៈការបោះឆ្នោតតំណាងរាស្ត្រនឹងធ្វើឡើងនៅខែកក្កដា ឆ្នាំ២០២៣។
* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ដំណើរការក្តីរបស់លោក កឹម សុខា មិនអាចប្រើរយៈពេលមួយថ្ងៃ ពីរថ្ងៃ មួយខែ ឬពីរខែនោះឡើយ គឺត្រូវប្រើរយៈពេលវែង។
* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ថ្ងៃ០៩ វិច្ឆិកា កន្លងទៅ អំបុក ២២៣តោនត្រូវបានបរិភោគ។ នេះរាប់តែតាមគោលដៅជួបជុំរៀបចំការហូបអំបុក មិនទាន់រាប់បញ្ចូលការហូបនៅតាមផ្ទះនៅឡើយនោះទេ។
* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ព្រឹត្តិការណ៍ហូបអំបុកកន្លងទៅ បានបង្ហាញពីស្មារតីរួមគ្នារបស់ប្រជាពលរដ្ឋក្នុងការរក្សាសន្តិភាព ការពារជាតិ សាសនា និងព្រះមហាក្សត្រ។
* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ទោះក្នុងតម្លៃណាក៏ដោយត្រូវតែរួមគ្នាថែរក្សាឱ្យបាននូវសុខសន្តិភាពនេះ។
* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា សម្តេចពិតជារីករាយឃើញសភាពការល្អប្រសើរនៃការប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែនាពេលកន្លងទៅនេះ។
* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ជិតឡើងប្រាក់បៀវត្សរ៍ទៀតហើយ គឺនៅខែមករា និងខែមេសា ឆ្នាំ២០២០ខាងមុខនេះ។
* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ទន្ទឹមនឹងការដំឡើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រាក់ឈ្នួលរបស់កម្មករ និយោជិតហើយនោះ ត្រូវប្រឹងប្រែងទប់តម្លៃទំនិញលើទីផ្សារមិនឱ្យឡើងថ្លៃផងដែរ ដើម្បីឱ្យមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ កម្មករ និយោជិត ទទួលបានជីវភាពប្រសើរពីការដំឡើងប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួលនេះ។
* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ដំណក់ប្រេងដាលើកដំបូងរបស់កម្ពុជានឹងទទួលបាននៅឆ្នាំ២០២០នេះ តែមិនទាន់បញ្ជាក់កាលបរិច្ឆេទជាក់លាក់នៅឡើយនោះទេ។
* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា កម្ពុជារករ៉ែធ្យូងថ្មនៅក្នុងខេត្តឧត្តរមានជ័យ ហើយនឹងបង្កើតជាកន្លែងផលិតថាមពលអគ្គិសនីតែម្តង។
* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ក្រៅពីរ៉ែប្រេង ធ្យូងថ្មហើយនោះ កម្ពុជានឹងមានការវិនិយោគលើរ៉ែមាសដោយក្រុមហ៊ុនអូស្ត្រាលី ដែលទទួលបានប្រាក់ចំណូលគួរសមផងដែរ។

* សម្តេចតេជោ ហ៊ុន សែន បានប្រកាសថា ចំណូលបានពីធនធានធម្មជាតិ នឹងចំណាយទៅលើហេដ្ឋារចនាសម្ព័ន្ធទាំងរឹង និងទន់ ពោលទាំងផ្លូវថ្នល់ ប្រឡាយទឹក និងការអប់រំ។

*សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា គយរកចំណូលលើសផែនការ ៧ ទៅ៨រយលានដុល្លារ ខណៈពន្ធដាររកចំណូលលើសផែនការ ៤ ទៅ៥រយលានដុល្លារ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ទោះបីចំណូលរកបានខ្ពស់យ៉ាងណាក៏ដោយ តែមិនមែនចេះតែចាយវាយនោះឡើយ គឺត្រូវសន្សំសំចៃថវិកាសម្រាប់ចំណាយលើតម្រូវការចាំបាច់។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា នៅឆ្នាំនេះរាជរដ្ឋាភិបាល បានចំណាយថវិកាសន្សំប្រមាណ១ពាន់លានដុល្លារ សម្រាប់វិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្តព្រះសីហនុ និងការទិញម៉ាស៊ីនភ្លើង៤០០មេហ្គាវ៉ាត់ និងចំណាយលើគម្រោងផ្សេងៗ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ទោះបីកាត់ EBA ក៏មិនធ្វើឱ្យរាជរដ្ឋាភិបាលលានអណ្តាតនោះឡើយ ព្រោះថវិកាចំណាយសម្រាប់ប្រាក់បៀវត្សរ៍មន្ត្រីរាជការមិនបានយកពី EBA ឡើយ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ចំណូលពន្ធបានពីការនាំចូលរថយន្ត និងម៉ូតូ មានជាង ៥០ភាគរយ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ពីមុនមានដីគ្មានអ្នកត្រូវការ តែឥឡូវមនុស្សដណ្តើមគ្នារកដី ដែលនេះបានមកពីកត្តាសន្តិភាព និងការអភិវឌ្ឍរបស់សង្គម។

* សម្តេចតេជោ ហ៊ុន សែន បានបញ្ចប់ការថ្លែងសុន្ទរកថានៅវេលាម៉ោង៩៖១១នាទីព្រឹកថ្ងៃដដែលនេះ។ សូមអរគុណចំពោះការទស្សនាផ្សាយផ្ទាល់តាមរយៈទូរទស្សន៍ព័ត៌មាន Fresh News។

## ពលករខ្មែរ ត្រូវយល់ឲ្យច្បាស់ រដ្ឋាភិបាល ជួយសម្រួលឲ្យពលករ បានចេញទៅបម្រើការងារ នៅប្រទេស ដើម្បីទទួលបានប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពគ្រួសារ

http://www.cen.com.kh/archives/ November 18, 2019

ភ្នំពេញ៖ សម្តេចនាយករដ្ឋមន្ត្រី បានប្រាប់ដល់បងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់ ដែលបានទៅបម្រើការការងារនៅក្រៅប្រទេសទាំងអស់ ត្រូវយល់ឲ្យបានច្បាស់ អំពីអ្វីដែលរាជរដ្ឋាភិបាលបានខិតខំធ្វើការចរចា ជាមួយបណ្តាប្រទេសផ្សេងៗ ដើម្បីជួយសម្រួលឲ្យពលករយើងបានចេញទៅបម្រើការងារនៅប្រទេសទាំងអស់នោះ ដើម្បីទទួលបានប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពគ្រួសារ។ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ប្រគល់សញ្ញាបត្រដល់និស្សិត នៃសាកលវិទ្យាល័យធនធានមនុស្សសរុបចំនួន១៩៥៨នាក់ បន្ទាប់ពីពួកគេបានបញ្ចប់ការសិក្សាដោយជោគជ័យ។ ពិធីប្រគល់សញ្ញាបត្រនេះ ធ្វើឡើងនៅវិទ្យាស្ថានជាតិអប់រំនៅព្រឹកថ្ងៃចន្ទទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយសម្តេចតេជោនាយករដ្ឋមន្ត្រី គឺបានខិតខំណាស់ក្នុងការផ្តល់ឱកាសការងារផ្សេងៗដល់យុវជនយើង ទាំងការងារក្នុងស្រុក និងក្រៅស្រុក ជាក់ស្តែងបច្ចុប្បន្ននេះ មានពលករយើងជាច្រើនបាន និងកំពុងបម្រើការងារនៅតាមបណ្តាប្រទេសមួយចំនួនហើយពួកគាត់កំពុងទទួលបានផលប្រយោជន៍យ៉ាងច្រើន ពីការងារទាំងអស់នោះផងដែរ។ ដូច្នេះបងប្អូនដែលបានបម្រើការការងារ នៅក្រៅប្រទេសទាំងអស់ ត្រូវយល់ឲ្យបានច្បាស់ អំពីអ្វីដែលរាជរដ្ឋាភិបាលបានខិតខំធ្វើការចរចាជាមួយបណ្តាប្រទេសផ្សេងៗ ដើម្បីជួយសម្រួលឲ្យពលករយើងបានចេញទៅបម្រើការងារនៅប្រទេសទាំងអស់នោះ ដើម្បីទទួលបានប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពគ្រួសារ។ សម្តេចតេជោនាយករដ្ឋមន្ត្រី បាននិងកំពុងខិតខំជំរុញការបង្កើតការងារក្នុងស្រុកទាក់ទាញវិនិយោគថ្មីៗនិងខិតខំស្វែងរកការងារក្រៅប្រទេស ជូនប្រជាពលរដ្ឋយើងជាបន្តបន្ទាប់។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ថា សម្តេចនៅតែបន្តផ្តល់ការឧបត្ថម្ភជាថវិកា និងអង្ករជាបន្តបន្ទាប់ទៀត ដល់និស្សិតក្រីក្រនៃសាកលវិទ្យាល័យធនធានមនុស្ស ក៏ដូចជាសាកលវិទ្យាល័យមួយចំនួនទៀត គឺក្នុង១

ខែ សម្ដេចតេជោបានឧបត្ថម្ភនូវអង្ករចំនួន២តោន និងថវិកាចំនួន៥លានរៀលផងដែរ សម្រាប់ផ្ដល់ជូនដល់និស្សិតក្រីក្រដែលកំពុងសិក្សាតាមបណ្ដាសាកលវិទ្យាល័យ និងវិទ្យាស្ថាននានា។ សម្ដេចតេជោ ហ៊ុន សែន ក៏បានជូនពរដល់និស្សិតជ័យលាភីដែលទទួលសញ្ញាបត្រនៅថ្ងៃនេះ សូមឲ្យទទួលបាននូវភាពជោគជ័យក្នុងការសិក្សា និងការងាររបស់ខ្លួនជាបន្តបន្ទាប់ទៀត៕ដោយៈកូឡាប

## ចោរលួចកូនបាត់២ថ្ងៃហើយ នៅតែរកមិនឃើញ, ឪពុកម្ដាយលើកដៃទទូចសុំការអន្តរាគមន៍ពីគ្រប់សមត្ថកិច្ច និងប្រជាពលរដ្ឋ

http://www.freshnewsasia.com/ 2019-11-16

**(ភ្នំពេញ)៖** គ្រួសារអ្នកស្រី លន ប៉ិ ត្រូវបាននារីម្នាក់លួចយកកូនស្រីពីផ្ទះបាត់ ដែលស្ថិតក្នុងភូមិផ្សារកំបូល សង្កាត់កំបូល ខេត្តពោធិ៍សែនជ័យ តាំងពីម៉ោង៨ព្រឹក ថ្ងៃទី១៥ ខែវិច្ឆិកា ម្សិលមិញ ហើយមកដល់ពេលនេះ នៅតែមិនទាន់រកឃើញនៅឡើយ ពួកគាត់បានលើកដៃទទូចសុំការអន្តរាគមន៍ ពីសមត្ថកិច្ចគ្រប់ច្រកល្ហក និងប្រជាពលរដ្ឋផងដែរ ប្រសិនបើឃើញក្មេងស្រីដូចក្នុងរូបភាពខាងក្រោម សូមមេត្តាជួយផ្ដល់ដំណឹងជូនគ្រួសារគាត់ផង។ បើតាមអ្នកស្រី លន ប៉ិ បានរៀបរាប់ប្រាប់អង្គភាពព័ត៌មាន Fresh News នាថ្ងៃទី១៦ ខែវិច្ឆិកានេះថា កូនរបស់អ្នកស្រីដែលត្រូវគេលួចនោះមានឈ្មោះ ប៊ុនថា សុពៀន អាយុ១ឆ្នាំ៩ខែ ត្រូវបាននារីម្នាក់លួចចេញពីផ្ទះរបស់អ្នកស្រីធៅៗតែម្ដង។ អ្នកស្រីបានបន្តថា ដំបូងឡើយ អ្នកស្រីបានជួលអ៊ំស្រីម្នាក់ឱ្យជួយមើលថែកូនរបស់អ្នកស្រី ពេលអ្នកស្រី និងស្វាមីទៅធ្វើការប្រកបការងារប្រចាំថ្ងៃ តែអ៊ំស្រីនោះមានធុរៈត្រូវចេញទៅស្រុកកំណើតប្រហែល ២-៣ថ្ងៃ ទើបត្រលប់មកវិញ អ្នកស្រីក៏បានរកនារីម្នាក់ទៀត អាយុប្រហែលជាង៣០ឆ្នាំ ឱ្យជួយមើលកូនជំនួសអ៊ំស្រី ដែលទៅស្រុកកំណើតនោះ។ ការងារមើលក្មេងស្រីនៅថ្ងៃដំបូង ត្រូវនឹងថ្ងៃទី១៤ ខែវិច្ឆិកា គឺប្រព្រឹត្តទៅធម្មតាទេ ដែលជាហេតុបង្ហាញការទុកដាក់ចំពោះនារីអ្នកមើលក្មេងខាងលើ ប៉ុន្តែចូលដល់ថ្ងៃទី២ ត្រូវនឹងថ្ងៃទី១៥ ម៉ោងប្រមាណ៨ព្រឹក ស្រាប់តែនារីចិត្តខ្មៅរូបនេះ លួចយកក្មេងស្រីកូនម្ចាស់ផ្ទះចេញទៅបាត់។

តាមការបញ្ជាក់បន្ថែមរបស់ អ្នកស្រី លន ប៉ិ បានឱ្យដឹងថា ក្នុងពេលបាត់កូនស្រី ក៏មានគេឃើញនារីខាងលើយកកូនរបស់អ្នកស្រី ទៅពពាយនាយលក់ នៅមណ្ឌលសុខភាពកំបូលដែរ ដោយកុហកថា ក្មេងស្រីនេះកូនរបស់ខ្លួន។ មានលោកគ្រូពេទ្យម្នាក់ បានឃើញនារីនោះពពាយនាយលក់ក្មេងស្រីនោះដែរ ដោយកើតចិត្តសង្ស័យ លោកគ្រូដដែលក៏ថតរូបភាព២ប៉ុស្តិ៍ ទុកក្នុងទូរស័ព្ទដៃរបស់គាត់។ លុះដល់ដឹងថា បាត់ក្មេងស្រី លោកគ្រូពេទ្យខាងលើក៏បានសួរ និងផ្ញើរូបដែលគាត់ថតបានបញ្ជូនមកម្ដាយក្មេងស្រី ដល់ពេលឃើញរូបភាពនោះហើយ ទើបដឹងថា ជាកូនរបស់អ្នកស្រីប្រាកដមែន។ ប៉ុន្តែទោះជាយ៉ាងណា អ្នកស្រី និងក្រុមគ្រួសារនៅមិនទាន់រកកូនស្រីរបស់ខ្លួនឃើញនៅឡើយទេ ខណៈលោកស្រីក៏បានរត់ទៅប្ដឹងសមត្ថកិច្ចរួចហើយ តែក៏នៅតែគ្មានតម្រុយទាល់តែសោះ។

និយាយពីសាវតាខ្លីរបស់នារីស៊ីឈ្នួលមើលកូនឱ្យអ្នកស្រី លន ប៉ិ៖ ដំបូលឡើយ នារីរូបនេះត្រូវប្ដីធ្វើបាបរហូតដល់លែងលះគ្នា ហើយបានរត់មកនៅភ្នំពេញ ក៏បានចូលធ្វើការជាមួយបងប្អូនជីដូនមួយរបស់អ្នកស្រី លន ប៉ិ។ ដោយឃើញដូច្នេះ អ្នកស្រីក៏កើតចិត្តអាណិតអាសូរ ហើយស្របពេលអ៊ំស្រី ដែលធ្លាប់ប់មើលកូនឱ្យអ្នកស្រីមានធុរៈទៅស្រុកកំណើរផងនោះ អ្នកស្រីក៏ហៅនារីខាងលើមកមើលកូន របស់អ្នកស្រីជំនួសអ៊ំចាស់សិនទៅ។ ប៉ុន្តែដូចពាក្យពោលថា មែន «ឈើកោងវល្លិព័ន្ធ មនុស្សខ្វាត់ព្រាត់កុំយកខ្លួនបៀត»។ ក្នុងនាមជាម្ដាយ និងក្រុមគ្រួសារដែលស្រលាញ់កូនស្រីស្មើជីវិត អ្នកស្រី លន ប៉ិ ក៏សូមលើកដៃប្រណមអំពាវនាវដល់សមត្ថកិច្ចគ្រប់ច្រកល្ហក សូមជួយអន្តរាគមន៍ចំពោះរឿងនេះផង ហើយក៏សូមទទូចដល់ប្រជាពលរដ្ឋផងដែរ ប្រសិនបើបានឃើញក្មេងស្រីដូចក្នុងរូបភាពខាងក្រោម សូមជួយផ្ដល់ដំណឹងតាមរយៈលេខទូរស័ព្ទ៖ 077 213 507 ដែលជាលេខទូរស័ព្ទរបស់អ្នកស្រី លន ប៉ិ ផ្ទាល់៕

## ពង្រឹងសមត្ថភាពមន្ត្រីនគរបាល នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ឆ្លើយតបសកម្មភាពបទល្មើស

http://www.cen.com.kh/archives/ November 18, 2019

ភ្នំពេញ៖ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានជំរុញឲ្យសិក្ខាកាមជាមន្ត្រីនគរបាល នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដែលត្រៀមទទួលការយកបណ្តុះបណ្តាល យកចិត្តទុកដាក់ក្នុងការសិក្សា ដើម្បីឆ្លើយតបទាន់ពេលវេលារាល់សកម្មភាពបទល្មើស។ ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធដល់នគរបាលរាជធានី នៅព្រឹកថ្ងៃទី១៨ វិច្ឆិកា ឆ្នាំ២០១៩នេះ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

លោក ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានបន្ថែមឲ្យដឹងថា វគ្គបណ្តុះបណ្តាល នៅពេលនេះមានគោលបំណងសំខាន់គឺ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីជំនាញ បន្ថែមទៀត ក្នុងពេលប្រតិបត្តិការបង្ក្រាបបទល្មើសលើបច្ចេកទេស ចាប់ជនសង្ស័យ ការកាពារខ្លួន និងការប្រើប្រាស់អាវុធ រួមទាំងការសង្គ្រោះបឋមពេលដែលមានការទទួលរងរបួស។ លោក ជីវ ផល្លី បន្ថែមថា តាមរយៈវគ្គបណ្តុះបណ្តាលនេះ សង្ឃឹមថានឹងផ្តល់នូវបទពិសោធន៍ និងចំណេះដឹងបន្ថែមទៀត សំដៅរកភាពរីកចម្រើន ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើផ្លូវភេទស្ត្រី និងកុមារ លើសពីនេះ លោកប្រធាននាយកដ្ឋាន ក៏បានផ្តាំផ្ញើឲ្យសិក្ខាកាមទាំងអស់ មិនត្រូវយកចំណេះវិជ្ជា ដែលទទួលបានពីការរៀនសូត្រ ទៅប្រើប្រាស់ខុសគោលដៅ និងជៀសវាងការប្រព្រឹត្តខុសឆ្គងផងដែរ។

គួរបញ្ជាក់ថា វគ្គបណ្តុះបណ្តាលមានរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី១៨ដល់ថ្ងៃទី២២ខែវិច្ឆិកា ដោយមានការចូលរួមសហការពីអង្គការចំនួនពីរ គឺអង្គការមេត្រីអន្តរជាតិ (AIM SWAT) និងអង្គការ ចយ អិនធើណេស្យូណល (JOY international) ដែលមានគ្រូឧទ្ទេសនាមមានបទពិសោធន៍ខ្ពស់ មកពីសហរដ្ឋអាមេរិក ព្រមទាំងមានការចូលរួមពីសិក្ខាកាមជា នាយ នាយរងនគរបាលមកពីនាយកដ្ឋាន និងស្នងការដ្ឋានរាជធានី៕ដោយៈកូឡាប

## នគរបាលខេត្តកំពង់ធំ ឃាត់ខ្លួនជនសង្ស័យម្នាក់ ពាក់ព័ន្ធករណីអំពើលក់ដូរមនុស្ស យកក្មេងស្រីអាយុជាង១ឆ្នាំ ទៅលក់

http://www.cen.com.kh/archives/ November 18, 2019

កំពង់ធំ៖ជនសង្ស័យ ០១នាក់ ពាក់ព័ន្ធករណីអំពើលក់ដូរមនុស្ស ក្នុងមាត្រា១៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ។ យោងតាមពាក្យបណ្តឹងរបស់ឈ្មោះ លន ប៊ុក ភេទស្រី អាយុ ៣៣ឆ្នាំ ស្នាក់នៅបន្ទប់ជួលនៅផ្សារកំបូល សង្កាត់កំបូល ខ័ណ្ឌកំបូល រាជធានីភ្នំពេញ មុខរបរកាត់ដេរ ប្តឹងពីឈ្មោះ ធុន ថុនា ភេទស្រី អាយុ ២៩ឆ្នាំ ស្នាក់នៅផ្សារកំបូល សង្កាត់កំបូល ខ័ណ្ឌកំបូល រាជធានីភ្នំពេញ ប្តឹងនៅប៉ុស្តិ៍រដ្ឋបាលកំបូល ស្តីពីករណីបាត់កូនស្រី អាយុ ០១ឆ្នាំ ០៦ ខែ ។

ដោយមានការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ពីសំណាក់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ឯកឧត្តម សុខ លូ អភិបាលខេត្តកំពង់ធំ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សមត្ថកិច្ចជំនាញបានប្រើប្រាស់វិធានការជំនាញស្រាវជ្រាវចាប់ឃាត់ខ្លួនជនសង្ស័យដែលរត់គេចខ្លួន បន្ទាប់ពីបានធ្វើសកម្មភាពយកក្មេងស្រីទៅលក់ នៅក្នុងភូមិសាស្ត្រខេត្តកំពត ។

ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង១៧ និង០០នាទី ដោយមានការសម្របសម្រួលនីតិវិធីពីលោក អ៊ិត សុជា ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពង់ធំ និងក្រោមការដឹកនាំបញ្ជាផ្ទាល់ពីលោកឧត្តមសេនីយ៍ទោ អ៊ុក កុសល

ស្នងការនគរបាលខេត្តកំពង់ធំ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ បានសហការជាមួយកម្លាំងអធិការដ្ឋាននគរបាលស្រុក ស្ទោងធ្វើការចាប់ឃាត់ខ្លួនជនសង្ស័យចំនួន០១នាក់ នៅចំណុចផ្សារស្ទោង ស្ថិតក្នុងភូមិ កំពង់ចិនត្បូង ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំពីករណីពាក់ព័ន្ធយកក្មេងទៅលក់ ។ ឈ្មោះ ធុន ថុនា ភេទស្រី អាយុ២៩ ឆ្នាំ មុខរបរកម្មកររោងចក្រ ស្នាក់នៅផ្សារកំបូល សង្កាត់កំបូល ខ័ណ្ឌកំបូល រាជធានីភ្នំពេញ ។

នៅព្រឹកថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៩ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ បានបញ្ជូនជនសង្ស័យទៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីចាត់ការបន្ត៕ ដោយៈកូឡាប

## វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ឃុំ-ថ្នាក់ស្រុក និងអ្នកពាក់ព័ន្ធ នៅស្រុកស្រីស្នំ

https://www.facebook.com/deputygovernoryousophear/ លេខាធិការដ្ឋាន គខបជសៀមរាប 15-11-2019

ខេត្តសៀមរាប៖ ថ្ងៃសុក្រ ទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រុមការងារលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប (គ,ខ,ប,ជ)សហការជាមួយរដ្ឋបាលសាលាស្រុកស្រីស្នំ ដែលគាំទ្រដោយរដ្ឋបាលសាលាខេត្តសៀមរាប និងមានការចូលរួមគាំទ្រពីអង្គការ UN WOMEN និងអង្គការ IJM បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ឃុំ-សង្កាត់/ក្រុង-ស្រុក និងអ្នកពាក់ព័ន្ធ អំពីការអនុវត្តតួនាទីភារកិច្ច ច្បាប់ពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការធ្វើ ចំណាកស្រុកប្រកបដោយសុវត្ថិភាព ការទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពានលើកុមារ និងពង្រឹងលើកិច្ចសហប្រតិបត្តិការក្នុងការផ្តល់សេវាជួយជនរងគ្រោះឲ្យបានសមស្របនិងមានប្រសិទ្ធិភាព។

វគ្គបណ្តុះបណ្តាលប្រព្រឹត្តទៅនៅបន្ទប់ប្រជុំរដ្ឋបាលស្រុកស្រីស្នំ ដែលដឹកនាំដោយ ឧត្តមសេនីយ៍ត្រី ដួង ថាវរី ស្នងការនគរបាលខេត្ត ជាអនុប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងជាតំណាងលោកជំទាវ យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងមានការអញ្ជើញចូលរួមពី លោកស្រី ចាន់ សួយ អភិបាលរងស្រុក តំណាងមន្ទីរជំនាញរួមមាន មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មន្ទីរកិច្ចការមន្ទីរសង្គមកិច្ចខេត្ត អង្គការIJM ដែលជាអ្នកសម្របសម្រួល និងមានការនិមន្តអញ្ជើញចូលរួមពីព្រះសង្ឃ អធិការស្រុក កងរាជអាវុធហត្ថស្រុក ប្រធាន អនុប្រធានការិយាល័យជុំវិញស្រុក មេឃុំ ស្មៀន អ.ក.ន.ក ប្រជាការពារ មណ្ឌលសុខភាព នាយប៉ុស្តិ៍ នាយកសាលា យុវជន និងអង្គការដៃគូ សរុប ៥០នាក់ ស្រី១៨នាក់។

ក្រោយពីការធ្វើបទបង្ហាញ ក្រុមការងារបានជំរុញឲ្យអាជ្ញាធរស្រុក មេឃុំ និងអ្នកពាក់ព័ន្ធក្នុងស្រុកទាំងអស់ត្រូវយកចិត្តទុកអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយត្រូវបង្កើនការផ្សព្វផ្សាយទប់ ស្កាត់បទល្មើស នានាពាក់ព័ន្ធ ពិសេសត្រូវពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការអន្តរាគមន៍បង្ក្រាបបទល្មើស និងការជួយផ្តល់សេវាជួយជនរងគ្រោះ ឲ្យបានសមស្រប និងទាន់ពេលវេលា។ បន្ថែមពីនោះ ក្រុមការងារ បានលើកទឹកចិត្តដល់គ្រប់ឃុំទាំងអស់ធ្វើការរៀបចំ និងអនុវត្តតាមផែនការសកម្មភាពនៅក្នុងកញ្ចប់ថវិកាសេវាសង្គមឃុំ ដែលបានដាក់បញ្ចូលសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហើយនៅរាល់ពេលមានបញ្ហាដែលអាជ្ញាធរមូលដ្ឋានមិនអាចដោះស្រាយបាន ឬមានការលំបាកក្នុងការអន្តរាគមន៍ សូមឲ្យធ្វើការរាយការណ៍ជាបន្ទាន់ទៅក្រុមការងារថ្នាក់ស្រុក ឬលេខាធិការដ្ឋាន ថ្នាក់ខេត្ត ឬទៅមន្ត្រីជំនាញតាមមន្ទីរ អង្គភាពផ្ទាល់ក៏បាន។

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៦នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 15-11-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៦នាក់ នាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ពាក់ព័ន្ធនឹងករណីស្នាក់នៅខុសច្បាប់។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៦នាក់នេះ មានស្រុកកំណើតនៅខេត្តព្រៃវែង ០២នាក់, ខេត្តបន្ទាយមានជ័យ ០១នាក់ ស្រី ០១នាក់ និងខេត្តប៉ៃលិន ០៣នាក់ ស្រី ០១នាក់៕

## ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២០១៩

## សម្តេច ហ៊ុន សែន សរសើរថៃដែលបញ្ជូនពលករទៅប្រទេសប្រាក់ខែខ្ពស់ ហើយនាំពលករពីកម្ពុជា និងឡាវ ជំនួសវិញ

https://thmeythmey.com/ 18, Nov 2019 , 9:19 pm

ភ្នំពេញ៖ បណ្តាប្រទេសក្នុងតំបន់អាស៊ាន សុទ្ធតែបញ្ជូនពលករទៅក្រៅប្រទេសទាំងអស់ មិនមែនមានតែកម្ពុជានោះទេ។ នេះជាការលើកឡើងរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលពន្យល់ពីការប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការសហការជាមួយប្រទេសដទៃ ដើម្បីបញ្ជូនពលករខ្មែរ ទៅធ្វើការនៅទីនោះ។ សម្តេច ហ៊ុន សែន ក៏ឆ្លៀតសរសើរថៃ ដែលបញ្ជូនពលករច្រើនទៅធ្វើការនៅប្រទេសប្រាក់ខែខ្ពស់ទៀតផង។

ពីពិធីចែកសញ្ញាបត្រដល់និស្សិតនៃសាកលវិទ្យាល័យធនធានមនុស្ស នៅព្រឹកថ្ងៃទី១៨ វិច្ឆិកានេះ សម្តេច ហ៊ុន សែន បានអះអាងថា ការបញ្ជូនពលរដ្ឋទៅក្រៅប្រទេស វាមិនមែនជារឿងអ្វីដែលខុសឆ្គងនោះទេ ប៉ុន្តែវាជាកាតព្វកិច្ចចាំបាច់ទៅវិញទេ ដែលរដ្ឋាភិបាលត្រូវដោះស្រាយបញ្ហាពលរដ្ឋអត់ការងារធ្វើ។ លើកពីបញ្ហាបញ្ជូនពលករនេះ ប្រមុខរដ្ឋាភិបាល បានអះអាងថា ប្រទេសក្នុងតំបន់អាស៊ាននេះ ភាគច្រើនគឺបញ្ជូនពលករចេញ សូម្បីតែថៃ ដែលនាំពលករពីកម្ពុជា មីយ៉ាន់ម៉ា និងឡាវនោះ ក៏បញ្ជូនពលករទៅប្រទេសក្រៅដែរ។ ត្រង់ចំណុចសម្តេច ហ៊ុន សែន បានសរសើរថៃ ដែលពូកែក្នុងការបញ្ជូនពលករទៅធ្វើការនៅប្រទេសមានប្រាក់ខ្ពស់ទៀតផងដែរ។ «ថៃគាត់ចេះ គាត់ពូកែ គាត់បញ្ជូនមនុស្សទៅធ្វើការនៅក្រៅប្រទេស ទៅកូរ៉េ ទៅជប៉ុន ទៅកោះតៃវ៉ាន់ ទៅមជ្ឈិមបូព៌ា ជនជាតិថៃច្រើនណាស់បញ្ជូនទៅ ។ ប៉ុន្តែគាត់(ថៃ)ខ្វះពលកម្មក្នុងស្រុក គាត់ទាញយកពលកម្មពីកម្ពុជា គាត់ទាញយកពលកម្មពីឡាវ គាត់ទាញយកពលកម្មពីមីយ៉ាន់ម៉ា មកជំនួសពលកម្ម(ថៃ) ដែលបញ្ជូនទៅធ្វើការនៅក្រៅប្រទេស ដែលមានប្រាក់ខែច្រើនជាង»។ នេះជាការបញ្ជាក់របស់សម្តេច ហ៊ុន សែន ដែលបានបន្ថែមថា ក្នុងតំបន់អាស៊ាន មានតែប្រទេសពីរប៉ុណ្ណោះដែលមិនបញ្ជូនពលករចេញនោះ គឺម៉ាឡេស៊ី និងឥណ្ឌូណេស៊ី ខណៈហ្វីលីពីនបញ្ជូនពលករទៅក្រៅប្រទេសជាង១២លាននាក់។

បើតាមសម្តេច ហ៊ុន សែន រដ្ឋាភិបាលកំពុងស្នើទៅរដ្ឋាភិបាលកូរ៉េខាងត្បូង និងជប៉ុន ដើម្បីសុំបញ្ជូនពលករបន្ថែមទៀត ខណៈប្រទេសទាំងពីរនេះ បានផ្តល់ប្រាក់ខែខ្ពស់ដល់ពលករ សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារនៅក្នុងស្រុក។ ពលករខ្មែរនៅក្រៅប្រទេសមានចំនួនប្រមាណ១,២លាននាក់ ដោយនៅប្រទេថៃច្រើនជាងគេ ១,១លាននាក់ ប្រទេសកូរ៉េប្រហែល៥ម៉ឺននាក់ និងប្រទេសផ្សេងៗទៀតដូចជា ម៉ាឡេស៊ី ជប៉ុនជាដើម។ ពលករខ្មែរដែលចេញទៅក្រៅប្រទេស មាននៅប្រទេសថៃក្នុងចំនួនលើសលុប តែជាទូទៅធ្វើការគ្មានជំនាញ ដូចជាធ្វើការនៅការដ្ឋានសំណង់ សេវាកម្មផ្សេង និងកសិកម្ម ដកដំឡូង កាច់ពោត ចៀរជ័រកៅស៊ូ នេសាទ ជាដើម។ តែនៅកូរ៉េ និងជប៉ុន ពលករខ្មែរធ្វើការគ្រាន់បើជាងពលករនៅថៃ និងម៉ាឡេស៊ី ដោយទទួលប្រាក់ឈ្នួលខ្ពស់ ហើយពួកគេភាគច្រើនមានការអប់រំខ្ពស់ជាងពេលនៅខ្មែរ ដែលអាចរៀនពីរបៀបរបបធ្វើការពីក្រៅ និងចាប់យកចំណេះជំនាញបានក្នុងកម្រិតណាមួយប្រសើរជាង។ តែយ៉ាងណាក៏ដោយ ពលករខ្មែរនៅកូរ៉េ ទោះធ្វើការនៅផ្នែកឧស្សាហកម្ម ក៏ក្នុងនាមជាពលករជំនាញកម្រិតទាបពោលគឺប្រើកម្លាំងពលកម្មលើសលុប។

**ពលករក្រៅប្រទេសនឹងក្លាយជាបន្ទុក បើមិនមានចំណេះជំនាញជាប់នឹងខ្លួន ពេលត្រឡប់មកវិញ**

សម្រាប់អ្នកវិភាគសេដ្ឋកិច្ច លោក គី សេរីវឌ្ឍន៍ បើពលករទៅធ្វើការនៅក្រៅប្រទេសហើយ ត្រឡប់មកវិញដោយគ្មានជំនាញអ្វីច្បាស់នោះ ពួកគេនឹងក្លាយទៅជាបន្ទុក។ «តែបើគាត់មិនបានស្រូបយកចំណេះដឹងទាំងអស់នោះមកវិញទេ ពួកគាត់នឹងប្រៀបបានកាកសំណល់ដែលហូរត្រឡប់មកវិញហើយ ព្រោះថានៅពេលត្រឡប់មកវិញត្រូវចាំចាយលុយហើយព្រោះកម្លាំងក៏ចុះខ្សោយ»។ នេះជាការយល់ឃើញរបស់អ្នកវិភាគសេដ្ឋកិច្ច។

បើតាមតួលេខពីធនាគារជាតិនៃកម្ពុជា ពលករខ្មែរបានផ្ញើរថវិកាតាមប្រព័ន្ធធនាគារប្រមាណ ១១០០លានដុល្លារចូលស្រុកកំណើតវិញកាលពីឆ្នាំ២០១៨ ដែលកើនឡើងប្រមាណ១០០លានដុល្លារ។ តែបើការអះអាងពីក្រសួងការងារ ថវិកាផ្ញើមកស្រុករបស់ពលករមានចំនួនច្រើនជាងនេះ៕

## ១០ខែ ឆ្នាំ២០១៩ ស្ថានភាពបទល្មើសជួញដូរមនុស្សបង្ការទប់ស្កាត់បានកាន់តែប្រសើរ

http://bayontv.com.kh/ 18/11/2019

ភ្នំពេញ៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស នាព្រឹកថ្ងៃទី១៨ វិច្ឆិកានេះ បានដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សាអំពីរបាយការណ៍១០ខែឆ្នាំ ២០១៩ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទីស្តីការក្រសួងមហាផ្ទៃ។ លោកជំទាវជូន ប៊ុនអេង បានបញ្ជាក់ថា រយៈពេល១០ខែឆ្នាំ២០១៩ ស្ថានភាពបទល្មើសជួញដូរមនុស្សត្រូវបានបង្ការ ទប់ស្កាត់កាន់តែប្រសើរឡើងជាបន្តបន្ទាប់អាស្រ័យដោយមានការប្រឹងប្រែង និងមានកិច្ចសហការគ្នាបានល្អរវាងក្រសួង ស្ថាប័នអង្គភាពសមាជិកនៃ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស រួមទាំងលេខាធិការដ្ឋាន នៃគណៈកម្មាធិការថ្នាក់ក្រោមជាតិ និងអង្គការ ដៃគូទាំងឡាយ ដែលមានសកម្មភាព និងគោលដៅរួមគ្នា។ កន្លងមកការផ្តល់ភាពស្របច្បាប់ជូនពលករ កម្ពុជាប្រមាណ ១លាន ៨ម៉ឺននាក់ គឺជាលទ្ធផលជោគជ័យសម្រាប់ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលនៃប្រទេសទាំងពីរ កម្ពុជា-ថៃ។ លោកជំទាវ ជូ ប៊ុនអេង បានជំរុញឲ្យសមត្ថកិច្ច ខិតខំប្រឹងប្រែងផ្សព្វផ្សាយអប់រំបង្ការទប់ស្កាត់ ដោយផ្ទាល់ និងដោយប្រយោលនៅគ្រប់មជ្ឈដ្ឋាន ច្រកល្ហក ដើម្បីឲ្យប្រជាពលរដ្ឋបានយល់ច្បាស់ឈប់ចាញ់បោកមេខ្យល់ និងជនខិលខូចដែលទាញយកផលចំណេញពីគ្រប់តំណាក់កាល នៃទេសន្តរប្រវេសន៍ ឲ្យធ្លាក់ចូលក្នុងភាពរងគ្រោះ ខូចខាតទ្រព្យសម្បត្តិ បាត់បង់ផ្ទះសម្បែង បែកបាក់កូនចៅក្រុម គ្រួសារ រហូតដល់ពិកា និងបាត់បង់អាយុជីវិត ក្នុងអំពើកេងប្រវ័ញ្ច គ្រប់រូបភាព ដែលហៅថា "ទាសភាព សម័យទំនើប"

ក្នុងរយៈពេល១០ខែ ឆ្នាំ២០១៩នេះ នៅមានពលករខ្មែរ មិនទាន់មានឯកសារច្បាប់ ត្រូវបានសមត្ថកិច្ច ថៃរកឃើញផាកពិន័យឃាត់ខ្លួន ហើយតម្រូវឲ្យ ត្រឡប់មករៀបចំឯកសារនៅ ក្នុងស្រុកឬបញ្ជូនត្រឡប់ជារៀងរាល់ថ្ងៃ។ ជនរងគ្រោះមួយចំនួនត្រូវបានរកឃើញថា កាន់ឯកសារមិនត្រឹមត្រូវ ឬក្លែងបន្លំ និងមិនអាចទទួលផលប្រយោជន៍ស្របច្បាប់បាន។ ជាមួយនេះក៏មានជនបោកប្រាស់ ដែលបានប្រើ រូបភាពជាភ្នាក់ងារមានសមត្ថកិច្ចផ្តល់ឯកសារក្លែងក្លាយជាអ្នករត់ការផ្តល់ភាពស្របច្បាប់ ឬឃោសនា ជាអ្នកជ្រើសរើស ដើម្បីបញ្ជូនទៅរកការងារក្រៅប្រទេស ហើយប្រមូលកម្រៃ សេវាពី ពលករជាដើម ។ ជនបោកប្រាស់ទាំនោះ សមត្ថកិច្ចប្រទេសថៃ និងកម្ពុជា បានស្រាវជ្រាវចាប់ខ្លួន និងផ្តន្ទាទោសជាបន្តបន្ទាប់។ ចំពោះបទល្មើសថ្មី ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សឆ្លងដែន ឬអំពើពពោះជំនួស និងមេខ្យល់នាំស្ត្រីជាកូនក្រមុំឆ្លងដែនស្វែង រកគូស្រករនៅក្រៅប្រទេស ក៏ត្រូវបានរកឃើញ ទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលា និងនៅតែបន្តស្រាវជ្រាវ ថែមទៀត។ ការកសាងច្បាប់ និងបទដ្ឋាន គតិយុត្តិពាក់ព័ន្ធ ក៏ត្រូវបានយកចិត្តទុកដាក់ ដើម្បីបំពេញភាពខ្វះចន្លោះនៃច្បាប់ ៕

## កម្ពុជា-ថៃ បើកកិច្ចប្រជុំពង្រឹងទំនាក់ទំនងកិច្ចសហកិច្ចប្រតិបត្តិការ ទប់ស្កាត់បង្រ្កាបបទល្មើស នៅតាមព្រំដែន

http://www.freshnewsasia.com/ 2019-11-18

**(បាត់ដំបង)៖** ប្រតិភូរដ្ឋបាលខេត្តបាត់ដំបង និងរដ្ឋបាលរដ្ឋបាលខេត្តច័ន្ទបុរីប្រទេសថៃ បើកកិច្ចប្រជុំពង្រឹងទំនាក់ទំនងសហកិច្ចប្រតិបត្តិការ បង្ក្រាបបទល្មើសនៅតាមព្រំដែននៃប្រទេសទាំងពីរ នៅរសៀលថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ ដឹកនាំដោយលោក ងួន រតនៈ អភិបាលខេត្ត។ លោក ងួន រតនៈ បានថ្លែងថា កិច្ចប្រជុំពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការល្អរវាងខេត្តជាប់ព្រំដែន នៃប្រទេសទាំងពីរ នៅសាលាខេត្តច័ន្ទបុរីនេះ ដើម្បីរួមគ្នាការពារ សុខសុវត្ថិភាពទប់ស្កាត់ បង្ក្រាបបទល្មើស ជួញដូរគ្រឿងញៀន និងពលករឆ្លងដែនខុសច្បាប់ ។ លោកអភិបាលខេត្តបាត់ដំបង បានជម្រាបជូនលោកអភិបាលខេត្តច័ន្ទបុរីថា ខេត្តយើងទាំងពីរត្រូវទំនងល្អជាមួយគ្នា ជាពិសេសទំនាក់ទំនងល្អនៅតាមច្រកទ្វារព្រំដែនអន្តរជាតិដូង និងច្រកបានទ្បែមខេត្តច័ន្ទបុរី ដែលបានទំនាក់ទំនងជាមួយកន្លងមក និងបន្តកិច្ចសហប្រតិបត្តិការល្អបន្ថែមទៀត។

ក្នុងឱកាសនោះដែរលោក ងួន រតនៈ ក៏បានសំណូមពរដល់ភាគីថៃ បន្តបង្កើតសាមគ្គីភាព មិត្តភាព តាមរយៈក្រុមកីឡាជិះកង់រវាងខេត្តទាំងពីរ នាខែធ្នូ ឆ្នាំ២០១៩ខាងមុខនេះ។ នៅក្នុងកិច្ចប្រជុំស្តីពីសហប្រតិបត្តិការមួយចំនួននោះ មានដូចជា៖ ការបង្កើនកិច្ចសហប្រតិបត្តិការ សុខសុវត្ថិភាពតាមព្រំដែន បញ្ហាពលករខ្មែរឆ្លងដែនខុសច្បាប់ ព្រមទាំងបទល្មើសឆ្លងដែននានា និងការនាំចេញកសិផល ការធ្វើពាណិជកម្មឆ្លងដែនរវាង ខេត្តច័ន្ទបុរី-បាត់ដំបង ជាពិសេសជួយសម្រួលដល់ ការនាំចេញកសិផលរបស់កសិករខ្មែរក្នុងខេត្តបាត់ដំបងទៅកាន់ប្រទេសថៃ ឲ្យបានកាន់ងាយស្រួល និងមានភាពល្អប្រសើរជាងមុនផងដែរ។ លោកអភិបាលខេត្ត បានកោតសរសើរដល់រដ្ឋបាលខេត្តច័ន្ទបុរីដែលកន្លងមកបានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយខេត្តជាប់ព្រំដែន នៃប្រទេសទាំង២ ដើម្បីរក្សាឲ្យបាននូវសន្តិសុខសណ្តាប់ ធ្នាប់តាមបណ្តោយព្រំដែន និងបម្រើឲ្យផលប្រយោជន៍របស់ប្រជាជន និងប្រទេសទាំងពីរដោយស្មើភាព និងស្មោះត្រង់គ្នាទៅវិញ៕

## អត់ព្រមសហការ...ចូលចាប់សែងស្រ្តីម្នាក់បញ្ជូលក្នុងឡានទៅសាកសួរ

https://news.kohsantepheapdaily.com.kh/ By sreyna November 19, 2019

រាជធានីភ្នំពេញ ៖ អាជីវករដូរលុយ និងវេរលុយម្នាក់ បានត្រូវកម្លាំងកងរាជអាវុធហត្ថខណ្ឌទួលគោកចាប់សែងចេញពីក្នុងអង្រឹងយកដាក់រថយន្ត បន្ទាប់ពីហៅសាកសួររឿងបាត់នាងក្រមុំម្នាក់ដែលមកស្នាក់នៅជាមួយមិនព្រមទៅ ។ ហេតុការណ៍នេះ បង្កឲ្យមានការភ្ញាក់ផ្អើល កាលពីវេលាម៉ោងប្រមាណ៣ និង៣០នាទី រសៀលថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅចំណុចផ្ទះដូរលុយ និងអាស៊ីវេលុយ មានអាសយដ្ឋានលេខ៣៧០ មហាវិថីម៉ៅសេទុង មុខផ្សារដើមគ ក្នុងសង្កាត់បឹងសាឡាង ខណ្ឌទួលគោក ។ ស្រ្តីដែលសមត្ថកិច្ចនាំខ្លួននេះ ឈ្មោះលឹម វ៉ាន់នី អាយុប្រមាណ៦៣ឆ្នាំ ស្នាក់នៅផ្ទះខាងលើ ។ តាមព័ត៌មានឲ្យដឹងថា មុនពេលកើតហេតុ សមត្ថកិច្ចកងរាជអាវុធហត្ថខណ្ឌទួលគោក បានមកអញ្ជើញអាជីវកររូបនេះទៅសាកសួរនៅបញ្ជាការដ្ឋានកងរាជអាវុធខណ្ឌ តែគាត់មិនព្រមទៅព្រមទាំងប្រកែកថា មិនបានដឹងនោះទេ ។ ដោយសារតែមិនព្រមសហការ សមត្ថកិច្ចក៏បានសុំគោលការណ៍ហើយនាំខ្លួនតែម្តង ។

តាមព័ត៌មានឲ្យដឹងទៀតថា ខណៈនោះគេឃើញអាជីវកររូបនេះព្យាយាមគេច ហើយក៏ត្រូវកម្លាំងកងរាជអាវុធហត្ថ នាំគ្នាចូលទៅចាប់ខ្លួន សែងចេញពីក្នុងអង្រឹងយកទៅដាក់ក្នុងរថយន្តបញ្ជូនទៅកាន់ញ្ជាការដ្ឋានដើម្បីសាកសួរ ។ មន្រ្តីកងរាជអាវុធហត្ថខណ្ឌទួលគោក បានឲ្យដឹងថា ការនាំខ្លួនអាជីវកររូបនេះធ្វើឡើងតាមបញ្ជាលោក កែវ សុជា ព្រះ

រាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ បន្ទាប់ពីមានពាក្យបណ្ដឹងរបស់ម្ដាយមីងនារីម្នាក់ដែលបាត់ខ្លួន ខណៈមកស្នាក់នៅធ្វើការនៅផ្ទះខាងលើ ។

តាមម្ដាយមីងឈ្មោះ គួច សុផល អាយុ៣៣ឆ្នាំ មានទីលំនៅក្នុងភូមិទួលក្រួស សង្កាត់ចំរើនផល ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ បានឲ្យដឹងថា ក្មួយស្រីរបស់គាត់ឈ្មោះ ចាន់ ស្រីណយ អាយុ១៨ឆ្នាំ បានបាត់ខ្លួនមិនដឹងទៅណា បន្ទាប់ពីមកធ្វើការជាអ្នកលក់បាយ និងស្នាក់នៅផ្ទះ ខាងលើ ។ ស្ត្រីជាម្ដាយមីងបានឲ្យដឹងទៀតថា តាមរយៈអ្នកស្គាល់គ្នា គាត់បានយកកូនស្រី២នាក់និងក្មួយស្រីម្នាក់មកធ្វើការជាមួយឈ្មោះ លឹម វ៉ាន់នី ។ លុះក្រោយមក គាត់បានយកកូនទៅរៀនវិញ នៅសល់តែក្មួយមកធ្វើការជាអ្នកលក់បាយ រយៈពេលជាង១ខែមកហើយ ។ នៅពេលថ្មីៗនេះស្រាប់តែឃើញហ្វេសប៊ុកកូនស្រីរបស់ឈ្មោះ លឹម វ៉ាន់នី បង្ហោះរូបថតក្មួយស្រីគាត់ជាមួយជនជាតិចិន ក៏មានការសង្ស័យថា ក្មួយរបស់គាត់ត្រូវបានគេនាំយកទៅលក់ឲ្យជនជាតិចិន និងបានទាក់ទងតាមទូរស័ព្ទតែក្មួយមិនលើក ។ បន្ទាប់មក គាត់បានធ្វើដំណើរមកភ្នំពេញសួរនាំឈ្មោះ លឹម វ៉ាន់នី តែគេមិនឆ្លើយ និងមិននិយាយ ថែមទាំងជេរទៀត ទើបគាត់ជាម្ដាយមីងទៅប្ដឹងសមត្ថកិច្ចតែម្ដង ។

ទោះបីជាយ៉ាងណា គេពុំដឹងថានាងក្រមុំរូបនេះ ត្រូវបានគេលក់មែនឬយ៉ាងណានោះទេ ដោយសារតែស្ត្រីអាជីវករមិននិយាយ និងបានត្រឹមតែប្រកែកថា មិនដឹងទេ ដែលទំនងជាមានការលាក់បាំងអ្វីមួយ ។ បន្ទាប់ពីនាំខ្លួនអាជីវកររូបនេះ សមត្ថកិច្ចបានបញ្ជូនបន្តទៅកាន់បញ្ជា ការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ ដើម្បីសាកសួរនិងស្រាវជ្រាវរកនារីវ័យក្មេងដែលបាត់ខ្លួននោះ ។គិតត្រឹមវេលាម៉ោង៥ល្ងាចថ្ងៃដដែល នៅមិនទាន់ដឹងថា ការបាត់ខ្លួននាងក្រមុំរូបនេះដោយសារមូលហេតុអ្វីនៅឡើយទេ ៕

## ប៉ុស្ដិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០២នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 18-11-2019

កម្លាំងប៉ុស្ដិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០២នាក់ នាវេលាម៉ោង ១៦និង០០នាទី ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩។ កម្លាំងនគរបាលប៉ុស្ដិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ស្លាប់ទៀតហើយពលករខ្មែរធ្វើការនៅប្រទេសថៃ

https://www.facebook.com/ ទឹកចិត្ត ពលករ ឆ្លងដែន 18-11-2019

ពលករខ្មែរម្នាក់មានឈ្មោះ មួន ធួន ភេទប្រុសអាយុ23ឆ្នាំ បានរងគ្រោះថ្នាក់ធ្លាក់ពីលើខេននៅពេលកំពុងធ្វើការបណ្ដាលអោយស្លាប់នៅនិងកន្លែងកើតហេតុ។ ស្រុកកំណើតជនរងគ្រោះរស់នៅភូមិវាលតូច ឃុំជំរីពួន ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។ បានរងគ្រោះស្លាប់នៅក្នុងប្រទេសថៃនៅកន្លែងកើតហេតុនៅកន្លែងកសាងក្នុងបរិស័ទBPVS ហេតុកាណ៍នេះបានកើតឡើងនៅក្នុងតំបន់លាតផាវ ក្រុងថេប កាលថ្ងៃទី15-12-2019។

## សូមចូលរួមសោកស្ដាយផងពលករខ្មែរ ទៅធ្វើការនៅប្រទេសកូរ៉េម្នាក់ បានទទួលមរណៈភាព ហើយកាលពីយប់មិញ ជាកូនអ្នកខេត្តកំពង់ចាម

https://khmernews.news/ ស៊ីហៀង 19-11-2019

នៅមុននេះបន្តិចនៅលើបណ្ដាញសង្គមហ្វេសប៊ុកមួយដែលមានឈ្មោះថា Meng Costa page បំណងល្អពីខ្ញុំគាត់បានបង្ហោះសារឲ្យបងប្អូនបានជ្រាបថា មានកូនខ្មែរដែលជាពលករចំនួនពីរនាក់បានស្លាប់បាត់បង់ពីជីវិត ដោយសារតែគាំងបេះដូង។ ម្ចាស់គណនីហ្វេសប៊ុកខាងលើ បានលើកឡើងថា "ដំណឹងមរណៈ ភាពជនជាតិខ្មែរយើង ឈ្មោះ

បុនថាន បានគាំងបេះដូងស្លាប់ម្នាក់ទៀតហើយកាលពីយប់មិញ ក្នុងរដូវត្រជាក់នេះ មានស្រុកកំណើត ភូមិអារក្ស ត្នោត ឃុំអារក្សត្នោត ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ ព័ត៌មានលំអិតនឹងផុសបន្តិចទៀតនេះកំពុងសាកសួរ។

ក្រោយពីទទួលបានដំណឹងដ៏សោកសៅនេះភ្លាម ធ្វើឲ្យបងប្អូនកម្ពុជា ពិតជាការសោកស្តាយ និងរន្ធត់ចិត្តជាខ្លាំង ព្រោះថា មិនដឹងកូនខ្មែរប៉ុន្មានមកហើយ ដែលគាត់បានស្លាប់ៗទន្ទឹមនឹងនេះ ក៏មានបងប្អូនជាច្រើន បានបង្ហោះសារ សូមឲ្យបងប្អូនខ្មែរយើង ថែរក្សាសុខភាពផង ព្រោះថានៅទីនោះត្រជាក់ណាស់ ។ ហើយក៏មានអ្នកខ្លះថា អាណិតបងប្អូនខ្មែរយើងណាស់ទៅធ្វើការស្រុកគេចង់ប្រាប់ថា គ្មានកន្លែងណាមានភាពកក់ក្តៅជាងប្រទេសខ្លួនឡើយសូមជួយចូលរួមសាងសង្គមរបស់ពូកយើងទាំងអស់គ្នា"។ អាណិតណាស់លោក បងប្អូនខ្មែរយើងនៅនឹងសូមថែរក្សាសុខភាពផង។សូមបងប្អូនការពារសុខភាព គេងយប់កុំបើកកំដៅខ្លាំងពេកហើយក៏កុំបិតបង្អួចអោយជិតពេកដែលនាំអោយខ្វះអុកស៊ីសែនអាចធ្វើអោយគាំងបេះដូងបាន"៕

## ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០១៩

## ប៉ាឡាវ និងកម្ពុជាបង្កើតទំនាក់ទំនងការទូតជាមួយគ្នា ហើយក៏អាចសហប្រតិបត្តិការ ក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន អំពើភេរវកម្ម គ្រឿងញៀន

http://www.cen.com.kh/ November 20, 2019

ភ្នំពេញ ៖ អនុប្រធានាធិបតីប្រទេសប៉ាឡាវ បានថ្លែងថា ប៉ាឡាវ និងកម្ពុជា បង្កើតទំនាក់ទំនងការទូតជាមួយគ្នា ហើយយើងក៏អាចសហប្រតិបត្តិការគ្នាបានក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន អំពើភេរវកម្ម គ្រឿងញៀន ហើយក្រៅពីនោះយើងក៏អាចពង្រឹងទំនាក់ទំនងលើវិស័យអភិវឌ្ឍន៍ធនធានមនុស្ស រួមទាំងការចែករំលែកបទពិសោធន៍ឲ្យគ្នាទៅវិញទៅមកទៀតផង។

នៅព្រឹកថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០១៩នេះ បន្ទាប់ពីអញ្ជើញបើក "កិច្ចប្រជុំកំពូលអាស៊ីប៉ាស៊ីហ្វិកលើកទី ២" នៅវិមានសន្តិភាពរួចហើយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជួបពិភាក្សាការងារបន្តជាមួយនឹង លោករ៉េនុល អ៊ុលឡេច (Raynold B.Oilouch) អនុប្រធានាធិបតី និង ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ប្រទេសប៉ាឡាវ។ សម្តេចតេជោ ហ៊ុន សែន បានស្វាគមន៍ និងអរគុណចំពោះ លោក Raynold B.Oilouch ដែលបានអញ្ជើញចូលរួមនៅក្នុង កិច្ចប្រជុំកំពូលអាស៊ីប៉ាស៊ីហ្វិកលើកទី ២ ដែលកម្ពុជាបានធ្វើជាម្ចាស់ផ្ទះក្នុងថ្ងៃនេះ។ សម្តេចតេជោ បានចាត់ទុកថា នេះគឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសម្រាប់ប្រទេសទាំងពីរ ដែលបានបង្កើតទំនាក់ទំនងការទូតជាមួយគ្នា ហើយសង្ឃឹមថាប្រទេសយើងទាំងពីរមានទំនាក់ទំនងដ៏ល្អចាប់ពីថ្ងៃនេះតទៅ។

លោកអនុប្រធានាធិបតី នៃប្រទេសប៉ាឡាវ លោក Raynold B.Oilouch បានសម្តែងនូវសេចក្តីរីករាយយ៉ាងខ្លាំងដែលបានជួបសំដែងការគួរសម និងពិភាក្សាការងារជាមួយ សម្តេចតេជោ ជាពិសេសដែលបាន ចូលរួមនៅក្នុងកិច្ចប្រជុំដ៏មានសារសំខាន់នាថ្ងៃនេះ។ លោកបានមានប្រសាសន៍ថាតាមរយៈការចូលរួមរបស់លោកនៅក្នុងកិច្ចប្រជុំកំពូលអាស៊ីប៉ាស៊ីហ្វិកថ្ងៃនេះ នឹងបើកឱកាសឲ្យប្រទេសយើងទាំងពីរចាប់ផ្តើមមានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទៅលើវិស័យផ្សេងៗជាច្រើនដែលអាចធ្វើទៅបាននៅពេលខាងមុខ។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ថា នេះគឺជាឱកាសដ៏ល្អដែលប្រទេសយើងទាំងពីរអាចចាប់ផ្តើមមានទំនាក់ទំនងល្អជាមួយគ្នា ដូចជាកិច្ចសហប្រតិបត្តិការដែលអាចធ្វើអោយស្របទៅនឹងអ្វីដែលប្រទេសទាំងពីរមាន។ សម្តេចតេជោក៏បានផ្តួចផ្តើមនូវគំនិតថាប្រទេសយើងទាំងពីរគួរតែមានការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាមួយស្តីអំពីការពិគ្រោះយោបល់រវាងក្រសួងការបរទេសនៃប្រទេសទាំងពីរ ដើម្បីចាប់ផ្តើមឲ្យក្រសួងការបរទេសទាំងពីរពិភាក្សាគ្នារកវិធីណា ដែលអាចសហប្រតិបត្តិការគ្នាបាន ដូចជាការចុះអនុសសារណៈនៃលើកលែងទិដ្ឋាការ និងលិខិតឆ្លងដែន ហើយបន្ទាប់មកយើងអាចចុះហត្ថលេខាលើវិស័យពាណិជ្ជកម្ម និងការវិនិយោគនៃ

ប្រទេសទាំងពីរផងដែរ។ នៅក្នុងឱកាសនោះដែរ សម្តេចតេជោ ក៏អញ្ជើញលោកប្រធានាធិបតី និងលោកស្រីមក បំពេញទស្សនកិច្ចនៅប្រទេសកម្ពុជានៅថ្ងៃណាមួយដែលអាចធ្វើទៅបាននាពេលខាងមុខនេះ។

លោកRaynold B.Oilouch អនុប្រធានាធិបតី បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ សម្តេចតេជោ ហើយគាត់សន្យាថា នឹងរង់ចាំនូវការពិភាក្សាគ្នារវាងក្រសួងការបរទេសនៃប្រទេសយើងទាំងពីរ ហើយលោកបានមានប្រសាសន៍ថា យើងក៏អាចសហប្រតិបត្តិការគ្នាបានក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន អំពើភេរវកម្ម គ្រឿងញៀន ហើយក្រៅពីនោះយើងក៏អាចពង្រឹងទំនាក់ទំនងលើវិស័យអភិវឌ្ឍន៍ធនធានមនុស្ស រួមទាំងការចែករំលែកបទពិសោធន៍ឲ្យគ្នាទៅវិញទៅមកទៀតផង។ សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ដែរថា កម្ពុជាក៏អាចមានផលិតផលខ្លះ ដើម្បីធ្វើការនាំចេញទៅប្រទេសប៉ាឡាវផងដែរ ពីព្រោះប៉ាឡាវ ក៏ជាទីផ្សារមួយដ៏ល្អសម្រាប់ទំនិញកម្ពុជា។ ក្នុងឱកាសនោះជួបពិភាក្សាការងារនេះ សម្តេចតេជោ ហ៊ុន សែន ក៏បានជំរាបពីបំណងអញ្ជើញទៅបំពេញទស្សនកិច្ចនៅប្រទេសប៉ាឡាវនៅពេលខាងមុខផងដែរ ដើម្បីចាប់ផ្តើមជំរុញទំនាក់ទំនងនៃប្រទេសទាំងពីរអោយមានសកម្មភាពរស់រវើកឡើង ។ ជាមួយគ្នានោះ លោកមអនុប្រធានាធិបតីប៉ាឡាវ ក៏បានជំរាបជូនសម្តេចតេជោផងដែរ អំពីកិច្ចប្រជុំកំពូលមួយចំនួន ដែលប្រទេសប៉ាឡាវ នឹងរៀបចំធ្វើដូចជា កិច្ចប្រជុំស្តីអំពីមហាសាគរ ដែលនឹងប្រព្រឹត្តទៅនៅឆ្នាំក្រោយនៅ គឺនៅខែសីហា ឆ្នាំ២០២០ ខាងមុខ និងកិច្ចប្រជុំកំពូលនៃស្ត្រីទី១តំបន់អាស៊ីប៉ាស៊ីហ្វិក ដែលនឹងប្រព្រឹត្តទៅនៅដើមខែធ្នូ ២០១៩ ខាងមុខនេះ។ នៅក្នុងឱកាសនេះដែរ លោក Raynold B.Oilouch បានគោរពអញ្ជើញ សម្តេចតេជោអញ្ជើញចូលរួមផងដែរ។ ជាការឆ្លើយតបសម្តេចបានមានប្រសាសន៍ថា បើសិនជា សម្តេច មិនរវល់ទេនោះ គឺសម្តេចនឹងអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំនោះមិនខានឡើយ៕ ដោយៈកូឡាប

## វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ឃុំ-ថ្នាក់ស្រុក និងអ្នកពាក់ព័ន្ធ នៅស្រុកវ៉ារិន

https://www.facebook.com/ លេខាធិការដ្ឋាន គខបជសៀមរាប 19-11-2019

ខេត្តសៀមរាប៖ ថ្ងៃអង្គារ ទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រុមការងារលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប (គ,ខ,ប,ជ) បានបន្តសហការជាមួយរដ្ឋបាលសាលាស្រុកវ៉ារិន ដោយមានការគាំទ្រពីរដ្ឋបាលសាលាខេត្តសៀមរាប និងមានការចូលរួមគាំទ្រពីអង្គការ UN Women បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ឃុំ-សង្កាត់/ក្រុង-ស្រុក និងអ្នកពាក់ព័ន្ធ អំពីការអនុវត្តតួនាទីភារកិច្ច ច្បាប់ពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពានលើកុមារ និងពង្រឹងលើកិច្ចសហប្រតិបត្តិការក្នុងការផ្តល់សេវាជួយជនរងគ្រោះឲ្យបានសមស្របនិងមានប្រសិទ្ធិភាព។

វគ្គបណ្តុះបណ្តាលប្រព្រឹត្តទៅនៅបន្ទប់ប្រជុំរដ្ឋបាលស្រុកវ៉ារិន ក្រោមអធិបតីភាព លោក ធិនី រិទ្ធ អភិបាលនៃគណៈអភិបាលស្រុក មានការអញ្ជើញចូលរួមពី លោកស្រី អភិបាលរងស្រុក តំណាងមន្ទីរជំនាញរួមមាន មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត និងមន្ទីរកិច្ចការមន្ទីរសង្គមកិច្ចខេត្ត និងក្រុមការងារលេខាធិការដ្ឋាន ដែលជាអ្នកសម្របសម្រួល និងមានការនិមន្តអញ្ជើញចូលរួមពីព្រះសង្ឃ អធិការស្រុក កងរាជអាវុធហត្ថស្រុក ប្រធាន អនុប្រធានការិយាល័យជុំវិញស្រុក មេឃុំ ស្មៀន អ.ក.ន.ក ប្រជាការពារ មណ្ឌលសុខភាព នាយប៉ុស្តិ៍ នាយកសាលា យុវជន និងអង្គការដៃគូ សរុប ៥៣នាក់ ស្រី១៦នាក់។

លោកអភិបាលស្រុកវ៉ារិន បានគាំទ្រលើការបណ្តុះបណ្តាលដល់ក្រុមការងារនៅថ្នាក់ឃុំ ស្រុក ហើយលោកបានជំរុញ ឱ្យអ្នកចូលរួមទាំងអស់យកចិត្តទុកដាក់ស្តាប់ និងលើកជាសំនួរក៏ដូចជាបញ្ហាដែលធ្លាប់ជួបកន្លងមក ដើម្បី

ចែករំលែកពត៌មាននិងបទពិសោធន៍ សម្រាប់ធ្វើការផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋឱ្យឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រជាតិ ផែនការខេត្ត ស្រុក និងឃុំផ្ទាល់របស់ខ្លួនឱ្យបានទូលំទូលាយ មានប្រសិទ្ធិភាព ដើម្បីការពារបងប្អូននៅមូលដ្ឋានពាក់ព័ន្ធនឹងបញ្ហាជួញដូរមនុស្ស ឬការកេងប្រវ័ញ្ចផ្សេងៗ និងពង្រឹងលើកិច្ចសហប្រតិបត្តិការ លើការបង្ការទប់ស្កាត់ ការបង្រ្កាប ការជួយជនរងគ្រោះ ចាប់ពីថ្នាក់ភូមិ ឃុំ ស្រុក និងថ្នាក់ខេត្ត ដើម្បីរួមគ្នាកុំឲ្យកើតមានអំពើជួយដូរមនុស្ស។

វគ្គបណ្តុះបណ្តាលទទួលបានការចូលរួមជាយោបល់ និងលើកពីបញ្ហាប្រឈមលើករណីជាក់ស្តែង នៅក្នុងមូលដ្ឋាន ហើយក្រុមការងារ បានផ្តល់ជាយោបល់ និងវិធីសាស្ត្រ និងការទំនាក់ទំនងជាមួយគ្រប់អ្នកពាក់ព័ន្ធ សម្រាប់អនុវត្តសកម្មភាព។

## ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១៩

### កិច្ចជំនួបពិភាក្សាការងាររវាងក្រុមការងារលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប ជាមួយតំណាងសហភាពអឺរ៉ុប

https://www.facebook.com/deputygovernoryousophear/ លេខាធិការដ្ឋាន គខបជសៀមរាប 21-11-2019

ខេត្តសៀមរាប ៖ នៅរសៀលថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រុមការងារលេខាធិការដ្ឋាន គ,ខ,ប,ជ បានទទួលជួបពិភាក្សាការងារជាមួយតំណាងសហភាពអឺរ៉ុប ស្តីពីសកម្មភាពរបស់អង្គការ GVC ដែលអនុវត្តគម្រោង គាំទ្រការផ្សព្វផ្សាយការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្ស ដែលអនុវត្តនៅក្នុងស្រុកជីក្រែង និងគម្រោងលើកកម្ពស់ការការពារសិទ្ធការងារសម្រាប់ពលករចំណាកស្រុកកម្ពុជានៅក្នុងប្រទេសថៃ ដែលគម្រោងអនុវត្តនៅក្នុងស្រុកពួក។

នៅក្នុងកិច្ចជំនួបនេះ តំណាងសហភាពអឺរ៉ុប បានធ្វើការស្វែងយល់អំពីកិច្ចសហការរវាងអង្គការ GVC ជាមួយអាជ្ញាធរខេត្តសៀមរាប និងប្រសិទ្ធិភាពនៃការអនុវត្តគម្រោង និងការអនុវត្តសកម្មភាពរបស់អាជ្ញាធរ ពិសេសក្រុមការងារគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប ក្នុងបង្ការទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់របស់ប្រជាពលរដ្ឋ ការដោះស្រាយលើបញ្ហាប្រឈមរបស់ពលករ ការពង្រឹងសមត្ថភាពដល់អ្នកពាក់ព័ន្ធ និងការកិច្ចសហការរវាងក្រុមការងារនៅថ្នាក់ខេត្ត ជាមួយក្រុមការងារនៅថ្នាក់ភូមិ ឃុំ ស្រុក ដែលមាននៅក្នុងរចនាសម្ព័ន្ធ និងជាមួយបណ្តាលអង្គការដៃគូជាតិ អន្តរជាតិ ទៅតាមផែនការសកម្មភាពប្រចាំឆ្នាំ ដែលឆ្លើយតបទៅផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

បន្ថែមពីនេះទៀត ឧត្តមសេនីយ៍ត្រី ដួង ថាវរី ស្នងការរងនគរបាលខេត្ត ជាអនុប្រធានលេខាធិការដ្ឋាន បានស្នើឲ្យសហភាពអឺរ៉ុប បន្តជួយគាំទ្រលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា ពិសេសនៅក្នុងខេត្តសៀមរាប ឲ្យកាន់តែទូលាយ និងបានស្នើឲ្យអង្គការដៃគូដែលទទួលបានការគាំទ្រថវិកាពីសហភាពអឺរ៉ុប ធ្វើការពង្រីកគោលដៅឲ្យបានច្រើនបន្ថែមទៀត។

### វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ឃុំ-ថ្នាក់ស្រុក និងអ្នកពាក់ព័ន្ធ នៅស្វាយលើ

https://www.facebook.com/deputygovernoryousophear/ លេខាធិការដ្ឋាន គខបជសៀមរាប 20-11-2019

ខេត្តសៀមរាប៖ ថ្ងៃពុធ ទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រុមការងារបានបន្តចុះបណ្តុះបណ្តាលដល់ក្រុមការងារនៅឃុំ ស្រុក ដើម្បីពង្រឹងសមត្ថភាពដល់ក្រុមការងារក្នុងការអនុវត្តតួនាទីភារកិច្ច លើការបង្ការទប់ស្កាត់ ការបង្រ្កាបបទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការធ្វើចំណាកខុសច្បាប់ និងពង្រឹងលើកិច្ចសហប្រតិបត្តិការក្នុងការផ្តល់សេវាជួយជនរងគ្រោះឲ្យបានសមស្រប និងមានប្រសិទ្ធិភាព។

## តើពលករខ្មែរវាយតម្លៃរដ្ឋាភិបាលយ៉ាងណាស្តីពីបញ្ជូនពលករទៅធ្វើការនៅកូរ៉េខាងត្បូង?

http://bayontv.com.kh/ 20/11/2019

ភ្នំពេញ៖ តាមតួលេខចុងក្រោយពលករខ្មែរ ប្រមាណ៥ម៉ឺន៤៣ពាន់នាក់ កំពុងធ្វើការនៅប្រទេសកូរ៉េខាងត្បូងក្នុងវិស័យសំខាន់ៗចំនួន ៣គឺសំណង់ ឧស្សាហកម្ម និងកសិកម្ម។ វិស័យទាំងនេះ បានកំពុងតែផ្តល់នូវប្រាក់កម្រៃខ្ពស់ និងជំនាញផងដែរ។ តើពលករខ្មែរយើងវាយតម្លៃយ៉ាងដូចម្តេចលើរដ្ឋាភិបាលរបស់ខ្លួន ដែលបានបញ្ជូនពលកររាប់ម៉ឺននាក់ទៅកាន់កូរ៉េខាងត្បូងដែលជាទឹកដីនៃការអភិវឌ្ឍ? ជាមធ្យមទឹកប្រាក់ប្រមាណជាង ៦០០លានដុល្លារសហរដ្ឋអាមេរិក ក្នុងរយៈពេលមួយឆ្នាំៗ ត្រូវបានបញ្ជូនពីកូរ៉េខាងត្បូងមកកាន់ព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ នឹងបង្កើតឱកាសអាជីវកម្ម។ ទឹកប្រាក់រាប់រយលានដុល្លារនេះ គឺបានមកពីប្រជាពលករខ្មែរប្រមាណ៥៤០០០នាក់ដែលបច្ចុប្បន្នកំពុងបម្រើការងារនៅក្នុងទឹកដីកូរ៉េខាងត្បូង។ពលករខ្មែរបានអានថានេះ គឺជាឱកាសមួយដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជាដែលគ្មានអ្នកណាអាចប្រកែកបានឡើយ។

សូមបញ្ជាក់ផងដែរថា ពលករខ្មែរប្រមាណ ៥ម៉ឺនបួនពាន់នាក់នេះមានប្រមាណជា ១ម៉ឺននាក់គឺជាស្ត្រីដែលកំពុងបម្រើការងារនៅក្នុងវិស័យបីសំខាន់ៗគឺវិស័យសំណង់ឧស្សាហកម្មនិងកសិកម្ម។ វិស័យទាំង 3 នេះក្រៅពីផ្តល់ចំណេះជំនាញដល់ប្រជាពលរដ្ឋកម្ពុជាហើយវាក៏បានផ្តល់ប្រាក់កម្រៃ ដែលគិតជាមធ្យមប្រមាណពី 2 ពាន់ដុល្លារសហរដ្ឋអាមេរិចដល់៣០០០ដុល្លារសហរដ្ឋអាមេរិកក្នុងរយៈពេលមួយខែៗ។ ជាមួយនឹងមោទនភាពរបស់ពលករខ្មែរតាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតឱកាសធ្វើការនៅក្នុងប្រទេសកូរ៉េខាងត្បូង ពលករទាំងអស់មានក្តីរីករាយនិងចិត្តអន្ទះសាជាខ្លាំងនៅពេលដែលទទួលដំណឹងថានាយករដ្ឋមន្ត្រីរបស់ខ្លួន គឺសម្តេចតេជោ ហ៊ុន សែន នឹងទៅជួបសួរសុខទុក្ខនៅថ្ងៃទី២៤ខាងមុខក្នុងទីក្រុងប៊ូសានប្រទេសកូរ៉េខាងត្បូង។

ពួកគាត់បានអានថានេះ គឺជាកាយវិការយកចិត្តទុកដាក់ពីសំណាក់ប្រមុខរដ្ឋាភិបាលដែលកម្រថ្នាក់ដឹកនាំរូបណាធ្វើដូចសម្តេចនាយករដ្ឋមន្ត្រីបែបនេះណាស់ព្រោះក្រៅពីការបង្កើតឱកាសការងារហើយ ឆ្លៀតមកជួបដោយផ្ទាល់ដើម្បីស្វែងយល់ពីសុខទុក្ខនិងស្ថានភាពរបស់ពួកគាត់ថែមទៀតផង។ ពលករទាំងចំពោះកាយវិការ និងសណ្តានចិត្តរបស់សម្តេចតេជោប្រៀបដូចទៅនឹងឪពុកម្តាយខ្លួនយ៉ាងដូចនេះដែរ។

សូមបញ្ជាក់ថា សម្តេចនាយករដ្ឋមន្ត្រីនឹងធ្វើដំណើរទៅកាន់ប្រទេសកូរ៉េខាងត្បូងពីថ្ងៃទី២៤ ដល់ថ្ងៃទី ២៧ ខែវិច្ឆិកានេះដើម្បីចូលរួមកិច្ចប្រជុំអាស៊ានកូរ៉េ កិច្ចប្រជុំមេគង្គកូរ៉េ និងឆ្លៀតឱកាសសួរសុខទុក្ខពលករខ្មែរដែលកំពុងធ្វើការនៅប្រទេសកូរ៉េខាងត្បូងផងដែរ។ ទន្ទឹមនេះ ពលករខ្មែរក៏បានអំពាវនាវឱ្យពលករទាំងអស់នៅប្រទេសកូរ៉េខាងត្បូងចូលរួមក្នុងកម្មវិធីជួបសំណេះសំណាលជាមួយសម្តេចនាយករដ្ឋមន្ត្រីនៅថ្ងៃទី២៤ ខាងមុខដើម្បីបង្ហាញកម្លាំងសាមគ្គីនិងការស្រឡាញ់រាប់អានរវាងខ្មែរនិងខ្មែរដោយមិនប្រកាន់និន្នាការអ្វីទាំងអស់៕

## អភិបាលខេត្តកំពង់ចាម ស្នើឲ្យសមាគម និងអង្គការក្រៅរដ្ឋាភិបាល ចូលរួមការពារបរិស្ថាន ធនធានធម្មជាតិ និងការប្រយុទ្ធប្រឆាំង នូវបទល្មើសគ្រប់ប្រភេទ

https://dap-news.com/national/ Posted on November 21, 2019

កំពង់ចាម ÷ អភិបាលខេត្តកំពង់ចាម លោក អ៊ុន ចាន់ដា ស្នើសុំសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ចូលរួមការងារការពារបរិស្ថាន ធនធានធម្មជាតិ និងការប្រយុទ្ធប្រឆាំង នូវបទល្មើសគ្រប់ប្រភេទ ។ នេះជាការលើកឡើង របស់លោកអភិបាលខេត្ត ក្នុងពេលចូលរួមជាអធិបតី នៃវេទិកាស្តីពីការពិគ្រោះយោបល់ ជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ លើកទី ២ ឆ្នាំ ២០១៩ នាព្រឹកថ្ងៃទី ២១ ខែវិច្ឆិកាឆ្នាំ ២០១៩ នៅសាលា ខេត្តកំពង់ចាម ។ លោក អ៊ុន ចាន់ដា បានមានប្រសាសន៍ថា សមាគម និងអង្គការមិនមែនរដ្ឋា

ភិបាល ក្នុងស្រុក និងបរទេស ដែលមានទីតាំង ស្នាក់ការក្នុងខេត្តកំពង់ចាម សរុបមានចំនួន៤៨ ក្នុងនោះសមាគមមានចំនួន ១០(ក្នុងស្រុកចំនួន០៩ បរទេសចំនួន ០១) អង្គការមិនមែនរដ្ឋាភិបាល មានចំនួន៣៨ (ក្នុងស្រុកចំនួន២៨ , បរទេសចំនួន១០) និងមានសហគមន៍ សរុបចំនួន៩០ ក្នុងនោះមានសហគមន៍ប្រើ ប្រាស់ទឹកចំនួន៤១ បានចុះបញ្ជីចំនួន ២២ និងមិនទាន់ចុះបញ្ជីចំនួន១៩ សហគមន៍កសិកម្មចំនួន២៥ បានចុះបញ្ជី សហគមន៍ផលផលចំនួន២២ បានចុះបញ្ជី និងសហគមន៍ទេសចរណ៍ចំនួន០២ មិនទាន់បានចុះបញ្ជីចំនួន០១ ខេត្តក៏នៅមាន សហជីពតាមរោងចក្រ ចំនួន១៥ ផងដែរ ។

ជាមួយគ្នានោះ លោកអភិបាលខេត្ត បានស្នើដល់អង្គការក្នុងស្រុក និងបរទេស មិនមែនរដ្ឋាភិបាល សូមចូលរួមការងារ ការពារបរិស្ថាន ធនធានធម្មជាតិ និងការប្រយុទ្ធប្រឆាំងនូវបទល្មើសគ្រប់ប្រភេទ ដែលមានជាអាទិ៍ បទល្មើសកាប់បំផ្លាញព្រៃឈើ បទល្មើសជួញដូរចែកចាយគ្រឿងញៀន បទល្មើសសម្អាតប្រាក់ និងបទល្មើសជួញដូរមនុស្ស ដែលជាមូលហេតុ ធ្វើឱ្យប៉ះពាល់ដល់សុខសន្តិភាព សុវត្ថិ ភាពសង្គម និងការអភិវឌ្ឍន៍ប្រទេសជាតិយើង ។ លោកអភិបាលខេត្ត ក៏បានស្នើដល់ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល បន្តផ្តល់ការគាំទ្រ និងចូលរួមជាមួយរាជរដ្ឋាលកម្ពុជា ក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស សិទ្ធិសេរីភាព របស់ប្រជាពលរដ្ឋ និងសុខសន្តិភាព ស្ថិរភាពសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ឱ្យកាន់តែមានភាពរីកចម្រើនរុងរឿង ដោយចូលរួមគាំទ្រ ដល់គោលនយោបាយកំណែ ទម្រង់របស់រាជរដ្ឋាភិបាល ស្របតាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ជាពិសេសកំណែទម្រង់ រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ និងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌៕

## អ្នកប្តឹង និងអ្នកពាក់ព័ន្ធរឿងបាត់ខ្លួននាងក្រមុំកំពុងវ័ណ្ឌកជួចគ្នា

https://news.kohsantepheapdaily.com.kh/ By thida November 21, 2019

រាជធានីភ្នំពេញ ៖ ស្ត្រីវ័យកណ្តាលម្នាក់ជាអ្នកប្តឹង និងស្ត្រីវ័យចំណាស់ម្នាក់ទៀតជាប់ពាក់ព័ន្ធករណីធ្វើឱ្យបាត់ខ្លួននាងក្រមុំ ដែលសាច់ញាតិសង្ស័យថា មានគេនាំនាងជួញដូរឆ្លងដែនទៅប្រទេសចិននោះ ត្រូវបានកម្លាំងសមត្ថកិច្ចកងរាជអាវុធហត្ថបញ្ជូនខ្លួនស្ត្រីទាំង២នាក់ទៅកាន់សាលាដំបូងរាជធានីភ្នំពេញកាលពីរសៀលថ្ងៃទី២០ ខែវិច្ឆិកា ។

ស្ត្រីទាំង២នាក់ខាងលើនេះ ក្នុងនោះស្ត្រីជាជនជាប់ពាក់ព័ន្ធឈ្មោះ លឹម វ៉ាន់នី អាយុ៦៣ឆ្នាំ មានអាស័យដ្ឋានផ្ទះជួលដូរលុយឃីហោ«អាស៊ីវលុយ»លេខ៣៧០ មហាវិថីម៉ៅសេទុង មុខផ្សារដើមគ សង្កាត់ក្នុងសង្កាត់បឹងសាឡាងខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ចំណែកស្ត្រីម្នាក់ទៀតជាអ្នកប្តឹងឈ្មោះ តុច សុផល អាយុ៣៣ឆ្នាំ មានទីលំនៅក្នុងភូមិទួលក្រួស សង្កាត់ចំរើនផល ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ។

នៅសាលាដំបូងរាជធានីភ្នំពេញត្រូវបានគេដឹងថា ស្ត្រីឈ្មោះ លឹម វ៉ាន់នី ដែលសមត្ថកិច្ចចាប់សែងចេញពីក្នុងអគ្រឹងនាំយកទៅសាកសួររឿងបាត់នាងក្រមុំម្នាក់ នៅតែបដិសេធមិនទទួលស្គាល់ការចោទប្រកាន់នោះទេ ។ ចំណែកស្ត្រីឈ្មោះ តុច សុផល ដែលជាម្តាយមីងនាងក្រមុំបាត់ខ្លួន ដំបូងគាត់ជាអ្នកបំភ្លឺជូនសមត្ថកិច្ចរឿងបាត់ក្មួយស្រីគាត់ទេ ប៉ុន្តែការបំភ្លឺនោះ ត្រូវបានវ័ណ្ឌកធ្លាក់មកលើខ្លួនឯងវិញ ដោយសមត្ថកិច្ចរកឃើញថា គាត់ជាអ្នកនាំក្មួយស្រីមកប្រគល់ឲ្យស្ត្រីឈ្មោះ លឹម វ៉ាន់នី ។ តាមប្រភពដដែលបានបន្តថា ដូច្នេះម្តាយមីងឈ្មោះ តុច សុផល នេះក៏ជាប់ពាក់ព័ន្ធនឹងករណីជួញដូរមនុស្សនាំចេញឆ្លងដែនដោយខុសច្បាប់ដែរ ទើបត្រូវបានសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនទៅតុលាការជាមួយគ្នា ។ ទោះបីយ៉ាងណា សំណុំរឿងស្មុគ្រស្មាញមួយនេះ តំណាងអយ្យការសាលាដំបូងរាជធានីភ្នំពេញ កំពុងធ្វើការសាកសួរ នឹងនៅមិនទាន់ចោទប្រកាន់ជាផ្លូវការទេ ។

សូមរំលឹកថា កាលពីវេលាម៉ោង៣និង៣០នាទីរសៀលថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ កម្លាំងកងរាជអាវុធហត្ថខណ្ឌទួលគោកបានចាប់សែងស្ត្រីម្នាក់ឈ្មោះ លឹម វ៉ាន្នី ចេញពីក្នុងអគ្រឹងលើកដាក់ចូលរថយន្ត បន្ទាប់ពីហៅសាកសួររឿងបាត់នាងក្រមុំម្នាក់នោះ ដែលមិនព្រមសហការជាមួយសមត្ថកិច្ច ។ តាមប្រភពព័ត៌មានបានបន្តថា មុនដំបូងកម្លាំងសមត្ថកិច្ចកងរាជអាវុធហត្ថខណ្ឌទួលគោក បានទៅអញ្ជើញស្ត្រីវ័យចំណាស់នោះទៅធ្វើការសាកសួរនៅទីបញ្ជាការដ្ឋានកងរាជអាវុធខណ្ឌ តែគាត់មិនព្រមទៅទេ ថែមទាំងប្រកែកថា មិនបានដឹងមិនបានឮរឿងនោះទេ តែដោយសារមិនព្រមសហការ ទើបសមត្ថកិច្ចបានសុំគោលការណ៍ពីខាងព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញនាំខ្លួនតែម្តង ។ ខណៈឃើញស្ត្រីរូបនេះមានបំណងព្យាយាមគេចផង ទើបកម្លាំងកងរាជអាវុធហត្ថចាប់សែងចេញពីក្នុងអគ្រឹងលើកដាក់ក្នុងរថយន្ត និងដឹកទៅកាន់ទីបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញទៅ ។

ចំណែកស្ត្រីឈ្មោះ តូច សុផល ដំបូងបានរៀបរាប់ប្រាប់សមត្ថកិច្ចថា ក្មួយស្រីរបស់គាត់ឈ្មោះ ចាន់ ស្រីណយ អាយុ១៨ឆ្នាំ បានបាត់ខ្លួនមិនដឹងទៅណា បន្ទាប់ពីមកធ្វើការជាអ្នកលក់បាយ និងស្នាក់នៅផ្ទះវេរលុយខាងលើ ។ ស្ត្រីជាម្តាយមីងបានបន្តថា តាមរយៈអ្នកស្គាល់គ្នា គាត់បានយកកូនស្រី២នាក់ និងក្មួយស្រីម្នាក់ឲ្យមកធ្វើការជាមួយស្ត្រីឈ្មោះ លឹម វ៉ាន្នី ។ លុះក្រោយមកគាត់បានយកកូនទៅរៀនវិញ នៅសល់តែក្មួយស្រីវងគ្រោះនៅធ្វើការជាអ្នកលក់បាយអស់រយៈពេលជាង១ខែមកនេះ ។ ស្រាប់តែថ្មីៗនេះឃើញហ្វេសប៊ុកកូនស្រីរបស់ស្ត្រីឈ្មោះ លឹម វ៉ាន្នី បង្ហោះរូបថតក្មួយស្រីគាត់ជាមួយជនជាតិចិន ក៏មានការសង្ស័យថា ក្មួយស្រីរបស់គាត់ត្រូវបានគេនាំយកទៅលក់ឲ្យជនជាតិចិន ហើយគាត់បានទាក់ទងតាមទូរស័ព្ទដែរ តែក្មួយស្រីមិនលើកនោះទេ ។ ស្ត្រីជាម្តាយមីងបានបន្តទៀតថា ដោយសារមានរឿងដូច្នេះហើយ ទើបគាត់ធ្វើដំណើរមកភ្នំពេញដើម្បីសួរនាំស្ត្រីឈ្មោះ លឹម វ៉ាន្នី ដែរ តែគេមិនឆ្លើយ និងមិននិយាយ ថែមទាំងជេរប្រមាថទៀត ទើបគាត់ជាម្តាយមីងបានទៅប្តឹងសមត្ថកិច្ចតែម្តង ទីបំផុតខ្លួនជាអ្នកប្តឹងក៏ត្រូវវ័ណ្ឌកដែរ ។

ទោះបីជាយ៉ាងណាក្តី គេពុំទាន់ដឹងថា នាងក្រមុំដែលបាត់ខ្លួនខាងលើនោះ ត្រូវបានគេលក់ដូរមែនឬយ៉ាងណាទេ ហើយស្ត្រីវ័យចំណាស់នៅតែបដិសេធ ដូច្នេះមានតែតំណាងអយ្យការជាអ្នកសម្រេចលើជោគវាសនាស្ត្រីទាំង២នាក់នេះ ៕ (កែសម្រួលដោយ ៖ ធីតា)

## ពលករ៧នាក់ឆ្លងដែនកាប់ឈើគ្រញូងខុសច្បាប់ ត្រូវសមត្ថកិច្ចថៃបញ្ជូនប្រគល់ឲ្យកម្ពុជាតាមច្រកទ្វារអន្តរជាតិជាំ

http://nokorwatnews.com/archives/ 20-11-2019

ខេត្តឧត្តរមានជ័យ៖ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ អាជ្ញាធរថៃបានបញ្ជូនប្រជាពលរដ្ឋខ្មែរចំនួន ០៧ នាក់ តាមច្រកអន្តរជាតិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

ពលរដ្ឋទាំងនោះ ឈ្មោះដូចខាងក្រោម៖

១.ឈ្មោះ រិន ភារុន ភេទប្រុស អាយុ ២៦ ឆ្នាំ រស់នៅភូមិកន្ទួត ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។

២.ឈ្មោះ ស៊ឹង នី ភេទប្រុស អាយុ ៣៦ឆ្នាំ រស់នៅភូមិអូរតាម៉ូក ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

៣.ឈ្មោះ សែម រ៉ែម ភេទប្រុស អាយុ ៥៥ឆ្នាំ រស់នៅភូមិត្រាំសសរ ឃុំស្វាយទំពារ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

៤.ឈ្មោះ ឈួន ហៀង ភេទប្រុស អយុ ៥៥ឆ្នាំ រស់នៅភូមិទួលចារ ឃុំសំរោង ស្រុកសំរោង ខេត្តតាកែវ ។

៥.ឈ្មោះ សុខ វាសនា ភេទប្រុស អាយុ ៤៧ឆ្នាំ រស់នៅភូមិកំពង់ក្តី ឃុំកំពង់ចិនខាងត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ ។

៦.ឈ្មោះ ចាន់ ថន ភេទប្រុស អយុ៣៥ឆ្នាំ រស់នៅភូមិមានជ័យ ឃុំដំបូងរូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

៧.ឈ្មោះ វុទ្ធ ធី ភេទប្រុស អយុ៣៧ឆ្នាំបរស់នៅភូមិមានជ័យ ឃុំដំបូងរូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

ទាំង០៧នាក់ចាប់ខ្លួននៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ ពីបទឆ្លងដែនកាប់ឈើគ្រញូងខុសច្បាប់ ដាប់គុក នៅខេត្តស៊ីសាកេត ប្រទេសថៃ។ សមត្ថកិច្ចបានអោយដឹងថា ពលករទាំង៧នាក់ខាងលើ ឆ្លងដែនខុសច្បាប់កាប់ឈើគ្រញូង ចូលតាមច្រកក្បាលអូរហាសិប ស្ថិតនៅភូមិសាស្ត្រភូមិត្រពាំងបី ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ជាប់នឹងភូមិសាស្ត្រខាងថៃ ភូមិដូនហាវ ឃុំដូនហាវ ស្រុកឃុនហាន ខេត្តស៊ីសាកេត ។ ពលករខាងលើត្រូវបានសមត្ថកិច្ចអប់រំ និងអោយវិលត្រឡប់ទៅស្រុកកំណើតរៀងខ្លួន ៕ ប៉ែន នួន

## ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០១៩

## នាយករដ្ឋមន្ត្រី អះអាងថា កម្ពុជា-កូរ៉េ នៅមានសក្តានុពល ជាច្រើន អាចសហការជាមួយគ្នាបាន

https://dap-news.com/national/ ByCR101 Posted on November 21, 2019

ភ្នំពេញ៖ សម្តេចតេជោហ៊ុនសែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅក្នុងជំនួបជាមួយលោក ផាក ហ៊ឹង យ៉ុង (Park Heung Kyeong) ឯកអគ្គរដ្ឋទូត សាធារណរដ្ឋកូរ៉េថ្មី ប្រចាំនៅកម្ពុជានៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ បានអះអាងថា កម្ពុជា-កូរ៉េ នៅមានសក្តានុពលជាច្រើន អាចសហការជាមួយគ្នាបាន ។ នេះបើយោងតាមហ្វេសប៊ុកសម្តេចតេជោ នាយករដ្ឋមន្ត្រី។

នៅក្នុងជំនួបនេះ សម្តេចតេជោ ហ៊ុន សែន បានសំដែងនូវការអបអរសាទរ ចំពោះលោកឯកអគ្គរដ្ឋទូតថ្មី នៃសាធារណរដ្ឋកូរ៉េ ដែលត្រូវបានតែងតាំង ជាឯកអគ្គរដ្ឋទូតប្រចាំ នៅព្រះរាជាណាចក្រកម្ពុជា។ អ្វីដែលសំខាន់ នៅក្នុងជំនួបនេះ ក្រោយពីបានតែងតាំង ជាឯកអគ្គរដ្ឋទូត សាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា រួចហើយ គឺមាន ១)កិច្ចប្រជុំកំពូលរម្លឹកខួបអនុស្សាវរីយ៍ អាស៊ាន-កូរ៉េ និង ២)កិច្ចប្រជុំកំពូលមេគង្គ-កូរ៉េ ដែលកន្លងមកភាគីកូរ៉េ ក៏បានទទួលយក នូវគំនិតផ្តួចផ្តើមនេះ ដែលកាលពីមុនគឺ មានត្រឹមតែកម្រិតរដ្ឋមន្ត្រី តែប៉ុណ្ណោះ ប៉ុន្តែពេលនេះ គឺកម្រិតប្រមុខដឹកនាំរដ្ឋាភិបាលចូលរួម។ សម្តេចតេជោ ហ៊ុន សែន ពិតជាមានក្តីសមោនស្សរីករាយ ដែលភាគីកូរ៉េ ក៏ដូចជាប្រទេសមេគង្គ៤ផ្សេងទៀត បានទទួលយកគំនិតផ្តួចផ្តើម បង្កើនកម្រិតប្រមុខដឹកនាំ ប្រទេសអោយបានចូលរួម នៅក្នុងកិច្ចប្រជុំកំពូលមេគង្គ-កូរ៉េ។ សម្តេចតេជោនាយករដ្ឋមន្ត្រី នឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់ អញ្ជើញទៅចូលរួមក្នុងកិច្ចប្រជុំ កំពូលទាំងពីរខាងលើនេះ នៅសាធារណរដ្ឋកូរ៉េ នៅថ្ងៃអាទិត្យ ទី២៤ វិច្ឆិកា នេះ។

ឆ្លៀតក្នុងឱកាសនេះដែរ សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ រំលឹកពីទំនាក់ទំនង កូរ៉េ និងកម្ពុជា ដែលមានរូបសម្តេចផ្ទាល់ ជាស្ថាបនិកនៃទំនាក់ទំនងការទូតរវាង ប្រទេសទាំងពីរ ដែលមកដល់ពេលនេះ គឺមានការរីកចម្រើនយ៉ាងច្រើន លើគ្រប់វិស័យ រួមទាំងវិស័យការងារ សំរាប់ពលករខ្មែរ ជាង៥ម៉ឺននាក់ ដែលកំពុងធ្វើការនៅសាធារណរដ្ឋកូរ៉េនាបច្ចុប្បន្ន ដែលនាំមកនូវប្រាក់ចំណូលរាប់រយលានដុល្លារមកកម្ពុជា។ សម្តេចតេជោ គ្រោងនឹងជួបជាមួយបងប្អូនពលករខ្មែរនៅកូរ៉េ នៅថ្ងៃទី២៤ ខែវិច្ឆិកា ខាងមុខនេះ។

លោក Park Heung Kyeong ក៏បានអរគុណ សម្តេចតេជោនាយករដ្ឋមន្ត្រី ហើយបានបញ្ជាក់ជូន សម្តេចតេជោ ថា ក្នុងនាមលោក ជាឯកអគ្គរដ្ឋទូតថ្មី នឹងបន្តធ្វើ យ៉ាងណាឲ្យ កិច្ចសហប្រតិបត្តិការទ្វេភាគី បន្តមានភាពរីកចម្រើន ថែមទៀត ជាពិសេសនឹងជំរុញ ធ្វើយ៉ាងណាអោយបន្ត លើការអភិវឌ្ឍលើវិស័យផ្សេងៗ ដូចជាវិស័យពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ និងវិស័យផ្សេងៗទៀត។ ពាក់ព័ន្ធនឹងការដំឡើង កម្រិតនៃកិច្ចប្រជុំ រដ្ឋមន្ត្រីការបរទេស មេគង្គ កូរ៉េ ឲ្យទៅជាកម្រិតកិច្ចប្រជុំកំពូល រវាងមេដឹកនាំប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលមេគង្គកូរ៉េនោះ អគ្គរដ្ឋទូតក៏បានកោតសរសើរ សម្តេចតេជោនាយករដ្ឋមន្ត្រី នូវគំនិតផ្តួចផ្តើម ដ៏ឈ្លាសវៃរបស់ សម្តេចនាយករដ្ឋមន្ត្រី។

នៅក្នុងកិច្ចពិភាក្សាគ្នានេះដែរសម្តេចតេជោ ហ៊ុន សែន បានថ្លែងអំណរគុណដល់កូរ៉េដែលបានជួយដល់កម្ពុជា រួមទាំងភ្នាក់ងារ សហប្រតិបត្តិការអន្តរជាតិកូ រ៉េដែលនឹងផ្តល់ជំនួយ១០ លានដុល្លារ ដល់វិស័យដោះមីននៅកម្ពុជា។ សម្តេចតេជោបានបញ្ជាក់ផងដែរថា កម្ពុជានិងកូរ៉េគឺនៅមានសក្តានុពលជាច្រើន ដែលយើងអាចសហការជាមួយគ្នា

បាន។ ប៉ុន្តែសហប្រតិបត្តិការមួយដ៏សំខាន់ ដែលសម្តេចតេជោ ចង់បានធាប់បំផុតនោះ គឺចង់អោយមាន " កិច្ចព្រមព្រៀងពាណិជ្ជកម្ម សេរីវាងកម្ពុជា-កូរ៉េ" ដើម្បីធ្វើយ៉ាងណាបើកទីផ្សារ នៅកូរ៉េឲ្យបានច្រើន សម្រាប់ការនាំចេញ កសិផលកម្ពុជាទៅកាន់នោះ។ សម្តេចតេជោ បានជូនពរអោយ លោកឯកអគ្គរដ្ឋទូត Park Heung Kyeong ទទួលបានជោគជ័យ នៅក្នុងបេសកកម្មការទូតនៅកម្ពុជា៕ដោយ បាន ធារ៉ូ

## ពលករឆ្លងដែនកាប់ឈើគ្រញូងនៅទឹកដីថៃ ចំនួន២រូប ត្រូវសមត្ថកិច្ចថៃចាប់ខ្លួន

http://nokorwatnews.com/ 21-11-2019

ខេត្តឧត្តរមានជ័យ៖ មានសេចក្តីរាយការណ៍មកថា នៅវេលាម៉ោង១៣ និង៣០នាទីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០១៩ អាជ្ញាធរថៃ ស្រុកប៊ូឆេត បានជូនដំណឹងមកក្រុមការងារទំនាក់ទំនងព្រំដែនកម្ពុជា ថៃ ប្រកអន្តរជាតិជាំនៅ វេលាម៉ោង១៨និង៣០នាទីថ្ងៃទី២០ខែវិច្ឆិកា ឆ្នាំ២០១៩ មេព្រៃថៃ សហការជាមួយ ប៉ូលិសព្រំដែនលេខ ២១៤ ថៃ និងប៉ូលិសស្រុកប៊ូឆេត បានឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរចំនួន២នាក់ ស្ថិតនៅចំណុចខាងជើងច្រកកណ្តុល ឃុំប្រាច ស្រុកប៊ូឆេត ខេត្តសូរិនប្រទេសថៃ ។ ទី១៖ ឈ្មោះ ប្រាក់ ព្រំ អាយុ ១៩ឆ្នាំ រស់នៅ ភូមិ គ្រោះ ឃុំស្វាយជង្គំ ខេត្តសៀមរាប ទី២៖ ឈ្មោះ ជឿន ឈឿន ភេទប្រុស អាយុ១៧ឆ្នាំរស់នៅភូមិជើងភ្នំ ឃុំត្រពាំងប្រីយ៍ ស្រុក អន្លង់ វែង ខេត្តឧត្តរមានជ័យ ។ វត្ថុតាងឈើគ្រញូង៨ដុំរណារ ១ ពូថៅ០១ ។ ពលករទាំង០២នាក់ ត្រូវបានសមត្ថកិច្ច ថៃ បញ្ជូនទៅអធិការដ្ឋាននគរបាលស្រុកប៊ូឆេតខេត្តសូរិន ប្រទេសថៃ ដើម្បីចាត់ការតាមច្បាប់ប្រទេសថៃ ៕ ប៉ែន នួន

## សម្តេចប៉ាបអំពាវនាវឲ្យគោរព និងការពារកុមារ និងស្ត្រីរកស៊ីផ្លូវភេទ

http://km.rfi.fr/asia/ ដោយ ឈាង បុប្ផា 21/11/2019

សម្តេចប៉ាប ហ្វ្រង់ស័រ កាលពីថ្ងៃព្រហស្បតិ៍ម្សិលមិញ បានអំពាវនាវឲ្យអាជ្ញាធរថៃ ជួយការពារ ភាពថ្លៃថ្នូររបស់កុមារ និងស្ត្រីដែលរងគ្រោះដោយការជួញដូរផ្លូវភេទ និងទាសភាព នៅតំបន់អាស៊ីអាគ្នេយ៍។ សេចក្តីអំពាវនាវរបស់ប្រមុខសាសនាកាតូលិកនៃបុរីវ៉ាទីកង់ ធ្វើឡើងនៅពេលព្រះអង្គ យាងជួបលោកនាយករដ្ឋមន្ត្រីថៃ ប្រាយុទ្ធ ចាន់អូចា កាលពីថ្ងៃព្រហស្បតិ៍នៅទីក្រុងបាងកក។ នៅក្នុងជំនួបជាមួយប្រមុខរដ្ឋាភិបាលថៃ សម្តេចប៉ាប ហ្វ្រង់ស័រ បានលើកសរសើរកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលថៃ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរស្ត្រី និងកុមារ។ ប៉ុន្តែជាមួយគ្នានោះ ព្រះអង្គបានអំពាវនាវផងដែរសុំឲ្យអាជ្ញាធរថៃ ជួយធានាឲ្យកុមារបានទទួលអនាគតដ៏ថ្លៃថ្នូរ។ ដោយមិននិយាយដៅចំឈ្មោះ ប្រទេសណាមួយ សម្តេចសង្ឃកាតូលិក បានលើកឡើងថា ស្ត្រី និងកុមារ នៅក្នុងលោកយើងសព្វថ្ងៃ ត្រូវគេរំលោភបំពាន យ៉ាងហិង្សា និងកំពុងប្រឈមរាល់ការរំលោភ កេងប្រវ័ញ្ច ជួញដូរ គ្រប់រូបភាព។

នៅក្នុងទស្សនកិច្ចរយៈពេល៣ថ្ងៃ នៅប្រទេសថៃ សាររបស់សម្តេចសង្ឃកាតូលិក ផ្តោតសំខាន់ ទៅលើការជួយកុមារ ដែលងាយនឹងរងគ្រោះ ហើយនិងស្ត្រី ដែលរងគ្រោះ ដោយសារពេស្យាចារ និងការជួញដូរមនុស្ស។ នៅក្នុងសាររបស់ព្រះអង្គទៅកាន់ គ្រិស្តសាសនិក ថៃ ជាង ៦ម៉ឺននាក់ ដែលបានចូលទៅស្តាប់ព្រះអង្គនៅស្តាតក្នុងទីក្រុងបាងកក នៅរសៀលថ្ងៃព្រហស្បតិ៍ សម្តេចប៉ាប ហ្វ្រង់ស័របានមានសង្ឃដីការអំពាវនាវឲ្យសហគមន៍គ្រីស្តសាសនិកទាំងអស់ ជួយកុមារ ដែលរងគ្រោះដោយសារការជួញដូរ អ្នកញៀនថ្នាំញៀន ជនអន្តោប្រវេសន៍ ហើយនិងអ្នកសុំទានទាំងអស់ ដែលអាចជាម្តាយ បងប្អូនប្រុស ស្រីរបស់យើងទាំងអស់គ្នា។ សារអំពាវនាវរបស់សម្តេចប៉ាប ហ្វ្រង់ស័រដែលចង់ឲ្យមានការគោរពភាពថ្លៃថ្នូ និងជួយយកអាសារ កុមារ និងស្ត្រី រកស៊ីផ្លូវភេទ ធ្វើឡើងនៅក្នុងតំបន់មួយ ដែលល្បីល្បាញខ្លាំងខាងការជួញដូរមនុស្ស ហើយនិងការជួញដូរផ្លូវភេទ ដែលភាគច្រើនជាកុមារដែលរងគ្រោះខ្លាំងជាងគេ។

តាមរបាយការណ៍ឆ្នាំ ២០១៩ របស់អង្គការសហប្រជាជាតិ ៧០ភាគរយនៃជនរងគ្រោះដោយសារការជួញដូរផ្លូវភេទ មានអាយុតិចជាងអាយុស្របច្បាប់។ នៅប្រទេសថៃ ជាទីដែលពេស្យាចារជាអំពើខុសច្បាប់ គេរកឃើញមានមនុស្សជាង ៣សែននាក់ ធ្វើការនៅក្នុសេវាកម្មបម្រើផ្លូវភេទ ហើយនៅក្នុងនោះ ៤ភាគរយ គឺជាកុមារ។ នេះបើតាម

តួលេខផ្តល់ដោយ អាជ្ញាធរថៃ។ នៅប្រទេសថៃ ជាទីដែលមានប្រជាជន៩៥ភាគរយ គោរពពុទ្ធសាសនា ទស្សនកិច្ចរបស់ប្រមុខសង្ឃកាតូលិក នឹងបិទបញ្ចប់នៅថ្ងៃសុក្រ ជាមួយនឹងពិធីសូត្រធម៌ក្នុងវិហារមួយ ក្នុងទីក្រុងបាងកក មុននឹងយាងធ្វើដំណើរបន្តទៅប្រទេសកាន់ពុទ្ធសាសនាដ៏ធំមួយទៀត របស់អាស៊ី គឺប្រទេសជប៉ុន នៅថ្ងៃសៅរ៍៕

## ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស កោតសរសើរសិក្ខាកាមយកចិត្តទុកដាក់ក្នុងការរៀនសូត្រ ទទួលបានលទ្ធផលល្អប្រសើរ

http://cambodiapolice.com/policekh/ 12:42 pm 22 វិច្ឆិកា 2019 106

**ភ្នំពេញ ៖** ឯកឧត្តម ឧត្តមសេនីយ៍ឯកជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កោតសរសើរសិក្ខាកាមដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ថាបានយកចិត្តទុកដាក់ក្នុងការរៀនសូត្រ ទទួលបានលទ្ធផលល្អប្រសើរ។ មានប្រសាសន៍ខណៈដែល ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន តំណាងអោយ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ អញ្ជើញជាអធិបតីភាព ក្នុងពិធីបិទវគ្គបណ្តុះបណ្តាលស្តីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធដល់នគរបាលនាយកដ្ឋាន និងរាជធានី ខេត្ត នៅព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានបន្ថែមអោយដឹងថា៖សិក្ខាកាមទាំងអស់មានការយកចិត្តទុកដាក់ក្នុងការរៀនសូត្រ ស្តាប់គ្រូពន្យល់ និងខិតខំប្រឹងប្រែងទទួលយកនូវចំណេះដឹង និងបទពិសោធន៍ពីលោកគ្រូទាក់ទងទៅនឹងការប្រើប្រាស់ក្បាច់គុណ ដើម្បីការពារខ្លួនឯងផង និងប្រយុទ្ធប្រឆាំងបទល្មើសជួញដូរមនុស្ស ដែលត្រូវតែរួមគ្នាបង្កា ទប់ស្កាត់ បង្ក្រាប និងសង្គ្រោះជនរងគ្រោះ។ ឯកឧត្តម បានបន្តអោយដឹងថា ជាការពិតក្នុងវគ្គបណ្តុះបណ្តាលនេះផ្អែកទាំងស្រុងទៅលើកាយសម្បទា និងការប្រើប្រាស់កម្លាំង ហើយវគ្គបណ្តុះបណ្តាលនេះ ក៏បានផ្សាភ្ជាប់ទៅនឹងកិច្ចការដែលយើងត្រូវប្រើប្រាស់ក្នុងការងារប្រចាំថ្ងៃ និងឆ្លើយតបទៅនិងសកម្មភាពគ្រប់ទំរង់ នៃអំពើជួញដូរមនុស្ស ដែលរួមមានការជួញដូរមនុស្សឆ្លងកាត់ព្រំដែនដូចជាពាក់ព័ន្ធនិងកម្មករលើទូកនេសាទ ការបំរើកិច្ចការផ្ទះនៅប្រទេសក្រៅអាពាហ៍ពិពាយ៍ផ្ទុយពីធន្ទៈ ការសុំទារក និងមានករណីថ្មីមួយទៀតគឺការពពោះជំនួសជាដើម។ លើសពីនេះ ឯកឧត្តម ប្រធាននាយកដ្ឋាន ក៏បានផ្តាំផ្ញើអោយសិក្ខាកាមទាំងអស់មិនត្រូវយកចំណេះវិជ្ជាដែលទទួលបានពីការរៀនសូត្រទៅប្រើប្រាស់ខុសគោលដៅ និងជៀសវាងការប្រព្រឹត្តខុសឆ្គងផងដែរ។

គួរបញ្ជាក់ថា វគ្គបណ្តុះបណ្តាលមានរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២២ ខែវិច្ឆិកា ដោយមានការចូលរួម និងគាំទ្រពីសំណាក់អង្គការចំនួនពីរ គឺអង្គការមេត្រីអន្តរជាតិ (AIM SWAT) និងអង្គការ ចយ អិនធើណេស្យូណល(JOY international) ដែលមានគ្រូឧទ្ទេសនាមដែលមានបទពិសោធខ្ពស់មកពីសហរដ្ឋអាមេរិក ព្រមទាំងមានការចូលរួមពីសិក្ខាកាមជា នាយ នាយរងនគរបាលមកពីនាយកដ្ឋាន និងស្នងការដ្ឋានរាជធានីផង ខេត្តដែរ៕

# ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១៩

## សម្តេចតេជោៈ វត្តមានខ្ញុំនៅកូរ៉េ នឹងជួយឲ្យលក្ខខណ្ឌការងារកូនក្មួយពលករខ្មែរ កាន់តែល្អប្រសើរឡើង

https://dap-news.com/national/ ByKD102 Posted on November 23, 2019

ភ្នំពេញ៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានថ្លែងថា តាមរយៈវត្តមានសម្តេច អញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូល អាស៊ាន-កូរ៉េ និងមេគង្គ-កូរ៉េ នៅកូរ៉េ ៤ថ្ងៃនេះ នឹងជួយឲ្យលក្ខខណ្ឌការ របស់បងប្អូនពលករខ្មែរ កាន់តែល្អប្រសើរឡើង ។

ខាងក្រោមនេះជាខ្លឹមសារ ទាំងស្រុងរបស់សម្តេចតេជោ ហ៊ុន សែន បង្ហោះលើបណ្តាញសង្គមហ្វេសប៊ុក នៅថ្ងៃទី២៣ វិច្ឆិកានេះថា ៖ សុខសប្បាយជាទេបងប្អូនជនរួមជាតិ ពេញមួយសប្តាហ៍នេះខ្ញុំពិតជារវល់ខ្លាំង ជាមួយកិច្ចការជាតិសំខាន់ៗ រួមទាំងការសម្ពោធរោងចក្រស៊ីម៉ងត៍នៅខេត្តកំពត និងបើកការដ្ឋានកសាងផ្លូវ៣៤ខ្សែនៅខេត្តព្រះសីហនុ និងកិច្ចប្រជុំកំពូលអន្តរជាតិអាស៊ីប៉ាស៊ីហ្វិកលើកទី២ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ។ ក្រៅពីនេះ គឺជួបភ្ញៀវព្រឹកល្ងាចៗរកដកឃ្លាសឹងមិនរួច។ ប៉ុន្តែទោះបីរវល់បែបនេះក្តីគឺខ្ញុំពេញចិត្ត ក្នុងការបម្រើប្រទេសជាតិ ដើម្បីសុខសន្តិភាព និងការរីកចម្រើនរបស់បងប្អូនប្រជាពលរដ្ឋ។

នៅថ្ងៃអាទិត្យស្អែកនេះ គឺចាប់ពីថ្ងៃទី២៤ ដល់ ២៧ វិច្ឆិកា ខ្ញុំនឹងដឹកនាំគណៈប្រតិភូ ចេញទៅប្រជុំកំពូលអាស៊ាន កូរ៉េ និងមេគង្គកូរ៉េជាបន្ត។ ខ្ញុំសង្ឃឹមថានឹងបានជួបបងប្អូនប្រជាពលរដ្ឋ និងកូនក្មួយសិស្ស និស្សិត ព្រមទាំងកូនក្មួយពលករ ពលការនីដែលកំពុងធ្វើការនៅទីនោះផងដែរ។ តាមរយៈវត្តមានខ្ញុំនៅកូរ៉េ នឹងជួយអោយលក្ខ័ណ្ឌការងារកូនក្មួយកាន់តែល្អប្រសើរឡើង។ សូមជូនពរបងប្អូនជនរួមជាតិ និងកូនក្មួយសប្បាយរីករាយជួបជុំក្រុមគ្រួសារក្នុងថ្ងៃចុងសប្តាហ៍គ្រប់ៗគ្នា ៕

## ក្រសួងការងារ ដាក់កំហិតឲ្យម្ចាស់សហគ្រាសគ្រឹះស្ថានប្រញាប់ដាក់ពាក្យស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេស ឆ្នាំ២០២០ ឲ្យបានមុនដំណាច់ឆ្នាំនេះ

---

http://kampucheathmey.com/ 23/11/2019 10:40 Am

ភ្នំពេញ ៖ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់កំហិតឲ្យម្ចាស់សហគ្រាសគ្រឹះស្ថានទាំងឡាយណាដែលស្ថិតនៅក្នុងដែនអនុវត្ត នៃច្បាប់ ស្តីពីការងារត្រូវប្រញាប់ដាក់សំណើសុំការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេសឆ្នាំ២០២០ ឲ្យមុនដំណាច់ឆ្នាំ២០១៩នេះ ដើម្បីឲ្យពួកគេទទួលបានសិទ្ធិធ្វើការងារដោយស្របច្បាប់នៅប្រទេសកម្ពុជា។

លោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានណែនាំឲ្យម្ចាស់ ឬនាយកសហគ្រាសគ្រឹះស្ថានទាំងអស់ ត្រូវប្រញាប់ដាក់ពាក្យស្នើសុំអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស(កូតា)តាមរយៈគេហទំព័រwww.fwcms. mlvt. gov.kh ឲ្យបានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩នេះដាក់កំហិតដើម្បីជៀសវាងនូវការផាកពិន័យតាមច្បាប់ជាធរមាន។ នៅក្នុងសេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលបានចុះផ្សាយកាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ លោករដ្ឋមន្ត្រីបានមានប្រសាសន៍ថា «ជាក់ស្តែងក្រសួងសង្កេតឃើញថាម្ចាស់ ឬនាយកសហគ្រាសគ្រឹះស្ថានមួយចំនួននៅមានភាពយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស (កូតា) សម្រាប់ឆ្នាំ២០២០។ ចំពោះស្ថានភាពបែបនេះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនម្ចាស់ ឬនាយកសហគ្រាសគ្រឹះស្ថានថាក្រសួងបានពន្យារពេលសម្រាប់ការស្នើសុំលិខិតអនុញ្ញាតប្រើប្រាស់ហត្ថកម្មបរទេស(កូតា) សម្រាប់ឆ្នាំ២០២០ រហូតដល់ដំណាច់ឆ្នាំ២០១៩»។ លោករដ្ឋមន្ត្រីបានបន្តទៀតថាចំពោះការខកខានមិនបានស្នើសុំការអនុញ្ញាត និងប្រើប្រាស់ហត្ថពលកម្មបរទេសដោយខុសច្បាប់ ក្រសួងនឹងចាត់វិធានការផាកពិន័យតាមទោសប្បញ្ញត្តិក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ នឹងចូលរួមអនុវត្តទាំតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

លោក មឿង តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្សធ្លាប់បានមានប្រសាសន៍ថាការតម្រូវសហគ្រាសគ្រឹះស្ថានដាក់ពាក្យស្នើសុំការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេសនេះ គឺដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងការពារជនបរទេសទាំងនោះដែលធ្វើការនៅប្រទេសកម្ពុជាពីការកេងប្រវ័ញ្ចកម្លាំងពលកម្ម ពិសេសអាចបង្កើនប្រាក់ចំណូលចូលថវិកាជាតិបានមួយកម្រិតផងដែរ។

គួរបញ្ជាក់ថា ឆ្នាំ២០១៨ កន្លងទៅនេះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តល់ប័ណ្ណ និងសៀវភៅការងារដល់ជនបរទេសដែលកំពុងធ្វើការ និងប្រកបមុខរបររកស៊ីនៅស្រុកខ្មែរបានចំនួនជាង១៣ម៉ឺន៩៣ពាន់នាក់៕

**អត្ថបទ ៖ សំអឿន**

## ចោទប្រកាន់ស្ត្រី២នាក់ពីបទនាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន

https://news.kohsantepheapdaily.com.kh/ By sreyna November 23, 2019

រាជធានីភ្នំពេញ ៖ លោក គុជ គីមឡុង ព្រះរាជអាជ្ញារង និងជាអ្នកនាំពាក្យអយ្យការសាលាដំបូងរាជធានីភ្នំពេញ បានឲ្យដឹង នារសៀលថ្ងៃទី២២ វិច្ឆិកា នេះថា តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចធ្វើការចោទប្រកាន់ស្ត្រី២នាក់ ពាក់ព័ន្ធធ្វើឲ្យបាត់នាងក្រមុំម្នាក់ពីបទ «ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន» ។ បទល្មើសនេះ បើយោងតាមបញ្ញត្តិមាត្រា១១ច្បាប់ ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តម្រូវឲ្យផ្តន្ទាទោសលើជនជាប់ចោទដាក់ពន្ធនាគារកំណត់ពី៧ ទៅ១៥ឆ្នាំ និងមានពិន័យជាប្រាក់ចូលថវិការដ្ឋទៀតផង ។ ក្រោយពីតំណាងអយ្យការធ្វើការចោទប្រកាន់ជាផ្លូវការហើយ សំណុំរឿងនេះ ត្រូវបានចាត់បញ្ជូនទៅចៅក្រមស៊ើបសួរ ដើម្បីសម្រេចឃុំខ្លួនស្ត្រីដែលជាជនសង្ស័យទាំងនាក់ ដាក់ពន្ធនាគារជាបណ្តោះអាសន្ន ។

ស្ត្រីម្នាក់ឈ្មោះ លឹម វ៉ាន់នី អាយុ៦៣ មានអាស័យដ្ឋានផ្ទះជួលដូរលុយឃីហោ(អាស៊ីវលុយ)លេខ៣៧០ មហាវិថីម៉ៅសេទុង មុខផ្សារដើមគ ស្ថិតក្នុងសង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ និងស្ត្រីម្នាក់ឈ្មោះ តុច សុផល អាយុ៣៣ឆ្នាំ មានទីលំនៅក្នុងភូមិទួលក្រួស សង្កាត់ចំរើនផល ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ហើយជនសង្ស័យទាំង២នាក់ បានធ្វើឲ្យបាត់នាងក្រមុំដែលសាច់ញាតិសង្ស័យថា អាចពួកគេរួមគំនិតគ្នាជួញដូរឆ្លងនាំដែនចេញទៅប្រទេសចិន ។

ជនសង្ស័យត្រូវកម្លាំងសមត្ថកិច្ចកងរាជអាវុធហត្ថខណ្ឌទួលគោកឃាត់ខ្លួន កាលពីថ្ងៃ១៨ វិច្ឆិកា និងបានបញ្ជូនទៅកាន់ទីបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ ចាត់ការតាមនីតិវិធី ។ សំណុំរឿងនេះ ដំបូងឡើយស្ត្រីឈ្មោះ តុច សុផល ដែលជាម្តាយមីងនាងក្រមុំបាត់ខ្លួន បានបំភ្លឺជូនសមត្ថកិច្ចរឿងបាត់ក្មួយស្រីគាត់ ប៉ុន្តែការបំភ្លឺនោះបានត្រូវវ៉ៃឆ្លកធ្លាក់មកខ្លួនឯងវិញ គឺគាត់ជាអ្នកនាំក្មួយមកប្រគល់ឲ្យស្ត្រីឈ្មោះ លឹម វ៉ាន់នី ដូច្នេះ ការស៊ើបអង្កេតបឋមត្រូវបានរកឃើញថា ជនសង្ស័យទាំង២នាក់ ពិតជាជាប់ពាក់ព័ន្ធពីបទ.ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែនពិតប្រាដជមែន ទើបបានតំណាងអយ្យការធ្វើការចោទប្រកាន់លើបទល្មើសនេះ ៕

## បង្កើតក្រុមប្រឆាំងបទល្មើស ទៅលើកុមារ តាមបណ្តាញអ៊ីនធឺណិត

http://www.cen.com.kh/archives/ November 23, 2019

ភ្នំពេញ៖ អង្គភាពការពារកុមារ (Child Protection Unit) នៅថ្ងៃទី២៣ខែវិច្ឆិកានេះ បានប្រកាសថា អនុញ្ញាតជាផ្លូវការ ពីអគ្គស្នងការនគរបាលជាតិ អង្គភាពការពារកុមារ បានបង្កើតឡើងក្រុមប្រឆាំងបទល្មើស ទៅលើកុមារតាមបណ្តាញអ៊ីនធឺណិត (ICAC) ដែលនេះ ជាការព្រមានសម្រាប់ជនណា ដែលប៉ុនប៉ងប្រព្រឹត្តបទល្មើស ទៅលើកុមារតាមបណ្តាញអ៊ីនធឺណិត។

លោក James McCabe នាយកប្រតិបត្តិការ អង្គភាពការពារកុមារ បានថ្លែងថា CPU ក្នុងកិច្ចសហប្រតិបត្តិការ ជាមួយនគរបាលជាតិកម្ពុជា មានភាពរំភើប និងមានមោទនភាព ប្រកាសអំពីការបង្កើតឡើងនូវក្រុមកម្លាំងការងារចម្រុះ JUNO ដែលជាក្រុមប្រឆាំងបទល្មើស ទៅលើកុមារតាមបណ្តាញអ៊ីនធឺណិត ហៅខ្លីថា 'ICAC'។ លោកនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានអនុញ្ញាតជាផ្លូវការ ក្នុងការបង្កើតឡើងក្រុម ICAC កាលពីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៩។ ប្រតិបត្តិការរបស់ក្រុមនេះ នឹងចាប់ផ្តើមដំណើរការភ្លាមៗ។ យើងសូម

ផ្តល់ការសរសើរ ជូនរាជរដ្ឋាភិបាលកម្ពុជា និងនគរបាលជាតិកម្ពុជា ដែលបានប្តេជ្ញាប្រឆាំង, ស្វែងរក, និងទប់ស្កាត់គ្រប់បទល្មើស ទៅលើកុមារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បទល្មើសទៅលើកុមារតាមបណ្តាញអ៊ីនធឺណិត គឺជាបញ្ហាដែលមាននៅជុំវិញពិភពលោក ឯប្រទេសកម្ពុជាកំពុងតែប្រឹងប្រែង ដើម្បីទប់ស្កាត់បទល្មើសទាំងនេះ មិនឲ្យកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

លោក James McCabe បានថ្លែងថា "យើងនៅកំពុងតែអភិវឌ្ឍ ICAC នៅឡើយ ដើម្បីស្វែងរកនីតិវិធីប្រសើរបំផុត ក្នុងការប្រមូលភស្តុតាង ប៉ុន្តែយើងមានភាពរីករាយ និងមោទនភាពយ៉ាងខ្លាំង ក្នុងកិច្ចសហប្រតិបត្តិការដ៏សំខាន់មួយនេះ "។ដោយៈបញ្ញាស័ក្តិ

## កម្ពុជា និងអូស្ត្រាលី រួមគ្នា ទប់ស្កាត់ អំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអ៊ីនធឺណិត និងប្រព័ន្ធបណ្តាញសង្គម

http://www.cen.com.kh/ November 23, 2019

ភ្នំពេញៈ ប្រធាននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា បានស្នើសុំដល់ស្ថានទូតអូស្ត្រាលី បន្តជួយជ្រោមជ្រែង លើការផ្តល់ជំនួយជាឧបករណ៍ បច្ចេកទេស ក៏ដូចជា ការបណ្តុះបណ្តាលដល់មន្ត្រីជំនាញ ក្នុងការបង្ការទប់ស្កាត់អំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអ៊ីនធឺណិត និងប្រព័ន្ធបណ្តាញសង្គម ។

នៅនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា នាថ្ងៃសុក្រ ទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ លោក ឧត្តមសេនីយ៍ឯក ជា ពៅ ប្រធាននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា បានអនុញ្ញាតមន្ត្រីតំណាងស្ថានទូតអូស្ត្រាលី ប្រចាំប្រទេសកម្ពុជា ចំនួន៤រូប គឺលោកស្រី Rebecca Goddard លោកស្រី Danielle Gardiner លោកស្រី Jennifer Burke និងលោក សិលា សារុំ ចូលជួបពិភាក្សាការងារ ដោយផ្តោតសំខាន់លើប្រធានបទស្តីពី សកម្មភាពបង្ការទប់ស្កាត់ អំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអ៊ីនធឺណិត និងប្រព័ន្ធបណ្តាញសង្គម ។

ភាគីមន្ត្រីតំណាងស្ថានទូតអូស្ត្រាលី មានគោលបំណងស្វែងយល់ ឲ្យកាន់តែច្បាស់អំពីស្ថានភាពទូទៅ នៃកិច្ចដំណើរការអនុវត្តការងារ របស់នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា ក្នុងការឆ្លើយតបនឹងការប្រយុទ្ធប្រឆាំង អំពើកេងប្រវ័ញ្ចផ្លូវភេទ លើកុមារតាមប្រព័ន្ធអ៊ីនធឺណិត ដើម្បីទទួលបានទិន្នន័យមូលដ្ឋាន សម្រាប់ការរៀបចំកិច្ចប្រជុំថ្នាក់តំបន់ស្តីអំពី "ការវិវឌ្ឍន៍ វិធីសាស្ត្រដោះស្រាយ ដើម្បីឆ្លើយតបចំពោះការទប់ស្កាត់ អំពើកេងប្រវ័ញ្ចកុមារតាមប្រព័ន្ធអ៊ីនធឺណិត" ដែលនឹងប្រារព្ធធ្វើឡើង នៅព្រះរាជាណាចក្រកម្ពុជា នាឆ្នាំ២០២០ ខាងមុខនេះ ។

លោក ឧត្តមសេនីយ៍ឯក បានគូសបញ្ជាក់ថា ទោះបីជានាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា ទើបបានបង្កើតថ្មី មានបទពិសោធន៍តិចតួច ពាក់ព័ន្ធនឹងបទល្មើសខាងលើ ក៏ដោយ ក៏នាយកដ្ឋាន មានរចនាសម្ព័ន្ធជាការិយាល័យជំនាញ ដែលមានការយកចិត្តទុកដាក់ ពិនិត្យទៅលើខ្លឹមសារលើប្រព័ន្ធអ៊ីនធឺណិត ក៏ដូចជាក្នុងបណ្តាញសង្គម ជាពិសេសបណ្តាញសង្គមហ្វេសប៊ុក ហើយក្នុងករណីដែលរកឃើញថា ខ្លឹមសារទាំងនោះ ល្មើសទៅច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា នាយកដ្ឋាន នឹងស្នើសុំសេចក្តីសម្រេចពីថ្នាក់ដឹកនាំ នៃអគ្គស្នងការនគរបាលជាតិ ដើម្បីដោះស្រាយបញ្ហាទាំងអស់នោះ។ លើសពីនេះទៅទៀត លោកឧត្តមសេនីយ៍ឯក បានបង្ហាញអំពីលទ្ធផល ការងារដែលសម្រេចបាន ដែលជាកិច្ចសហការជាមួយស្ថាប័នផ្សេងៗ មានដូចជា កិច្ចសហការកោសល្យវិច័យឧបករណ៍អេឡិកត្រូនិក ដែលទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន ក៏ដូចជាបណ្តាស្នងការរាជធានី-ខេត្តផ្សេងៗ ដែលមានបទល្មើសខាងលើនេះ បានកើតឡើង។

ទោះបីជាយ៉ាងណាក៏ដោយ លោកឧត្តមសេនីយ៍ឯក បានសម្តែងនូវក្តីបារម្ភ ដោយលោកបានបញ្ជាក់ថា ថ្នាក់ដឹកនាំអគ្គស្នងការនគរបាលជាតិ មានការព្រួយបារម្ភចំពោះការវិវឌ្ឍន៍យ៉ាងឆាប់រហ័ស របស់បច្ចេកវិទ្យាអ៊ីនធឺណិត ពីមួយថ្ងៃទៅមួយថ្ងៃ ដែលអាចនឹងជះឥទ្ធិពលអវិជ្ជមាន ដល់កុមារតូចៗ ពីព្រោះថាបច្ចុប្បន្ន ឪពុកម្តាយភាគច្រើន ផ្តល់ឱ

កាសឲ្យកូនតូចរបស់ខ្លួន ប្រើប្រាស់ទូរស័ព្ទដៃ ដែលមានកម្មវិធី ចូលទៅប្រើប្រាស់អ៊ីនធឺណិត និងកម្មវិធីបណ្ដាញសង្គមផ្សេងៗ ហើយភាគច្រើន ការប្រើប្រាស់នោះពុំមានសុវត្ថិភាព ដោយសារតែពួកគាត់ ខ្វះនូវចំណេះដឹងនៃការប្រើប្រាស់ ដែលអាចនាំឲ្យក្លាយខ្លួនទៅជាជនរងគ្រោះ នៃអំពើកេងប្រវ័ញ្ចផ្លូវភេទនេះតែម្ដង។

ឆ្លៀតក្នុងឱកាសនេះដែរ លោកឧត្តមសេនីយ៍ឯក ប្រធាននាយកដ្ឋាន ក៏បានស្នើសុំដល់ស្ថានទូតអូស្ត្រាលី បន្តជួយជ្រោមជ្រែង លើការផ្ដល់ជំនួយជាឧបករណ៍បច្ចេកទេស ក៏ដូចជាការបណ្ដុះបណ្ដាលដល់មន្ត្រីជំនាញ ដោយផ្អែកលើបទពិសោធន៍ជាក់ស្ដែង ដែលមន្ត្រីនគរបាលអូស្ត្រាលីជួបប្រទះ និងដោះស្រាយកន្លងមក។ ជាចុងបញ្ចប់ លោកឧត្តមសេនីយ៍ឯក បានថ្លែងអំណរគុណដល់តំណាងស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា ជាពិសេសមន្ត្រីនគរបាលអូស្ត្រាលី ដែលតែងតែសហការល្អ ជាមិត្តល្អ ក្នុងចែករំលែកបទពិសោធន៍ ចំណេះដឹង ដល់មន្ត្រីនគរបាលជាតិកម្ពុជា៕ ដោយៈកូឡាប

## វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ឃុំ-ថ្នាក់ស្រុក និងអ្នកពាក់ព័ន្ធ នៅស្រុកអង្គរធំ

https://www.facebook.com/deputygovernoryousophear/ November 23 at 9:41 PM

ខេត្តសៀមរាប៖ ថ្ងៃសុក្រទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រុមការងារបានបន្តចុះបណ្តុះបណ្តាលដល់ក្រុមការងារនៅឃុំ ស្រុក ដើម្បីពង្រឹងសមត្ថភាពដល់ក្រុមការងារក្នុងការអនុវត្តតួនាទីភារកិច្ច លើការបង្ការទប់ស្កាត់ ការបង្ក្រាបបទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ការធ្វើចំណាកខុសច្បាប់ និងពង្រឹងលើកិច្ចសហប្រតិបត្តិការក្នុងការផ្តល់សេវាជួយជនរងគ្រោះឲ្យបានសមស្រប និងមានប្រសិទ្ធិភាព។ ក្រុមការងារលេខាធិដ្ឋានបានជំរុញឲ្យអាជ្ញាធរភូមិ ឃុំ និងស្រុក ពិនិត្យធ្វើបច្ចុប្បន្នកម្មលើប្រជាពលរដ្ឋដែលចំណាស្រុកទៅក្រៅប្រទេស ដើម្បីទទួលបានបច្ចុប្បន្នភាពជាក់លាស់ ងាយស្រួលក្នុងការគ្រប់គ្រង ឬការផ្តល់ណាមួយសម្រាប់ពួកគាត់ ឲ្យការធ្វើចំណាកស្រុកដោយសុវត្ថិភាព ទទួលបានការពារសិទ្ធសមស្រប គ្មានការជួញដូរកំលាំងពលកម្ម ឬការកេងប្រវ័ញ្ចផ្សេងៗ។

## CPU ព្រមានចាត់វិធានការ ចំពោះអ្នកប្រព្រឹត្តល្មើសលើកុមារតាមអ៊ីនធឺណិត

https://www.postkhmer.com/ រី សុចាន់ | Publication date 25 November 2019 | 13:28 ICT

**ភ្នំពេញៈ** អង្គភាពការពារកុមារ (Child Protection Unit) ហៅថា CPU បានព្រមានដល់ជនដែលប៉ុនប៉ងប្រព្រឹត្តបទល្មើសទៅលើកុមារតាមអ៊ីនធឺណិតដោយអះអាងថា ការប្រឆាំងបទល្មើសនេះនឹងចាប់ផ្ដើមអនុវត្តភ្លាមៗ ស្របពេលដែលក្រុមប្រតិបត្តិការនេះទើបត្រូវបានបង្កើតថ្មីៗនេះ។

លោក James McCabe នាយកប្រតិបត្តិការអង្គភាពការពារកុមារបានសរសេរក្នុងទំព័រហ្វេសប៊ុក CPU កាលពីថ្ងៃសៅរ៍ថា ក្នុងកិច្ចសហប្រតិបត្តិការជាមួយនគរបាលជាតិកម្ពុជា CPU បានបង្កើតក្រុមប្រឆាំងបទល្មើសទៅលើកុមារតាមបណ្ដាញអ៊ីនធឺណិតហៅកាត់ថា ICAC។ លោក James បានសរសេរថា៖ «ឯកឧត្ដមនាយឧត្ដមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិបានអនុញ្ញាតជាផ្លូវការក្នុងការបង្កើតឡើងក្រុម ICAC កាលពីថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០១៩។ ប្រតិបត្តិការរបស់ក្រុមនេះនឹងចាប់ផ្ដើមដំណើរការភ្លាមៗ»។ លោក James ថា៖ «យើងនៅកំពុងតែអភិវឌ្ឍ ICAC នៅឡើយ ដើម្បីស្វែងរកនីតិវិធីប្រសើរបំផុតក្នុងការប្រមូលភ័ស្តុតាង ប៉ុន្តែយើងមានភាពរីករាយ និងមោទនភាពយ៉ាងខ្លាំងចំពោះកិច្ចសហប្រតិបត្តិការដ៏សំខាន់មួយនេះ»។ នៅក្នុងសំណេរនោះលោក James បានសរសើរដល់រដ្ឋាភិបាល និងនគរបាលជាតិកម្ពុជាចំពោះការប្ដេជ្ញាចិត្តប្រឆាំងទប់ស្កាត់គ្រប់បទល្មើសលើកុមារនៅកម្ពុជា។ លោកបន្តថា បទល្មើសទៅលើកុមារតាមអ៊ីនធឺណិតគឺជាបញ្ហាដែលមាននៅជុំវិញពិភពលោក ឯប្រទេសកម្ពុជាកំពុងតែប្រឹងប្រែងដើម្បីទប់ស្កាត់បទល្មើសទាំងនេះ។

លោក James បានបញ្ជាក់ប្រាប់ភ្នំពេញប៉ុស្ដិ៍កាលពីម្សិលមិញថា រឿងទោសទណ្ឌ វាអាស្រ័យលើការប្រព្រឹត្ត។ ឧទាហរណ៍ ប្រសិនបើជនល្មើសបានលួងលោមរួមភេទជាមួយអនីតិជន ជននោះនឹងចោទពីបទរួមភេទ

ជាមួយអនីតិជនដែលមានទោសទណ្ឌធ្ងន់ធ្ងរ។ ក្រៅពីនេះមានបទល្មើសផ្សេងទៀតទាក់ទងនឹងរូបអាសអាភាស។ លោកថា៖ «រហូតមកទល់ពេលនេះ យើងបានចាប់ខ្លួនជនល្មើសម្នាក់ដែលបានលួងលោមក្មេងស្រីអាយុ ១២ ឆ្នាំតាមអ៊ីនធឺណិត ហើយបន្ទាប់មកបានរួមភេទជាមួយក្មេងស្រីនោះ»។ លោកបន្តថា នៅដើមឆ្នាំនេះ ក៏មានមនុស្ស ៩ នាក់នៅសៀមរាបបានចែករូបអាសអាភាសកុមារតាមអ៊ីនធឺណិតផងដែរ។ លោក James ថ្លែងថា វាជាកិត្តិយសចំពោះរដ្ឋាភិបាល និងនគរបាលជាតិកម្ពុជាដែលបានមើលឃើញបញ្ហាជាមុន ហើយបានត្រៀមលក្ខណៈប្រយុទ្ធ និងដោះស្រាយបញ្ហាដែលកើតមានឡើងជាសកលនេះ។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សបានប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញថា អ្វីដែលក្រសួងត្រូវធ្វើនោះគឺអាចត្រួតពិនិត្យការឆ្លើយឆ្លងតាមប្រព័ន្ធបច្ចេកវិទ្យាបាន ប៉ុន្តែសំខាន់ត្រូវការកិច្ចសហប្រតិបត្តិការរវាងអ្នកពាក់ព័ន្ធ។ លោកស្រីបញ្ជាក់ថា៖ «រឿងសំខាន់គឺទំនាក់ទំនងតាមប្រព័ន្ធអនឡាញហ្នឹងដែលក្មេងៗនៅស្រុកខ្មែរយើងហ្នឹងភាគច្រើនគាត់ប្រើអនឡាញ ហើយជនដែលឆ្លៀតឱកាសទាក់ទងតាមហ្នឹង។ មិនមែនតែក្មេងៗទេ សូម្បីតែមនុស្សមានវ័យធំ វ័យចំណាស់ក៏គាត់ប្រើអាហ្នឹង។ ពេលខ្លះដោយសារតែគាត់បានឃើញ បានដឹងរឿងតាមប្រព័ន្ធអនឡាញហ្នឹង គាត់យកទៅអនុវត្តជាមួយក្មេងៗ...»។ លោកស្រី ជូ ប៊ុនអេង បានថ្លែងថា ករណីបែបនេះក្រសួងមហាផ្ទៃមានតែត្រួតពិនិត្យពីព្រោះប្រសិនបើបិទប្រព័ន្ធទំនាក់ទំនងតាមបច្ចេកវិទ្យា ឬមួយ online គឺមិនអាចធ្វើទៅបានទេ ដោយសារក្រសួងមិនមែនជាម្ចាស់ server។ គេអាចបិទបានដោយអន្លើ ប៉ុន្តែមិនអាចបិទបានទាំងស្រុងនោះទេពីព្រោះអ្នកដែលចេះប្រើប្រាស់បច្ចេកវិទ្យា សូម្បីតែជនល្មើសក៏មានបច្ចេកទេសខ្ពស់ដែរ ។ លោកស្រីថា៖ «អ៊ីចឹងវាត្រូវតែតប្រជេញអ៊ីចឹង ។ បានន័យថា បទល្មើសកើតឡើងគឺយើងតាមស្រាវជ្រាវរកអ៊ីចឹងទៅ»៕

## អាជ្ញាធរថៃបញ្ជូនប្រជាពលរដ្ឋខ្មែរ០៥នាក់

https://www.facebook.com/cpnnews.net/ ចក្រភពព័ត៌មាន CPN News November 23 at 8:07 PM

ឧត្តរមានជ័យ: អាជ្ញាធរថៃបានបញ្ជូនប្រជាពលរដ្ឋខ្មែរចំនួន០៥ នាក់ តាមច្រកអន្តរជាតិជាំ ដែលមានឈ្មោះដូចខាងក្រោម។ ១, ឈ្មោះញ៉ែត វាសនា ភេទប្រុស អាយុ ២៧ឆ្នាំ រស់នៅភូមិអូរឈើទាល ឃុំជ្រេស ស្រុកឈូក ខេត្តកំពត។ ២,ឈ្មោះសៀង វុទ្ធី ភេទប្រុស អាយុ ៣១ ឆ្នាំ រស់នៅភូមិដំណាក់ត្រយឹង ឃុំខ្មៅយខាងត្បូង ស្រុកដងទង់ខេត្តកំពត។ ៣,ឈ្មោះសាយ ធី ភេទប្រុសអាយុ៣១ឆ្នាំ រស់នៅរស់នៅភូមិអូរក្រូច ឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបង។ ៤,ឈ្មោះជុំ ដន ភេទប្រុស អាយុ២៧ឆ្នាំរស់នៅរស់នៅភូមិអូរក្រូច ឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបង។ ៥,ឈ្មោះជិន ម៉េត ភេទប្រុសអាយុ ៦៨ ឆ្នាំរស់នៅភូមិបឹងមាលា ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាបអ្នកទាំង៥ចាប់ខ្លួននៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៧ ពីបទឆ្លងដែនកាប់ឈើជាប់គុកនៅខេត្តស៊ីសាកេត ប្រទេសថៃ ចូលតាមច្រកអូរស្វាយ ស្ថិតនៅភូមិ/ឃុំអូរស្វាយ ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ជាប់ខាងថៃភូមិ/ឃុំស្នឹងចាន់ ស្រុកឃុនហាន ខេត្តស៊ីសាកេត។ ដោយ: ចរិយា

## រថយន្តដឹកពលករខ្មែរ បុកនឹងរថយន្តអ្នកដំណើរ របួសធ្ងន់ស្រាល១៥នាក់ ក្នុងនោះកុមារ៣នាក់

http://kampucheathmey.com/ 25/11/2019 9:13 Am

បន្ទាយមានជ័យ ៖ មានករណីគ្រោះថ្នាក់ចរាចរណ៍មួយបានកើតឡើងនៅប្រទេសថៃ រវាងរថយន្តដឹកពលករទៅធ្វើការបេះផ្លែមៀន បុកជាមួយរថយន្តអ្នកធ្វើដំណើរ បណ្តាលឲ្យមានពលករខ្មែររងរបួសចំនួន១៥នាក់ ក្នុងនោះមានកុមាររងរបួសចំនួន៣នាក់ផងដែរ កាលពីវេលាម៉ោង១០យប់ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៩ ចំណុចផ្លូវជាតិវ៉ាំងណាមយ៉េន ត្រង់ផ្លូវបំបែកសួនប៉ា ក្នុងស្រុកវ៉ាំងណាមយ៉េន ខេត្តស្រះកែវ ប្រទេសថៃ។

បើតាមការអះអាងរបស់តម្រួតនៅស្រុកថៃបានឲ្យដឹងថា នៅមុនពេលកើតហេតុនោះ មានរថយន្តដឹកពលករខ្មែរធ្វើការបេះផ្លែមៀន១ក្រុម លុះបើកទៅដល់ចំណុចកើតហេតុនោះ ស្រាប់តែបើកទៅបុកនឹងរថយន្តអ្នកធ្វើដំណើរ បណ្តាលឲ្យមានពលករខ្មែរជិះក្នុងរថយន្តរងរបួសរដូករណែលពេញថ្នល់ជាតិ ហើយសមត្ថកិច្ចបានរាប់មនុស្សឃើញចំនួនរបួសធ្ងន់/ស្រាលមាន១៥នាក់ ក្នុងនោះ ក៏មានកុមាររងរបួស៣នាក់ផងដែរ។ ក្នុងហេតុការណ៍ខាងលើនោះដែរ តម្រួតថៃបានបញ្ជាក់ឲ្យដឹងទៀតថា ក្រោយពីកើតហេតុហើយជនរងគ្រោះត្រូវបានអាជ្ញាធរមូលដ្ឋានជួយដឹកបញ្ជូនទៅមន្ទីរពេទ្យដើម្បីសង្គ្រោះបន្ទាន់ ចំណែករថយន្ត សមត្ថកិច្ចថៃអូសយកទៅរក្សាទុកដើម្បីដោះស្រាយនៅពេលក្រោយ៕

## ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៩

## កាត់ទោសស្ត្រីខ្មែរចិន៣៨នាក់ក្នុងសំណុំរឿងពពោះជំនួស

http://kampucheathmey.com/ 25/11/2019 11:08 Pm

ភ្នំពេញ ៖ ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ នៅព្រឹកថ្ងៃទី ២៥វិច្ឆិកា ឆ្នាំ២០១៩នេះ បានបើកសវនាការលើសំណុំរឿងចាក់មេជីវិតចូលទៅក្នុងផ្ទៃស្ត្រីខ្មែរ ដើម្បីឲ្យពពោះជំនួសជនជាតិចិនដែលចង់បានកូន។ ជនជាប់ចោទទាំងអស់មានចំនួន៣៨នាក់ ក្នុងនោះមានជនជាប់ចោទដែលពពោះជំនួសចំនួន៣៣នាក់ និងជនជាប់ចោទដែលតុលាការឃុំខ្លួនហើយនាំយកមកកាត់ទោសឈ្មោះ ១ / Tiu Qiang ភេទប្រុស ជនជាតិចិន ឆ្នាំកំណើត១៩៦៩ ជាមេការ។

ទី ២ / ឈ្មោះ ស្វាយ ស៊ីណុច ហៅ សី ភេទស្រី ជនជាតិខ្មែរ អាយុ៣៤ឆ្នាំ ជាមេការ។ ទី៣ / ឈ្មោះ នឿន ស្រីឡាង ភេទស្រី អាយុ២៧ឆ្នាំ ជនជាតិខ្មែរជាមេការ។ ទី/ ៤ ឈ្មោះ លឹម សុភាព ហៅស្ទើង ភេទស្រី អាយុ១៩ឆ្នាំ ជាអ្នកបកប្រែ។ ទី៥ / ឈ្មោះ ថៃ ភាព ភេទស្រី អាយុ៤៣ឆ្នាំ ជាមេការ។ បុរសជនជាតិចិននិងនារីខ្មែរទាំង៥នាក់ ត្រូវបានជាប់ចោទក្នុងការប្រព្រឹត្តបទល្មើសលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន តាមមាត្រា១៦នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្សនិងការធ្វើអាជីវកម្មលើផ្លូវភេទ និងបទអន្តរការីរវាងអ្នកសុំកូននិងស្ត្រីពពោះជំនួស មាត្រា៣៣២នៃក្រមព្រហ្មទណ្ឌ។

សវនាការនេះ បានធ្វើឡើងពេញមួយថ្ងៃទៅ២៥វិច្ឆិកាតែម្តង ពោលគឺជំនុំជំរះតាំងពីព្រឹករហូតដល់យប់ ឈប់សម្រាកតែពេលបាយថ្ងៃត្រង់ប៉ុណ្ណោះ។ នៅក្នុងសវនាការថ្ងៃនេះ តុលាការទើបតែសាកសួរជនជាប់ចោទជនជាតិចិនឈ្មោះ Tiu Qiang ម្នាក់ប៉ុណ្ណោះ ដែលជាមេការធំរ៉ាប់រងកិច្ចការទូទៅរបស់ក្រុមហ៊ុននៅកម្ពុជា។ ជនជាប់ចោទរូបនេះបានសារភាពថា នៅកម្ពុជាខ្លួនមានតួនាទីមើលថែទាំនារីខ្មែរទាំងអស់ដែលចាក់បញ្ចូលមេជីវិតដើម្បីពពោះជំនួសគេ លុះដល់ពេលសំរាលកូន ខ្លួនមិនដឹងទៀតទេ ព្រោះមានគេចាត់ចែងកិច្ចការបន្តដើម្បីនាំក្មេងចេញទៅក្រៅប្រទេស។

សូមរំលឹកថា ការឃាត់ខ្លួនជនជាប់ចោទទាំង៥នាក់ខាងលើនេះ ធ្វើឡើងកាលពីវេលាម៉ោង៦ល្ងាច ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ចំណុចផ្ទះវីឡាលេខ២A ផ្លូវ៣៤៨ និងផ្ទះវីឡាលេខ៩A ផ្លូវ៣៤៨ ស្ថិតនៅក្នុងបុរី វិមានភ្នំពេញ តាមបណ្តោយផ្លូវលេខ៥ ក្នុងសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ។ ប្រតិបត្តិការណ៍នេះ មានការសម្របសម្រួល ពីលោក គុជ គីមឡុង ព្រះរាជអាជ្ញារង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដឹកនាំមន្ត្រីនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនរាជធានីភ្នំពេញ។ ក្នុងប្រតិបត្តិការនេះ ផ្ទះទី១ ផ្ទះផ្ទះលេខ២A ផ្លូវ៣៤៨ ឃាត់ខ្លួនមនុស្សបានចំនួន២៥នាក់ ប្រុស២នាក់ ដែលបុរសម្នាក់ ឈ្មោះ LIU QIANG ភេទប្រុស អាយុ៤៩ឆ្នាំ (ជនជាតិចិន) និងរថយន្ត១គ្រឿងម៉ាក់ស្តារិច ពណ៌ស ពាក់ស្លាកលេខ ព្រះសីហនុ ២A -៦៨៨៣ ម៉ូតូហុងដា today ពណ៌ខ្មៅ ១ គ្រឿង និងផ្ទះទី២ ផ្ទះលេខ៩A ផ្លូវ៣៤៨ ឃាត់ខ្លួនបានមនុស្សចំនួន១៨នាក់ រួមទាំងក្មេង២នាក់ និងរថយន្ត១គ្រឿង ម៉ាក់Lexus 470 ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ 2C-8863។ ថែមទាំងដកហូតឯកសារមួយចំនួន រួមមានលិខិតឆ្លងដែនមួយចំនួន និងឯកសារពាក់ព័ន្ធនឹងឱសថការពារទារកមួយចំនួនធំ។

តាមចម្លើយនារីពពោះជំនួសទាំង៣៣នាក់ គឺក្នុងកូន១ដែលពួកគាត់ពពោះជំនួសនេះទទួលបានប្រាក់កម្រៃចំនួន១ម៉ឺនដុល្លារ គិតចាប់ពីខែដំបូងឲ្យចំនួន៥០០ដុល្លារខែបន្ទាប់៣០០ដុល្លារ រហូតដល់កើត ទើបទទួលបានចំនួន៦០០០ដុល្លារបន្ថែមទៀត។ ចំពោះការថែទាំគភ៌ ការប្រសូត្រ គឺជាបន្ទុករបស់ក្រុមហ៊ុន។ លក្ខណៈពិសេសនៃការពពោះជំនួសក្នុងករណីនេះគឺពេលជិតដល់ត្រូវឆ្លងទន្លេ ប្រសូត្រ គឺក្រុមហ៊ុនបញ្ជូនស្ត្រីពពោះទៅប្រទេសចិនសម្រាលកូនរួច ទើបបញ្ជូនមកស្រុកខ្មែរវិញ ហើយប្រគល់លុយបង្គ្រប់១ម៉ឺនដុល្លារ។ ឥឡូវនេះស្ត្រីពពោះជំនួសទាំង៣៣នាក់ត្រូវបញ្ជូនឲ្យមន្ទីរសង្គមកិច្ចរាជធានីគ្រប់គ្រងបណ្តោះអាសន្នរង់ចាំសម្រេចពីតុលាការ។ ចំណែកមេការក្រុមហ៊ុនទាំង៥នាក់ ត្រូវបានបញ្ជូនឡើងតុលាការឃុំខ្លួនតាំងពីថ្ងៃទី២៨ មិថុនា ឆ្នាំ២០១៨ រហូតមកដល់ថ្ងៃកាត់ទោសនេះ៕ មករា

## បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ឃុំ-ថ្នាក់ស្រុក

http://www.rasmeinews.com/ November 26, 2019, 1:17 PM

*ដោយៈគួលៃន/សៀមរាប ៖* នៅសាលា ស្រុកប្រាសាទបាគង នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ មានបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅថ្នាក់ឃុំ-ថ្នាក់ស្រុក។ ពិធីបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ឃុំ-ថ្នាក់ស្រុក ក៏មានការអញ្ជើញចូលរួមពីលោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប ។

លោកស្រី ប៊ុន ទៀង អភិបាលរងស្រុកប្រាសាទបាគង បានថ្លែងអំណរគុណដល់ក្រុមការងារលេខាធិការដ្ឋានថ្នាក់ខេត្ត ដែលតែងតែចុះមកធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ក្រុមការងារនៅថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ ផ្ទាល់ជារៀងរាល់ឆ្នាំ។ លោកស្រី បានបន្តថា រដ្ឋបាលស្រុក បន្ទាប់ពីបានរៀបចំក្រុមការងារទាំងនៅថ្នាក់ស្រុក និងថ្នាក់ឃុំ ក្រុមការងារបានធ្វើការរៀបចំផែនការសកម្មភាព និងទទួលបានការគាំទ្រថវិកាពីរដ្ឋបាលស្រុកផងដែរ។ មិនតែប៉ុណ្ណោះ ក្រុមការងារ បានធ្វើការណែនាំ និងជំរុញដល់ក្រុមការងារនៅថ្នាក់ឃុំ ឲ្យមានការគ្រោងកញ្ចប់ថវិកាលើការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យបានសមស្របឆ្លើយតបទៅនឹងបញ្ហានិងតម្រូវក្នុងមូលដ្ឋានរបស់ខ្លួន។

លោកស្រី យូ សុភា បាននិយាយថា ដោយមានការសម្របសម្រួលពីក្រុមការងារបច្ចេកទេស (ក្រុមការងារកិច្ចការអនុវត្តច្បាប់ និងក្រុមការងារកិច្ចការទេសន្តរប្រវេសន៍) មកពីស្នងការរដ្ឋាននគរបាលខេត្ត និងមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវខេត្ត ។ វគ្គបណ្តុះបណ្តាលនេះ មានកិច្ចសហការជាមួយរដ្ឋបាលសាលាស្រុកប្រាសាទបាគង ដែលមានការគាំទ្រពីរដ្ឋបាលសាលាខេត្តសៀមរាប និងមានការចូលរួមគាំទ្រពីអង្គការ UN WOMEN និងអង្គការសកម្មភាពដើម្បីកុមារ (APLE) ផងដែរ ដើម្បីពង្រឹងសមត្ថភាព ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ឃុំ-សង្កាត់/ក្រុង-ស្រុក និងអ្នកពាក់ព័ន្ធ អំពីការអនុវត្តតួនាទីភារកិច្ច ច្បាប់ពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពានលើកុមារ និងពង្រឹងលើកិច្ចសហប្រតិបត្តិការក្នុងការផ្តល់សេវាជួយជនរងគ្រោះឲ្យបានសមស្របនិងមានប្រសិទ្ធិភាព។ លោកស្រី បានជំរុញដល់ក្រុមការងារ និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវយកចិត្តទុកដាក់ខ្ពស់បន្ថែមទៀតលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយត្រូវបង្កើនការបង្ការទប់ស្កាត់លើ ការកេងប្រវ័ញ្ចកំលាំងពលកម្ម ការកេងប្រវ័ញ្ចផ្លូវភេទ ការនាំឆ្លងដែនខុសច្បាប់ អំពើជួញដូរមនុស្ស និងការរំលោភបំពាននានា សំខាន់បន្ថែមលើការផ្សព្វផ្សាយអំពីច្បាប់ពាក់ព័ន្ធ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។ ដើម្បីការអនុវត្តសកម្មភាពទទួលបានប្រសិទ្ធភាព ទាំងក្រុមការងារថ្នាក់ស្រុក និងឃុំ ត្រូវរៀបចំផែនការសកម្មភាពបញ្ចូលទៅក្នុងកម្មវិធីវិនិយោគស្រុក-ឃុំ ដោយក្នុងនោះត្រូវលើកសកម្មភាពពាក់

ព័ន្ធនឹងសេវាសង្គម (ត្រូវគ្រោងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សផងដែរ) ដោយថ្នាក់ស្រុកត្រូវមានឬគ្រោងកញ្ចប់ថវិកាសេវាសង្គមយ៉ាងហោច១០% និងថ្នាក់ឃុំយ៉ាងហោចក៏៣០% ទៅតាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ។ លោកស្រីបានបញ្ជាក់ជូនផងដែរថា លេខាធិការដ្ឋាន នឹងខិតខំជួយគាំទ្រទៅដល់ថ្នាក់ស្រុក ឃុំ ទាំងបច្ចេកទេសតាមរយៈការពង្រឹងសមត្ថភាព ឬ តាមរយៈការជួយសម្របសម្រួល ករណីមានបញ្ហាពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សនៅក្នុងមូលដ្ឋានទូទាំង១២ ក្រុង-ស្រុក។ ដូចនេះ សូមគ្រប់ឃុំទាំងអស់ ត្រូវមានកិច្ចសហការរវាងជាថ្នាក់ស្រុក និងថ្នាក់ខេត្ត លើការអន្តរាគមន៍ករណី ឬការជួយផ្តល់សេវាជួយជនរងគ្រោះឲ្យបានសមស្រប និងមានប្រសិទ្ធិភាព៕B/

## រដ្ឋមន្ត្រីក្រសួងការបរទេស ស្នើកូរ៉េខាងត្បូង ពិចារណាបង្កើនចំនួនពលករកម្ពុជា ឱ្យបានច្រើនថែមទៀត

http://www.freshnewsasia.com/ 2019-11-25

**(ប៊ូសាន, សាធារណរដ្ឋកូរ៉េ)៖** ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានស្នើរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ (កូរ៉េខាងត្បូង) បង្កើនចំនួនពលករចូលធ្វើការនៅសាធារណរដ្ឋកូរ៉េ ឱ្យបានកាន់តែច្រើនថែមទៀត ខណៈបច្ចុប្បន្នផ្តល់បានប្រមាណ៦ពាន់នាក់ក្នុងមួយឆ្នាំ។ សំណើរបស់លោកឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន បានធ្វើឡើងនៅក្នុងជំនួបពិភាក្សាការងារទ្វេភាគីជាមួយលោកស្រី កាង ឃៀង-វ៉ា រដ្ឋមន្ត្រីក្រសួងការបរទេសសាធារណរដ្ឋកូរ៉េនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ។

លោក ឡុង ឌីម៉ង់ ឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ ដែលអមលោកឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ចូលរួមជំនួបពិភាក្សានេះ បានឱ្យ Fresh News ដឹងថា នៅក្នុងជំនួបនោះ លោកឧបនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណដល់សាធារណរដ្ឋកូរ៉េ ដែលបានផ្តល់ការងារជូនពលករខ្មែរ។ លោកឧបនាយករដ្ឋមន្ត្រី បានគូសរំលេចថា ពលករខ្មែរដែលបានមកធ្វើការនៅសាធារណរដ្ឋកូរ៉េនេះ មិនត្រឹមតែទទួលបានចំណូលខ្ពស់សម្រាប់ទ្រទ្រង់ជីវភាពផ្ទាល់ខ្លួន និងគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែថែមបានជួយឱ្យពួកគេមានជំនាញខ្ពស់សម្រាប់ប្រកបរបរនៅពេលត្រលប់ទៅកម្ពុជាវិញផងដែរ។ លោក ឡុង ឌីម៉ង់ បានបញ្ជាក់យ៉ាងដូច្នេះ «**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានស្នើសុំឱ្យមានការបង្កើនកូតាបន្ថែមទៀត។ ការបង្កើនកូតានេះ មិនត្រឹមតែជួយឱ្យពលរដ្ឋកម្ពុជាទទួលបានប្រាក់ឈ្នួលខ្ពស់នោះទេ ប៉ុន្តែបានទាំងជំនាញថែមទៀត**»។ លោកឯកអគ្គរាជទូត បានបន្ថែមថា លោកស្រី កាង ឃៀង-វ៉ា មិនទាន់មានការឆ្លើយតបបែបណានៅឡើយទេចំពោះសំណើនេះ។ ប៉ុន្តែលោកស្រី បានបង្ហាញការរីករាយនៅពេលសាធារណរដ្ឋកូរ៉េ បានរួមចំណែកធ្វើឱ្យជីវភាពប្រជាពលរដ្ឋខ្មែរបានប្រសើរតាមរយៈការងារនេះ។ លោកស្រី ក៏បានបញ្ជាក់ផងដែរថា សាធារណរដ្ឋកូរ៉េមានលក្ខខណ្ឌការងារច្បាស់លាស់ និងមានការគាំពារខ្ពស់ដល់សិទ្ធិ សុខមាលភាពរបស់ពលករ។

លោកស្រីរដ្ឋមន្ត្រីការបរទេសសាធារណរដ្ឋកូរ៉េ ក៏បានអះអាងដែរថា ពលករកម្ពុជា ដែលបាននិងកំពុងធ្វើការនៅក្នុងប្រទេសកូរ៉េនេះ បានរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់សាធារណរដ្ឋកូរ៉េផងដែរ។

សូមបញ្ជាក់ថា ការបញ្ជូនពលករកម្ពុជាទៅបម្រើការងារនៅសាធារណរដ្ឋកូរ៉េ ត្រូវបានចុះអនុស្សរណៈនៃការយោគយល់ក្រោមអធិបតីភាពរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា និង លោក Roh Moo-Hyun អតីតប្រធានាធិបតីសាធារណរដ្ឋកូរ៉េកាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៦។

គិតចាប់ពីឆ្នាំ២០០៧ រហូតមកត្រឹមឆ្នាំ២០១៩នេះ មានពលករសរុបចំនួន ៦៦,៥៦៥នាក់ បានបញ្ជូនមកបំពេញការងារនៅសាធារណរដ្ឋកូរ៉េ។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ មានពលករជាមធ្យមចំនួន ៦,០០០នាក់ បានទទួលការងារពីសាធារណរដ្ឋកូរ៉េក្នុងមួយឆ្នាំៗ។ របាយការណ៍របស់ក្រសួងការងារបានអះអាងថា ពលករកម្ពុជាដែលកំពុងបម្រើការងារនៅប្រទេសកូរ៉េធ្វើលើវិស័យសំខាន់ៗចំនួន៣ រួមមាន៖ វិស័យកសិកម្ម ឧស្សាហកម្ម និងសំណង់។

ពួកគេអាចទទួលបានប្រាក់ខែពី ១,៥០០ ទៅ ២,០០០ដុល្លារ និងមួយចំនួនទៀត ទទួលបានជាង ៣,០០០ដុល្លារ ក្នុងមួយខែ។ ក្នុងចំណោមពលករមកពីប្រទេសចំនួន១៦ ដែលកំពុងបម្រើការងារនៅសាធារណរដ្ឋកូរ៉េ ពលករកម្ពុជា ទទួលបានការសរសើរថា មានភាពអត់ធ្មត់នឹងការងារ ហើយក៏ទទួលបានការពេញចិត្តពីថៅកែផងដែរ៕

## រដ្ឋមន្ត្រីការបរទេសកម្ពុជា-កូរ៉េ បានចុះហត្ថលេខាលើឯកសារចំនួនពីរ ដើម្បីផ្តល់ការងារ និង បង្កើនពលករខ្មែរបន្ថែមទៀត

http://www.cen.com.kh/ November 26, 2019

កូរ៉េ ៖ ក្រសួងការបរទេសកម្ពុជា បានប្រកាសព័ត៌មានា នៅរសៀលថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ លោក ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន បានជួបពិភាក្សាទ្វេភាគីជាមួយលោកស្រី កាង យ៉ុង-វ៉ា (Kang Kyung-wha) រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋកូរ៉េ។ នៅចុងបញ្ចប់នៃជំនួប រដ្ឋមន្ត្រីការបរទេសទាំងពីរបាន ចុះហត្ថលេខាលើឯកសារចំនួនពីរ។

លោក ឡុង ឌីម៉ង់ ឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ ដែលអមលោកឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ចូលរួមជំនួបពិភាក្សានេះ បានឱ្យថា លោកឧបនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណដល់សាធារណរដ្ឋកូរ៉េ ដែលបានផ្តល់ការងារជូនពលករខ្មែរ។ លោកឧបនាយករដ្ឋមន្ត្រី បានលើកឡើងថា ពលករខ្មែរដែលបានមកធ្វើការនៅសាធារណរដ្ឋកូរ៉េនេះ មិនត្រឹមតែទទួលបានចំណូលខ្ពស់ សម្រាប់ទ្រទ្រង់ជីវភាពផ្ទាល់ខ្លួន និងគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែថែមបាន ជួយឱ្យពួកគេមានជំនាញខ្ពស់ សម្រាប់ប្រកបរបរនៅពេលត្រឡប់ទៅកម្ពុជាវិញ។ លោក ឡុង ឌីម៉ង់ បានបញ្ជាក់ថា លោកឧបនាយករដ្ឋមន្ត្រី បានស្នើសុំឱ្យមានការបង្កើនកូតាបន្ថែមទៀត។ ការបង្កើនកូតានេះ មិនត្រឹមតែជួយឱ្យពលរដ្ឋកម្ពុជាទទួលបានប្រាក់ឈ្នួលខ្ពស់នោះទេ ប៉ុន្តែបានទាំងជំនាញថែមទៀត។ លោកឯកអគ្គរាជទូត បានបន្ថែមថា លោកស្រី កាង ឃៀង-វ៉ា មិនទាន់មានការឆ្លើយតបបែបណានៅឡើយទេ ចំពោះសំណើនេះ។ ប៉ុន្តែលោកស្រី បានបង្ហាញការរីករាយ នៅពេលសាធារណរដ្ឋកូរ៉េ បានរួមចំណែកធ្វើឱ្យជីវភាព ប្រជាពលរដ្ឋខ្មែរ បានប្រសើរតាមរយៈការងារនេះ។ លោកស្រី ក៏បានបញ្ជាក់ផងដែរថា សាធារណរដ្ឋកូរ៉េ មានលក្ខខណ្ឌការងារច្បាស់លាស់ និងមានការគាំពារខ្ពស់ដល់សិទ្ធិ សុខុមាលភាពរបស់ពលករ។

លោកស្រីរដ្ឋមន្ត្រីការបរទេសសាធារណរដ្ឋកូរ៉េ ក៏បានអះអាងដែរថា ពលករកម្ពុជា ដែលបាននិងកំពុងធ្វើការនៅក្នុងប្រទេសកូរ៉េនេះ បានរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច របស់សាធារណរដ្ឋកូរ៉េ។

គួរកត់សម្គាល់ផងដែរថា ក្នុងដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ នៃរាជរដ្ឋាភិបាលកម្ពុជា លើទឹកដីកូរ៉េនេះ ក៏មានពលករខ្មែរជាច្រើននាក់ ដែលមាននិន្នាការប្រឆាំង និងជាសមាជិករបស់គណបក្សប្រឆាំង ដែលដឹកនាំដោយទណ្ឌិត សម រង្ស៊ី នៅកូរ៉េខាងត្បូង ត្រៀមខ្លួននិងកម្លាំង ដើម្បីធ្វើបាតុកម្ម ទាមទារឲ្យរដ្ឋាភិបាលសម្តេច ហ៊ុន សែន ស្តារប្រជាធិបតេយ្យនៅកម្ពុជាឡើងវិញ៕ ដោយៈកូឡាប

## យុទ្ធនាការ១៦ថ្ងៃជាសកលប្រឆាំងអំពើហិង្សាលើស្ត្រីចាប់ផ្តើមនៅថ្ងៃនេះ ក្នុងសកម្មភាពផ្សេងៗគ្នា

http://km.rfi.fr/cambodia/ ដោយ អ៊ឹង ប៊ុនថន 25/11/2019

នៅថ្ងៃចន្ទនេះ គឺជាថ្ងៃចាប់ផ្តើមនៃយុទ្ធនាការ១៦ថ្ងៃជាសាកល ក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រីភេទ ដែលចាប់ផ្តើមពីថ្ងៃទី២៥ ខែវិច្ឆិកា រហូតដល់ ថ្ងៃទី១០ ខែធ្នូ ខាងមុខ។ ក្រុមអ្នកធ្វើការងារខាងផ្នែក សិទ្ធិស្ត្រីនៅកម្ពុជាបានចាប់ផ្តើមសកម្មភាពរបស់ខ្លួននៅក្នុងរូបភាពផ្សេងៗគ្នា ខណៈគេកត់សំគាល់ឃើញថា អំពើហិង្សានៅក្នុងគ្រួសារ ពិសេសហិង្សាទៅលើស្ត្រីភេទនៅតែកើតមានជាបន្តបន្ទាប់ ហើយនៅជាក្តីកង្វល់ដដែល។

យោងតាមរបាយការណ៍ដែលផ្សព្វផ្សាយដោយអង្គការលីកាដូ បើគិតត្រឹមខែកញ្ញា ឆ្នាំ២០១៨ មានករណីហិង្សាលើក្មេងស្រីប្រមាណ១១០ករណី ក្នុងនោះមានករណីរំលោភសេពសន្ថវៈចំនួន៩០ករណី បានកើតឡើង ហើយមានករណីរំលោភសម្លាប់៨ករណី ដែលបានកត់ត្រា។ ការកើតមានអំពើហិង្សាគឺដោយសារតែកត្តាជាច្រើនរួមមាន ការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន ភាពក្រីក្រ និងការអនុវត្តច្បាប់ទៅលើជនល្មើសនៅមានភាពទន់ខ្សោយ។ នេះជាការកត់សំគាល់របស់ លោកស្រី ជឹម ចាន់នាង អគ្គលេខាធិការនៃគណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)។លោកស្រីបានបន្ទោសទៅលើភាពបរាជ័យនៃការប្រើប្រាស់ច្បាប់ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីថាមិនមានប្រសិទ្ធភាព។

បើតាមសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ សំណុំរឿងអំពើហិង្សាក្នុងគ្រួសារដែលត្រូវបានបិទបញ្ចប់ចំនួន ២៣៧ករណី ដែលលីកាដូបានឃ្លាំមើលចាប់ពីដើមឆ្នាំ២០១៤ ដល់ ចុងឆ្នាំ២០១៦។ មានជាង៤០ភាគរយនៃករណីទាំងនេះ ត្រូវបានបិទបញ្ចប់ដោយជនរងគ្រោះនៃអំពើហិង្សា ត្រឡប់ទៅរស់នៅជាមួយដៃគូដែលមានចរិតហិង្សាវិញ ហើយមានតែ២០ភាគរយប៉ុណ្ណោះដែលត្រូវបានបិទបញ្ចប់ដោយបណ្ដឹងព្រហ្មទណ្ឌប្រឆាំងនឹងជនល្មើស។ ករណីក្រៅពីនេះផ្សេងទៀត ត្រូវបានបិទបញ្ចប់ដោយប្តីប្រពន្ធរស់នៅផ្សេងគ្នា ឬលែងលះគ្នា ប៉ុន្តែមិនមានបណ្តឹងព្រហ្មទណ្ឌប្រឆាំងនឹងជនល្មើសទេ។

ការស្រាវជ្រាវបានរកឃើញថា មានករណីជាច្រើនដែលអាជ្ញាធរមិនបានទទួលស្គាល់ ឬចាត់ទុកអំពើហិង្សាក្នុងគ្រួសារថាជា បទល្មើសព្រហ្មទណ្ឌ ដូច្នេះហើយទើបពួកគាត់មិនសូវយកចិត្តទុកដាក់ខ្លាំងក្នុងការចាត់វិធានការលើករណីនេះ។ របាយការណ៍ដែលផ្សព្វផ្សាយដោយ អង្គការលីកាដូនេះសន្និដ្ឋានថា ការឆ្លើយតបចំពោះអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា នាពេលបច្ចុប្បន្ន ពុំទាន់មានប្រសិទ្ធភាពទេ ដោយសារស្ត្រីមានជម្រើសតិចតួចពេក ក្រៅតែពីការសម្រេចចិត្តបន្តរស់នៅជាមួយស្ថានភាពហិង្សា៕

## លោកស្រី តុង ណារី ជំរុញដល់ក្រុមការងារត្រូវសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ក្នុងការទប់ស្កាត់អំពើហិង្សា ការជួញដូរគ្រឿងញៀន

https://grandnewsasia.com/ 26-11-2019

កំពង់ឆ្នាំង៖ លោកស្រី តុង ណារី សមាជិកក្រុមប្រឹក្សាខេត្ត និងជាប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ខេត្តកំពង់ឆ្នាំង បានជំរុញដល់សមាជិក សមាជិកា របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត ត្រូវសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងមន្ទីរ អង្គភាពពាក់ព័ន្ធក្នុងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ, ទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ, ការកេងប្រវ័ញ្ចកំលាំងពលកម្មលើកុមារ, ការជួញដូរគ្រឿងញៀន និងចូលរួមរក្សាស្ថេរភាពជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានទទួលខុសត្រូវរបស់ខ្លួន និងផ្សព្វផ្សាយអោយប្រជាពលរដ្ឋចូលរួមគោរពច្បាប់ចរាចរណ៍ផ្លូវគោកទាំងអស់គ្នា។ លោកស្រី បានជំរុញបែបនេះនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅសាលប្រជុំ "គ"សាលាខេត្តកំពង់ឆ្នាំង ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំ ខែវិច្ឆិកា ឆ្នាំ២០១៩ និងលើកទិសដៅការងារអនុវត្តបន្តសម្រាប់ខែបន្ទាប់ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត ដោយមានការចូលរួមពីអនុប្រធាន សមាជិក សមាជិកា គ.ក.ស.ក ខេត្ត និងអង្គភាពពាក់ព័ន្ធក្នុងខេត្តចូលរួមផងដែរ ៕

# រដ្ឋមន្ត្រីការបរទេសកូរ៉េ បញ្ជាក់ថាពលករខ្មែរ បានរួមចំណែកយ៉ាងសំខាន់ ដល់ការអភិវឌ្ឍសេដ្ឋកិច្ច របស់សាធារណរដ្ឋកូរ៉េ

https://dap-news.com/national/ ByKD102 Posted on November 26, 2019

ភ្នំពេញ៖ លោកស្រី Kang Kyung-wha រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋកូរ៉េ បានគូសបញ្ជាក់ថា ពលករខ្មែរដែលស្នាក់នៅ និងធ្វើការងារនៅកូរ៉េ បានចូលរួមចំណែកយ៉ាងសំខាន់ ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច របស់សាធារណរដ្ឋកូរ៉េ ។ នេះបើយោងតាម AKP ។

យោងតាមសេចក្តីប្រកាសព័ត៌មាន របស់ក្រសួងការបរទេសខ្មែរ នៅថ្ងៃទី២៥ ខែវិច្ឆិកា បានឲ្យដឹងថា លោក ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសខ្មែរ បានជួបពិភាក្សាទ្វេភាគី ជាមួយលោកស្រី Kang Kyung-wha រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋកូរ៉េ ។ ក្នុងជំនួបទ្វេភាគីនោះ លោកស្រី Kang Kyung-wha បានស្វាគមន៍លោកឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន និងសម្តែងនូវការសោកស្តាយ ដែលសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា មិនអាចអញ្ជើញមកចូលរួមកិច្ចប្រជុំកំពូលរម្លឹកខួប អនុស្សាវរីយ៍អាស៊ាន-សាធារណដរដ្ឋកូរ៉េ និងកិច្ចប្រជុំកំពូលមេគង្គ-សាធារណរដ្ឋកូរ៉េលើកទី១ នៅទីក្រុងប៊ូសានបាន ដោយសារមាតាក្មេករបស់សម្តេចមានជំងឺធ្ងន់ធ្ងរ ដែលត្រូវការចាំបាច់នូវផ្សល់កម្លាំងចិត្ត និងការយកចិត្តទុកដាក់ពីក្រុមគ្រួសារ។ លោកស្រី ក៏បានពាំនាំនូវការជូនពរជ័យ ពីលោកប្រធានាធិបតី មូន ចែអ៊ិន ដែលជូនពរឲ្យមាតាក្មេករបស់ សម្តេចតេជោ ឆាប់ជាសះស្បើយពីជំងឺ។

លោក ប្រាក់ សុខុន បានថ្លែងអំណរគុណចំពោះលោកស្រី Kang Kyung-wha សម្រាប់ការទទួលបដិសណ្ឋារកិច្ចដ៏កក់ក្តៅ និងការជូនពររបស់លោកប្រធានាធិបតី មូន ចែអ៊ិន។ លោកឧបនាយករដ្ឋមន្ត្រី គូសបញ្ជាក់ថា សម្តេចតេជោ បានផ្តល់សារៈសំខាន់យ៉ាងខ្លាំង ចំពោះកិច្ចប្រជុំកំពូលទាំងពីរនេះ ពីព្រោះសម្តេចតេជោ គឺជាបុគ្គលដែលជំរុញយ៉ាងខ្លាំងក្នុងការឱ្យមានកិច្ចប្រជុំកំពូលរម្លឹកខួប អនុស្សាវរីយ៍អាស៊ាន-សាធារណរដ្ឋកូរ៉េ និងជាអ្នកដែលផ្តួចផ្តើមឲ្យកិច្ចសហប្រតិបត្តិការមេង្គ-សាធារណរដ្ឋកូរ៉េ ឈានឡើងដល់កម្រិតកិច្ចប្រជុំកំពូល។ លោកឧបនាយករដ្ឋមន្ត្រីក៏បានរម្លឹកដែរថា ទស្សនកិច្ចផ្លូវរដ្ឋរបស់លោកប្រធានាធិបតី មូន ចែអ៊ិន នៅកម្ពុជា កាលពីដើមឆ្នាំកន្លងមកនេះ គឺជាព្រឹត្តិការណ៍ដ៏សំខាន់និងបានរួមចំណែកធ្វើឱ្យទំនាក់ទំនងទ្វេភាគីកម្ពុជា-សាធារណរដ្ឋកូរ៉េកាន់តែស៊ីជម្រៅថែមទៀត។ លោកជឿជាក់ថា កិច្ចប្រជុំនៅក្នុងពេលនេះ នឹងរួមចំណែកធ្វើឲ្យកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីខ្ពស់ឡើងមួយកម្រិតថែមទៀត។ ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ក៏បានស្នើសុំការគាំទ្រ និងមានកិច្ចសហប្រតិបត្តិការ ពីសាធារណរដ្ឋកូរ៉េ នៅក្នុងវិស័យកសិ-ឧស្សាហកម្ម និងដំណើរការវេចខ្ចប់កសិកម្ម។ ទន្ទឹមគ្នានេះលោកឧបនាយករដ្ឋមន្ត្រី បានស្នើសុំឲ្យមានការគាំទ្រលើ គម្រោងព្រៃឈើចំនួនពីរ រួមមាន ការបង្កើតស្ថានីយ៍ដើមព្រៃឈើឡើងវិញ នៅខេត្តសៀមរាប និងការបង្កើនការគាំទ្រសម្រាប់ប្រតិបត្តិការ មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការព្រៃឈើមេគង្គ-សាធារណរដ្ឋកូរ៉េ។

ដោយឡែកចំពោះកិច្ចសហប្រតិបត្តិការ លើវិស័យពាណិជ្ជកម្ម រដ្ឋមន្ត្រីការបរទេសទាំងពីរ បានស្វាគមន៍ការចុះហត្ថលេខា ស្តីពីការសិក្សារួមគ្នាលើតំបន់ ពាណិជ្ជកម្មសេរីកម្ពុជា-សាធារណរដ្ឋកូរ៉េ ដែលនឹងជួយពាណិជ្ជកម្ម រវាងប្រទេសទាំងពីរកាន់តែកើនឡើងថែមទៀត។ ក្នុងឱកាសនោះ លោកឧបនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណដល់កូរ៉េ សម្រាប់ការរួមចំណែក ដល់ការអភិវឌ្ឍនៅក្នុង វិស័យហេដ្ឋារចនាសម្ព័ន្ធ តាមរយៈការបង្កើនកម្ចីសម្បទានពី ៣៥០ លានដុល្លារ ដល់៧០០លានដុល្លារ សម្រាប់ឆ្នាំ២០១៩-២០២៣។ លោកក៏បានថ្លែងអំណរគុណដល់កូរ៉េ សម្រាប់ជំនួយចំនួន ១០លានដុល្លារ ដើម្បីប្រតិបត្តិការដោះមីននៅខេត្តចំនួនបី ដែលរងគ្រោះដោយសារគ្រាប់មីនធ្ងន់ធ្ងរ គឺខេត្តបាត់ដំបង ប៉ៃលិន និងខេត្តបន្ទាយមានជ័យ។ ចំពោះវិស័យការងារវិញ លោកឧបនាយករដ្ឋមន្ត្រី ក៏បានថ្លែងអំណរគុណដល់កូរ៉េ ដែលបានបង្កើនចំនួនកូតាពលករខ្មែរ ទៅធ្វើការនៅសាធារណរដ្ឋកូរ៉េ ដែលមិនត្រឹមតែបានជួយឱ្យមាន

ចំណូល ខ្ពស់សម្រាប់ពលករ និងគ្រួសាររបស់ពលករប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានជួយឲ្យពួកគេមានជំនាញខ្ពស់សម្រាប់ប្រកបរបរ នៅពេលត្រលប់ទៅកម្ពុជាវិញ។

ជាការឆ្លើយតប លោកស្រី Kang Kyung-wha ទទួលយកសំណើរបស់កម្ពុជាពាក់ព័ន្ធ នឹងគម្រោងព្រៃឈើ ដើម្បីដាក់ជូនឯកឧត្តមប្រធានាធិបតី។ សម្រាប់វិស័យពាណិជ្ជកម្មទ្វេ ភាគីកម្ពុជា-សាធារណរដ្ឋកូរ៉េ លោកស្រីបានបញ្ជាក់ថា បានឈានដល់ប្រមាណជិតមួយ ប៊ីលានដុល្លារអាម៉េរិក។ លោកស្រី គូសបញ្ជាក់ថា ពលករខ្មែរនៅកូរ៉េ បានរួមចំណែកដល់ការអភិវឌ្ឍ សេដ្ឋកិច្ចរបស់សាធារណរដ្ឋកូរ៉េ ។ ទន្ទឹមនេះ លោកស្រីបានជានា អំពីការបន្តជួយដល់វិស័យដោះមីននៅកម្ពុជា។ លោកស្រីក៏បានជម្រាបជូន លោកឧបនាយករដ្ឋមន្ត្រី អំពីគម្រោងរៀបចំកិច្ចប្រជុំកំពូលភាពជាដៃគូសម្រាប់កំណើតបៃតង (Partnership for Green Grow) នៅពាក់កណ្តាល ឆ្នាំ២០២០។

បន្ទាប់ពីជំនួបរបស់ប្រមុខការទូត នៃប្រទេសទាំងពីរ កម្ពុជានិងសាធារណរដ្ឋកូរ៉េ បានចុះហត្ថលេខាលើឯកសារ សារសំខាន់ៗចំនួន៥ ដែលក្នុងនោះឯកសារចំនួន៣ត្រូវបានចុះហត្ថលេខានៅក្រោយកិច្ចប្រជុំ រវាងរដ្ឋមន្ត្រីក្រសួងការបរទេសទាំងពីរ។ ឯកសារចំនួនពីរផ្សេងទៀតចុះ ហត្ថលេខានៅក្រៅជំនួប ដែលឯកសារសំខាន់ៗទាំង៥នោះរួមមាន ១. កិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នា និងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេសពន្ធ និងការចៀសវាងពន្ធ។ ២. សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។ ៣. អនុស្សរណៈយោគយល់គ្នា (MoU) ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យកសិកម្ម។ ៤. អនុស្សរណៈយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យបច្ចេកវិទ្យា គមនាគមន៍ និង ព័ត៌មាន។ ៥. សេចក្តីថ្លែងការណ៍រួមស្តីពីការចាប់ផ្តើម ការសិក្សារួមគ្នាលើលទ្ធភាពបង្កើត កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-សាធារណរដ្ឋកូរ៉េ ៕

## ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០១៩

### វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ឃុំ-ថ្នាក់ស្រុក និងអ្នកពាក់ព័ន្ធ នៅស្រុកអង្គរជុំ

https://www.facebook.com/deputygovernoryousophear/ លេខាធិការដ្ឋាន គឧបជសៀមរាប 26-11-2019

ខេត្តសៀមរាប៖ ថ្ងៃអង្គារ ទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រុមការងារលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប (គ,ខ,ប,ជ) ដឹកនាំដោយឧត្តមសេនីយ៍ដ្ធង ថាវរី ស្នងការរងនគរបាលខេត្ត ជាអនុប្រធានលេខាធិការដ្ឋាន និងមានការអញ្ជើញចូលរួមពី លោកអភិបាលនៃគណៈអភិបាលស្រុក អង្គរជុំដោយមានការសម្របសម្រួលពីក្រុមការងារបច្ចេកទេស (ក្រុមការងារកិច្ចការអនុវត្តច្បាប់ និងក្រុមការងារកិច្ចការទេសន្តរប្រវេសន៍) មកពីស្នងការដ្ឋាននគរបាលខេត្ត និងមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវខេត្ត និងតំណាងអង្គការAPIE ។

វគ្គបណ្តុះបណ្តាលនេះ មានកិច្ចសហការជាមួយរដ្ឋបាលសាលាស្រុកអង្គរជុំ ដែលមានការគាំទ្រពីរដ្ឋបាលសាលាខេត្តសៀមរាប និងមានការចូលរួមគាំទ្រពីអង្គការ UN WOMEN និងអង្គការសកម្មភាពដើម្បីកុមារ (APLE) ផងដែរ ដើម្បីពង្រឹងសមត្ថភាព ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ឃុំ-សង្កាត់/ក្រុង-ស្រុក និងអ្នកពាក់ព័ន្ធ អំពីការអនុវត្តតួនាទីភារកិច្ច ច្បាប់ពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពានលើកុមារ និងពង្រឹងលើកិច្ចសហប្រតិបត្តិការក្នុងការផ្តល់សេវាជួយជនរងគ្រោះឲ្យបានសមស្របនិងមានប្រសិទ្ធិភាព។ វគ្គបណ្តុះបណ្តាលនេះ មានការអញ្ជើញចូលរួមពី លោក លោកស្រី អភិបាលរងស្រុកអធិការស្រុក កងរាជអាវុធហត្ថស្រុក ប្រធាន អនុប្រធានការិយាល័យជុំវិញស្រុក មេឃុំ ស្មៀន អ.ក.ន.ក ប្រជាការពារ មណ្ឌលសុខភាព នាយប៉ុស្តិ៍ នាយកសាលា យុវជន និងអង្គការដៃគូ សរុបចំនួន៤៥នាក់។

# ឯកអគ្គរដ្ឋទូតអូស្ត្រាលី ជំរុញឲ្យនគរបាលកម្ពុជានិងអូស្ត្រាលី សហប្រតិបត្តិការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន

http://www.cen.com.kh/archives/ November 27, 2019

ភ្នំពេញ ៖ ឯកអគ្គរដ្ឋទូតអូស្ត្រាលី ដែលបញ្ចប់អាណត្តិនៅកម្ពុជា បានជំរុញឲ្យនគរបាលរវាងប្រទេសទាំង២ (កម្ពុជា អូស្ត្រាលី) បន្តកិច្ចសហប្រតិបត្តិការជាមួយគ្នាបន្ថែមទៀត ជាពិសេសកិច្ចសហប្រតិបត្តិការ ប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដែលបានធ្វើឲ្យបទល្មើសបានធ្លាក់ចុះគួរឲ្យកត់សម្គាល់។

លោក នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានអនុញ្ញាតឲ្យ លោកស្រី Angela Corcoran ឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា នាព្រឹកថ្ងៃ២៧ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ ខណៈលោកស្រី បានបញ្ចប់អាណត្តិការទូត នៅព្រះរាជាណាចក្រកម្ពុជា។ ទំនាក់ទំនងការទូតរវាងអូស្ត្រាលីជាមួយកម្ពុជា គិតរហូតមកទល់នឹងពេលនេះ មានរយៈពេល ៦៧ឆ្នាំហើយ។ ក្រៅពីការប្រាស្រ័យកិច្ចការទំនាក់ទំនងរវាងរដ្ឋាភិបាល និងរដ្ឋាភិបាល ខាងផ្នែកកម្លាំងអនុវត្តច្បាប់ ក៏មានកិច្ចសហប្រតិបត្តិការរវាងអគ្គស្នងការដ្ឋាននគរបាលជាតិ ជាមួយនឹងប៉ូលីសសហព័ន្ធអូស្ត្រាលី AFP ផងដែរ។ មានប្រសាសន៍ក្នុងឱកាសនោះ លោក នេត សាវឿន បានចាត់ទុកកិច្ចសំណេះសំណាលនាពេលនេះ គឺជាការលើកទឹកចិត្តថែមទៀត ចំពោះកម្លាំងនគរបាលកម្ពុជា។ លោកអគ្គស្នងការនគរបាលជាតិកម្ពុជា បានថ្លែងអំណរគុណ ចំពោះរដ្ឋាភិបាលអូស្ត្រាលី និងអរគុណប៉ូលីសសហព័ន្ធអូស្ត្រាលី AFP តាមរយៈលោកស្រីឯកអគ្គរដ្ឋទូត និងបានបញ្ជាក់ការពេញចិត្តជាខ្លាំង ចំពោះកិច្ចសហប្រតិបត្តិការ ជាមួយនឹងប៉ូលីសសហព័ន្ធអូស្ត្រាលី។ លោក នេត សាវឿន បានមានប្រសាសន៍រំលឹកអនុស្សាវរីយ៍មួយ ដែលប៉ូលីសសហព័ន្ធអូស្ត្រាលី បានជួយដល់នគរបាលកម្ពុជា ក្នុងការរៀបចំសរសេរយុទ្ធសាស្ត្រនគរបាលជំហានទី១ ដែលការជួយរៀបចំនោះហើយ បានជួយឲ្យមន្ត្រីនគរបាលកម្ពុជាកាន់តែម្ចាស់ការ និងមានបទពិសោធន៍ពេញលេញ។

ក្នុងប្រសាសន៍តប លោកស្រី Angela Corcoran បានលើកឡើង នូវកិច្ចការខ្លះពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការ រវាងរដ្ឋាភិបាលនៃប្រទេសទាំង២ និងដោយឡែកកិច្ចសហប្រតិបត្តិការ រវាងនគរបាលកម្ពុជា ជាមួយនឹងប៉ូលីសសហព័ន្ធអូស្ត្រាលី។ លោកស្រី បានសម្តែងក្តីរីករាយ ចំពោះកិច្ចសហប្រតិបត្តិការរវាងនគរបាល នៃប្រទេសទាំង២ ជាពិសេសកិច្ចសហប្រតិបត្តិការ ប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដែលបានធ្វើឲ្យបទល្មើសបានធ្លាក់ចុះគួរឲ្យកត់សម្គាល់។ លោកស្រីឯកអគ្គរដ្ឋទូត បានថ្លែងថា ខាងនគរបាលអូស្ត្រាលី មានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការបន្តការអនុវត្តច្បាប់ជាមួយនឹងមន្ត្រីកម្ពុជា និងលោកស្រី ក៏បានជំរុញឲ្យនគរបាលរវាងប្រទេសទាំង២ បន្តកិច្ចសហប្រតិបត្តិការជាមួយគ្នាបន្ថែមទៀត៕ដោយៈកូឡាប

# ប្រទេសជាច្រើនជុំវិញពិភពលោក ចាត់វិធានការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ

http://nokorwatnews.com/archives/ 26-11-2019

អំពើហិង្សាក្នុងគ្រួសាគឺជាបញ្ហា ស្មុគស្មាញបំផុតនៅប្រទេសជាច្រើន លើពិភពលោក។ ក្នុងនោះស្ត្រីគឺជាជនរងគ្រោះដោយផ្ទាល់នៅក្នុងអំពើហិង្សា ក្នុងគ្រួសារ មិនត្រឹមតែ រងការវាយដំ ស្ត្រីមួយចំនួន ក៏រងការប្រើអាវុធដើម្បីវាយប្រហារ ដូចជាកាំភ្លើង កាំបិតជាដើម។

តាមតួលេខរបស់អង្គការសហប្រជាជាតិ មានស្ត្រីដល់ទៅ៣៥ភាគរយនៅលើពិភពលោក បានក្លាយជាជនរងគ្រោះ ក្នុងអំពើហិង្សា ក្នុងគ្រួសារ។ អំពើហិង្សាក្នុងគ្រួសារ មិនត្រឹមតែកើនមាននៅប្រទេសអ្នកក្រ នោះឡើយសូម្បីតែប្រទេសអ្នកមាន អាមេរិក អឺរ៉ុប ក៏មានអំពើហិង្សា កើនឡើងផងដែរ។ តាមលទ្ធផលស្រាវជ្រាវ មានស្ត្រីអាមេរិក១០លាននាក់ជាជនរងគ្រោះក្នុងអំពើហិង្សាក្នុងគ្រួសារ។ តាមលទ្ធផលស្រាវជ្រាវ ក្នុងចំណោមស្ត្រីអាមេរិក ៤នាក់ គឺមានម្នាក់រង

គ្រោះដោយអំពើហិង្សាក្នុងគ្រួសារ។ ជនរងគ្រោះដោយអំពើហិង្សានោះបានធ្វើឲ្យវិស័យសុខាភិបាលអាមេរិក ត្រូវចំណាយប្រាក់អស់ ដល់ទៅ៥,៨លានដុល្លារក្នុងមួយឆ្នាំ។

ជាមួយគ្នានេះ បារាំងបង្ហាញផែនការទប់ស្កាត់នឹងអំពើហិង្សាក្នុងគ្រួសារ ចំថ្ងៃទិវាពិភពលោកលុបបំបាត់អំពើហិង្សាលើស្ត្រី ។ ថ្ងៃទី ២៥វិច្ឆិកា ជាទិវាលុបបំបាត់អំពើហិង្សាលើស្ត្រីពិភពលោក។ អង្គការសហប្រជាជាតិបានបើកយុទ្ធនាការពីថ្ងៃនេះរហូតដល់ថ្ងៃទី១០ធ្នូ ដើម្បីបំផុសមតិសាធារណៈពិភពលោក ឱ្យប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាលើស្ត្រី។ ចំណែកនៅប្រទេសបារាំងវិញ រដ្ឋាភិបាលបានលាតត្រដាងអំពីវិធានការជិត៥០ចំណុច ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី។ ពាក្យថាហិង្សាមិនមែនរាប់តែការវាយដំលើរាងកាយមួយមុខទេ។ ហិង្សាលើស្ត្រី ដែលពិភពលោកចង់លុបបំបាត់ឱ្យអស់ គឺសំដៅទៅអំពើហិង្សាលើរាងកាយ អំពើហិង្សាលើផ្លូវភេទ និងអំពើហិង្សាលើផ្លូវចិត្ត មានជាអាទិ៍ ៖ អំពើហិង្សារបស់ដៃគូជីវិត (វាយដំ គំរាមកំហែងធ្វើបាបផ្លូវចិត្ត បង្ខំឱ្យប្រពន្ធរួមដំណេក សម្លាប់...) អំពើហិង្សា ឬ ការបៀតបៀនផ្លូវភេទ ដោយបុរស (រំលោភ បង្ខំឱ្យបម្រើផ្លូវភេទ រៀបការដោយបង្ខំ បៀតបៀនផ្លូវភេទតាមទីសាធារណៈ តាមផ្លូវ តាមប្រព័ន្ធអ៊ីនធ័រនែត បំពារបំពានឧក្រិដ្ឋ) ជួញដូរមនុស្ស (មកធ្វើជាទាសករ មកជួញដូរផ្លូវភេទ)។ កាត់ប្រដាប់ភេទស្ត្រី រៀបការដោយបង្ខំ ជាដើម។

នៅលើពិភពលោកយើងនេះ មានស្ត្រីម្នាក់ក្នុងចំណោមបីនាក់ រស់រងអំពើហិង្សាផ្លូវកាយ និងផ្លូវភេទ ពីបុរសជាប្តី ពីបុរសជាដៃគូជីវិត ឬអំពើហិង្សាផ្លូវភេទពីសំណាក់បុរសដទៃផ្សេងទៀត។ មានស្ត្រីជាភរិយាគេប្រមាណតែ៥២%ប៉ុណ្ណោះនៅលើភពផែនដីទាំងមូលនេះ ដែលមានសិទ្ធិសេរីភាព យ៉ាងពេញលេញក្នុងការសម្រេចចិត្ត ដោយខ្លួនឯង លើជីវិតផ្លូវភេទ លើជម្រើសប្រើវិធីពន្យារកំណើត ឬលើការថែទាំសុខភាព។ ស្ត្រីនិងយុវតី ជាង២០០លាននាក់ត្រូវរងគំនាបប្រពៃណីទំនៀមទម្លាប់កាត់ប្រដាប់ភេទ។ ៧៥០លាននាក់ រៀបអាពាហ៍ពិពាហ៍ មុនថ្ងៃខួបកំណើតទី១៨ឆ្នាំរបស់ខ្លួន (មុនអាយុដែលគេចាត់ទុកថាជាមនុស្សពេញវ័យ)។ នៅក្នុងឆ្នាំ២០១៧ ក្នុងចំណោមស្ត្រីដែលស្លាប់ដោយការធ្វើឃាត ពាក់កណ្តាលជាឃាតកម្មដែលបង្កឡើងដោយដៃគូជីវិតរបស់ស្ត្រី ឬដោយក្រុមគ្រួសារ។ ស្ថានភាពឃាតកម្មបែបនេះ មានត្រឹមតែ១លើ២០ករណីប៉ុណ្ណោះចំពោះបុរស។ នៅលើពិភពលោកយើងនេះ ជនរងគ្រោះក្នុងសកម្មភាពជួញដូរមនុស្ស ចំនួន៧២%ជាមនុស្សស្រី និងក្មេងស្រី។ ហើយបីភាគបួន ត្រូវបានគេបង្ខំឱ្យរកស៊ីលក់ខ្លួន។ បើតាមការសិក្សារបស់ធនាគារពិភពលោក នៅខែកុម្ភៈឆ្នាំ២០១៨ បានបង្ហាញថាមានស្ត្រី ជាង១ពាន់លាននាក់នៅលើពិភពលោកមិនបានទទួលការការពារតាមផ្លូវច្បាប់ ពីទង្វើហិង្សាផ្លូវភេទ និងក្នុងគ្រួសារទេ។

បើតាមតួលេខរបស់ភ្នាក់ងារសារព័ត៌មានបារាំង គិតពីឆ្នាំ២០១៩មកដល់ពេលនេះ មានស្រីយ៉ាងហោច១១៧នាក់បានស្លាប់ ដោយស្នាដៃរបស់ដៃគូជីវិត ឬអតីតគូកំណាន់។ ក្នុងមួយឆ្នាំៗ មានស្ត្រីពេញវ័យប្រមាណ២១៣០០០នាក់ ជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ (ប្តីប្រពន្ធ) លើផ្លូវកាយនិងផ្លូវភេទ។ នេះបើតាមតុល្យការផ្លូវការបារាំង។ តាំងពីថ្ងៃសៅរ៍និងបន្តមកដល់ថ្ងៃចន្ទ ចលនាការពារស្ត្រីបាននាំគ្នាធ្វើបាតុកម្ម នៅតាមទីក្រុងធំៗ ស្ទើរទូទាំងពិភពលោក។ នៅប្រទេសបារាំង ចលនាការពារស្ត្រីប្រឆាំងនឹងអំពើហិង្សាបានទទួលជោគជ័យយ៉ាងខ្លាំង និងបានជំរុញឱ្យរដ្ឋាភិបាលមានវិធានការ។

ក្រោមសម្ពាធសាធារណៈ រដ្ឋាភិបាលបានបើកកម្មវិធីពិគ្រោះ ពិចារណាតាំងពីដើមខែកញ្ញា រកវិធីទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងយុវតី។ នៅក្នុងថ្ងៃបិទបញ្ចប់ ការពិគ្រោះយោបល់ នៅថ្ងៃចន្ទទី២៥នេះ និងជាការផ្តល់ភាពសំខាន់ដល់ទិវាពិភពលោកដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រីផង ប្រមុខរដ្ឋាភិបាលបារាំងបានប្រកាសអំពីវិធានការប្រមាណ៤០ចំណុច ដែលមានទម្រង់និងតម្លៃតាមផ្លូវច្បាប់ ដើម្បីការពារស្ត្រីពីអំពើហិង្សាក្នុងគ្រួសារ។ វិធានការខ្លះត្រូវបាន គេស្គាល់រួចមកហើយ។ វិធានការខ្លះនឹងមានចែងក្នុងសំណើច្បាប់។វិធានការទាំងនោះរាប់ឃើញមានតាំងពី ការបង្កើតជំរក១០០០កន្លែងសម្រាប់ស្ត្រីរងគ្រោះ។ ការទទួលបន្ទុកព្យាបាលរោគចិត្តរបស់បុរស រឹបអូសអាវុធពីបុរស

ហិង្សានៅពេលស្ត្រីប្តឹង ដល់ការបង្កើតលេខទូរស័ព្ទពិសេស ទាក់ទងបានគ្រប់ម៉ោងគ្រប់ថ្ងៃ សម្រាប់ស្តាប់និងជួយជនរងគ្រោះ ឱ្យហ៊ាននិយាយនិងបរិហារទង្វើរបស់បុរស៕

## ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០១៩

### ចាប់ខ្លួនបុរស និងស្ត្រីម្នាក់ ពាក់ព័ន្ធបទល្មើសលក់ព្រហ្មចារីក្មេងស្រីឲ្យជនបរទេស

http://kampucheathmey.com/ 27/11/2019 2:29 Pm

ភ្នំពេញ ៖ ស្ត្រីចំណាស់ម្នាក់ និងបុរសម្នាក់ ត្រូវបាននគរបាលប្រឆាំងការជួញដូរមនុស្សក្នុងប្រទេសចាប់ខ្លួនបញ្ជូនឡើងតុលាការកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ ពាក់ព័ន្ធករណីលួងលោមក្មេងស្រីៗអាយុ១៣ឆ្នាំ ១៤ឆ្នាំ ១៥ឆ្នាំ លក់ខ្លួនឲ្យជនបរទេសនៅតាមសណ្ឋាគារ។

ជនសង្ស័យ ដែលសមត្ថកិច្ចចាប់ខ្លួនឈ្មោះអ៊ឹម សុផល ហៅយាយមី អាយុ៧៥ឆ្នាំ និងឈ្មោះ ព្រឿង ចាន់ ភេទប្រុស អាយុ៤៥ឆ្នាំ។ ជនសង្ស័យទាំង២នាក់ ត្រូវបានសមត្ថកិច្ចចាប់ខ្លួនកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅផ្ទះលេខ ១៨៤ ផ្លូវលេខ៤៥០ ភូមិ១ សង្កាត់ ទួលទំពូង ខណ្ឌចម្ការមន។

ពាក់ព័ន្ធការចាប់ខ្លួន ខាងលើនេះ តាមចម្លើយសារភាពរបស់យាយ មី បានឲ្យដឹងថា គាត់ពិតជាបាននាំក្មេងស្រីឲ្យទៅរួមភេទជាមួយភ្ញៀវនៅតាមផ្ទះសំណាក់ សណ្ឋាគារ ដោយទទួលបានប្រាក់ចំនួន១០០ដុល្លារ ហើយខ្លួនដកយកតែ១០ដុល្លារ ឲ្យទៅក្មេងស្រី៩០ដុល្លារ តាមតម្រូវការរបស់ភ្ញៀវ១ថ្ងៃម្តង ឬ២ថ្ងៃម្តង ដោយជិះផាសអាប់ នាំក្មេងស្រីទៅប្រគល់ឲ្យឈ្មោះ ឆាង ដែលជាអ្នកទាក់ទងភ្ញៀវតាមសណ្ឋាគារនានា។

ចំណែកឈ្មោះ ព្រឿង ចាន់ បានសារភាពថា ខ្លួនជាអ្នកទាក់ទងភ្ញៀវតាមសណ្ឋាគារជាមួយឈ្មោះ ឈុន ប៊ុនឆាង ហៅ ឆាង ដើម្បីផ្តល់សេវាផ្លូវភេទដែលយាយមីនាំមក ដោយក្នុងមួយម៉ូយខ្លួនអាចបានប្រាក់កម្រៃ១០០ដុល្លារទៅ១៥០ដុល្លារ ចែកគ្នាស្មើជាមួយឈ្មោះ ឆាង។

សូមបញ្ជាក់ថា ក្នុងប្រតិបត្តិការបង្ក្រាបអំពើលក់ដូរក្មេងស្រីនេះ សមត្ថកិច្ចក៏បានរំដោះក្មេងស្រី៣នាក់ផងដែរ ក្នុងនោះមានម្នាក់អាយុ១៣ឆ្នាំ ម្នាក់ទៀតអាយុ១៤ឆ្នាំ និងម្នាក់ទៀតអាយុ១៥ឆ្នាំប៉ុណ្ណោះ។ ពួកគេសុទ្ធតែជាក្មេងស្រីមិនទាន់គ្រប់អាយុ ដែលអាណាព្យាបាលនាំមកឲ្យធ្វើការរត់តុកាហ្វេនាក្រុងភ្នំពេញ ហើយក៏ត្រូវក្រុមមនុស្សចាស់ឆ្លៀតឱកាសបោកបញ្ឆោតឲ្យលក់ខ្លួន លក់ព្រហ្មចារីឲ្យភ្ញៀវតាមនៅតាមសណ្ឋាគារនានា។ រឿងក្តីនេះ ព្រះរាជអាជ្ញាអមតុលាការកំពុងសាកសួរជនសង្ស័យនៅឡើយ៕ មករា

### វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ឃុំ-ថ្នាក់ស្រុក និងអ្នកពាក់ព័ន្ធ នៅស្រុកបន្ទាយស្រី

https://www.facebook.com/deputygovernoryousophear/ លេខាធិការដ្ឋាន គ.ខ.ប.ជ សៀមរាប 27-11-2019

ខេត្តសៀមរាប៖ ថ្ងៃពុធ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រុមការងារលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប (គ,ខ,ប,ជ) ដឹកនាំដោយឧត្តមសេនីយ៍ដួង ថាវរី ស្នងការរងនគរបាលខេត្ត ជាអនុប្រធានលេខាធិការដ្ឋាន និងមានការអញ្ជើញចូលរួមពី លោកស្រីអភិបាលរងនៃគណៈអភិបាលស្រុកបន្ទាយស្រី ដោយមានការសម្របសម្រួលពីក្រុមការងារបច្ចេកទេស (ក្រុមការងារកិច្ចការអនុវត្តច្បាប់ និងក្រុមការងារកិច្ចការទេសន្តរប្រវេសន៍) មកពីស្នងការដ្ឋាននគរបាលខេត្ត និងមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។

វគ្គបណ្តុះបណ្តាលនេះ មានកិច្ចសហការជាមួយរដ្ឋបាលសាលាស្រុកបន្ទាយស្រី ដែលមានការគាំទ្រពីរដ្ឋបាលសាលាខេត្តសៀមរាប និងមានការចូលរួមគាំទ្រពីអង្គការ UN WOMEN ដើម្បីពង្រឹងសមត្ថភាព ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ឃុំ-សង្កាត់/ក្រុង-ស្រុក និងអ្នកពាក់ព័ន្ធ អំពីការអនុវត្តតួនាទីភារកិច្ច ច្បាប់

ពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពានលើកុមារ និងពង្រឹងលើកិច្ចសហប្រតិបត្តិការក្នុងការផ្តល់សេវាជួយជនរងគ្រោះឲ្យបានសមស្របនិងមានប្រសិទ្ធិភាព។

វគ្គបណ្តុះបណ្តាលនេះ មានការអញ្ជើញចូលរួមពី លោក លោកស្រី អភិបាលរងស្រុកអធិការស្រុក កងរាជអាវុធហត្ថស្រុក ប្រធាន អនុប្រធានការិយាល័យជុំវិញស្រុក មេឃុំ ស្មៀន អ.ក.ន.ក ប្រជាការពារ មណ្ឌលសុខភាព នាយប៉ុស្តិ៍ នាយកសាលា យុវជន និងអង្គការដៃគូ សរុបចំនួន ៦៦នាក់ ក្នុងនោះស្រីចំនួន ២១នាក់។ ការរៀបចំវគ្គបណ្តុះបណ្តាលនេះបានប្រព្រឹត្តទៅទូទាំង១២ ក្រុង-ស្រុក ក្នុងខេត្តសៀមរាប និងបានបញ្ចប់ទៅដោយរលូនតាមការផែនការ និងមានការគាំទ្រពីគ្រប់អ្នកពាក់ទាំងអស់។

## ឧបទ្ទវហេតុក្នុងការងារ បណ្តាលឲ្យពលករខ្មែរ ស្លាប់បាត់បង់ជីវិតម្នាក់

https://www.facebook.com/prakpheaktraofficial/ ប្រាក់ ភក្ត្រា-Prak Pheaktra 27/11/19

ប្រភពពីខេត្តត្រាតប្រទេសថៃ នៅថ្ងៃពុធ ទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ នេះបានអោយដឹងថា ពលករខ្មែរម្នាក់ឈ្មោះ សេម សំណាង ភេទប្រុស បានស្លាប់បាត់បង់ជីវិតបន្ទាប់ពីត្រូវរថយន្តដឹកកំណាត់ដើមស៊ូមួយគ្រឿងបានក្រឡាប់សង្កត់បណ្តាលឲ្យរងរបួសធ្ងន់ នៅផ្លូវជាតិស្ថិតក្នុងស្រុកមឿងខេត្តត្រាត ក្រោយមកជនរងគ្រោះបានស្លាប់បាត់បង់ជីវិតបន្ទាប់ពីបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យខេត្តត្រាត នាវេលាបន្តបន្ទាប់។ ក្រោយពេលកើតហេតុកម្លាំងអាជ្ញាធរសមត្ថកិច្ចតម្រួតខេត្តត្រាត បានធ្វើការចោទប្រកាន់អ្នកបើកបររថយន្តបង្កខាងលើពីបទបើកបរដោយប្រមាថបណ្តាលឲ្យអ្នកដ៏ទៃស្លាប់បាត់បង់ជីវិត និងចាត់វិធានការតាមផ្លូវច្បាប់។

# ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០១៩

## ជ្រើសរើសពលរដ្ឋខ្មែរ ឱ្យទៅធ្វើការនៅប្រទេសជប៉ុន

http://www.cen.com.kh/ November 29, 2019

ភ្នំពេញ៖ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយអង្គការ JITCO នៃប្រទេសជប៉ុន រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ទៅដល់ទីភ្នាក់ងារជ្រើសរើសឯកជន អំពីស្ថានភាព នៃគម្រោងកម្មសិក្សាការី និងចែករំលែកព័ត៌មាន អំពីគម្រោងពលករជំនាញ។

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយអង្គការ JITCO នៃប្រទេសជប៉ុនបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយទៅដល់ទីភ្នាក់ងារជ្រើសរើសឯកជន អំពីស្ថានភាពនៃគម្រោងកម្មសិក្សាការីជំនាញបច្ចេកទេស និងចែករំលែកព័ត៌មានអំពីគម្រោងពលករជំនាញ ដោយមានការចូលរួមពីសមាគម និងទីភ្នាក់ជ្រើសរើសឯកជនកម្ពុជាចំនួន ១០៩ក្រុមហ៊ុន។ ថ្លែងបើកកម្មវិធីសិក្ខាសាលានេះ លោកហ៊ូ វុឌ្ឍី អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានថ្លែងថា រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសជប៉ុន បានសហការបញ្ជូន និងទទួលកម្មសិក្សាការីជំនាញកម្ពុជា ចាប់តាំងពីឆ្នាំ២០០៣ ហើយអគ្គនាយកដ្ឋានការងារតំណាងឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការលើគម្រោងបញ្ជូនកម្មសិក្សាការីជំនាញបច្ចេកទេស ជាមួយអង្គការ JITCO ដែលជាតំណាងនៃរដ្ឋាភិបាលនៃប្រទេសជប៉ុន តាំងពីឆ្នាំ២០០៧មកម្លេះ។

លោកអនុរដ្ឋលេខាធិការសង្ឃឹមថា កម្មវិធីសិក្ខាសាលានាថ្ងៃនេះ បានផ្តល់ឱកាសដល់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា បានពិភាក្សា និងទទួលបានការណែនាំពីអង្គការ JITCO នូវចំណេះដឹងថ្មីៗ សម្រាប់ពង្រឹងប្រសិទ្ធភាព ក្នុងការជ្រើសរើសពលរដ្ឋខ្មែរ ឱ្យទៅធ្វើការនៅប្រទេសជប៉ុន តាមរយៈគម្រោងកម្មសិក្សាការីជំនាញបច្ចេកទេស និងគម្រោងពលករជំនាញ សំដៅពង្រឹងសុខដុមរមនាសង្គម ដោយផ្តល់ជូនប្រជាពលរដ្ឋនូវឱកាសការងារសមរម្យ និងប្រកបដោយផលិតភាពការងារខ្ពស់។

គួរបញ្ជាក់ដែរថា កម្មសិក្ខាសាលានៅប្រទេសកម្ពុជានេះ ជាលើកទី២ ហើយដែលលើកទី១ ត្រូវបានរៀបចំកាលពីឆ្នាំ២០១៧៕ ដោយៈកូឡាប

## តើទីប្រឹក្សាការងារប្រចាំស្ថានទូតកម្ពុជានៅកូរ៉េខាងត្បូងមានភារកិច្ចអ្វីខ្លះ?

https://thmeythmey.com/ 28, Nov 2019 , 6:29 pm

មានទីប្រឹក្សាការងារ២រូប ដែលកំពុងបំពេញបេសកកម្មប្រចាំស្ថានទូតកម្ពុជានៅសាធារណកូរ៉េ ខណៈដែលពលករខ្មែរដែលកំពុងធ្វើការនៅក្នុងសាធារណកូរ៉េមានជាង៤ម៉ឺននាក់។ ទីប្រឹក្សាទាំងពីររូបត្រូវមានយុទ្ធសាស្ត្រធ្វើការងារ ដើម្បីអាចទទួលបានព័ត៌មានច្រើនជាអតិបរមាតាមតែអាចធ្វើបានអំពីបញ្ហារបស់ពលករ។ តើពួកគេត្រូវធ្វើដូចម្តេចខ្លះ?

ថៅកែមិនអនុវត្តកិច្ចសន្យាការងារ ពលករ ពលការិនី មានបញ្ហាសុខភាព បញ្ហាបើកប្រាក់ខែយឺត គ្រោះថ្នាក់ការងារ មរណភាព និងបញ្ហានានាជាច្រើនទៀតសុទ្ធតែធ្លាប់បាន និងកំពុងកើតលើពលករ ពលការិនីកម្ពុជាដែលកំពុងធ្វើការងារនៅសាធារណរដ្ឋកូរ៉េ។ ទីប្រឹក្សាការងារនៃស្ថានទូតកម្ពុជាប្រចាំប្រទេសកូរ៉េខាងត្បូងត្រូវជួយអន្តរាគមន៍រកដំណោះស្រាយជូនពលករខ្មែរ។

លោក សាម៉េន សុខា ទីប្រឹក្សាការងារមួយរូបបានផ្តល់បទសម្ភាសដល់សារព័ត៌មានថ្មីៗកាលពីពេលថ្មីៗកន្លងទៅនេះ ដើម្បីពន្យល់ ពន្យល់អំពីរបៀបនៃការអនុវត្តការងាររបស់លោក និងរៀបរាប់អំពីស្ថានភាពរបស់ពលករខ្មែរនៅក្នុងប្រទេសកូរ៉េនោះ។ បើតាមការរៀបរាប់របស់លោក សាម៉េន សុខា លោកត្រូវមានកិច្ចសហការល្អជាមួយអាជ្ញាធរកូរ៉េមជ្ឈមណ្ឌលគាំពារពលកររបស់ប្រទេសកូរ៉េ និងជាពិសេសការបង្កើតបណ្តាញការងារជាមួយនឹងស្ត្រីខ្មែរដែលរៀបការជាមួយស្វាមីកូរ៉េ។ «នៅពេលពលករ ពលការិនីខ្មែរជួបបញ្ហាអ្វីមួយ យើងមិនអាចទៅដល់ទីកន្លែងទាន់ពេលវេលានោះឡើយ។ ដូច្នេះមានតែពួកគេដែលអាចអន្តរាគមន៍បន្ទាន់ មុននឹងក្រុមការងារស្ថានទូតទៅដល់។»។ នេះជាការបញ្ជាក់របស់លោក សាម៉េន សុខា នៅក្នុងការិយាល័យរបស់លោកក្នុងស្ថានទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ។

លោក សុខា បានបង្ហាញករណីខ្លះៗដែលទាក់ទងនឹងការងាររបស់លោក។ «ឧទាហរណ៍ថាមានពលករយើងជួបគ្រោះថ្នាក់ការងារ។ យើងខ្ញុំត្រូវទៅជួបថៅកែ ដើម្បីពិនិត្យឱ្យច្បាស់ថា ជនរងគ្រោះបានទទួលការព្យាបាល និងសំណងពេញលេញស្របតាមការកំណត់របស់ច្បាប់។ ជាទូទៅ យើងតែងទទួលបានជោគជ័យនៅក្នុងការអនុវត្តភារកិច្ចរបស់យើង។ បើតាមការអះអាងរបស់លោក សាម៉េន សុខា មានពលករ ពលការិនីកម្ពុជាជាង៤ម៉ឺននាក់ដែលកំពុងបំពេញការងារនៅក្នុងសាធារដ្ឋកូរ៉េ នេះដោយមិនគិតពីសហគមន៍ស្ត្រីខ្មែរដែលរៀបការជាមួយស្វាមីកូរ៉េផង។

លោកបន្តថា កូតាចំនួនពលករខ្មែរដែលសាធារណរដ្ឋកូរ៉េផ្តល់ឱ្យកម្ពុជានៅតែមានជំនួនច្រើន ដោយសារតែភ្នាក់ងារអភិវឌ្ឍធនធានមនុស្សរបស់កូរ៉េ បានសរសើរអំពីគុណសម្បត្តិរបស់ពលករ ពលការិនីកម្ពុជាដែលឧស្សាហ៍ព្យាយាម។ «ខ្ញុំសង្កេតឃើញថា ពលករ ពលការិនីខ្មែរយើងបានខិតខំធ្វើការងារ និងឆ្លៀតអភិវឌ្ឍខ្លួនឯងដោយរៀនជំនាញផ្សេងៗ និងពង្រឹងផ្នែកភាសាផង នៅពេលដែលពួកគេកំពុងរស់នៅ និងធ្វើការនៅក្នុងប្រទេសកូរ៉េនេះ។ ម្យ៉ាងវិញទៀត ខ្ញុំក៏សង្កេតឃើញពួកគេហ៊ានសរហ្សេនច្រើន»។ នេះជាការអត្ថាធិប្បាយរបស់លោក សាម៉េន សុខា ទីប្រឹក្សាការងារប្រចាំស្ថានទូតកម្ពុជានៅសាធារណរដ្ឋកូរ៉េ៕

## កម្ពុជា ស្នើសមាជិកអាស៊ានរួមគ្នា ជួយទប់ស្កាត់ ឧក្រិដ្ឋកម្មឆ្លងដែន

https://www.dap-news.com/national/ ByPH104 Posted on November 28, 2019

ភ្នំពេញ ៖ នាយឧត្តមសេនីយ៍ មៀច សុផាន់ណា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ក្នុងក្របខ័ណ្ឌអាស៊ាន (SOMTC-Leader) បានស្នើឲ្យ សមាជិកអាស៊ាន ចូលរួមទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន ខណៈឧក្រិដ្ឋកម្មឆ្លងដែន បានបង្កគ្រោះថ្នាក់ដល់ប្រទេសជាច្រើនផងដែរ។ នេះបើយោងតាមគេហទំព័រហ្វេសប៊ុករបស់ ក្រសួងមហាផ្ទៃ។

ក្នុងកិច្ចប្រជុំ រដ្ឋមន្ត្រីសមាជិកអាស៊ាន លើកទី១៣ ស្តីពី ឧក្រិដ្ឋកម្មឆ្លងដែន (AMMTC-13) និងកិច្ចប្រជុំផ្សេងទៀត នៅទីក្រុងបាងកក កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ លោក មៀច សុផាន់ណា បានថ្លែងថា ឧក្រិដ្ឋកម្មឆ្លងដែន បានបង្កគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរ ដល់ប្រទេសជាច្រើនក្នុងសតវត្សរ៍ទី២០។ហើយការខ្វះខាតនូវគោលនយោបាយដ៏ជាក់លាក់ ប្រទាក់ក្រឡាគ្នាក្នុងកំរិតអន្តរជាតិក្នុងពេលដែល ឧក្រិដ្ឋកម្មឆ្លងដែនកាន់តែកើនឡើងនោះ សន្តិសុខពិភពលោកទាំងមូល ត្រូវបានគំរាមកំហែងយ៉ាងខ្លាំង ក្នុងសតវត្សរ៍ទី២១នេះ។ លោក ថា "ស្នើឲ្យមានគោលនយោបាយសម្រាប់អនុវត្ត និងឆ្លើយតបក្នុងកំរិតថ្នាក់តំបន់ ដើម្បីដោះស្រាយបញ្ហានេះ ពីព្រោះពុំមានប្រទេសណាមួយ អាចដោះស្រាយបញ្ហានេះតែឯងបានទេ"។

បន្ទាប់ពីប្រជុំពាក់ពន្ធ័ឧក្រិដ្ឋកម្មឆ្លងដែន នាថ្ងៃដដែល លោក មៀច សុផាន់ណា ក៏បានបន្តដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំទ្វេភាគី ជាមួយ គណៈប្រតិភូជាន់ខ្ពស់ចិន ដោយបានពិភាក្សាលើការងារពង្រឹង ការការពារសន្តិសុខ និងសុវត្ថិភាពប្រជាជន នៅខេត្ត ព្រះសីហនុ ។ នៅក្នុងកិច្ចប្រជុំនេះដែរ ភាគីចិន ក៏បានមានមតិចូលរួមគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបិទល្បែងស៊ីសងតាមប្រពន្ធ័អ៊ីនធឺណិត (Game Online)៕ដោយ អេង ប៊ូ ឆេង

## ពលករឆ្លងដែនកាប់ឈើខុសច្បាប់៤រូប ត្រូវបានអាជ្ញាធរថៃប្រគល់ជូនភាគីកម្ពុជា តាមច្រកទ្វារអន្តរជាតិជាំ

http://nokorwatnews.com/ 28-11-2019

ខេត្តឧត្តរមានជ័យ៖ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ អាជ្ញាធរថៃបានបញ្ជូនប្រជាជនខ្មែរចំនួន០៤នាក់ តាមច្រកអន្តរជាតិជាំ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សមត្ថកិច្ចបានឲ្យដឹងថាពលករទាំង៤នាក់ខាងលើមានឈ្មោះ ឈ្មោះ ស៊ូ យុគ ភេទប្រុស អាយុ៣៥ឆ្នាំ រស់នៅភូមិដានគោម ឃុំដានគោម ស្រុកអង្គរជ័យ ខេត្តកំពត ចាប់ខ្លួនថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៧, ឈ្មោះ ឆាយ ឆើត ភេទប្រុស អាយុ៣៦ឆ្នាំ រស់នៅភូមិគោកចារ ឃុំគោកស្រុក ស្រុកដំបែរ ខេត្តកំពង់ចាម ចាប់ខ្លួនថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៨, ឈ្មោះ ឈិន រុន ភេទប្រុស អាយុ៤០ឆ្នាំ រស់នៅភូមិវាលពោល ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ចាប់ខ្លួនថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៨ និងឈ្មោះ ឈាវ ផុន ភេទប្រុស អាយុ៥៨ឆ្នាំ រស់នៅភូមិកោះចារ ឃុំមោងឫស្សី ស្រុកមោងឫស្សី ខេត្តបាត់ដំបង ចាប់ខ្លួនថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥ អ្នកទាំង ៤ ជាប់គុកនៅខេត្តស៊ីសាកេត ប្រទេសថៃ ពីបទឆ្លងដែនកាប់ឈើគ្រញូង ចូលតាមច្រកតាថាវ ។ ពលករទាំង៤នាក់ខាងលើ ត្រូវបានសមត្ថកិច្ចច្រកទ្វារជាំបានអប់រំ រួចឲ្យវិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន ៕ ប៉ែន នួន

## ហេតុតែចង់បាន iPhone 11 ពេក ដាច់ចិត្តលួចចៅគេលក់

http://www.rasmeinews.com/ November 29, 2019, 10:42 AM

យើងធ្លាប់តែឮថាអ្នកនិយមចូលចិត្តទូរស័ព្ទរបស់ក្រុមហ៊ុនApple តម្រង់ជួររង់ចាំទិញទូរស័ព្ទiPhone ស៊េរីចុងក្រោយរបស់វា តែចំណង់របស់ស្ត្រីវៀតណាមម្នាក់សំរាប់ទូរស័ព្ទiPhone 11នាំអោយគាត់ធ្វើរឿងដែលគេមិននឹកស្មានដល់ គឺលួចចៅអ្នកជិតខាងទៅលក់ដើម្បីទូរស័ព្ទ។ ថាយ ធី ប៊ីច ហាញ់ អាយុ៤២ឆ្នាំ ត្រូវបានចាប់ខ្លួននៅក្នុងខេត្តអានយ៉ាងកាលពីថ្ងៃ១៦វិច្ឆិកា ចំពោះលក់ក្មេងស្រីអាយុ២ឆ្នាំទៅអោយបុរសម្នាក់ ដែលស្គាល់គ្នាតាមបណ្តាញសង្គម។

ក្មេងស្រីរងគ្រោះ បានរស់នៅជាមួយជីដូនរបស់នាងតែនាងថាយបានទៅមើលថែនិងលេងជាមួយក្មេងនេះម្តងម្កាល។ នាងបាននៅជាមួយក្មេងស្រីនេះនិងបានជជែកលេងក្នុងវីដេអូជាមួយបុរសម្នាក់ដែលចាប់អារម្មណ៍នឹងរូបសម្រស់របស់ក្មេងនេះ។ ថាយ ធី ប៊ីច ហាញ់ បន្ទាប់មកក៏មានគំរោងលក់ក្មេងនេះទៅអោយបុរសដែលទើបស្គាល់ឈ្មោះត្រាន់ដោយប្រាប់ទៅបុរសនោះថាឪពុករបស់ក្មេងនេះបានបោះបង់វាចោលនិងម្តាយរបស់វាញៀនល្បែង ហើយ«ក្មេងនេះនឹងត្រូវបញ្ជូនអោយទៅរស់នៅក្នុងវត្ត»។

ដោយមើលឃើញថា ត្រាន់ មានចិត្តអាណិតក្មេងនេះ នាងក៏សុំប្រគល់ក្មេងនេះទៅគាត់ជាថ្នូរនឹងទូរស័ព្ទ iPhone 11ថ្មីមួយ ដែលមានតំលៃ២២លានដុង( ១.៣០០ដុល្លារ )នៅវៀតណាម។ នៅថ្ងៃ៣១តុលា ថាយ បានប្រាប់ជីដូនរបស់ក្មេងនេះថា នាងយកវាទៅលេង។តែនាងបានលក់វាទៅអោយត្រាន់ ដែលបានផ្តល់អោយនាងនូវទូរស័ព្ទមួយ បន្ថែមប្រាក់១,៥លានដុងសម្រាប់ថ្លៃតាក់ស៊ី។ ថៃបន្ទាប់មកធ្វើជាមិនដឹងកន្លែងរស់នៅរបស់ក្មេងនេះនិងបានរាយការណ៍ទៅប៉ូលិសថាបាត់វានៅពេលនាងទុកក្មេងស្រីនេះនៅផ្ទះនិងបានចេញទៅធ្វើការ។ ទោះជាយ៉ាងណា ថាយបានសារភាពប្រាប់ការពិតនៅពេលប៉ូលិសកាន់តែសង្ស័យក្រោយឈ្លេចសួរនាងជាប់។ នៅថ្ងៃ០៣ វិច្ឆិកា ប៉ូលិសបានតាមរកឃើញក្មេងនេះនៅផ្ទះរបស់ត្រាន់និងបាននាំទៅជួបជីដូនរបស់វាវិញ។ ច្បាប់ព្រហ្មទណ្ឌវៀតណាម ជនណាលក់ដូរឬលួចយកក្មេងប្រឈមការជាប់គុក៣ទៅ១០ឆ្នាំ៕ដោយៈ*វាសនា*

---